ទស្សនាវដ្តីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ការផ្ញើលិខិតទៅកាន់សមមិត្ត នួន ជា
- សមមិត្ត ខៀវ សំផន ៖ ការដាក់ឱ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋក្នុងរបបខ្មែរក្រហម

[illegible]

លេខ៩៩ ខែមីនា ឆ្នាំ២០០៨

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៥១ ខែមីនា ឆ្នាំ២០០៤

## មាតិកា


◆ សំបុត្រៈ ការពិតរបស់សមមិត្ត នួន ជា ..............................១

**ផ្នែកឯកសារ**

◆ ដាំ វ៉ុន អតីតទាហានស័ក្ដិ២អាកាសចរណ៍.............................. ២

◆ ទូរលេខៈ គោរពជូន ម-៨៧០ ជាទីស្នេហានីករលឹក................៦

◆ សម្ភារនាំចូលពីបរទេសក្នុងត្រីមាសទីមួយឆ្នាំ១៩៧៦................ ៧

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១........... ៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ង៉ិល គន់ៈ ខ្ញុំមិនចង់បានអ្វីទាំងអស់.................................. ១០

◆ ទង្វើរបស់មេខ្មែរក្រហមមិនមែនជាគំរូល្អ............................. ១២

◆ ស៊ឹន អានៈ និយាយអំពីជីវិតពិត.......................................១៥

◆ នៅតែដិតដាមក្នុងចិត្ត....................................................១៧

◆ ខ្ញុំរីករាយណាស់បានដឹងថាមានតុលាការខ្មែរក្រហម................២០

◆ សមមិត្ត ខៀវ សំផនៈ ការដាក់ឲ្យទទួលខុសត្រូវ...................២២

**ផ្នែកច្បាប់**

◆ នយោបាយអន្តរការណ៍និងយុត្តិធម៌នៅកម្ពុជា.......................២៧

◆ កសាងសំណុំរឿងចោទប្រកាន់អតីតមេដឹកនាំខ្មែរក្រហម.......... ៣៧

◆ តុលាការព្រហ្មទណ្ឌអន្តរជាតិៈ ទីបញ្ចប់របស់វប្បធម៌............... ៤០

**វេទិកាពិភាក្សាសាធារណៈ**

◆ ខៀវ សំផន ផ្ញើស័យទិតៀនឆ្នាំ២០០៤............................ ៤៨

◆ សូមសួរទៅអតីតអង្គការ.................................................៥១

◆ ភាពកំសាករបស់ ខៀវ សំផន ដូចស្វាទាំងបី .......................៥៦

◆ មិននិយាយមិនបាន.......................................................៥៨

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ អតីតកាលដែលនៅតែចងចាំជានិច្ច ...................................៦០




នួន ជា


# រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នេរលេខនេះ** យិន នាន, ឆេង វើង, លី សុខឃាង, សូ ហ្វារីណា, សឹម សុរិយ៉ា, សុខ វណ្ណៈ, ឌី ខាំបូលី, ឡាច ឆវាង, ណៃ ឌីណា, ព្រាប ច័ន្ទដាណ្ណា, ស៊ីវ ហេឌ័រ, ប្រាយ៉ាន់ ធីទីម័រ, ចន ឆវធីអារី, ម៉ាហ្គារ៉េត ដប់គីន, ម៉ូដ សាន់យ៉ើស, **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, ផាត រចនា, **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងៈ** ស្ទួ ប៊ុនស៊ូ **អ្នកបកប្រែៈ** អេង កុកថាយ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន

*សំបុត្រៈ*

# ការពិតរបស់សមមិត្ត នួន ជា

នៅថ្ងៃទី២៨ ខែកុម្ភៈ នួន ជា បានបញ្ជាក់អំពីការមិនពេញចិត្តរបស់ខ្លួនចំពោះឈ្មោះរបស់ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា“ស្វែងរកការពិត” ។ នួន ជា បាននិយាយថា “មានតែប្រជាជនដែលបានឈឺចាប់ឬទទួលរងការជិះជាន់ប៉ុណ្ណោះដែលយល់អំពីការពិត” ។

ខ្ញុំយល់ស្របជាមួយ នួន ជា ថាមានតែអ្នកដែលបានទទួលនូវការឈឺចាប់ ឬត្រូវគេគាបសង្កត់ទេដែលអាចយល់អំពីការពិត ។ ជាការពិតណាស់ ប្រជាជនខ្មែររាប់លាននាក់បានទទួលរងនូវទុក្ខលំបាកវេទនានៅក្រោមរបបរបស់ នួន ជា ។ ព្រះមហាក្សត្រ និងប្រជាជនខ្មែរទាំងអស់ សុទ្ធតែមានបងប្អូនយ៉ាងហោចណាស់ចំនួនមួយរូបដែលបានទទួលរងការធ្វើទារុណកម្មផ្លូវចិត្ត ឬរូបរាងកាយ ការបង្អត់អាហារ និងការប្រហារជីវិតដោយរបបរបស់ នួន ជា ។ នួន ជា បានបដិសេធមិនព្រមទទួលស្គាល់ការឈឺចាប់ដែលខ្លួនបានបង្កទៅលើប្រជាជនកម្ពុជា ពីព្រោះខ្លួនគឺជាអ្នកជិះជាន់ ប្រសិនបើមិនមែនជាឃាតករសម្លាប់មនុស្សដោយផ្ទាល់ដៃទេនោះ ។

ប្រជាជនកម្ពុជាដែលបានឆ្លងកាត់សម័យខ្មែរក្រហម រួមទាំងរូបខ្ញុំផង ដឹងអំពីការពិតច្បាស់លាស់ណាស់ ហើយគ្មានការបដិសេធណាមួយរបស់អតីតមេដឹកនាំខ្មែរក្រហមដូចជា នួន ជា និង ខៀវ សំផន អាចបំភ្លើសការពិតបានឡើយ ។

ខ្ញុំសង្ឃឹមថា នួន ជា នឹងមិនទៅជួបជាមួយ ប៉ុល ពត នៅក្នុងផ្លូវដើសោះកក្រោះមុនពេលត្រូវយកទៅកាត់ទោសនៅក្នុងតុលាការឆាប់ៗខាងមុខ ។ នៅមានសំណួរជាច្រើនដែល នួន ជា ត្រូវឆ្លើយតបចំពោះជនរងគ្រោះនៃរបបរបស់ខ្លួន និងចំពោះខ្លួនឯងផ្ទាល់ ។

**ឆាំង យុ**



*(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)*

# ដាំរ៉ុង: ទាហានការិយាល័យអាកាសចរខេត្តដំបង

ដាំ ណារ៉ុង ហៅ ដាំរ៉ុង ជាអតីតទាហានស័ក្តិ២ការិយាល័យអាកាសចរនៃរបបសាធារណរដ្ឋខ្មែរ ។ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច គាត់និងក្រុមគ្រួសារមិនត្រូវបានជម្លៀសចេញពីភូមិគោកពន្លៃ ឃុំឱម៉ាល់ ស្រុកភ្នំសំពៅ ខេត្តបាត់ដំបងទេ ។ ដោយសារគាត់ជាទាហានរបស់របប លន់ ណុល និងជាមុខសញ្ញារបស់អង្គការខ្មែរក្រហមផង មិនយូរមិនឆាប់គាត់ក៏ត្រូវចាប់ខ្លួនជាមួយនឹងអតីតនាយទាហានជាច្រើនរូបទៀត ។ ដាំរ៉ុង បានត្រូវបង្ខំឲ្យសារភាពអំពីប្រវត្តិរបស់ខ្លួនតាំងពីកុមារភាពរហូតដល់ថ្ងៃចាប់ខ្លួន ។

កាលពីកុមារភាព ដាំរ៉ុង ត្រូវបានម្តាយបញ្ជូនឲ្យទៅស្នាក់នៅឯវត្តជាមួយឪពុកមាម្នាក់ឈ្មោះ ព្រហ្ម ណម ដែលជាព្រះចៅអធិការវត្តនរា ខេត្តបាត់ដំបង ។ ក្រោយពីឪពុកមារបស់ ដាំរ៉ុង បានចូលបម្រើនៅក្នុងអង្គការសេ.អា.តូ(ខ្មែរសេរី) តាមការអូសទាញរបស់ កែវ សំណាង គាត់ក៏អូសទាញ ដាំរ៉ុង ព្រះសង្ឃនិងសិស្សសាលាមួយចំនួនឲ្យចូលក្នុងចលនាសេ.អា.តូជាមួយដែរ ។ បងប្រុសរបស់ ដាំរ៉ុង ឈ្មោះ ដាំ យឿន ហៅ សារិត ដែលកំពុងបួសជាសង្ឃ និងបងប្អូនជីដូនមួយពីរនាក់ឈ្មោះ ញ៉ុក ពន្លក និងឈ្មោះ ញាណ ក៏បានចូលរួមក្នុងចលនានោះដូចគ្នា ។

នៅក្នុងឆ្នាំ១៩៦០ នៅពេលដែល ដាំរ៉ុង កំពុងសិក្សានៅថ្នាក់ទី៦ទំនើបនៅឡើយ ដាំរ៉ុង បានជួយអូសទាញសិស្សចំនួន១៣នាក់មកឲ្យបងប្រុសរបស់គាត់ឈ្មោះ ដាំយឿន ហៅ សារិត ។

នៅឆ្នាំ១៩៦២ ដាំរ៉ុង និងមនុស្ស១៥នាក់ទៀត បានចូលបម្រើក្នុងអង្គការសេ.អ៊ី.អាតាមការណែនាំរបស់ ដាំ យឿន និងបានទទួលប្រាក់ឧបត្ថម្ភចំនួន១០ម៉ឺនរៀលក្នុងមួយខែ ដោយបំពេញភារកិច្ចជាអ្នកដើរស៊ើបការណ៍និងធ្វើវិទ្ធង្សនា ។ ដាំរ៉ុង និងគ្នីគ្នារបស់គាត់បានកសាងកម្លាំងសិស្សចំនួន១២នាក់ និងប្រជាជន៣នាក់ ។ ឈ្មោះទាំងនេះត្រូវបានភ្ជាប់ទៅនឹងខ្សែបណ្តាញមួយចំនួនទៀតដើម្បីចូលរួមគាំទ្រផែនការសេ.អា.តូនៅកម្ពុជា ។ នៅចុងឆ្នាំ១៩៦៣ ដាំ យឿន បានបញ្ជូន ដាំរ៉ុង, ខៀវ កោវិទោ និង ជុន ទ្រី ទៅធ្វើការនៅគណបក្សប្រជាធិបតេយ្យប្រចាំក្រុងបាត់ដំបង ជាមួយឈ្មោះ ពៅ ។ គណបក្សនេះបង្កើតឡើងដើម្បីប្រឆាំងនឹងគណបក្សកុម្មុយនិស្ត ។ នៅឆ្នាំ១៩៦៤ ដាំរ៉ុង, ខៀវ កោវិទោ និង ជុន ទ្រី ត្រូវបាន ម៉ៅរុន ចាត់តាំងឲ្យចូលបង្កប់ខ្លួនក្នុងចលនាចម្រើននិងអង្គការពីរទៀតរបស់គណបក្សកុម្មុយនិស្តគឺអង្គការយុវជនស្នេហាជាតិ និងអង្គការពលករ ។ ដាំរ៉ុង បានសារភាពថា គាត់បានបំផ្លាញនិងបំបែកបំបាក់កម្លាំងផ្ទៃក្នុងរបស់អង្គការពលករ ហើយបានអូសទាញបុគ្គលិករបស់អង្គការនេះមួយចំនួនឈ្មោះ អេន, សែម, ពុំ និង ផល ឲ្យចូលបម្រើអង្គការសេ.អ៊ី.អា ។

នៅឆ្នាំ១៩៦៥ សោម សំអ៊ុន បានឡើងកាន់តំណែងជាប្រធានចលនាចម្រើនដែលពីមុនតំណែងនេះជារបស់ ម៉ៅ រុន ។ ដាំរ៉ុង, ខៀវ កោវិទោ និង ជុន ទ្រី បានអូសទាញសមាជិករបស់អង្គការស.ក.ប(សម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ?)ម្នាក់ឈ្មោះ ឌុច ចក់ ឲ្យចូលរួមក្នុងអង្គការសេ.អ៊ី.អា ។ នៅឆ្នាំ១៩៦៦ ដាំរ៉ុង, ខៀវ កោវិទោ និង ជុន ទ្រី បានភ្ជាប់ទំនាក់ទំនងជាមួយភ្នាក់ងារបង្កប់ចំនួន១៨នាក់ដើម្បីបន្តការងារសម្ងាត់របស់ខ្លួនតទៅទៀត ។

ឆ្នាំ១៩៦៧ ពេលរៀននៅថ្នាក់ទីបញ្ចប់ ដាំរ៉ុង និងមិត្តភ័ក្ត្ររបស់គាត់ឈ្មោះ តែ ឡេងហៃ, គង់ វុទ្ធី, ឈរ ឈុនលី, និង ឃិម គិមសាន បានបញ្ចុះបញ្ចូលមិត្តរួមថ្នាក់និងប្រជាជនឲ្យចូលក្នុងចលនាសេ.អ៊ី.អា៩នាក់ ហើយឈ្មោះទាំងអស់នេះត្រូវបានបញ្ជូនឲ្យតាមដានផ្ទៃក្នុងរបស់ចលនាចម្រើនតាមដានសិស្សនិងប្រជាជន ក្រៅពីនេះគឺដើរឃោសនាប្រជាជននៅក្នុងភូមិរបស់ខ្លួនឲ្យគាំទ្ររដ្ឋាភិបាល លន់ ណុល ។

នៅក្នុងឆ្នាំដដែលនោះ ដាំរ៉ុង និងមិត្តភក្តិពីរនាក់ បានប្រឡង

ជាប់មករៀននៅភ្នំពេញជាមួយគ្នា ។ នៅក្នុងរយៈពេលនោះអ្នកទាំងបីបានស្គាល់ប៉ូលិសសម្ងាត់ស័ក្តិ៥ម្នាក់ឈ្មោះ ឡាយ គិមហុង ជាខ្មែរសេ.អ៊ី.អានៅភ្នំពេញ ។ អ្នកទាំងបីបានចូលជាសមាជិកសមាគមនិស្សិតទូទៅនៃប្រទេសកម្ពុជាដែលមាន ភោគ ឆាយ ជាប្រធាន ក្រោយមកក្នុងឆ្នាំ១៩៧៧ (ភោគ ឆាយ ត្រូវខ្មែរក្រហមចាប់ខ្លួនមកគុកទួលស្លែង ។ ចម្លើយសារភាពរបស់ ភោគ ឆាយ ចុះផ្សាយនៅក្នុងទស្សនាវដ្តីស្វែងរកការពិតលេខ១៦ ខែមិថុនា ឆ្នាំ២០០០) ។

ឆ្នាំ១៩៦៨ ដាំ វ៉ុង និង ខៀវ កោវិទោ បានចូលរួមនៅក្នុងអង្គការបដិវត្តមួយទៀតដែលមានឈ្មោះថាយុវជនកម្ពុជាប្រជាធិបតេយ្យ (ហៅកាត់ថា យុវកប) ។ នៅក្នុងអង្គការនោះ អ្នកទាំងពីរបានបង្កបាតុភាពផ្សេងៗធ្វើឲ្យសមាជិកនៃសមាគមនិងអង្គការយុវជនកម្ពុជាប្រជាធិបតេយ្យបែកខ្ចាត់ខ្ចាយរលំរលាយ ខ្លះត្រូវជាប់ឃុំឃាំង ខ្លះទៀតងាកទៅចូលសេ.អ៊ី.អា ។ ចំពោះអ្នកដែលអូសទាញបាន គឺត្រូវចាត់តាំងឲ្យធ្វើសកម្មភាពតាមដានខ្មែរចម្រើនផ្ទៃក្នុងសិស្សនិងសាស្ត្រាចារ្យដូចគ្នា ។ នៅក្នុងឆ្នាំនេះមានសមាជិកសេ.អ៊ី.អា ជាច្រើនបានបង្កប់ទៅក្នុងជួរចម្រើន ។ ចំណែកនៅក្នុងស្រទាប់ប្រជាជនមាន ញ៉ុក ពន្លក, ដាំ យឿន, ពៅ, ញាណ, ស៊ាង និង គោ សារឿន បានកៀងគរកម្លាំងប្រជាជនឲ្យចេញធ្វើការបង្ក្រាបចលនាតស៊ូរបស់ប្រជាជននៅភ្នំវាយចាប ហើយថែមទាំងបានឃោសនាប្រជាជនឲ្យជឿលើរដ្ឋាភិបាល លន់ ណុល ថែមទៀត ។

ឆ្នាំ១៩៦៩ នៅក្នុងខេត្តបាត់ដំបង អង្គការសេ.អ៊ី.អាបានធ្វើសកម្មភាពឃោសនានិងបំផុសឲ្យប្រជាជនចេញបង្ក្រាបចលនាតស៊ូរបស់ប្រជាជន ។ ដាំវ៉ុង និងមិត្តភក្តិរបស់គាត់ បានកៀងគរកម្លាំងដើម្បីគាំទ្រការធ្វើរដ្ឋប្រហាររបស់រដ្ឋាភិបាល លន់ ណុល ។ ចំណែក តូ វ៉ាន់នី និស្សិតមហាវិទ្យាល័យវិទ្យាសាស្ត្រ និងជាមិត្តរបស់ ដាំវ៉ុង បានអូសទាញនិស្សិតដូចគ្នាបានចំនួន៤នាក់ រួចបញ្ជូនឲ្យទៅធ្វើសកម្មភាពបំបែកបំបាក់ចលនានិស្សិតនៅក្នុងមហាវិទ្យាល័យវិទ្យាសាស្ត្រជាមួយនារី បុន សត់ និងនារី ឌី វ៉ាន់ថាន និងអូសទាញបានអតីតមេបញ្ជាការទាហានចំនួន៥នាក់ទៀត ។

ឆ្នាំ១៩៧០ ដាំវ៉ុង ស្ម័គ្រចិត្តធ្វើជាទាហានកងទ័ពអាកាស ។ សំរិត ពូន និង ដាំវ៉ុង បានចូលបង្កប់ខ្លួននៅក្នុងអង្គការចម្រើនក្នុងខេត្តបាត់ដំបងតាមការចាត់តាំងរបស់ វ៉ាត់ វ៉ាន់នី ។ ដាំវ៉ុង បានដើរឃោសនាប្រជាជនចូលធ្វើទាហានឲ្យបានច្រើន ក្នុងនោះមានសមាជិកសេ.អ៊ី.អាចំនួន១១នាក់ក៏បាននាំគ្នាចូលធ្វើទាហានលន់ណុលដែរ ។

នៅឆ្នាំ១៩៧១ សំរិត ពូន និង ដាំវ៉ុង ត្រូវបានបំពាក់ស័ក្តិ១ ។ នៅក្នុងឆ្នាំនេះ ដាំវ៉ុង, សំរិត ពូន, ម៉ៅ រុន, ម៉ម ច័ន្ទណា (អតីតសាស្ត្រាចារ្យនៅមហាវិទ្យាល័យវិទ្យាសាស្ត្រ ជាសាច់ញាតិរបស់ អ៊ិន តាំ), កង ចំរើន, សោម សំអ៊ុន, ឡុក ឆួត, តូច ឈួង, កុល យឿត, និង ប៊ុន សម្ភាជ បានបង្កើតសមាគមមួយ ។

ឆ្នាំ១៩៧២ ដាំ យឿន បានត្រឡប់មកពីហាត់រៀនយុទ្ធសាស្ត្រទ័ព នៅវៀតណាមខាងត្បូង ហើយបានមកកាន់តំណែងខាងផ្នែកប្រតិបត្តិការសឹក ។ ដាំវ៉ុង បានប្រគល់កិច្ចការរបស់ខ្លួនឲ្យទៅបងប្រុសធ្វើបន្តទៀត ចំណែកខ្លួនបានទាក់ទងនារីម្នាក់ឈ្មោះ នី ដែលជានិស្សិតរបស់ តែ ឡេងហៃ ជាគ្រូបង្រៀនដើម្បីស៊ើបរកពត៌មានស្តីអំពីគម្រោងការវាយស្កាត់ផ្លូវរបស់ពួកកងទ័ពរំដោះនៅភូមិអូរតាប៉ោងនិងគម្រោងការវាយប្រហារបន្ទាយដូនកែវ ។

ឆ្នាំ១៩៧៣ ជុន ទ្រី និង ដាំវ៉ុង បានសំណូមពរឲ្យ ហឿន និង ពុំ ដែលធ្វើការនៅក្នុងក្របខ័ណ្ឌបដិវត្តន៍ជួយផ្តល់ពត៌មានរបស់អង្គការបដិវត្តន៍ទៅឲ្យអង្គការសម្ងាត់សេ.អ៊ី.អា ។ បន្ទាប់មក ដាំ វ៉ុង, ជុន ទ្រី, សោម សំអ៊ុន និងប្រាក់ សាវ៉ាត បានពិភាក្សាគ្នាដាក់ផែនការវាយបដិវត្តបន្ត។ នៅក្នុងចម្លើយសារភាពរបស់ ដាំវ៉ុង បានសរសេរថា "ខ្ញុំ, ជុន ទ្រី, សោម សំអ៊ុន និង ប្រាក់ សាវ៉ាត បានទាក់ទងគ្នាដើម្បីរៀបចំផែនការទប់ទល់នឹងបដិវត្ត ហើយបានសម្រេចដូចតទៅៈ១) បង្កើនកម្លាំងសេ.អ៊ី.អា ក្នុងស្រទាប់មជ្ឈដ្ឋាននៅក្នុងក្រុង ។ ២) បង្កើតកម្លាំងចារកម្មទៅក្នុងតំបន់រំដោះ និងទី៣) ចាត់តាំងឲ្យកម្លាំងសេ.អ៊ី.អាចុះជាប់ប្រជាជនដើម្បីតាមដានសកម្មភាពវិទ្ធង្សនារបស់បដិវត្តន៍" ។ ក្រោយពីរៀបចំផែនការហើយ ប្រាក់ សាវ៉ាត បានធ្វើដំណើរទៅកាន់តំបន់រំដោះហើយស្នាក់នៅជាមួយ ខៀវ កោវិទោ, ប្រាក់ សោភ័ណ និង ឌុច ចក់ នៅផ្ទះរបស់ វន ជាលេខាឃុំស្រុកសង្កែតំបន់១ ។ ដាំវ៉ុង អូសទាញបានទាហានស័ក្តិ១ម្នាក់ឈ្មោះ ខ្ទីង សាម៉ន បញ្ចូលជាសមាជិក

សេ.អ៊ី.អាថែមទៀត ។

នៅក្នុងខែកញ្ញា ស្ថានការណ៍សឹកនៅក្នុងខេត្តបាត់ដំបង កាន់តែមានភាពតានតឹង ដាំរ៉ុង គឺជាអ្នកទទួលខុសត្រូវការពារសាលាទ័ពអាកាស ។ ដាំរ៉ុង បានចូលបង្កប់ជួរនៅភូមិខ្សាយដើម្បីឃ្លាំមើលគ្រប់សកម្មភាពកងទ័ពរំដោះដែលឆ្លងកាត់តំបន់នោះ ហើយរាយការណ៍ទៅឲ្យ ដាំ យឿន ចុះធ្វើប្រតិបត្តិការកម្ទេចមន្ទីរបដិវត្តន៍នៅល្អាងភ្នំចាក់អង្ការ ព្រមទាំងចាប់បុគ្គលិកពេទ្យចំនួន ៥ នាក់យកមកឃុំឃាំង ។

ឆ្នាំ១៩៧៤ ដាំរ៉ុង បានឡើងឋានៈជាអនុសេនីយ៍ទោ ។ ដាំរ៉ុង ត្រូវបានតែងតាំងឲ្យធ្វើជានាយសេនាធិការដ្ឋាននៅសាលារៀនកងទ័ពអាកាសខេត្តបាត់ដំបងវិញ ។ នៅទីនោះ ដាំរ៉ុង បានបញ្ចុះបញ្ចូលអតីតទាហានព្រិន្ទបាលឯកម្នាក់ឲ្យចូលធ្វើការនៅក្នុងអង្គការរបស់ខ្លួន ។

ដើមឆ្នាំ១៩៧៥ សភាពការណ៍នៅជុំវិញទីក្រុងមានសភាពកាន់តែធ្ងន់ធ្ងរឡើង ។ ដាំរ៉ុងនិងបក្ខពួករបស់គាត់ នៅតែបន្តសកម្មភាពជាបន្តបន្ទាប់ ដោយបញ្ចូលកម្លាំងបង្កប់ដែលអូសទាញបាន ទៅក្នុងអង្គការបដិវត្តន៍និងជួរប្រជាជន ដើម្បីបង្កឲ្យមានការបះបោរប្រឆាំងនឹងបដិវត្តន៍ ។ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងបដិវត្តបានផ្តួលរំលំរបប លន់ ណុល បណ្តាញខ្មែរបង្កប់របស់ ដាំរ៉ុង ក៏ត្រូវបែកខ្ញែកគ្នាអស់ ខ្លះត្រូវកងទ័ពរំដោះកម្ទេចចោល ខ្លះភៀសខ្លួនទៅប្រទេសថៃ ហើយខ្លះទៀតត្រូវអង្គការប្រមូលឲ្យទៅរស់នៅភ្នំអូរពងមាន់ ។ ដាំ យឿន និង ហ៊ូ មាន ក៏ត្រូវអង្គការបដិវត្តកៀរយកទៅដែរ ។ បន្ទាប់ពីពេលនោះមក ដាំរ៉ុង បានជួប សោម សំអ៊ុន, កុល យឿត ជុន នេត, សុខុំ, ខៀវ ម៉ាឃឿន និង ជា សុខន ហើយបាននាំគ្នាត្រឡប់ចូលមកក្រុងបាត់ដំបងវិញ ។ អង្គការតំបន់បានចាត់តាំង សោម សំអ៊ុន ឲ្យប្រមូលកម្លាំងអ្នកតស៊ូនៅក្នុងក្រុងបាត់ដំបងទាំងអស់មកធ្វើការវិញ ។ សោម សំអ៊ុន ប្រមូលកម្លាំងសេ.អ៊ី.អាបង្កប់ក្នុងជួរចម្រើន បានចំនួនម្ភៃនាក់រួមទាំង ដាំរ៉ុង ផង បន្ទាប់មកបានបែងចែកកម្លាំងជាបីក្រុមឲ្យទៅធ្វើការនៅតាមស្រុកចំនួនបីគឺស្រុក៤១ ស្រុក៤២ និងស្រុក៤៣ ដែលឋិតនៅក្នុងតំបន់៤ ។ ចំពោះឈ្មោះដែលត្រូវបែងចែកគឺបំបែកទៅតាមឃុំផ្សេងៗទៀតដើម្បីងាយស្រួលក្នុងការរៀបចំខ្មែរបណ្តាញសេ.អ៊ី.អាបន្តទៀត ។ មុនពេលចុះធ្វើការជាមួយកម្មាភិបាលបដិវត្តម្តងៗ សោម សំអ៊ុន និង កុល យឿត តែងតែផ្តល់ដំណឹងឲ្យខ្មែរសេ.អ៊ី.អារបស់គាត់នៅតាមឃុំនានាដឹងមុនជានិច្ច ។ សោម សំអ៊ុន និង កុល យឿត ត្រូវអង្គការតំបន់៤ ផ្តល់ការទុកចិត្ត ហើយអនុញ្ញាតឲ្យធ្វើការនៅកៀកនឹងខ្លួនទៀតផង ។ នៅខែឧសភា ឆ្នាំ១៩៧៥ អង្គការតំបន់៤បានកោះហៅ សោម សំអ៊ុន និងក្រុមបញ្ញាជន ទៅរៀនសូត្រនៅវត្តសម្តេចមួយថ្ងៃ ។ ក្រោយរៀនសូត្រចប់ អង្គការតំបន់៤បានសុំឲ្យ សោម សំអ៊ុន ជួយរៀបចំពិធីបុណ្យរំឭកខួបថ្ងៃទី១៧ ខែមេសា ១៩៧៥ នៅក្នុងស្រុក៤១ ។ ជាឱកាសល្អ សោម សំអ៊ុន, កុល យឿត, ដាំរ៉ុង និងគ្នីគ្នា៨នាក់ទៀតបានដាក់ផែនការអនុវត្តបីចំណុច ទី១) គឺបង្កទំនាស់ផ្ទៃក្នុងកម្មាភិបាលដែលចុះជាប់ជាមួយ ។ ទី២) បំផុសឲ្យប្រជាជនថ្មីជ្រួលច្របល់ និងទី៣) បំផ្លាញទ្រព្យសម្បត្តិរបស់រដ្ឋនៅតាមមន្ទីរនិងក្រសួង ។ ដាំរ៉ុង និងឈ្មោះ ប្រាក់ សាវ៉ាត់ បានចុះធ្វើការជាមួយខ្មែរបង្កប់នៅតាមឃុំនានា បំភិតបំភ័យប្រជាជននៅពេលដែលអង្គការបដិវត្តន៍ដើរប្រមូលកុមារអាយុចាប់ពី៨ដល់១៨ឆ្នាំឲ្យរៀនសូត្រនៅតាមមន្ទីរ ។ ដាំរ៉ុង បានញុះញង់ថា “អង្គការយកកុមារតូចៗទាំងអស់នេះទៅសងយួនយៀកកុងដែលបានស្លាប់ក្នុងពេលមកជួយច្បាំងក្នុងពេលសង្គ្រាម” ។ ការឃោសនានេះបានធ្វើឲ្យប្រជាជនជ្រួលច្របល់នាំគ្នាយកកូនទៅលាក់ ហើយតវ៉ាមិនព្រមប្រគល់កូនទៅឲ្យអង្គការ ។ ក្រោយមកទៀត ដាំរ៉ុង បានដឹកនាំ ឌឹង សាម៉ន, នូ សាម៉ន, ជល, ពុំ, ដោក និង សោភ័ណ បង្កភាពភ័យខ្លាចចំពោះកុមារជារៀងរាល់យប់ រហូតដល់កុមារខ្លះទៅជាឈឺ និងខ្លះទៀតទ្រាំមិនបានលួចរត់ត្រឡប់ទៅផ្ទះវិញ ។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥ អង្គការបានចាត់តាំង ដាំរ៉ុង ឲ្យមើលថែរក្សាក្មេងនៅវត្តបសេដ្ឋ ដាំរ៉ុង បែរជាអប់រំណែនាំកុមារចំនួន ១២នាក់ជាកូនរបស់ប្រជាជនថ្មីឲ្យជួយបំបែកបំបាក់ផ្ទៃក្នុងកុមារ បំផ្លិចបំផ្លាញផ្លែឈើនៅក្នុងការដ្ឋាននិងរបស់ប្រជាជន ។ ពីរខែក្រោយមក ដាំរ៉ុង ត្រូវផ្លាស់មកនៅឃុំអូម៉ាល់ស្រុកសំពៅមាស ។ អង្គការបានចាត់តាំង ដាំរ៉ុង និង អៀង ឲ្យទៅជួយដឹកស្រូវឲ្យកងចល័តយុវជនយុវនារីនៅតាមភូមិនានា ។ នៅពេលនោះ ដាំរ៉ុង បានដើរបញ្ចុះបញ្ចូលបងប្អូនប្រជាជននៅក្នុងឃុំអូរម៉ាល់ឲ្យមាន

ទំនាស់នឹងអង្គការឃុំថែមទៀត ។

ឆ្នាំ១៩៧៦ ដាំរ៉ុង បានដឹកនាំកងចល័តទៅកាន់ការដ្ឋានបឹងពោធិ៍ ហើយបន្តការងារអូសទាញប្រជាជននៅទីនោះបានបួននាក់ឈ្មោះ សេង ឡេង, ដោក, ហេង, សួន និង ឌឿន ឲ្យចូលរួមសកម្មភាពជាមួយគ្នា ។ បន្ទាប់ពីដឹងខ្លួនថាអង្គការឃុំតាមចាប់ អ្នកទាំងបួនបានភៀសខ្លួនទៅប្រទេសថៃ ប៉ុន្តែកងឈ្លបបដិវត្តន៍បានស្ទាក់កម្ទេចចោលនៅត្រឹមអូរជីបង ។

ដាំរ៉ុង និង អៀង ចេះតែបន្តញុះញង់ឲ្យប្រជាជនមានទំនាស់ជាមួយកម្មាភិបាលពេទ្យអំពីការដែលមិនបានផ្តល់ថ្នាំល្អៗឲ្យអ្នកជំងឺនិងឃោសនាប្រជាជនឲ្យប្រឆាំងនឹងអង្គការឃុំ ។ ខែសីហា ដាំរ៉ុង បានទទួលផែនការពីរថ្មីទៀតពីប្រធានភូមិដងទង់ ទី១) កសាងកម្លាំងដោយឃោសនាអប់រំណែនាំនិងបំផុសបំផុលឲ្យប្រជាជនប្រឆាំងនឹងបដិវត្តន៍ ទី២) ស្រាវជ្រាវរកខ្សែទាក់ទងទៅខាងព្រៃអំពិលប្រាំដើមនៅតំបន់៣ ។ ដាំរ៉ុង អូសទាញបានអតីតទាហានម្នាក់ឈ្មោះ សម សំផុន ។ ដាំរ៉ុង បានធ្វើដំណើរទៅកាន់ស្រុក៤១ តំបន់៤ ពិភាក្សាជាមួយ ប្រាក់ សាវ៉ាត់ អំពីផែនការថ្មីទៀតដែលផ្តោតសំខាន់ទៅលើចំណុចបំបែកផ្ទៃក្នុងជួរកម្មាភិបាលធ្វើវិច្ឆេទកម្មខាងកសិកម្មនិងឧស្សាហកម្ម ។

នៅចុងខែសីហា ដាំរ៉ុង ត្រូវបានប្រធានគណៈឃុំអូរម៉ាល់បញ្ឈប់ពីការងារជាអ្នកផលិតថ្នាំ ហើយបញ្ជូនឲ្យទៅនៅភូមិគោកពន្លៃ ក្នុងសហករណ៍១ ។ ចាប់តាំងពីនោះមក ដាំរ៉ុង បានធ្លាក់ខ្លួនឈឺនិងសម្រាកព្យាបាលខ្លួនអស់រយៈពេលមួយខែ ។ ដាំរ៉ុង បំពេញការងារផងនិងឆ្លៀតពេលជួបពិភាក្សាជាមួយខ្សែរបស់គាត់ជាញឹកញយផងដើម្បីរាយការណ៍អំពីលទ្ធផលការងារទៅវិញទៅមក មុននឹងពិភាក្សាអនុវត្តផែនការថ្មី ។ រហូតដល់ចុងឆ្នាំ១៩៧៦ ទើបត្រឡប់មកធ្វើការនៅឃុំអូរម៉ាល់ជាមួយ អៀង ។ ស្របពេលជាមួយគ្នានោះអង្គការបានចាត់តាំងឲ្យ ដាំរ៉ុង ធ្វើជាអ្នកគូរផែនទី ។ ដាំរ៉ុង ក៏បានប្រើប្រាស់ពេលវេលានេះទៅបំផុសបំផុលប្រជាជនឲ្យស្អប់បដិវត្តន៍ ដោយលើកយកចំណុចសំខាន់ៗពីរគឺ ទី១) ការរស់នៅក្នុងរបបសមូហភាពគ្មានចម្រើនគឺអន់ថយជាងការរស់នៅជាឯកជន និងទី២) ការរស់នៅក្នុងរបបបដិវត្តន៍សព្វថ្ងៃគ្មានសិទ្ធិសេរីភាពបរិបូរណ៍ទេ ទាំងការហូបចុកស្លៀកពាក់ ដើរហើរ និងនិយាយស្តី ។

នៅឆ្នាំ១៩៧៧ កម្លាំងរបស់សេ.អ៊ី.អា បានបង្កើនការបំផ្លិចបំផ្លាញផ្នែកសេដ្ឋកិច្ចនិងកសិកម្មរបស់អង្គការបដិវត្តកាន់តែខ្លាំងឡើយ ។ ជឿន, អឿប និង ឆិត បានលួចទម្លាយទំនប់ទឹកដើម្បីដាក់លបចាប់ត្រីបណ្តាលឲ្យស្រែខ្វះទឹក ខូចសន្ទូងប្រាំងអស់៨ហិកតា ។ ដាំរ៉ុង និង គ្រឿន បានលួចដោះលែងក្របីឲ្យចូលស៊ីស្រូវអស់៤០ថាំង ។ អៀង ត្រូវអង្គការផ្លាស់ពីមន្ទីរស្រុកភ្នំសំពៅឲ្យទៅនៅការដ្ឋានបឹងពោធិ៍វិញ ។ ដាំរ៉ុង ត្រូវរ៉ាប់រងផែនការជំនួស អៀង តទៅទៀត ។ ដាំរ៉ុង បានយកផែនការរបស់ អៀង ទៅសហការជាមួយ ជឿន និង សឿន ដើម្បីអនុវត្តប្រឆាំងនឹងបដិវត្តនៅក្នុងរដូវចម្រូត ។ នៅពាក់កណ្តាលខែ



ខៀវ សំផន

មីនា ឆ្នាំ១៩៧៧ អង្គការបានចាប់ផ្តើមរឹតបន្តឹងផ្នែកសន្តិសុខ ហាមប្រាមមិនឲ្យប្រជាជនផ្លាស់ចេញពីកន្លែងមួយទៅកន្លែងមួយ ដោយគ្មានការអនុញ្ញាត និងបានតាមដានឈ្មោះអ្នកប្រឆាំងដែលជាប់សង្ស័យមួយចំនួនទៀត ។ ដាំរ៉ុង និង ស៊ុន លី ក៏ស្ថិតនៅក្នុងការតាមដានរបស់អង្គការដែរ ប៉ុន្តែអ្នកទាំងពីរនៅតែលួចជួបគ្នាដដែល ។ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៧ នៅខណៈដែល ដាំរ៉ុង កំពុងរង់ចាំ ស៊ុន លី នៅការដ្ឋានបឹងពោធិ៍ គាត់ក៏ត្រូវអង្គការចាប់ខ្លួន ។

ដាំរ៉ុង ត្រូវសួរចម្លើយដោយឈ្មោះ ៣ ហ៊ាង នៅក្នុងក្រុម ១០ ។ មិនមែនមានតែ ដាំរ៉ុង ម្នាក់ប៉ុណ្ណោះទេដែលត្រូវបានចាប់ខ្លួន ។ នៅក្នុងចម្លើយរបស់គាត់គឺមានមន្ត្រីទាហានឋានៈចាប់ពីស័ក្តិមួយទៅឡើងក៏ត្រូវចាប់ខ្លួនដែរដោយយោងតាមចំណារមួយដែលសរសេរថា "ឈ្មោះក្នុងក្របខ័ណ្ឌពាយ័ព្យចាប់ទាំងអស់" ។

**ជីវប្រវត្តិនិងក្រុមគ្រួសារ**

ដាំរ៉ុង មានស្រុកកំណើតនៅភូមិចម្ការសំរោង ឃុំចម្ការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។ ដាំរ៉ុង មានប្រពន្ធពីរនាក់ ។ ប្រពន្ធទីមួយឈ្មោះ ខាវ គិមហាន បានលែងលះគ្នា ។ ដាំរ៉ុង បានរៀបការប្រពន្ធទីពីរឈ្មោះ ដុន វ៉ាត រស់នៅភូមិគោកពន្លៃ ឃុំឱម៉ាល់ ស្រុកភ្នំសំពៅ (តំបន់៣) ខេត្តបាត់ដំបង មានកូនពីរនាក់ដែលសុទ្ធបានរៀនដល់ថ្នាក់ទីបញ្ចប់ ។ ឪពុកឈ្មោះ ដាំ ឈឿវ ម្តាយឈ្មោះ ញ៉ុក មៀច ។

**លី សុផល**

*(ឯកសារខ្មែរក្រហម)*

## គោរពជូន ម.៨៧០ ជាទីស្នេហានឹករលឹក

សូមជ្រាប ។

យើងខ្ញុំសូមជម្រាបអំពីឈ្មោះ៣នាក់ដែលខាង៥០៥ចាប់បានកន្លងមកមានដូចខាងក្រោម÷

សេចក្តីបញ្ជាក់របស់គណៈស្រុកឆ្លូងៈ នៅថ្ងៃទី១៥-៩-៧៧ មិត្តចាន់គណៈកងធំកញ្ចរ បានមកសុំលិខិតធ្វើដំណើរ១ច្បាប់ឲ្យឈ្មោះ កែវ ហ៊ាង និងឈ្មោះ ម៉ក់ ទ្រេន ធ្វើដំណើរទៅស្រុកក្រចេះដើម្បីរកត្បូងនៅឃុំបុស្សលាវ ដើម្បីយកមកដោះស្រាយជីវភាពប្រជាជនក្នុងកងធំរបស់ខ្លួន ។

លិខិតលេខ ១៨៩/៧៧ ចុះថ្ងៃទី១៥/៩/៧៧ រយៈ១៥ថ្ងៃដល់ថ្ងៃ៣០-៩៧៧ ផុតកំណត់ចុះហត្ថលេខាគណៈបម្រើប្រជាជនស្រុកឆ្លូងរបស់ខ្លួន ។ តែឈ្មោះទាំងពីរខាងលើ ពេលធ្វើដំណើរទៅជីកត្បូងក៏យកឈ្មោះ លី គឿង ទៅជាមួយដែរបានជាគ្នាបីនាក់ ។ តាំងពីធ្វើដំណើរទៅបានឬមិនបានមិនដែលបានមករាយការណ៍ឲ្យកងធំបានដឹងទេ ។ គណៈស្រុកឆ្លូងមានការចាប់អារម្មណ៍ក៏ឲ្យកងធំទៅតាមរក តែរកមិនឃើញ ហើយក៏មិនដឹងទិសដៅទៅកន្លែងណា ។ ១) អំពីឈ្មោះ កែវ ហ៊ាង និន្នាការនយោបាយពីដើមគ្មានចូលអង្គការនយោបាយណាទេ ។ និន្នាការនយោបាយបច្ចុប្បន្ននៅក្នុងជួរកងតូច ។ ២) អំពីឈ្មោះ ម៉ក់ ទ្រេន និន្នាការនយោបាយពីមុនគ្មានចូលអង្គការនយោបាយទេ ។ និន្នាការនយោបាយបច្ចុប្បន្នជាគណៈបញ្ជាការ កងអនុសេនាតូច មុខព្រួញខាងក្រោយ ។ ៣) អំពីឈ្មោះ លី គឿង និន្នាការនយោបាយកន្លងមកពាលាអាវ៉ាសែ ប្រព្រឹត្តអំពើចោរកម្ម ។ យើងខ្ញុំស្នើសុំមនុស្សទាំងបីនាក់នេះប្រគល់តាមការចាត់តាំងមកគណៈស្រុកឆ្លូងវិញ ដើម្បីមានវិធានការតាមការជាក់ស្តែងនៅខាងនេះ ។ សូមមិត្តជួយជម្រាបជូនខាង៥០៥ យើងខ្ញុំជម្រាបខាងគណៈស្រុកឆ្លូងឲ្យទៅទទួលតាមការចាត់តាំងដូចបានជម្រាបជូនខាងលើស្រាប់ ។

គោរពសូមជូនពរសុខភាពល្អមហាជ័យជំនះ ។

ភូមិភាគបូព៌ាៈ ទី១៦/១០/៧៧

ស.ម ៣ម

# សម្ភារនាំចូលពីបរទេសក្នុងត្រីមាសទីមួយឆ្នាំ១៩៧៦

តាមរយៈរបាយការណ៍ពាណិជ្ជកម្មនៅក្នុងឆ្នាំ១៩៧៥ យើងឃើញថា កម្ពុជាប្រជាធិបតេយ្យបានធ្វើពាណិជ្ជកម្មតែជាមួយប្រទេសចិននិងប្រទេសកូរ៉េខាងជើង។ មកដល់ឆ្នាំ១៩៧៦ ប្រទេសចិននៅតែជាដៃគូដ៏សំខាន់របស់កម្ពុជាប្រជាធិបតេយ្យ។ ក្រៅពីប្រទេសចិនក៏មានប្រទេសមួយចំនួនទៀតដូចជា ហុងកុង ថៃ វៀតណាម និងកូរ៉េ។ ភាគច្រើនទំនិញត្រូវបាននាំចូលតាមសមុទ្រ។ ក្នុងត្រីមាសទីមួយ ឆ្នាំ១៩៧៦ ការនាំចូលសម្ភារពីបរទេសមានពីរដំណាក់កាលធំៗ ។ ដំណាក់កាលទីមួយពីថ្ងៃទី១ ដល់ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងដំណាក់កាលទីពីរគឺពីថ្ងៃទី១ ដល់ថ្ងៃទី៣១ ខែមីនាឆ្នាំ១៩៧៦ ។

ក្នុងដំណាក់កាលទីមួយ កម្ពុជាប្រជាធិបតេយ្យបាននាំចូលសម្ភារមកពីបរទេសចំនួន៣៨មុខ ក្នុងនោះមានក្រណាត់ចំនួន ១៣.៧៧៥.៩៩៦,៦០ម៉ែត្រ ចបកាប់ចំនួន៥៩៩.០៤៤ចបកង់ចំនួន២.២០៥ ប៉ែលចំនួន៤.៩៤៧ អំបោះហុងចំនួន៥១ឡាំង ម៉ាស៊ីនដេរចំនួន២០០គ្រឿង ពោះវៀនកង់ឡានចំនួន ១.០០០ ម្ជុលដេរដៃចំនួន៧៣កញ្ចប់កន្លះ, ម្ជុលម៉ាស៊ីនចំនួន ១៤.៩២០ កន្ត្រៃចំនួន៥១១៨ កាំបិតកោរចំនួន២.៤៤៨ ឡេវអាវចំនួន៩០០កញ្ចប់និង៥៥ឡាំង ថ្មដែកកេះចំនួន១.០២៤ ម្សៅសាប៊ូចំនួន២.៥៣៥ ជីកសិកម្មចំនួន៤.១៧២ បំពង់បាញ់ថ្នាំចំនួន៣.៣៧៥ សារជាតិគីមីចំនួន៧.០១៤ធុង សូដ្យូមស៊ុលហ្វាតចំនួន១៣.៧៦២បាវ អាស៊ីដហ្វ័រមីកចំនួន៦៧៦កាន, ថ្នាំអូលីវចំនួន៨.១៦៩ធុង ម្សៅរំសេវចំនួន១៩.០៩៣ឡាំង លួសចំនួន១.០០០ដុំ គ្រឿងបន្លាស់ឡានចំនួន៩.៧៣៨ឡាំង ម្សៅសូសាចំនួន៩៨៧បាវ ទ្រីសូដ្យូមហ្វូស្វាតចំនួន១០បាវ សូប៉ាប់មូលដែកស្វិតចំនួន៨ឡាំង បំពង់មាត់សូប៉ាប់ចំនួន៨៩ដុំ កង់ដែកជើងតុចំនួន៣៦៥ឡាំង អេឡិចត្រូតចំនួន៨០ឡាំង គ្រឿងសំណង់ចំនួន៩ឡាំង កាសទ្រនាប់ដែកមូលសំប៉ែតចំនួន ៣៩៦បាវ អំបោះហោចំនួន៨.៦៩៣ដុំនិង៣បាវ។ ក្នុងចំណោមសម្ភារខាងលើនេះ ភាគច្រើនមកពីតំបន់ផ្សេងៗនៃប្រទេសចិន ដូចជាធានជីន ក្រុងតាលាន និងសៀងហៃ។

ក្នុងដំណាក់កាលទីពីរមុខទំនិញដែលនាំចូលមកក្នុងប្រទេសកម្ពុជាមានប្រហាក់ប្រហែលនឹងដំណាក់កាលទីមួយដែរ គឺមានសម្ភារ៤៤មុខ ដែលមានកង់ឡានចំនួនសរុប៩៧០ កន្ត្រៃ ៥១១៨ ជាតិរំសេវចំនួន១៩.០៩៣ឡាំង ក្រណាត់ចំនួន ១២.៣៨៥.០៣៦,៦០ម៉ែត្រ ម្សៅសាប៊ូចំនួន២៥៣៥ឡាំង ប្រេងឥន្ធនៈចំនួន៦៩.៥៨១.៦៨២លីត្រ សារធាតុគីមីចំនួន ១២.៦២៥ធុង និងគ្រឿងសំណង់ចំនួន៣៧៩ឡាំង។ រាល់ការទិញដូរត្រូវគិតជារូបិយប័ណ្ណបរទេសដោយឡែកពីគ្នាអាស្រ័យទៅលើមុខទំនិញ ឧទាហរណ៍ប្រេងសាំង គិតជាដុល្លារហុងកុង, ស៊ីម៉ង់ត៍គិតជាប្រាក់បាត ហើយប្រេងម៉ាស៊ីនគិតជាប្រាក់ដុល្លារអាមេរិក។ បន្ថែមពីនេះកម្ពុជាប្រជាធិបតេយ្យបានទទួលការឧបត្ថម្ភធំផ្នែកក្រណាត់ពីប្រទេសចិននិងកូរ៉េខាងជើង។ នៅក្នុងខែមីនា ឆ្នាំ១៩៧៦ កម្ពុជាប្រជាធិបតេយ្យក៏បានទទួលជំនួយឧបត្ថម្ភពីប្រទេសវៀតណាមដែរ ពិសេសផ្នែកប្រេងឥន្ធនៈ។

ផលិតផល ត្រូវបានផ្តល់ដល់ក្រសួង ភូមិភាគ និងរោងចក្រ ហើយភាគច្រើននៃសម្ភារទាំងនោះផ្តល់ទៅរោងចក្រស៊ីម៉ង់, រោងចក្រកង់ឡាន វិទ្យុជាតិ ក្រសួងឧស្សាហកម្មនិងក្រសួងឃោសនាការ។

**ផាត រចនា**

## ស្តាប់ប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតដែលចាក់ផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៣:៣០-៣:៤៥នាទី តាមរយៈវិទ្យុ ១០២ MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា។

ផាត រចនា និង លី សុផល

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយ: យិន នាន

*(តពីលេខមុន)*

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ១២៥៥ | យឹម ម៉ាឡៃ (ស្រី) | ប្អូន យឹម សារិន | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៥៦ | ឌឹម សុខេន (ស្រី) | ប្រពន្ធ ឌី សាម៉េត | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៥៧ | វង់ សុភាព (ស្រី) | កូន អ៊ុក សាខន | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៥៨ | ចាន់ គឹមលី ស្រី) | ក្មួយ ចាន់ ស៊ីណាត | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៥៩ | ដោ សេថា (ស្រី) | ក្មួយ ឡាំ ដោ | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៦០ | ធុយ មិថុនា (ស្រី) | កូនសិស្ស | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៦១ | អ៊ឹម សារិន (ស្រី) | ប្រពន្ធ ប៉ិច សេងថៃ | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៦២ | ដា ស៊ីនួន ស្រី) | ប្រពន្ធ គោ ឈុន | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៦៣ | អ៊ីវ យឹម (ស្រី) | ប្រពន្ធ ឡាយ ប៊ុនលី | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៦៤ | ប៊ិត សារី (ស្រី) | ប្រពន្ធ នូ រឿង | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៦៥ | លាស់ សារីម (ស្រី) | ប្អូន លាស់ អឿន | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៦៦ | ធូ អូន (ស្រី) | រោងចក្រគ-៥ | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៦៧ | ធូ អាន (ស្រី) | រោងចក្រគ-៥ | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៦៨ | លុយ ហ៊ី (ស្រី) | ប្រពន្ធ អ៊ុក ស៊ុម | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៦៩ | ហង់ សោអ៊ី (ស្រី) | ប្រពន្ធ នាក់ ផ្ទួន | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៧០ | អ៊ឹម ផាភ្លឹម (ស្រី) | ប្រពន្ធ កៀត សំអឿន | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៧១ | ចាន់ សារូ (ស្រី) | ប្រពន្ធ ហ៊ុន សាន់ | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៧២ | គឹម ហំប៊ីន (ស្រី) | ប្រពន្ធ ឈឹម សាក់ | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៧៣ | លាង សុគុណ (ស្រី) | ប្រពន្ធ សំ ហាយុន | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៧៤ | ណាវ សាវន (ស្រី) | ប្រពន្ធ ម៉ៅ សុផានី | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៧៥ | គឹម ហុង (ស្រី) | ប្រពន្ធ តែម សុផុន | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៧៦ | ព្រឿង ស៊ីលៀង (ស្រី) | យុទ្ធនារី | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៧៧ | ឌឿ ប្រាក់ (ស្រី) | ប្រពន្ធ នូ ពុំ | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៧៨ | ហង់ សៀង (ស្រី) | ម្ដាយ នាក់ ផ្ទួន | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៧៩ | សំ ពៅ (ស្រី) | ប្រពន្ធ ឡៃ អ៊ី | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៨០ | ឃូ លុនខេង (ស្រី) | ប្រពន្ធ ឃី សេង | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |

| | | | | | |
|---|---|---|---|---|---|
| ១២៨១ | មាស សាម៉ន (ស្រី) | ប្រពន្ធ អ៊ិន សារឿន | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៨២ | គីម លី (ស្រី) | ប្រពន្ធ ភ៉ាន់ដា | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៨៣ | ស៊ីន ស៊ីផូន (ស្រី) | ប្រពន្ធ លាស់ អឿន | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៨៤ | ឈីវ គីមសុច (ស្រី) | ប្រពន្ធ កែប សារឿន | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៨៥ | សំ ខែម (ស្រី) | ប្រពន្ធ ម៉ា សួស | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៨៦ | ឡាយ យូស្រ៊ាន (ស្រី) | ប្រពន្ធ ដៃ សែ | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៨៧ | ព្រាប ស៊ីភឿន (ស្រី) | ប្រពន្ធ ឡុង សាគុណ | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ |
| ១២៨៨ | ញ៉ូវ ឌឿន | យុទ្ធជន | កងពល២៩០ | ២២-៨-៧៦ | ១៥-១១-៧៦ ឈឺស្លាប់ |
| ១២៨៩ | ម៉ម កេង ហៅ សាក់ | កងផលិត | តំបន់១៥ | ៣០-១០-៧៦ | ១៦-១១-៧៦ ឈឺស្លាប់ |
| ១២៩០ | យឹម អឿន | កងហា | ពាណិជ្ជកម្ម | ១៣-៩-៧៦ | ១៦-១១-៧៦ ឈឺស្លាប់ |
| ១២៩១ | មិន ណេង | កម្មករចាស់ | អគ្គិសនី | ៤-៨-៧៦ | ១៦-១១-៧៦ ឈឺស្លាប់ |
| ១២៩២ | ប៉ុល ហៀក | វរសេនាតូច | កងពល១៧០ | ២៩-៨-៧៦ | ១៦-១១-៧៦ ឈឺស្លាប់ |
| ១២៩៣ | ហួត សម្បត្តិ | ទូត | ប្រាំងចំរេះ | ៩-៩-៧៦ | ១៧-១១-៧៦ ឈឺស្លាប់ |
| ១២៩៤ | ស៊ីង ភៀកថ | ចាងហ្វាងកាសែត | បាត់ដំបង | ៣០-១០-៧៦ | ១៨-១១-៧៦ ឈឺស្លាប់ |
| ១២៩៥ | ហុក សុត ហៅ សាក់ | កម្មករចាស់ | រទេះភ្លើង | ១៨-១០-៧៦ | ១៩-១១-៧៦ ឈឺស្លាប់ |
| ១២៩៦ | អ៊ុម សាវ៉ាវុធ | កម្មករចាស់ | អគ្គិសនីទី៣ | ៤-៨-៧៦ | ២០-១១-៧៦ ឈឺស្លាប់ |
| ១២៩៧ | ស៊ិន សោ ហៅ មិន | ជំនួយវរសេនាធំ | កងពល១៧០ | ១៧-៩-៧៦ | ២១-១១-៧៦ ឈឺស្លាប់ |
| ១២៩៨ | នឹម សារឿន | យុទ្ធជន | កងពល៨០១ | ២៨-៨-៧៦ | ២១-១១-៧៦ ឈឺស្លាប់ |
| ១២៩៩ | ស៊ឹម ហ៊ាន | មេក្រុម | ព្រែកព្នៅ | ២៦-៨-៧៦ | ២២-១១-៧៦ ឈឺស្លាប់ |
| ១៣០០ | ទឹម សែ | អាត់សាជង់ | តាឡី | ៣០-៨-៧៦ | ២២-១១-៧៦ ឈឺស្លាប់ |
| ១៣០១ | ជិន ម៉ុន ហៅ សែន | យុទ្ធជន | កងពលទី៣ | ១-៩-៧៦ | ២៣-១១-៧៦ ឈឺស្លាប់ |
| ១៣០២ | ថាច់ ពេជ | លោកសង្ឃ | យួន | ១៦-៩-៧៦ | ២៦-១១-៧៦ ឈឺស្លាប់ |
| ១៣០៣ | គាំង សំអឿន | យុទ្ធជន | កងពល២៩០ | ១៩-១០-៧៦ | ២៦-១១-៧៦ ឈឺស្លាប់ |
| ១៣០៤ | ចាន់ វុធ | ចោរព្រៃ | ពេជនិល | ១០-១១-៧៦ | ២៦-១១-៧៦ ឈឺស្លាប់ |
| ១៣០៥ | ថៅ ដៃ | សេដ្ឋកិច្ច | កងពល១៧០ | ១៧-៩-៧៦ | ២៧-១១-៧៦ ឈឺស្លាប់ |
| ១៣០៦ | ហេង អឿន | យុទ្ធជន | មន្ទីរ ស-៨ | ៤-៨-៧៦ | ២៩-១១-៧៦ ឈឺស្លាប់ |
| ១៣០៧ | យូ ឈុន | វរសេនាធំ | កងពល៧០៣ | ១-៩-៧៦ | ២៩-១១-៧៦ ឈឺស្លាប់ |
| ១៣០៨ | អ៊ុង សារិន | កម្មករចាស់ | រទេះភ្លើង | ៤-១០-៧៦ | ២៩-១១-៧៦ ឈឺស្លាប់ |
| ១៣០៩ | ហេង ហួន | សក្តិ១ | តាឡី | ៣១-៨-៧៦ | ២៩-១១-៧៦ ឈឺស្លាប់ |
| ១៣១០ | សួន ណន | កងហា | កងពល៥០២ | ៦-១១-៧៦ | ៤-១២-៧៦ ឈឺស្លាប់ |
| ១៣១១ | សំអុន សាក់ប៊ុនថុន | កូនសិស្ស | កំពង់ចាម | ១៨-១១-៧៦ | ៤-១២-៧៦ ឈឺស្លាប់ |
| ១៣១២ | អា ម៉ាប់ | ? | ? | ? | ៦-១២-៧៦ |

**(នៅមានត)**

# ស ឌិលៈ ខ្ញុំមិនចង់បានអ្វីទាំងអស់ ក្រៅពីចង់ជួបមុខកូនរបស់ខ្ញុំ

លោកតា ស ឌិល ជាកូនពៅក្នុងចំណោមបងប្អូន៩នាក់ ។ លោកតាចាប់កំណើតនៅក្នុងត្រកូលកសិករនៅស្រុកព្រៃកប្បាស ខេត្តតាកែវ ដោយសារមានទំនាស់ដែលឈានដល់អំពើហិង្សាជាមួយបងថ្លៃប្រុស តាឌិល បានចាកចេញពីស្រុកកំណើតនៅពេលដែលគាត់មានអាយុ២៣ឆ្នាំ ។ គាត់មករស់នៅស្រុកកោះធំ និងបានកសាងក្រុមគ្រួសារមួយពីបាតដៃទទេ ។ នៅក្នុងរបបខ្មែរក្រហម កូនប្រុសតែមួយរបស់ តាឌិល បានចូលបម្រើក្នុងជួរបដិវត្តន៍ ហើយបាត់ដំណឹងរហូតដល់សព្វថ្ងៃ ។ តាឌិល ទន្ទឹងរង់ចាំមើលផ្លូវកូនរបស់គាត់អស់រយៈពេលជិត៣០ឆ្នាំមកហើយ និងនៅតែរង់ចាំតទៅទៀត ។ ក្នុងចិត្តរបស់គាត់នៅតែសង្ឃឹមថា កូនរបស់គាត់នៅរស់ ហើយនឹងវិលមករកគាត់នៅថ្ងៃណាមួយជាក់ជាមិនខាន ។

លោកតា ស ឌិល រស់នៅស្រុកកោះធំប្រកបរបរចិញ្ចឹមជីវិតដោយស៊ីឈ្នួលធ្វើការឲ្យអ្នកស្រុក ។ រស់នៅស្រុកកោះធំបាន៥ឆ្នាំ គាត់បានស្ដីដណ្ដឹងកូនអ្នកស្រុកនៅទីនេះរៀបការ ។ ឪពុកម្ដាយក្មេកគ្មានកេរមរតកចែកឲ្យទេ ។ ទាំងពីរនាក់ប្ដីប្រពន្ធប្រកបរបរនេសាទត្រីដើម្បីចិញ្ចឹមជីវិត ។ គាត់មានកូនស្រីពីរនាក់ ប៉ុន្តែសំណាងមិនល្អកូនស្រីទាំងពីរបានស្លាប់ជាបន្តបន្ទាប់តាំងពីកុមារដោយសារជំងឺកញ្ជ្រឹលនិងអុតស្វាយ ។ កូនទីបីគឺជាកូនប្រុស ។ ដោយសារតែភាពអកុសលនេះ លោកអាចារ្យបានណែនាំឲ្យ តាឌិល ដាក់ឈ្មោះកូនក្រោយថា គង់ ។ រយៈពេល ១១ឆ្នាំក្រោយពេលរៀបការ ប្រពន្ធរបស់តាបានស្លាប់ដោយជំងឺពាន់ឃ្លង់ ។ ជំងឺនេះបណ្ដាលឲ្យខ្លួនប្រាណរបស់ប្រពន្ធតាហើមដើរមិនរួច នៅតែមួយកន្លែងអស់រយៈពេល៣ឆ្នាំ ក្រោមការថែទាំរបស់គាត់និងកូនប្រុសពៅ ។ តាឌិល បានខំប្រឹងអស់ពីលទ្ធភាពក្នុងការព្យាបាលប្រពន្ធ ប៉ុន្តែនៅទីបំផុតប្រពន្ធគាត់បានស្លាប់ក្នុងអាយុ២៧ឆ្នាំ ។ ចាប់តាំងពីពេលនោះមក តាឌិល រស់នៅតែពីរនាក់នឹងកូនប្រុសបន្តមុខរបរនេសាទត្រី ។ ៩ឆ្នាំក្រោយមក តាឌិល បានរៀបការជាមួយស្ត្រីមេម៉ាយកូនមួយនៅភូមិព្រៃកប្បុស្សី ប៉ុន្តែគាត់បានចុះចោលប្រពន្ធក្រោយនេះបន្ទាប់ពីរៀបការបានតែមួយថ្ងៃ ។ គាត់បានវិលមករកជីវិតពោះម៉ាយ រស់នៅតែពីរនាក់ឪពុកនិងកូនប្រកបរបរនេសាទដូចពីពេលមុន ។

នៅក្នុងរបប លន់ ណុល កូនរបស់តាឈ្មោះ ឌិល គង់ បានបួសនៅវត្តកោះវាំងកែវនៅក្នុងស្រុកកោះធំ ។ គង់ បួសបានរយៈពេល១ឆ្នាំ ប្រទេសកម្ពុជាក៏ធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ គង់ សឹកពីបួសហើយចូលបម្រើក្នុងជួរកងទ័ពបដិវត្តន៍ខ្មែរក្រហមដោយមិនបានជម្រាបឪពុកឲ្យដឹងឡើយ ។ តាឌិល ថប់បារម្ភក្នុងចិត្តមិនស្រាកស្រាន្ត ។ គាត់ព្រួយចិត្តទាំងយប់ទាំងថ្ងៃ ខ្លាចកូនជាទីស្រលាញ់ជួបគ្រោះថ្នាក់ក្នុងសមរភូមិ ។ គាត់មានប្រសាសន៍ថា *«តាំងពីពេលដែលកូនចេញធ្វើយោធាថ្ងៃណាខ្ញុំបន់ព្រះអង្គវត្តកោះឲ្យព្រះអង្គជួយទ្រទ្រង់កូនខ្ញុំជានិច្ច ឲ្យតែកូនខ្ញុំគង់វង្សអាយុជីវិត ខ្ញុំនឹងធ្វើបុណ្យកោរសក់ថ្វាយព្រះអង្គ ។»*

ចាប់តាំងពីកូនចាកចេញទៅបម្រើក្នុងជួរកងទ័ពបដិវត្តន៍ តាឌិល រស់នៅតែម្នាក់ឯងគត់ ។ ប្រធានសហករណ៍ភូមិព្រៃធន់បានចាត់តាំងគាត់ឲ្យធ្វើការនៅក្នុងកងកាប់និងរែកដី ។ រែកដីមិនបានយូរប៉ុន្មាន ប្រធានពេទ្យឃុំព្រៃកថ្មីឈ្មោះ មិត្តកែះ បានស្នើឈ្មោះគាត់ឲ្យធ្វើជាគ្រូសង្គមកិច្ច(គ្រូពេទ្យ) ។ មិត្តកែះ បានបញ្ជូនឈ្មោះ តាឌិល ទៅគណៈតំបន់ដើម្បីសុំការយល់ព្រម ។ ក្នុងរយៈពេលដែលគាត់រង់ចាំសេចក្ដីសម្រេចពីថ្នាក់តំបន់ មិត្តកែះ មិនឲ្យតាឌិល ធ្វើអ្វីទាំងអស់ គឺនៅទំនេរចាំតែបើករបបអង្ករពីសហករណ៍ និងដើររកម្ហូបដោយខ្លួនឯង ។ តាឌិល បាននិយាយថា តាមពិតគាត់មិនមានបំណេះដឹងអ្វីទាក់ទងនឹងវិជ្ជាពេទ្យសូម្បីតែបន្តិចបន្តួចសោះទេ ។ គាត់គ្រាន់តែចេះស្ដោះផ្លុំព្យាបាលជំងឺខ្លះៗតាមក្បួន

បុរាណតែប៉ុណ្ណោះ ប៉ុន្តែដោយសារ មិត្តកែះ ចាត់តាំង ទើបគាត់មិនហ៊ានប្រកែក ចេះតែទទួលរៀនបណ្តើរអនុវត្តបណ្តើរ ។ តាបន្ថែមទៀតថា ពេទ្យផ្សេងៗដែលធ្វើការជាមួយគ្នា មានពេលមានម៉ោងសម្រាក ចំណែកគាត់គ្មានម៉ោងគ្មានវេលាទេ គឺត្រូវនៅជិតដិតនឹងអ្នកជំងឺជានិច្ច ។ ជួនកាលមានមនុស្សមកហៅឲ្យទៅពិនិត្យជំងឺទាំងយប់អធ្រាត្រក៏មានដែរ ។ គាត់ព្យាបាលអ្នកជំងឺដោយប្រើថ្នាំអាចម៍ទន្សាយនិងថ្នាំផ្សំពីដើមឈើបុសឈើប៉ុណ្ណោះ ចំណែកឱសថបែបសម័យមានតែពេទ្យស្រុកទេដែលមានខ្លះៗសម្រាប់ប្រើ ។ ដោយសារគាត់មិនសូវចំណានខាងវិជ្ជាពេទ្យម៉្លោះហើយពេលណាជួបនឹងជំងឺដែលដាក់ថ្នាំមិនជល់ តាឌិល បានទៅសួរពេទ្យស្រុកម្នាក់ឈ្មោះ ឡៃហ៊ិន ដែលធ្លាប់ស្គាល់គ្នាឲ្យជួយណែនាំអំពីវិធីព្យាបាលជំងឺនោះ ។ ពេទ្យ ឡៃហ៊ិន ធ្លាប់រៀនវិជ្ជាពេទ្យខ្លះៗតាំងពីមុនការគ្រប់គ្រងរបស់ខ្មែរក្រហម ។ លុះដល់របបខ្មែរក្រហមកាន់អំណាច គាត់ក៏បម្រើការនៅពេទ្យស្រុក ហើយដល់ពេលដែលរបបនេះដួលរលំទៅ គាត់ក៏នៅតែបន្តអាជីពជាគ្រូពេទ្យដដែល ។ តាឌិល បន្ថែមទៀតថា បើគាត់មើលទៅទំនងជាអ្នកជំងឺណាធ្ងន់ធ្ងរ មើលមិនជាទេ គាត់បញ្ជូនទៅពេទ្យស្រុក ។ ទៅដល់ពេទ្យស្រុក ទោះជាអ្នកជំងឺស្លាប់ឬរស់ ក៏គាត់លែងដឹងហើយ ព្រោះនៅឆ្ងាយពីគ្នា ។



លោកតា ស ឌិល

តាំងពីពេលចេញទៅបម្រើបដិវត្តន៍ គង់ ឆៀតមកលេងនឹងឪពុកជារឿយៗ ហើយ តាឌិល ក៏ទៅលេងនឹងកូននៅឯបន្ទាយទាហានក្នុងស្រុកលើកដែកបានពីរដងដែរ ។ មួយរយៈក្រោយមកបាត់លែងឃើញកូនរបស់គាត់មកលេងនឹងគាត់ទៀត ។ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម យុវជនមួយចំនួនដែលបានចេញពីភូមិទៅបម្រើបដិវត្តន៍ជាមួយ គង់ បានវិលត្រឡប់មកស្រុកកំណើតវិញ ហើយបានប្រាប់ តាឌិល ថា គង់បានស្លាប់ហើយ ប៉ុន្តែគាត់មិនជឿសម្តីអ្នកទាំងនោះឡើយ ។ គាត់នៅតែគិតថាប្រហែលជាកូនរបស់គាត់នៅរស់នៅទីកន្លែងណាមួយ ហើយនឹងវិលមករកគាត់នៅថ្ងៃណាមួយមិនខាន ។ លោកតាបានបន់ស្រន់ដល់បារមីព្រះអង្គវត្តកោះវាំងកែវ សូមជួយថែរក្សាកូនឲ្យមានជីវិតវិលមកជួបគាត់វិញ ប៉ុន្តែរហូតមកដល់សព្វថ្ងៃនេះអស់រយៈកាលជិត៣០ឆ្នាំហើយ នៅតែមិនឃើញកូនរបស់គាត់វិលមកវិញ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ តាឌិល មិនដែលអស់សង្ឃឹមក្នុងការរង់ចាំដែរ ។ គាត់និយាយថា សព្វថ្ងៃនេះគាត់គ្មានប្រាថ្នាអ្វីក្រៅពីចង់ជួបមុខកូនប្រុសតែប៉ុណ្ណោះ បើមិនបានជួបយូរ សូមជួបតែមួយភ្លែតក៏អស់ចិត្តដែរ ។ បច្ចុប្បន្ន លោកតាឌិលគ្មានផ្ទះសម្បែងខ្លួនឯងទេ គាត់រស់នៅជាមួយអ្នកភូមិ ហើយក៏មិនចង់ប្តូរទីលំនៅទៅកន្លែងផ្សេងដែរ ព្រោះបារម្ភក្រែងកូនត្រឡប់មកវិញរកគាត់មិនឃើញ ។ ក្នុងចិត្តរបស់តាឌិលគ្មានរបស់អ្វីមានតម្លៃស្មើនឹងកូនប្រុសជាទីស្រលាញ់ឡើយ ទោះបីជាយកអ្វីមក ដូរក៏គាត់មិនចង់បានដែរ ។ គាត់ចង់ជួបកូនប្រុសតែម្យ៉ាងគត់ ។ គាត់បន្ថែមថា "តាំងពីកូនចេញទៅធ្វើយោធា ខ្ញុំតែលតោលមិនដឹងទីពឹងអីទេ ។ កូនតែមួយមានម៉ែឪបងប្អូនឯណាទៀត មានតែឪពុកនិងកូនតែលតោលដូចគ្រាប់កណ្តឹង ។ ខ្ញុំជាកណ្តឹង កូនខ្ញុំជាគ្រាប់វាយក្លឹកៗ ។ តាំងពីកូនចេញធ្វើប្រតិបត្តិការថ្ងៃណាមកគឺខ្ញុំយំរហូត ។ ទល់គ្នានឹងឥឡូវអត់ឃើញ នឹកតែកូនទៀត នឹកអើយមហានឹក ។ សព្វថ្ងៃសុំឲ្យតែឃើញមុខកូន សុំតែជួបនឹងកូនតែប៉ុណ្ណឹងទេ គ្មានអីទៀតទេ ។ ...ខ្ញុំលើកដៃថ្វាយព្រះអង្គ ឲ្យព្រះអង្គជួយទ្រទ្រង់កូនខ្ញុំ" ។

តាមការសិក្សាស្រាវជ្រាវឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា យើងបានរកឃើញឈ្មោះ ឌិល គង់ ដែលមានតួនាទីជាយុទ្ធជនសួរចម្លើយនៅមន្ទីរស-២១ នៅក្នុងបញ្ជីឈ្មោះអ្នកទោសគុកទួលស្លែងត្រូវកម្ទេចនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៧៧ ។

**សាន់ កល្យាណ**

# ទង្វើរបស់មេដឹកនាំរបបខ្មែរក្រហមមិនមែនជាគំរូល្អ សម្រាប់មនុស្សជំនាន់ក្រោយ

វ៉ែ មឿន មានស្រុកកំណើតនៅភូមិលិចវត្ត ឃុំថ្មពូន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ មឿន ធ្លាប់ធ្វើជាទាហានលន់ណុលដើម្បីប្រយុទ្ធជាមួយខ្មែរក្រហម ហើយក៏ធ្លាប់ធ្វើជាទាហានខ្មែរក្រហមប្រយុទ្ធដើម្បីជាមួយទាហានលន់ណុលនិងវៀតណាមដែរ ។ នៅទីបំផុត លទ្ធផលនៃការលះបង់របស់គាត់គឺបានត្រឹមតែទទួលការលត់ដំលំបាកវេទនាស្ទើរស្លាប់ស្ទើររស់ ។ កាលពីមុន មឿន រំឭកប្រាប់កូនៗជារឿយៗអំពីរឿងរ៉ាវរបស់គាត់នៅក្នុងរបបខ្មែរក្រហម ប៉ុន្តែឥឡូវនេះគាត់លែងចង់នឹកនាដល់រឿងនោះទៀតហើយ ។ គាត់ចង់បំភ្លេចចោលឲ្យអស់ ព្រោះគាត់ឆ្អែតឆ្អន់នឹងរបបខ្មែរក្រហមណាស់ ។ គាត់គ្រាន់តែសុំឲ្យមានតុលាការមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ គាត់និយាយថា នេះជាអំពើដែលខ្មែរក្រហមបង្កឡើង ដូច្នេះខ្មែរក្រហមត្រូវតែហ៊ានទទួលទោស ។

កាលពីកុមារភាព មឿន រៀននៅសាលាថ្មពូន ។ មឿន បានឈប់រៀនត្រឹមថ្នាក់ទី៥ (ថ្នាក់ទី៨បច្ចុប្បន្ន) ហើយមកជួយធ្វើស្រែឪពុកម្តាយ ។ រយៈពេល១ឆ្នាំក្រោយមក ប្រហែលក្នុងឆ្នាំ១៩៧០ មឿន បានស្ម័គ្រចិត្តចូលធ្វើទាហានលន់ណុលក្នុងវ័យ១៦ឆ្នាំ ។ មឿន ធ្វើទាហានបានប្រហែល៥ខែ ដោយជួបការលំបាកខ្លាំង ម្យ៉ាងទៀតដោយឃើញឪពុកម្តាយរបស់គាត់មានការនឹករឭកនិងបារម្ភចំពោះគាត់ផង មឿន ក៏លាឈប់ពីទាហាន មកនៅជាមួយឪពុកម្តាយវិញ ។ មឿន នៅជាមួយឪពុកម្តាយរយៈពេល៣ខែ ក៏ត្រូវបានជ្រើសរើសឲ្យចូលបម្រើកងទ័ពខ្មែរក្រហម ។ ឪពុកម្តាយរបស់ មឿន មិនចង់ឲ្យ មឿន ចូលបម្រើកងទ័ពទៀតទេ ពីព្រោះ មឿន នៅក្មេង ។ គាត់ទាំងពីរនាក់បាននិយាយជាមួយ មឿន ថា "កុំទៅអីកូន បើចូលទ័ពមានតែស្លាប់ទេ" ។ សម្តីរបស់ឪពុកម្តាយរបស់ មឿន មិនអាចឃាត់ មឿន បានឡើយ ។ មឿន និងក្មួយរបស់គាត់ឈ្មោះ ប្រឿន និងយុវជន៥នាក់ទៀតដែលនៅភូមិជិតខាង មានឈ្មោះ ព្រែក, ឈាន់, អៀង, ចិន និងនៅ បានរួមដំណើរជាមួយគ្នាឆ្ពោះទៅឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម ។ នៅទីនោះ មឿន បានហាត់រៀនយុទ្ធសាស្ត្របាញ់ម៉ារីន ។ រយៈពេល៦ខែក្រោយ មឿន ត្រូវផ្លាស់ទៅកងពលធំលេខ៣១០ នៅខេត្តកំពង់ធំ ។ មឿន ហាត់រៀនក្បួនយុទ្ធសាស្ត្រទ័ពបានរយៈពេល២ឆ្នាំ នៅចុងឆ្នាំ១៩៧៣ មឿន ត្រូវបញ្ជូនមកប្រយុទ្ធនៅខេត្តកំពង់ចាម ។ មឿន ប្រយុទ្ធចាប់ពីសមរភូមិស្គន់រហូតមកដល់ព្រែកក្តាម ។ គាត់ហែលឆ្លងទន្លេមកត្រើយខាងលិច រួចបន្តដំណើររហូតដល់ភ្នំប្រសិទ្ធ ។ អង្គភាពរបស់ មឿន បោះទីតាំងនៅភ្នំប្រសិទ្ធ ដើម្បីការពារខ្សែក្រវ៉ាត់ទីក្រុងភ្នំពេញ ។ ក្នុងអំឡុងពេលដែលនៅប្រចាំការនៅភ្នំប្រសិទ្ធ មឿន បានឃើញទ័ពខ្មែរក្រហមចាប់ទាហានលន់ ណុល ជាច្រើននាក់រុំមុខចងបណ្តើរយកមកសម្ងាប់ដាក់ក្នុងអណ្តូងម្ទុំទួលគោក ។ ទាហានទាំងនោះសុទ្ធតែជាទាហានដែលចូលមកសារភាពជាមួយកងទ័ពខ្មែរក្រហម ដោយចាញ់ឃោសនាថា "ឲ្យចូលមកទទួលការងាររបុណ្យស័ក្តិដូចកាលជំនាន់មុនវិញ" ។ គ្មានអ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងនោះអាចរត់រួចឡើយ ។ មឿន បញ្ជាក់ថា កាលណោះគាត់បានឮមេបញ្ជាការរបស់គាត់និយាយថា "បើដឹកស្មៅត្រូវដឹកទាំងឫស" ។ ពាក់កណ្តាលខែមេសា ឆ្នាំ១៩៧៥ មឿន ទទួលដំណឹងថាកងទ័ពបដិវត្តន៍បានកាន់កាប់ទីក្រុងភ្នំពេញ ប៉ុន្តែក្នុងពេលជាមួយគ្នានោះ មឿន មិនបានចូលទីក្រុងភ្នំពេញភ្លាមទេ គឺមានបញ្ជាមកថាត្រូវរង់ចាំរយៈពេលកន្លះខែទៀតទើបអាចចូលទីក្រុងភ្នំពេញ ដោយហេតុថាតំបន់ខាងភ្នំប្រសិទ្ធនៅតែស្ថិតក្រោមការប្រទាញប្រទង់រវាងកងទ័ពខ្មែរក្រហមនិងទាហានលន់ណុលនៅឡើយ ។ ប្រមាណកន្លះខែក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ទើប មឿន ចូលដល់ទីក្រុងភ្នំពេញ ។ គាត់ឃើញទីក្រុងមានសភាពស្ងាត់ជ្រងំបន្ទាប់ពីប្រជាជនត្រូវជម្លៀសចេញទៅជនបទអស់ ។ សម្ភារប្រើប្រាស់ដូចជា រថយន្ត ម៉ូតូ ពូក កៅអី សាឡុង គ្រែ តុ ទូ និងរបស់របរ

ផ្សេងៗទៀត ស្ថិតនៅរាត់រាយពាសពេញទីក្រុង ។ ការងាររបស់ មឿន គឺដើរមើលតាមផ្ទះប្រមែប្រមូលរបស់របរដែលមានតម្លៃទុក ។ នៅទីក្រុងភ្នំពេញរយៈពេលជិតមួយឆ្នាំ មឿន បានទទួលបញ្ជាឲ្យទៅធ្វើស្រែនៅបឹងបាយាបវិញ ។ មឿន ដឹងថាការដែលគាត់ត្រូវដកឲ្យទៅធ្វើស្រែគឺអង្គការឲ្យគាត់ទៅលត់ដំខ្លួន ប៉ុន្តែដោយសារមូលហេតុអ្វីនោះគាត់មិនដឹងទេ ។

ប្រហែលឆ្នាំ១៩៧៧ កម្មាភិបាលភូមិភាគនិរតីបានចូលមកចាប់មេបញ្ជាការខាងទ័ពបូព៌ាជាច្រើននាក់ ហើយអ្នកដែលត្រូវចាប់ទៅគឺបាត់ដំណឹងឈឹងមិនដឹងថាត្រូវយកទៅទីណាទេ ។ កម្មាភិបាលភូមិភាគនិរតីបានដកហូតកាំភ្លើងខ្លីនិងសម្ភារទ័ពទាំងអស់ ហើយបញ្ជាឲ្យទៅបារបឿន(ត្រីប) ។ ចំណែក មឿន ដែលកាលណោះមានឋានៈជាប្រធានភ័ស្តុភារ មិនត្រូវបានចាប់ខ្លួនឡើយ ។ នៅវេលាប្រហែលម៉ោង១០យប់ អង្គការស្នើឲ្យ មឿន ទៅមើលទាហានដែលលត់ដំនៅបឹងបាយាប ។ គាត់នឹកក្នុងចិត្តថា «គេហៅអញឲ្យទៅម៉ោង១០យប់យ៉ាងនេះ ច្បាស់ជាយកទៅវាយចោលហើយ» ។ មឿន ចង់រត់គេច ប៉ុន្តែកងទ័ពខ្មែរក្រហមបានរាយបណ្តាក់គ្នាគ្រប់ទីកន្លែងមិនអាចឲ្យ មឿន រត់បានឡើយ ។ ដូច្នេះគាត់ក៏ព្រមឡើងជិះលើរថយន្តហ្ស៊ីបឃ្មុប ដែលមានអ្នកបើកបរម្នាក់និងយុទ្ធជនខ្មែរក្រហមម្នាក់នៅក្នុងនោះ ។ មឿន គិតថា បើបំណាច់នឹងអង្គការសម្លាប់គាត់សុំបើករថយន្តនោះដោយផ្ទាល់ដៃ ។ គោលបំណងរបស់គាត់គឺចង់លោតពីលើឡាន ប៉ុន្តែអ្នកបើកបរឡានបានប្រាប់ថា «មិត្តឯងមិនស្លាប់ទេ អង្គការឲ្យមិត្តឯងកសាងខ្លួន បើមិត្តឯងទ្រាំបាននឹងរស់ បើទ្រាំមិនបាននឹងត្រូវស្លាប់» ។

នៅបឹងបាយាប មឿន ត្រូវបញ្ជាឲ្យចុះក្នុងភក់ត្រឹមកដើម្បីបារកំប្លោក ។ ធ្វើការងារនេះអស់រយៈពេលប្រហែល៦ឬ៧ខែ អង្គការបានជ្រើសរើសមនុស្សមួយក្រុមឲ្យដើរចាក់សត្វទោម ។ មឿន ស្ម័គ្រចិត្តធ្វើការក្នុងក្រុមចាក់សត្វទោមវិញ ព្រោះគិតថាការដើរចាក់សត្វទោមនៅលើគោកងាយស្រួលជាងបារកំប្លោកនៅក្នុងភក់ ។ ផ្ទុយទៅវិញ ការងារថ្មីនេះមិនស្រួលដូចដែលគាត់បានគិតឡើយ ព្រោះត្រូវសត្វទាកខាំដៃជើងក្រហមដូចរលាកភ្លើង ប៉ុន្តែ មឿន នៅតែប្រឹងប្រែងធ្វើការមិនហ៊ានត្អូញត្អែរ ។ ក្នុងមួយយប់ មឿន អាចចាក់សត្វទោមបានពី២០០ទៅ៣០០ក្បាល ។ យូរៗទៅសត្វទោមកាន់តែហោចទៅៗគាត់អាចរកបានត្រឹមតែ១០ទៅ២០ក្បាលប៉ុណ្ណោះក្នុងមួយយប់ ។ កាលនៅជាកងទ័ព មឿន ធ្លាប់តែបរិភោគបាយ ដល់ពេលមកធ្វើការនៅបឹងបាយាប គាត់បានទទួលទានតែបបរ ធ្វើឲ្យខ្លួនរបស់គាត់ហើមនិងចុះជមជយកម្លាំង ។ មឿន ត្រូវបានបញ្ជូនទៅព្យាបាលជំងឺនៅមន្ទីរពេទ្យ ។ អំឡុងពេលដែល មឿន សម្រាកនៅមន្ទីរពេទ្យ កម្មាភិបាលពេទ្យយកចិត្តទុកដាក់នឹងគាត់ណាស់ ព្រោះដឹងថាគាត់មានឋានៈធំ ។ រយៈពេល៥ឬ៦ខែក្រោយមកជំងឺរបស់ មឿន បានធូរស្រាល គាត់ក៏វិលត្រឡប់ទៅបឹងបាយាបវិញ ។ ការងារថ្មីរបស់គាត់គឺដើររកត់ត្រាស្ថិតិយុទ្ធជននៅបឹងបាយាប ។ អំឡុងពាក់កណ្តាលឆ្នាំ១៩៧៧ មឿន បានឮពាក្យចចាមអារ៉ាមថាកងទ័ពវៀតណាមបានវាយសម្រុកចូលប្រទេសកម្ពុជា ។ ហេតុផលនេះហើយដែលខ្មែរក្រហមប្រមូលទ័ពនិងបំពាក់អាវុធឡើងវិញ ។

មឿន ត្រូវអង្គការដកទៅខាងកាំភ្លើងធំនៅពោធិ៍ចិនតុង ។ មឿន រៀនយុទ្ធសាស្ត្របានរយៈពេលប្រហែលជា១ខែ ត្រូវបញ្ជូនទៅប្រយុទ្ធនៅខេត្តកំពង់ចាម ។ មឿន មិនសូវបារម្ភអំពីគ្រោះថ្នាក់ទេ ពីព្រោះគាត់កាន់ខាងកាំភ្លើងធំត្រូវនៅក្រោយទ័ពថ្មើរជើងនៅជួរមុខ ដូច្នេះគាត់អាចមានឱកាសគេចផុតពីការវាយប្រហាររបស់ទ័ពវៀតណាម ។ នៅវេលាយប់មួយប្រហែលម៉ោង៣ទៀបភ្លឺ មឿន ទទួលដំណឹងថាកងទ័ពវៀតណាមបានវាយចូលមកដល់ឃុំស្ពួង ស្រុកត្បូងឃ្មុំ ។ គាត់បានទទួលបញ្ជាឲ្យដោងចំនួន១០គ្រាប់ទាំងមិនដឹងទីតាំងពិតប្រាកដ ។ គ្រាប់ដែល មឿន ដោងធ្លាក់ចំទាហានគ្នាឯងដែលនៅជួរខាងមុខបណ្តាលឲ្យស្លាប់អស់មួយចំនួន ។ ការប្រយុទ្ធគ្នាជាមួយទ័ពវៀតណាមមានសភាពស៊ិតស្វាញក្រៃលែង ។ អត្រាយុទ្ធជនខ្មែរក្រហមស្លាប់ច្រើនជាងកាលប្រយុទ្ធជាមួយទាហានលន់ណុលទៅទៀត ។ មួយសប្តាហ៍ក្រោយមក មឿន ធ្វើដំណើរទៅស្ពួង ។ ទៅដល់ទីនោះស្ងាត់ជ្រងំគ្មានមនុស្សម្នាក់ឡើយ មានតែសត្វជ្រូកមាន់ទាគោដែលអ្នកស្រុកចិញ្ចឹមដើរពាសវាលពាសកាល ។ ចំណែកប្រជាជនត្រូវខ្មែរក្រហមជម្លៀសទៅកន្លែងផ្សេងអស់ហើយ ។

ជាងមួយឆ្នាំបន្ទាប់ពីនៅក្នុងកាំភ្លើងធំ មឿន ត្រូវបានផ្លាស់ឲ្យទៅនៅខាងថ្មើរជើងវិញ ។ អង្គការបានបញ្ជាឲ្យគាត់កាន់កាំភ្លើងដេកា៨២ជាមួយមនុស្សបីនាក់ទៀត ។ មិនយូរប៉ុន្មានអ្នកនៅក្នុងក្រុមជាមួយ មឿន បានស្លាប់អស់២នាក់ ហើយអ្នកកាន់កាំភ្លើងខូសេតក៏ស្លាប់ទៀត ។ ដូច្នេះក្រុមរបស់ មឿន ដែលនៅសល់តែ២នាក់ ត្រូវបានចាត់តាំងឲ្យកាន់កាំភ្លើងខូសេតផងដេកា៨២ផង ។ ដោយសារតែមានទ័ពស្លាប់ច្រើន ខ្មែរក្រហមបានជ្រើសរើសកុមារដែលមានអាយុជាងដប់ឆ្នាំឲ្យចូលបម្រើកងទ័ពបន្ថែមទៀត ។ នៅពេលចូលសមរភូមិប្រយុទ្ធ ទ័ពក្មេងទាំងនោះស្លាប់អស់ជាច្រើននាក់ ពីព្រោះអ្នកទាំងនោះពុំធ្លាប់បានទទួលការហ្វឹកហាត់ខាងយុទ្ធសាស្ត្រយោធាបន្តិចសោះ ។ នៅឆ្នាំ១៩៧៨ កងទ័ពដែលដឹកនាំដោយ កែ ពក បានសម្រុកចូលដល់ខេត្តអានយ៉ាងរបស់ប្រទេសវៀតណាម ប៉ុន្តែមិនបានពើបប្រទះនឹងទាហានវៀតណាមឡើយ ។ នៅឆ្នាំ១៩៧៩ មឿន បានទទួលដំណឹងថា ទីក្រុងភ្នំពេញធ្លាក់ក្នុងកណ្តាប់ដៃវៀតណាម ។ មេបញ្ជាការរបស់គាត់បានប្រមូលទ័ពដែលនៅសេសសល់ ហើយរត់ចូលព្រៃ ។ ទាំងអស់គ្នាធ្វើដំណើរទៅដល់ខេត្តកំពង់ចាម ហើយត្រូវឆ្លងទន្លេទៅត្រើយម្ខាង ប៉ុន្តែទូកត្រូវកងទ័ពវៀតណាមដាន់ពន្លិចអស់ទៅហើយ ។ ដូច្នេះទាំងអស់គ្នាត្រូវតែហែលទឹកឆ្លងទន្លេ ។ យុទ្ធជនមួយចំនួនបានស្លាប់នៅពេលហែលឆ្លងកាត់ទន្លេ ។ បន្ទាប់ពីឆ្លងរួច ក្បួនទ័ពបានឈប់សម្រាកនៅបឹងធំ ហើយក៏បន្តដំណើរឆ្ពោះទៅភូមិក្តុលឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។ កងទ័ពត្រូវបានបញ្ជាឲ្យធ្វើដំណើរទៅមុខទាំងគ្មានស្បៀងអាហារបរិភោគ ។ នៅក្នុងស្ថានភាពនេះ មឿន ចង់វិលត្រឡប់មកស្រុកកំណើតវិញ ។ មឿន បានសួរយោបល់សមាជិកក្រុមទាំង៣នាក់ ហើយក៏បានព្រមព្រៀងគ្នា ។ ទាំងបួននាក់ធ្វើពុតជាឈឺពោះយ៉ាងខ្លាំង ។ ដោយស្មានថានេះជាការពិត មេបញ្ជាការរបស់ មឿន បានអនុញ្ញាតឲ្យ មឿន និងសមាជិកក្រុម សម្រាកសិនចំណែកឯយុទ្ធជនដទៃទៀតធ្វើដំណើរទៅមុន ។ ក្រោយពីទ័ពទាំងអស់ចេញទៅផុត មឿន និងសមាជិកក្រុមទាំង៣នាក់ ដើរត្រឡប់ក្រោយវិញ ដោយមានអាវុធនិងគ្រាប់បែកមកជាមួយផង ។ អ្នកទាំងបួនធ្វើដំណើររហូតដល់ម៉ោង៣ទៀបភ្លឺទើបទៅដល់ភ្នំសន្ទុង ។ នៅតាមផ្លូវ មឿន ឃើញប្រជាជនកំពុងតែដណ្តើមស្រូវគ្នា ។ ម្នាក់ៗមានការស្រេកឃ្លានយ៉ាងខ្លាំងបន្ទាប់ពីរួចផុតពីរបបខ្មែរក្រហម ។ សូម្បីតែ មឿន ខ្លួនឯងក៏មានការស្រេកឃ្លានខ្លាំងណាស់ដែរ ។ មឿន បានដកដំឡូងមីហូប ។ នៅពេលដែលធ្វើដំណើរមកដល់ជិតភូមិកំណើត គាត់បានឮពាក្យចចាមអារ៉ាមពីក្នុងចំណោមប្រជាជនថា បើចូលស្រុកប្រយ័ត្នយួនអារ-ក ។ ដំណឹងនេះធ្វើឲ្យ មឿន រារែកលែងចង់ចូលផ្ទះ ប៉ុន្តែគាត់នៅតែលបលួចចូលក្នុងភូមិនៅពេលយប់ ។ មឿន បានឲ្យសមាជិកក្រុម២នាក់រង់ចាំនៅក្នុងផ្ទះបោះបង់មួយ ។ ចំណែកខ្លួនគាត់និងកូនក្រុមម្នាក់ទៀតលបចូលទៅក្នុងផ្ទះឪពុកម្តាយដោយសន្មតសញ្ញាគ្នាទុកជាមុនថា «បើឃើញអញមកហើយលើកដៃឡើងលើបញ្ជាក់ថាអញនាំមនុស្សមកជួយ ប៉ុន្តែបើអញដាក់ដៃចុះក្រោមគឺត្រូវបាញ់មកចុះ អញសុខចិត្តស្លាប់» ។ មឿន បានចូលដល់ផ្ទះនៅវេលាយប់ ឃើញម្តាយនិងប្អូនៗរបស់គាត់ដេកដោយកាន់ខ្សែវនៅជាប់នឹងដៃផង ។ ឃើញដូច្នោះ មឿន ភ័យខ្លាចមិនហ៊ានចូលទៅក្នុងទេ ហើយក៏ត្រឡប់ទៅវិញ ។ វិលងបាន៣យប់ ដោយមិនអាចអត់ទ្រាំទ្រភាពស្រេកឃ្លានបាន មឿន ដាច់ចិត្តចូលទៅលួចបាយម្តាយរបស់ខ្លួនបរិភោគ ។ ដោយមានការលំបាកក្នុងការរស់នៅតែលគោលគ្មានគោលដៅនិងគេចខ្លួនជានិច្ចនោះ មឿន សុខចិត្តចូលប្រគល់ខ្លួនឲ្យរដ្ឋាភិបាល ហើយគាត់បានរស់នៅជាមួយក្រុមគ្រួសារវិញ ។

ការតស៊ូរបស់ មឿន គ្មានន័យអ្វីទាល់តែសោះ គឺគ្រាន់តែជាបដិវត្តន៍បោកប្រាស់របស់ខ្មែរក្រហមធ្វើឲ្យយុវជនជាច្រើនជឿលង់ ហើយស្ម័គ្រចិត្តប្រគល់ខ្លួនចូលបម្រើទ័ពដើម្បីរំដោះប្រទេសជាតិ ។ មឿន បានបញ្ជាក់ថា «ជីវិតខ្ញុំនៅក្រោមរបបខ្មែរក្រហមលំបាកណាស់ ។ ខ្ញុំខិតខំធ្វើការសង្ឃឹមថាអង្គការនឹងតបស្នងដល់ខ្ញុំវិញយ៉ាងគាប់ប្រសើរ ហើយខ្ញុំរស់នៅក្នុងសន្តិភាពគ្មានសង្គ្រាម ។ ផ្ទុយទៅវិញ ខ្ញុំត្រូវបញ្ជូនឲ្យទៅលត់ដំទទួលទានតែបបររាវ ធ្វើឲ្យខ្លួនរបស់ខ្ញុំហើមស្ទើរតែស្លាប់» ។ បច្ចុប្បន្ន មឿន រស់នៅឃុំគរ ស្រុកព្រៃឈរ ជាមួយប្រពន្ធនិងកូន៦នាក់ ។

ទង្វើរបស់មេដឹកនាំខ្មែរក្រហមមិនមែនជាគំរូល្អសម្រាប់មនុស្សជំនាន់ក្រោយឡើយ ។

**សុ ហ្វារីណា**

# ស៊ឹន អាន និយាយអំពីជីវិតពិតនៅក្នុងរបបខ្មែរក្រហម

បន្ទាប់ពីសេនាប្រមុខ លន់ ណុល ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ យុវជនមួយចំនួននៅក្នុងឃុំក្រូច ស្រុកព្រៃឈរ ខេត្តកំពង់ចាម បានស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ពរំដោះ ។ មួយចំនួនទៀតត្រូវរដ្ឋអំណាចមូលដ្ឋានចាប់បង្ខំឲ្យចូលរួម ទោះបីជាសាមីខ្លួនមិនពេញចិត្តក៏ដោយ ។


ស៊ឹន អាន

ស៊ឹន អាន ត្រូវបានប្រធានភូមិឈ្មោះ តាងែត ចុចឈ្មោះបញ្ជូនឲ្យចូលបម្រើបដិវត្តន៍នៅឆ្នាំ១៩៧១ ក្នុងអាយុ១៥ឆ្នាំ ។ ឪពុកម្តាយរបស់ អាន មិនចង់ឲ្យ អានទៅទេ ។ អាន ក៏មិនចង់ទៅដែរ ប៉ុន្តែគ្មាននរណាម្នាក់ហ៊ានប្រឆាំងនឹងអង្គការឡើយ ។ ពេលចេញពីភូមិ អាន បានទៅជាមួយមិត្តម្នាក់ឈ្មោះ អុល ។ អាន មានសំណាងបានវិលត្រឡប់មករស់ជួបជុំឪពុកម្តាយនិងក្រុមគ្រួសាររបស់ខ្លួនវិញ ចំណែក អុល បានស្លាប់បាត់បង់ជីវិត ។

មុនដំបូង អានត្រូវបាន តាងែត បញ្ជូនទៅបុសខ្នុរ ។ បន្ទាប់មកត្រូវថ្នាក់លើបញ្ជូនបន្តឲ្យទៅនៅក្នុងកងវរសេនាតូចលេខ៣១៤ ក្រោមការគ្រប់គ្រងរបស់ឈ្មោះឈិន ។ (ក្រោយមក ឈិន ឡើងឋានៈកងពល ហើយត្រូវបានអង្គការយកទៅសម្លាប់ចោលដោយចោទថាក្បត់នឹងបដិវត្តន៍) ។ អាន មិនបានហាត់រៀនក្បួនយុទ្ធសាស្ត្រទេ ។ ឆ្នាំ១៩៧៤ ពេលដែលអង្គការបើកយុទ្ធនាការវាយផ្លូវជាតិលេខ៧ អាន ត្រូវបានបញ្ជូនទៅសមរភូមិព្រែកក្តាម ហើយត្រូវរបួសត្រង់ខ្នងដៃនិងមុខ ដោយសារអម្បែងគ្រាប់កាំភ្លើង ប៉ុន្តែរបួសនោះមិនមានសភាពធ្ងន់ធ្ងរទេ ។ អាន បានទៅសម្រាកព្យាបាលនៅភូមិថ្មី ឃុំស្គុករពាក់ រយៈពេល១ខែ ។ ដើមឆ្នាំ១៩៧៥ អាន ស្ថិតនៅក្នុងអង្គភាពវរសេនាធំលេខ១១៤ ចំណុះឲ្យកងពល៣១០ ដែលទើបតែបង្កើតឡើងក្រោមការគ្រប់គ្រងរបស់ តាអឿន ។ បន្ទាប់ពីរបួសបានជាសះស្បើយ អាន ត្រូវបានបញ្ជូនទៅអង្គភាពដើមដែលបោះទីតាំងនៅព្រែកតាទែនវិញ និងរស់នៅទីនោះរហូតដល់ពេលដែលខ្មែរក្រហមដណ្តើមបានទីក្រុងភ្នំពេញនាឆ្នាំ១៩៧៥ ។

បន្ទាប់ពីខ្មែរក្រហមបានទទួលជ័យជម្នះហើយ អាន សង្ឃឹមថានឹងបានវិលត្រឡប់មកផ្ទះរស់នៅជួបជុំឪពុកម្តាយវិញ ប៉ុន្តែខុសស្រឡះ ។ កងទ័ពទាំងអស់ត្រូវបានថ្នាក់លើដាក់បញ្ជាឲ្យនៅក្នុងអង្គភាពរបស់ខ្លួនដដែល ហើយឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដោយនិយាយប្រាប់ថា "អង្គការតម្រូវឲ្យបងប្អូនទាំងអស់ចេញពីផ្ទះជាបណ្តោះអាសន្នសិនដើម្បីអង្គការងាយស្រួលរៀបចំទីក្រុងភ្នំពេញឡើងវិញ" ។ មនុស្សម្នាច្រើនស្អេកស្កះដើរពពាក់ពពូនតាមផ្លូវ ។ អ្នកខ្លះមិនដឹងពីគោលដៅថា ខ្លួនត្រូវទៅទីណាផង ។ មនុស្សស្លាប់ហូរហែតាមដងផ្លូវជារៀងរាល់ថ្ងៃដោយសារជំងឺតម្កាត់គ្មានថ្នាំពេទ្យព្យាបាល កង្វះស្បៀងអាហារ និងត្រូវខ្មែរក្រហមសម្លាប់ ។ កងពល៣១០ ដែលមាន អាន នៅក្នុងនោះដែរ បានដាក់ពង្រាយចាប់ពីវត្តភ្នំទៅទល់ស្ពានជ្រោយចង្វា និងពង្រាយបន្តចាប់ពីទួលគោករហូតដល់ឃ្លូញ អន្ទង់ក្វាន ។ អង្គភាពរបស់ អាន ចូលមកភ្នំពេញបានតែមួយថ្ងៃប៉ុណ្ណោះ ក៏ត្រូវអង្គការបញ្ជូនបន្តឲ្យទៅនៅឃ្លូញរយៈពេល១ខែ ។ ពេលនោះ អង្គការមិនឲ្យកងទ័ពធ្វើអ្វីទេគឺគ្រាន់តែពង្រាយកម្លាំងនៅតាមផ្លូវ ។ នៅអន្ទង់ក្វានក្នុងឆ្នាំដដែលនេះដែរ អាន បានឃើញពួកខ្មែរក្រហមចាប់បុរសម្នាក់ដែលលួចហូបផ្លែត្រប់និងម្ទេសចងដាក់កណ្តាលរោងបាយ ។ បន្ទាប់មក អ្នកទោសនោះត្រូវរុញបញ្ចូលឡានឡង់រូវែ បញ្ជូនទៅបាត់តាំងពីពេលនោះមកគ្មាននរណាម្នាក់ឃើញគាត់វិលត្រឡប់មកវិញឡើយ ។

មួយខែបានកន្លងផុតទៅ ។ ក្រោយពីប្រទេសត្រូវបានរំដោះ អង្គការបានដកហូតយកអាវុធពីយុទ្ធជន ហើយចែកចប កាំបិត ពូថៅជំនួសវិញ ។ បន្ទាប់មកបែងចែកកម្លាំងឲ្យទៅធ្វើស្រែនៅ

តាមទីកន្លែងផ្សេងៗគ្នា ។ អង្គភាពខ្លះត្រូវទៅធ្វើស្រែនៅស្រុកសន្ទុក ខេត្តកំពង់ធំ ខ្លះទៅធ្វើស្រែនៅផ្លូវក្នុងទឹកដីខេត្តកំពង់ចាម ។ ចំណែក អាន ត្រូវអង្គការបញ្ជូនឲ្យទៅធ្វើនៅក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម ។ ទើបតែស្ទូងស្រូវនៅស្រុកជើងព្រៃរួចរាល់ អាន ត្រូវបានបញ្ជូនឲ្យទៅធ្វើស្រែនៅភ្នំប្រសិទ្ធិ ។ អាន បានឲ្យដឹងថាធ្វើស្រែនៅភ្នំប្រសិទ្ធិគ្មានគោក្របីជាកម្លាំងអូសនង្គ័លភ្ជួរដីទេ គឺប្រើកម្លាំងមនុស្សកាប់ដីធ្វើស្រែ ។ ដួនកាលកាប់ចំគ្រាប់បណ្ដាលឲ្យផ្ទុះស្លាប់មនុស្សស្ទើររាល់ថ្ងៃ ។ ចំពោះការហូបចុក គឺមិនបានគ្រប់គ្រាន់ទេ ។ នៅក្នុងឆ្នាំ១៩៧៦ អង្គការបានផ្លាស់ អាន ឲ្យទៅធ្វើស្រែនិងលើកប្រព័ន្ធប្រឡាយទំនប់នៅឃុំញដែលត្រូវសម្រុកធ្វើទាំងថ្ងៃទាំងយប់ ។ សុន សេន រដ្ឋមន្ត្រីក្រសួងការពារប្រទេស បានចុះមកសួរសុខទុក្ខយុទ្ធជនដល់ការដ្ឋានជីកប្រឡាយ ហើយបានប្រកាសឲ្យយុទ្ធជនទាំងអស់ខិតខំយកចិត្តទុកដាក់ធ្វើស្រែឲ្យបានទិន្នផលពតោនក្នុងមួយហិកតា ។ សុន សេន ថែមទាំងបានពន្យល់អំពីបច្ចេកទេសក្នុងការធ្វើស្រែឲ្យបានទិន្នផលខ្ពស់ទៀតផង ។

ឆ្នាំ១៩៧៧ វិទ្យុខ្មែរក្រហមបានប្រកាសថា "យួនបានឈ្លានពានទឹកដីខ្មែរ" ។ អង្គការបានដកកងទ័ពដែលកំពុងធ្វើព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំងឲ្យទៅទប់ទល់កងទ័ពយួនឈ្លានពាននៅតាមព្រំដែន ហើយបានឲ្យកងវរៈ៣១៨ទៅធ្វើព្រលានយន្តហោះជំនួសវិញ ។ អង្គការបានជ្រើសរើសយុទ្ធជនដែលសុទ្ធសឹងជាអ្នកដែលជាប់ក្នុងសមាសភាពមិនល្អ (ក្នុងនោះក៏មាន អាន ដែរ) ហើយបញ្ជូនទៅខេត្តកំពង់ឆ្នាំងទាំងយប់ ។ ក្រុមនេះជាក្រុមដែលអង្គការមិនទុកចិត្ត បន្ទាប់ពីប្រធានកងពលនិងអ្នកមានតួនាទីផ្សេងៗទៀតត្រូវអង្គការចាប់យកទៅសម្លាប់ចោលក្នុងបទចង់បះបោរប្រឆាំងបដិវត្តន៍ ។ អាន បានរៀបរាប់បន្តទៀតថា ការងារធ្វើព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំងស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកជំនាញការនិងវិស្វករជនជាតិចិនជាច្រើនពាន់នាក់ ។ ការងារនៅព្រលានយន្តហោះមានសភាពយ៉ាប់យ៉ឺនខ្លាំងណាស់ ដូចជាការជីកដីយកឫសឈើចេញបុកបង្ហាប់ដីដោយប្រើក្បាលដីរដែលមានមុខ៧-៨តឹក ។ ការងារធ្វើព្រលានយន្តហោះត្រូវចំណាយកម្លាំងមនុស្សប្រមាណពី៣ទៅ៥ម៉ឺននាក់ ។

នៅខែមករា ឆ្នាំ១៩៧៩ គ្រាន់តែឮថាកងទ័ពវៀតណាមវាយចូលដល់ទីក្រុងភ្នំពេញ អ្នកជំនាញការចិនបាននាំគ្នាជិះឡានភៀសខ្លួនទៅខេត្តបាត់ដំបង ហើយបន្តដំណើរចេញពីប្រទេសកម្ពុជាតាមច្រកព្រំដែនកម្ពុជា-ថៃ ។ ចំណែក អាន និងយុទ្ធជនផ្សេងទៀតបានរត់ចេញពីព្រលានយន្តហោះទៅស្រុកអមលាំង ។ នៅអមលាំង អង្គការបានចាប់ផ្ដើមសម្លាប់យុទ្ធជនដែលមកពីភូមិភាគបូព៌ា ។ អាន បានបញ្ជាក់ថា "អង្គការបានសម្លាប់យុទ្ធជនបូព៌ាដោយចោទប្រកាន់ថា សុទ្ធតែជាខ្សែរយៈក្បត់របស់សោភឹម" ។ មុនពេលសម្លាប់ អង្គការបានឆបោកយុទ្ធជនទាំងអស់នោះឲ្យរៀបចំខ្លួនទៅវាយយួន ប៉ុន្តែតាមការពិតយុទ្ធជនទាំងអស់នោះត្រូវកម្មាភិបាលភូមិភាគនិរតីសម្លាប់នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដាក់ក្នុងរណ្ដៅដែលមានទំហំ៣ម៉ែត្របួនជ្រុង ។ យុទ្ធជនភូមិភាគបូព៌ាដែលត្រូវសម្លាប់នៅពេលនោះមានចំនួនប្រហែលមួយពាន់នាក់ ក្នុងនោះមួយចំនួនជាយុទ្ធជនពិការ ។ យុទ្ធជនប្រមាណ៧០នាក់ (រួមទាំង អាន ផង) ដែលមានសំណាងបានរួចជីវិតត្រូវបានអង្គការយកទៅផ្ញើឲ្យនៅជាមួយប្រជាជននៅអមលាំង ។ រស់នៅជាមួយប្រជាជនក្នុងសហករណ៍អមលាំងបានមួយរយៈ ប្រធានសហករណ៍អមលាំងបានប្រាប់យុទ្ធជនទាំង៧០នាក់ថា "ខ្ញុំលែងទទួលខុសត្រូវចំពោះអ្នកទាំងអស់គ្នាទៀតហើយ ព្រោះខ្ញុំគ្មានបាយឲ្យហូបទៀតទេ អ្នកណាចង់ទៅណាក៏ទៅចុះ " ។ អាន បានរត់ទៅដល់ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។ អាន បានរស់នៅជាមួយខ្មែរក្រហមរហូតដល់ខែមិថុនា ឆ្នាំ១៩៧៩ ទើបដាច់ចិត្តមកចុះចូលរួមរស់ជាមួយសង្គមជាតិវិញ ។

អាន បានរៀបការនៅក្នុងឆ្នាំ១៩៨០ ជាមួយនារីម្នាក់ឈ្មោះ ទិន ម៉ាច សព្វថ្ងៃមានអាយុ៤២ឆ្នាំ និងមានកូនប្រុស៥នាក់នៅក្នុងបន្ទុក ។ បច្ចុប្បន្ន អាន មានអាយុ៤៧ឆ្នាំហើយ គាត់ខិតខំរកស៊ីធ្វើស្រែចម្ការលែងខ្វល់ខ្វាយពីរឿងស្រុកទេសទៀតឡើយ ព្រោះគាត់នឿយណាយនឹងការតស៊ូកន្លងមកដែលមិនបានផ្ដល់ផលប្រយោជន៍អ្វីបន្តិចសោះចំពោះរូបគាត់និងក្រុមគ្រួសារ ។

**អេង ឡេង**

# នៅតែដិតជាប់ក្នុងចិត្ត


អ៊ុក វ៉ាន់នី (អតីត)

អ៊ុក វ៉ាន់នី ហៅ ញ៉ែម នី ហៅ ភា បានចូលបម្រើបដិវត្តន៍ខ្មែរក្រហមគឺដើម្បីសុវត្ថិភាពគ្រួសារ ។ ក្រោយមក នី ក៏ត្រូវខ្មែរក្រហមបដិវត្តន៍ចាប់ខ្លួននិងធ្វើទារុណកម្ម ហើយត្រូវបញ្ជូនទៅដាក់គុកជាច្រើនកន្លែងរហូតដល់ដើមឆ្នាំ១៩៧៩ ។

ចាប់តាំងពីឆ្នាំ១៩៧០ដែលប្រទេសកម្ពុជាបានធ្លាក់ទៅក្នុងស្ថានភាពជ្រួលច្របល់ កងឈ្លបភូមិតែងតែមកគំរាមកំហែងអ្នកភូមិឲ្យបញ្ជូនកូនដែលពេញវ័យចូលបម្រើកងទ័ព ។ ឪពុករបស់ នី ត្រូវមេភូមិមកគំរាមថានឹងសម្លាប់ចោល ប្រសិនបើមិនបញ្ជូនកូនឲ្យចូលបម្រើបដិវត្តន៍ ។ ដោយឃើញសភាពដូច្នេះ នី ដែលកាលណោះមានអាយុត្រឹមតែ១៦ឆ្នាំ ត្រូវបង្ខំចិត្តចូលបម្រើចលនាខ្មែរក្រហមក្នុងឆ្នាំ១៩៧៣ ។ តាប៉ួន ប្រធានមន្ទីរឃុំគស្រុកព្រៃឈរ ខេត្តកំពង់ចាម ជ្រើសរើស នី ឲ្យធ្វើជានិរសារផ្ទាល់របស់គាត់ក្នុងចំណោមនិរសារ១២នាក់ ។ នី បានធ្វើនិរសារឲ្យតាប៉ួន អស់រយៈពេលប្រហែលពីរឆ្នាំ ។ ក្រៅពីមុខងារជានិរសារ នី ត្រូវបានតម្រូវឲ្យដាំបន្លែបន្ថែមទៀត ។

នៅក្នុងដំណាក់កាលកំពុងត្រៀមវាយចូលទីក្រុងភ្នំពេញឆ្នាំ១៩៧៥ នី ត្រូវបានបញ្ជូនទៅធ្វើជានិរសាររបស់ អឿន ប្រធានកងពល៣១០ ។ នី ត្រូវបានចាត់តាំងឲ្យទៅសមរភូមិខេត្តសៀមរាបរយៈពេល៧ថ្ងៃ រួចត្រឡប់មកស្នាក់នៅឃុំផ្តៅជុំ ស្រុកជើងព្រៃខេត្តកំពង់ចាមអស់រយៈពេល៣ខែ និងនៅពេលចុងក្រោយ នី ត្រូវបានបញ្ជូនបន្តឡើងទៅសមរភូមិវាយយកទីក្រុងភ្នំពេញ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមវាយលុកដណ្តើមបានទីក្រុងភ្នំពេញ ។ មនុស្សម្នាជ្រួលច្របល់ដើរប្រសេចប្រសាចតាមផ្លូវថ្នល់ ។ នី បាននិយាយថា នៅពេលនោះ កងទ័ពខ្មែរក្រហមខ្លះបានអនុញ្ញាតឲ្យប្រជាជនត្រឡប់ចូលតាមផ្ទះរបស់គេវិញ ប៉ុន្តែក៏មានយុទ្ធជនខ្មែរក្រហមខ្លះបានវាយតប់និងសម្លាប់ប្រជាជនតាមអំពើចិត្តដែរ ។

បន្ទាប់ពីកងទ័ពបដិវត្តន៍វាយដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ តាអឿន បញ្ជូន នី ឲ្យធ្វើជាគ្រូពេទ្យនៅមន្ទីរពេទ្យអង្គឌួង ក្រោមការគ្រប់គ្រងរបស់ប្រពន្ធតាអឿន ។ នី រៀនវិជ្ជាពេទ្យនេះពី ផែនដែលជាវេជ្ជបណ្ឌិតពីរបបមុន ។ នី បានរៀបរាប់ថា មន្ទីរពេទ្យនោះមានបុគ្គលិកពេទ្យ២២នាក់ ស្រី១១នាក់ និងប្រុស១១នាក់ ។ អ្នកជំងឺដែលចូលមកព្យាបាលនៅមន្ទីរពេទ្យនោះភាគច្រើនជាអ្នកមានជំងឺគ្រុនចាញ់និងយុទ្ធជនរងរបួស ចំណែកប្រជាជនសាមញ្ញមិនត្រូវបានអនុញ្ញាតឲ្យសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យនោះទេ” ។ នៅឆ្នាំ១៩៧៧ ពេលដែលដឹងថាមានសភាពការណ៍មិនស្រួល តាអឿន បានហែកប្រវត្តិរូបអ្នកនៅជាមួយគាត់ចោល ។ មិនយូរប៉ុន្មាន តាអឿន ត្រូវអង្គការចាប់ខ្លួន ។ តាអឿនត្រូវបានបង្ខំឲ្យសារភាពអំពីសកម្មភាពប្រឆាំងបដិវត្តន៍របស់គាត់ ។ ចម្លើយរបស់ តាអឿន ត្រូវបានចាក់ផ្សាយឲ្យយុទ្ធជនកងពល៣១០ទាំងអស់ស្តាប់នៅក្នុងពេលប្រជុំមួយ ។ នី បាននិយាយថា គាត់និងយុទ្ធជនជាច្រើនទៀតត្រូវបានហៅឲ្យចូលរួមស្តាប់កាសែតដែល តាអឿន រៀបរាប់ពីសកម្មភាពក្បត់របស់គាត់ ។ ក្រោយពី តាអឿន ត្រូវចាប់ខ្លួន តំណែងរបស់គាត់ត្រូវជំនួសដោយប្រធាន


អ៊ុក វ៉ាន់នី (បច្ចុប្បន្ន)

កងពលថ្មីដែលមកពីភូមិភាគនិរតី ។ ប្រធានកងពលថ្មីនេះបានអប់រំយុទ្ធជនទាំងអស់កុំឲ្យបះបោរនិងក្បត់តាមគ្នា ។ យុទ្ធជនមួយភាគធំដែលប្រហែលជានៅសល់ប្រវត្តិរូបត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ ។ ចំណែក នី ក៏ត្រូវចាប់ខ្លួនដែរ ។ កាលណោះប្រហែលវេលាម៉ោង៣រសៀល ពេលដែលគាត់កំពុងស្ទូងស្រូវនៅឯស្រែ យុទ្ធជនថ្មីបានមកហៅគាត់ថា «ទៅរៀនសូត្រនៅកន្លែងថ្មី» ។ នី ត្រូវឃុំខ្លួននៅក្នុងគុករបស់កងពល៣១០ ។

នី បានរៀបរាប់ពីស្ថានភាពនៅពេលនោះថា គាត់ត្រូវយុទ្ធជនរូបនោះចាប់ចងមុខ ចងស្លាបសេក និងចងជើងម្នាងបណ្តើរចេញពីមន្ទីរពេទ្យអគ្គខ្លួនទៅកាន់មន្ទីរឃុំឃាំងកងពល៣១០ ។ នី ដឹងថា កាលនោះមានមនុស្សពីរនាក់ផ្លាស់ប្តូរគ្នានាំគាត់ដើរពេញមួយយប់នៅកន្លែងដដែលៗក្នុងគោលបំណងបង្វែងដាន ប៉ុន្តែគាត់អាចចំណាំបាន ព្រោះគាត់ដើរជំពប់ជើងនឹងវត្ថុដដែលៗ ។ នៅក្បែរនោះ នី បានឮសំឡេងមនុស្សស្រែកយំទាំងក្តីឈឺចាប់ ។ នី តក់ស្លុតនិងភ័យភិតជាខ្លាំង ។ គាត់គិតថាខ្លួនគាត់ប្រហែលជានឹងមានជោគវាសនាមិនខុសពីអ្នកទាំងនោះទេ ។ លុះព្រឹកឡើង នី ត្រូវបានបញ្ជូនមកដាក់នៅក្នុងបន្ទប់មួយបិទជិតងងឹតរកមើលអ្វីមិនយល់ ។ នី ត្រូវបានស្រាយចំណងដៃចេញ ប៉ុន្តែជើងទាំងពីររបស់គាត់នៅតែជាប់ច្រវាក់ដដែល ។ នី បាននិយាយថា «បន្ទប់នោះធ្វើពីឈើនៅក្នុងផ្ទះថ្ម ច្រវាក់(ជើង) ត្រូវចងភ្ជាប់នឹងបង្គួច សូម្បីតែងើបឈរក៏ងើបមិនបានដែរ ។ នៅពេលចង់បត់ជើង ខ្ញុំស្រែកហៅអ្នកយាមគុកឲ្យមកចាក់សោឲ្យ រួចហើយគេបញ្ចូលខ្ញុំទៅក្នុងបន្ទប់និងដាក់ច្រវាក់វិញ» ។ នៅវេលាម៉ោងប្រហែល៨ព្រឹក នី ត្រូវអ្នកសួរចម្លើយពីរនាក់ធ្វើទារុណកម្មដោយវាយនឹងរំពាត់ខ្សែភ្លើងដែលវេញចូលគ្នានិងប្រើខ្សែភ្លើងឆក់ ។ អ្នកសួរចម្លើយសួរសំណួរដដែលៗថា «តើមីហងឯងចូលសេ.អ៊ី.អាយួនពីអង្កាល់?» ។ នី ក៏ឆ្លើយដដែលៗថា «ខ្ញុំអត់ដែលស្គាល់យួនទេ» ។ អ្នកសួរចម្លើយក៏ស្រែកគំហកថា «ប្រធានមីហងឯងចូលសេ.អ៊ី.អាយួន ចំណែកមីហងឯងថាមិនចូលអញមិនជឿ» ។ នី បានឲ្យដឹងថា «អ្នកសួរចម្លើយមានគ្នាពីរនាក់ សម្បុរសជ្រះ បានចាប់ផ្តើមវាយខ្លួន ដៃ និងជើងរបស់ខ្ញុំ តែមិនវាយក្បាលទេ បន្ទាប់មកពួកវាប្រើខ្សែភ្លើងឆក់ត្រចៀករបស់ខ្ញុំទាំងសងខាង ។ ខ្ញុំសន្លប់បាត់ស្មារតីអស់ជាច្រើនដង ។ ពួកវាបានជះទឹកដាក់ខ្ញុំ រួចអ្នកសួរក៏ចាប់ផ្តើមឆក់និងសួរបន្តទៀត ។ ដោយទ្រាំទ្រទៅនឹងទារុណកម្មមិនបាន ខ្ញុំចេះតែឆ្លើយៗដើម្បីយករួចខ្លួនទៅ» ។


បន្ទប់ឃុំឃាំងអ្នកទោសនៅគុកទួលស្លែង

បន្ទាប់ពីសួរចម្លើយចប់ នី ត្រូវអ្នកយាមបង្ខំឲ្យហូបបាយដែលស្រដៀងនឹងបាយជ្រូក ។ នី បានបដិសេធ ប៉ុន្តែត្រូវអ្នកយាមនោះគំហកថា «បើមីហងឯងមិនស៊ីបាយបដិវត្តន៍ មានតែមីហងឯងខ្លាំងយួន» ។ ដោយសារហូបបាយនោះមិនអស់ នី ត្រូវបានបង្អត់អាហាររហូត នី ត្រូវចងមុខជិតដឹកតាមឡានឡង់រ៉ឺម៉កមួយគ្រឿង ។ នី បានរំឭកថា «ខ្ញុំគ្រាន់តែចាំថា ពេលចុះពីឡានភ្លាម ទាហានបាននាំខ្ញុំឡើងជណ្តើរមួយគន្លាក់ទៅកាន់បន្ទប់តូចជិតឈឹងមួយ បន្ទាប់មកស្រាយមុខខ្ញុំចេញហើយដាក់ច្រវាក់ជើងភ្ជាប់ទៅនឹងចម្រឹងបង្គួច ។ នៅពេលយប់ស្ងាត់ ខ្ញុំបានឮសំឡេងស្រែកល្ហើយៗដោយក្តីឈឺចាប់ចេញពីបន្ទប់ផ្សេងៗដែលនៅក្បែរនោះ ។ ជាមួយគ្នានោះ ខ្ញុំបានឮសំឡេងស្រែកខ្លាំងៗសន្ធាប់ពីលើសំឡេងយំស្រែកនោះថា «បើហ្អែងមិនព្រមឆ្លើយទេ អញវាយហ្អែងឲ្យទាល់តែងាប់» ។ នី អស់សង្ឃឹមជាខ្លាំង នៅពេលឮសម្រែករបស់អ្នកទោសនិងការគំរាមកំហែងរបស់អ្នកសួរចម្លើយ ។ នៅក្នុងគុកទួលស្លែងបីយប់ នី មិនត្រូវបានសួរចម្លើយទេ ។ នី ត្រូវបានបញ្ជូនទៅកាន់មន្ទីរលត់ដំព្រៃសទៀត ។ មុនពេលទៅកាន់ព្រៃស នី ត្រូវបានព្រមានថា «អញបញ្ចេញហងពីទួលស្លែងហើយ តែប្រយ័ត្នបើធ្វើខុសទៀតចូលមកត្រង់នេះវិញ ហងឯងងាប់មិនខាន» ។ លើកនេះ នី ត្រូវចងមុខជិតដូចពេលមុនៗដែរ ។ នី

ស្ថិតនៅក្រោមការតាមដានគ្រប់ជំហានតាំងពីទៅមុជទឹក បត់ជើង រហូតដល់ធ្វើការងារលើកទំនប់ដីកប្រឡាយជាដើម ។ ក្នុងមួយថ្ងៃ នី ត្រូវលើកទំនប់ដែលមានបណ្តោយ៥ម៉ែត្រនិងជម្រៅ០,៨ម៉ែត្រ និងទទួលបានបាយមួយវែក ។ ប្រសិនបើអ្នកទោសណាម្នាក់ធ្វើការមិនទាន់តាមការកំណត់របស់អង្គការទេ នឹងត្រូវវាយធ្វើបាប បង្អត់អាហារ ។ នៅមន្ទីរលត់ដំព្រៃស នី បានធ្វើការនៅក្នុងកង១៤ ដែលជាកងលត់ដំខ្លាំងបំផុត ។ អ្នកទោសនៅក្នុងកង១៤ ទាំងអស់ត្រូវក្រោកទៅធ្វើការតាំងពីម៉ោង២ៈ៣០ទៀបភ្លឺ ។ នី បានប្រាប់ទៀតថា នៅពេលយប់ខ្លះ ខ្មែរក្រហមបញ្ជាឲ្យក្រុមរបស់គាត់ដេកទល់ខ្នងគ្នារហូតដល់ភ្លឺ បើមិនធ្វើតាមបញ្ជាទេនោះនឹងត្រូវលើកទំនប់ទាំងយប់ ។ ក្រោយមក នី ត្រូវបានបញ្ជូនមកកង១៧ ដែលជាកងសម្រាប់អ្នកទោសដែលមានកំហុសស្រាល ដោយសារអនុប្រធានក្រុមរបស់គាត់ពេញចិត្តគាត់ ។ ។

នៅឆ្នាំ១៩៧៩ នី និងអ្នកទោសជាច្រើនត្រូវខ្មែរក្រហមកៀរទៅដល់ភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។ នៅទីនោះ នី បានជួបតាម៉ុក និង ឌុច ប្រធានគុកទួលស្លែង ។ នី បានឃើញ ឌុច សម្លាប់អ្នករត់ទៅជាមួយដែលបានលួចអង្ករដែលស្ពាយតាមខ្លួន ។ នី ធ្លាប់បាននិយាយលេងធម្មតាជាមួយ តាម៉ុក ប៉ុន្តែ ឌុច វិញ កុំថាឡើយនិយាយលេង សូម្បីតែមុខក៏គាត់មិនហ៊ានមើលផង ។

នី រស់នៅលើភ្នំក្រវាញអស់រយៈពេលប្រហែល៣ខែ ទើបរត់ទៅភ្នំទ្រនាប់គគីរ ភ្នំរលាក់កងជើង និងបន្តទៅនៅកន្លែងផ្សេងៗទៀតអស់រយៈពេលជិតមួយឆ្នាំ ។ នី និងគ្នីគ្នា៤នាក់បានសម្រេចចិត្តលួចរត់ត្រឡប់មកភ្នំទ្រនាប់គគីរវិញ ។ តាមផ្លូវ នី បានធ្លាក់ខ្លួនឈឺ ហើយមិត្តរបស់គាត់៤នាក់ទៀតក៏ចាកចោលគាត់អស់ ។ សំណាងល្អ នី ត្រូវបានកងទ័ពវៀតណាមជួយសង្គ្រោះ ហើយគាត់បានវិលត្រឡប់មកស្រុកកំណើតវិញនៅឆ្នាំ១៩៨០ ។ បច្ចុប្បន្ន នី រស់នៅភូមិត្រពាំងបី ឃុំបារាយការណ៍ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ជាមួយប្តីនិងកូន៦នាក់ ។

ឆ្លងតាមបទពិសោធន៍នៃជីវិតដ៏សែនវេទនានេះ នី បានចាត់ទុករបបខ្មែរក្រហមថាជារបបកាចសាហាវឃោរឃៅបំផុត ដែលសម្លាប់មនុស្សគ្មានគិតពិចារណា ។ បងប្អូនបង្កើតរបស់ នី ២នាក់ ក៏ត្រូវខ្មែរក្រហមយកទៅសម្លាប់ ។ នី តែងតែរំឭករឿងរ៉ាវរបស់គាត់ឲ្យកូនចៅនិងអ្នកជិតខាងស្តាប់ជានិច្ច ។ នី បានរំពុកទាំងទឹកភ្នែកថា “នៅពេលខ្ញុំឃើញគេវាយចោរ ឬឮសំឡេងឆ្កែព្រុសនៅពេលយប់ ខ្ញុំចេះតែនឹកឃើញ ហើយភ្ញាក់ៗភ័យតក់ស្លុតញ័រខ្លួនទទ្រើក ។ ខ្ញុំនៅតែនឹកឃើញស្រមោលទាំងអស់នោះជិតដាមជាប់ក្នុងចិត្តខ្ញុំជានិច្ច ។” សព្វថ្ងៃ នី ឆាប់ហត់ និងឈឺចុកចាប់ពេញខ្លួន រាល់ពេលដែលធ្វើការងារធ្ងន់ ត្រចៀកទាំងសងខាងរបស់គាត់ ឈឺចាប់ខ្ទោកៗនៅពេលណាដែលគាត់ខឹង ។

នី បានសម្តែងនូវការគាំទ្រយ៉ាងខ្លាំងចំពោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងឡាយ ដែលទទួលខុសត្រូវក្នុងរបបខ្មែរក្រហម ព្រោះគាត់គិតថា ការកាត់ទោសនេះនឹងមានប្រយោជន៍និងជាគំរូដល់ក្មេងៗជំនាន់ក្រោយកុំឲ្យរៀនសូត្រតាមអំពើសម្លាប់និងធ្វើបាបមនុស្សយ៉ាងព្រៃផ្សៃបែបនេះ ។

**លី សុខឃាង**

# សេចក្តីជូនដំណឹង

## ពិធីជូនរង្វាន់ជ័យលាភីវេទិកាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

សមាគមអ្នកនិពន្ធខ្មែរសូមថ្លែងអំណរគុណនិងជម្រាបជូនដំណឹងដល់បេក្ខជនទាំងអស់ដែលបានចូលរួមជាមួយកម្មវិធី “វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ” ឲ្យបានជ្រាបថា សមាគមនឹងធ្វើពិធីជូនរង្វាន់នៅថ្ងៃទី២ ខែមេសា ឆ្នាំ ២០០៤ ដល់បេក្ខជនជ័យលាភីចំនួន៤រូបគឺ ១) លោកស្រី ហេង ផាន់ណា រឿងស្រមោលបង ២) លោក ជូ សូភា រឿងមានទោសព្រោះអ្វី ៣) លោកស្រី អ៊ុំ សុផានី រឿងកាលណាយើងជួបគ្នា និង៤) លោក ម៉ម ដៃប៊ុន រឿងស្រមោលអតីតកាល ។

សូមបេក្ខជនជ័យលាភីទាំងបួនរូបខាងលើទាក់ទងមកសមាគមតាមរយៈទូរស័ព្ទលេខ ០១២ ៨៨៣ ០៧២ ឬ០១១ ៨៨៣ ២៧៦ ដើម្បីទទួលពត៌មានបន្ថែម ។

សូមអរគុណ ។

**ប្រធានសមាគមអ្នកនិពន្ធខ្មែរ**

**យូ បូ**

# ខ្ញុំរីករាយណាស់ពេលបានដឹងថាមានតុលាការខ្មែរក្រហម



ប៉ាល់ សិត

*ប៉ាល់ សិត កើតក្នុងគ្រួសារកសិករនៅភូមិតាណើង៧ ឃុំកងតាណើង ស្រុកកងមាស ខេត្តកំពង់-ចាម ។ សិត កើតឆ្នាំរកា ឪពុកឈ្មោះ ប៉ាល់ ម្តាយឈ្មោះ ហេង ។ ឪពុកម្តាយរបស់គាត់បានស្លាប់នៅក្នុងរបបខ្មែរក្រហមអស់ហើយ ។ សិត មានបងប្អូនប្រាំពីរនាក់ ហើយមាន៤នាក់បានចូលបម្រើបដិវត្តន៍ ។ សិត បានរៀបរាប់ថា ក្នុងចំណោមបងប្អូនបួននាក់ដែលចូលបម្រើបដិវត្តន៍ មានតែពីរនាក់ប៉ុណ្ណោះដែលបានត្រឡប់មកផ្ទះវិញ គឺម្នាក់ឈ្មោះ សុខ និងខ្លួនគាត់ ចំណែកពីរនាក់ទៀតឈ្មោះ ប៉ែន និង ហ៊ាយ បានបាត់ខ្លួនរហូតមកដល់បច្ចុប្បន្ន ។*

*កាលពីកុមារភាព សិត រៀនជាមួយព្រះសង្ឃនៅសាលាបាលីវត្តកងតាណើង ។ ប៉ុន្តែដោយសារគ្រួសារមានជីវភាពខ្វះខាត សិត ឈប់រៀនត្រឹមថ្នាក់ទី១០ មកជួយធ្វើការឪពុកម្តាយរហូតដល់អាយុ១៥ឆ្នាំ ។ នៅឆ្នាំ១៩៧២ សិត បានចូលបម្រើបដិវត្តន៍ដោយស្ម័គ្រចិត្ត ។ សិត និយាយថា កាលណោះខ្លួននៅក្មេងពេកពុំបានពិចារណាវែងឆ្ងាយ ឃើញបង១ ធ្វើកងទ័ពស្លៀកពាក់ស្អាតមានស្ពាយកាំភ្លើងមើលទៅរាងសង្ហាគួរឲ្យស្រលាញ់ ក៏សម្រេចចិត្តបបួលបងប្អូនជីដូនមួយឈ្មោះ នឿន និង សែ រត់ចេញពីផ្ទះទាំងយប់ដោយមិនបានជម្រាបឪពុកម្តាយទេ ។ ពេលរត់ទៅដល់ភូមិមួយឈ្មោះ អង្គរបាន ខាងខ្មែររំដោះបានទទួលបងប្អូនរបស់ សិត និងចាប់ផ្តើមបំពាក់អាវុធឲ្យ ។ សិត បាននិយាយបន្តទៀតថា "កាលណោះខ្ញុំសប្បាយចិត្តណាស់ មិនខ្លាចស្លាប់ទេ ។ ហាត់បានតែពីរថ្ងៃអង្គការក៏ចាត់តាំងឲ្យទៅសមរភូមិប្រយុទ្ធជាមួយទាហានលន់ណុលភ្លាមតែម្តង ។ កងខ្ញុំសុទ្ធតែក្មេង១អាយុទើបតែ ១៥-១៦ឆ្នាំប៉ុណ្ណោះ មាឌល្អិតមែន តែចិត្តក្លាហានគ្មានខ្លាចស្លាប់ ។ អង្គការចាត់ទុកជាកងពិសេស ។ ខ្ញុំធ្លាប់បានឡើងប្រយុទ្ធច្រើនកន្លែងណាស់ដូចជា ស្គន់ ព្រៃទទឹង ផ្លូវ ជាដើម" ។ អង្គភាពរបស់ សិត ចំណុះកងពលធំលេខ៣១០ ។ ឆ្នាំ១៩៧៣ អង្គភាពរបស់ សិត ចល័តមកកំពង់ចាមនិងប្រយុទ្ធជាមួយកងម៉ារីនរបស់ លន់ ណុល ដែលបណ្តាលឲ្យមានអ្នកស្លាប់និងរបួសជាច្រើននាក់ ។ សិត ត្រូវរបួសជើងមកសម្រាកព្យាបាលនៅមន្ទីរពេទ្យ "ចម្ការសាមសិប" អស់រយៈពេលប្រហែលមួយខែកន្លះ ។ បន្ទាប់ពីជាសះស្បើយអង្គការក៏បញ្ជូនមកទីក្រុងភ្នំពេញស្នាក់នៅទួលគោក ។*

មួយខែក្រោយមក ថ្ងៃមួយប្រហែលនៅម៉ោងប្រាំល្ងាច មានរថយន្ត១៥គ្រឿងបានមកដឹកយុទ្ធជនជិតមួយកងពលតូចទៅក្រុងកំពង់សោម ។ ទៅដល់ក្រុងកំពង់សោមបានមួយថ្ងៃ អង្គការចាត់តាំងឲ្យលីសែងរបស់របរផ្សេង១ដូចជា អំបិល អង្ករ កៅស៊ូ កប្បាស ម្រេច ជាដើម ដាក់ចូលក្នុងឃ្លាំង រួចហើយដឹកបញ្ជូនចេញពីឃ្លាំងដាក់កប៉ាល់ដឹកទៅប្រទេសចិន ។ របស់របរដែលខ្មែរក្រហមដឹកពីប្រទេសចិនមកវិញគឺកាំភ្លើងធំធុនទំនើបដាក់ភ្ជាប់ជាមួយរថយន្ត ព្រមទាំងមានរថក្រោះមួយចំនួនផង ។ សិត ហ៊ាននិយាយបែបនេះព្រោះបានឃើញជនជាតិចិនផ្ទាល់នឹងភ្នែក ។ សិត និយាយថាល្ងាចមួយពេលឈប់សម្រាកពីការងារ គាត់បានបបួលមិត្តភក្តិដើរលេងនៅជិតកំពង់ផែ ។ ចៃដន្យមានភ្លៀងធ្លាក់យ៉ាងខ្លាំង ។ ពេលនោះមានជនជាតិចិនពីរនាក់បានចុះមកទាញដៃគាត់ឲ្យចូលជ្រកនៅក្នុងកប៉ាល់ ។ ថ្វីត្បិតតែ សិត មិនចេះភាសាចិន ប៉ុន្តែគាត់អាចស្តាប់ដឹងថាបុរសពីរនាក់នោះ និយាយភាសាចិន ហើយនៅលើកប៉ាល់មានសរសេរអក្សរចិនថែមទៀត ។

នៅឆ្នាំ១៩៧៦ យុទ្ធជនមួយចំនួនរួមទាំង សិត ផងត្រូវអង្គការបញ្ជូនមកលីសែងទំនិញនៅគីឡូម៉ែត្រលេខ៦ ។ សិត បញ្ជាក់ថា "យើងជាយុទ្ធជន ប៉ុន្តែយើងក៏ត្រូវតែធ្វើជាកម្មករលីសែងដែរ ព្រោះអង្គការបានប្រជុំប្រាប់ថា យើងជាយុទ្ធជនផងជាកម្មករផងមិនមានបែងចែកទេ បើមានសភាពការណ៍អ្វីកើតឡើងគឺយើងមានអាវុធនៅក្នុងឃ្លាំងស្រាប់" ។

សិត និយាយថា គាត់ធ្លាប់បានមកចូលរួមមហាសន្និបាត បក្សនៅស្តាតអូឡាំពិកម្តង ។ កាលណោះគាត់បានឃើញ ខៀវ សំផន, នួន ជា ដែលឈរទន្ទឹមនឹង អៀង សារី ចំណែក ប៉ុល ពត បង្ហាញខ្លួនតែមួយភ្លែតប៉ុណ្ណោះ ។ សិត បញ្ជាក់ទៀតថា ក្នុងមហាសន្និបាតនោះមានការយាមកាមម៉ឺងម៉ាត់ណាស់ ។ កងសន្តិសុខឆែកឆេរមនុស្សគ្រប់គ្នាដោយហ្មត់ចត់បំផុតមិនថាអ្នកនោះមានឋានៈជាប្រធានកងពលឬយុទ្ធជនឡើយ ។ អ្នកយាមបានរកឃើញកាំភ្លើងខ្លីមួយដើមនៅក្នុងស្បែកជើងឃ្លុបរបស់យុទ្ធជនម្នាក់ដែលបានមកចូលរួមមហាសន្និបាត ហើយក៏ចាប់យុទ្ធជននោះយកទៅបាត់ ។ បីថ្ងៃក្រោយមកមានពាក្យខ្សឹបខ្សៀវតៗគ្នាថា សោ ភឹម បានដាក់ផែនការសម្លាប់ ប៉ុល ពត បន្ទាប់មកនឹងវាយប្រហារចូលទីក្រុងភ្នំពេញដើម្បីដណ្តើមអំណាច ។ ជាអកុសល គម្រោងទាំងប៉ុន្មានត្រូវបែកការណ៍អស់ ហើយខាង ប៉ុល ពត ស្រាវជ្រាវចាប់កម្លាំងខាង សោ ភឹម មកដាក់គុកសួរចម្លើយរួចសម្លាប់ចោលជាបន្តបន្ទាប់ ។ សិត ខ្លួនឯងត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការនៅគីឡូម៉ែត្រលេខ៦ បន្ទាប់មកទៅតាខ្មៅ ហើយនៅទីបំផុតផ្លាស់ទៅធ្វើការនៅរោងចក្រសំឡីគនៅទួលទំពូង ។

ពេលដែលរបបខ្មែរក្រហមត្រូវផ្តួលរំលំនៅឆ្នាំ១៩៧៩ សិត បានរត់គៀសខ្លួនជាមួយយុទ្ធជនមួយចំនួនទៅភាគខាងលិចប្រទេស ដោយធ្វើដំណើរឆ្លងកាត់ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ។ ដោយមានការលំបាកពេករកតែអ្វីហូបមិនបាន សិត ក៏សម្រេចចិត្តចូលសារភាពជាមួយរដ្ឋាភិបាលនៅឆ្នាំ១៩៨២ ។

សព្វថ្ងៃ ប៉ាល់ សិត មានអាយុ៥០ឆ្នាំ មានប្រពន្ធឈ្មោះ ម៉ុម សំ អាយុ៥១ឆ្នាំ ។ សិត បានមានប្រសាសន៍ថា គាត់រីករាយណាស់ពេលដឹងថា រដ្ឋាភិបាលព្រមព្រៀងចុះហត្ថលេខាជាមួយអង្គការសហប្រជាជាតិដើម្បីបង្កើតតុលាការចម្រុះមួយសម្រាប់កាត់សេចក្តីមេដឹកនាំខ្មែរក្រហម ។ សិត និយាយថា នេះជាការត្រឹមត្រូវហើយដើម្បីឲ្យក្មេងៗជំនាន់ក្រោយបានដឹងនិងជាប្រវត្តិសាស្ត្រមួយកុំឲ្យយកតម្រាប់តាម ។

**សុខ ខណ្ណៈ**



# សមមិត្ត ខៀវ សំផន: ការដាក់ឱ្យទទួលខុសត្រូវចំពោះ បទឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម

(ដកស្រង់ចេញពីសៀវភៅ «បេក្ខភាព៧រូបសម្រាប់ការកាត់ទោស»)

ភស្តុតាងដែលបានរកឃើញទាក់ទងទៅនឹង ខៀវ សំផន អតីតប្រធានគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ បានផ្សារភ្ជាប់ ខៀវ សំផន ទៅនឹងឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនិស្តកម្ពុជា ទោះបីជាឯកសារនេះមិនទូលំទូលាយដូចឯកសារផ្សេងៗទៀត ដែលទាក់ទងទៅនឹងប្រធានបទនៃការវិភាគនេះក៏ដោយ ។ ឯកសារជាច្រើនបានបង្ហាញអំពីការដឹងឮរបស់ ខៀវ សំផន ទៅលើអំពើឃោរឃៅរបស់បក្សកុម្មុយនិស្តកម្ពុជា ហើយបញ្ជាក់ថា ខៀវ សំផន បានរួមចំណែកជាលក្ខណៈបុគ្គលនៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ គាំទ្រគោលនយោបាយនៅពីក្រោយ និងតាមរយៈការត្រួតពិនិត្យសកម្មភាពអនុវត្តគោលនយោបាយទាំងនោះដោយអាជ្ញាធរតំបន់និងអាជ្ញាធរផ្សេងទៀត ។

## ការវិភាគទៅលើភស្តុតាង

ឯកសារជាច្រើនផ្អែកបង្ហាញថា ខៀវ សំផន បានដឹងច្បាស់អំពីវត្តមាននិងការអនុវត្តគោលនយោបាយប្រហារជីវិតរបស់បក្សកុម្មុយនិស្តកម្ពុជា ។ ឯកសារទាំងនេះចង្អុលបង្ហាញថា ស្ទើរពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន មានមុខងារសំខាន់ៗមួយចំនួននៅក្នុងបក្ស ។ ឧទាហរណ៍ មានរបាយការណ៍បង្ហាញថា ខៀវ សំផន បានចូលរួមក្នុងគណៈកម្មាធិការមជ្ឈិមនៅក្នុងឆ្នាំ១៩៧១ ប្រហែលក្នុងតួនាទីជាសមាជិកបម្រុង ។ ប៉ុល ពត បានអះអាងថា មកដល់ឆ្នាំ១៩៧៥ ខៀវ សំផន «មានឋានៈជាសមាជិកនៃគណៈមជ្ឈិម» ។ នេះជាសម្តីមិនច្បាស់លាស់មួយដែលហាក់ដូចជាបង្ហាញថា ខៀវ សំផន មានឋានៈតូចជាងសមាជិកពេញសិទ្ធិ ។ ប៉ុន្តែមកដល់សម័យប្រជុំបក្សនៅខែមករា ឆ្នាំ១៩៧៦ ខៀវ សំផន បានក្លាយទៅជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិមរួចជាស្រេច ។ ដោយមូលហេតុនេះ ខៀវ សំផន បានដឹងឮអំពីនយោបាយសម្ងាត់ទាំងឡាយដែលដាក់ចេញពីគណៈមជ្ឈិម រួមទាំងគោលនយោបាយនៃការចាប់ចងនិងការប្រហារជីវិតជនដែលត្រូវបានសង្ស័យថាជាសត្រូវរបស់របបកម្ពុជាប្រជាធិបតេយ្យផង ។ ទោះបីជាមានមុខងារជាប្រធានគណៈប្រធានរដ្ឋបង្កើតនៅឆ្នាំ១៩៧៦ដែលហាក់ដូចជាមានតែរូបរាងក៏ដោយ ក៏សមាជិកភាពរបស់ ខៀវ សំផន នៅក្នុងគណៈមជ្ឈិមគួរតែធ្វើឲ្យគាត់ដឹងឮអំពីគោលនយោបាយប្រហារជីវិតរាល់បុគ្គលដែលត្រូវបានសង្ស័យថាជាខ្មាំងបង្កប់ដូចជាសមាជិកផ្សេងទៀតដែរ ។

នៅក្នុងឆ្នាំ១៩៧៧ ខៀវ សំផន ត្រូវបានតែងតាំងជាប្រធាន «មន្ទីរ៨៧០» ដែលមានលក្ខណៈជាក្រុមប្រឹក្សានៃគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តកម្ពុជា ។ ទោះបីនេះមិនមែនជាតំណែងដែលមានអំណាចសម្រេចចិត្តក៏ដោយ ក៏ប្រធានមន្ទីរ៨៧០មានភារកិច្ច«តាមដានការអនុវត្តជាក់ស្តែង»នៃគោលនយោបាយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ដែរ ។ ដោយសារមុខងារនេះ ខៀវ សំផន ពិតជាបានដឹងឮអំពីការសម្រេចចិត្តចាប់ខ្លួននិងប្រហារជីវិតដែលធ្វើឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍ ។ ជាពិសេសដោយសារ ខៀវ សំផន ជាប្រធានមន្ទីរ៨៧០ ខៀវ សំផនចូលរួមជា «អ្នកធ្វើកំណត់ហេតុអង្គប្រជុំ» នៅក្នុងជំនួបសម្ងាត់មួយនៅឆមាសទីមួយនៃឆ្នាំ១៩៧៨ ។ នៅក្នុងអង្គប្រជុំ ប៉ុល ពត, នួន ជា និង សុន សេន បានបញ្ជាឲ្យធ្វើវិសុទ្ធកម្ម(ការបោសសម្អាត) និងប្រហារជីវិតលេខាភូមិភាគបូព៌ាឈ្មោះ សោ ភឹម និងកម្មាភិបាលយោធានិងនយោបាយធំៗភាគច្រើននៅក្នុងភូមិភាគបូព៌ា ។

ការអះអាងថា ខៀវ សំផន បានដឹងឮពីអំពើឃោរឃៅរបស់បក្សកុម្មុយនិស្តកម្ពុជា ត្រូវបានគាំទ្រដោយភស្តុតាងបញ្ជាក់ថា ខៀវ សំផន បានដឹងថាមានចម្លើយសារភាព និងដឹងសេចក្តី

រៀបរាប់នៅក្នុងចម្លើយសារភាព ។ ដូចក្នុងករណី អៀង សារី ភ័ស្តុតាងជាក់លាក់មួយចំនួនបង្ហាញថា ខៀវ សំផន បានអានចម្លើយសារភាពនៅក្នុងជំនួបជាសាធារណៈ ហេតុនេះ ខៀវ សំផន បានដឹងថាមានចម្លើយសារភាពនិងអ្វីដែលមានសរសេរនៅក្នុងនោះ ។ អតីតសមាជិកបក្សកុម្មុយនិស្តកម្ពុជាមួយរូបដែលបានជួបសម្ភាសន៍នៅឆ្នាំ១៩៩៦ បានរៀបរាប់ថា នៅក្នុងអង្គប្រជុំមួយនៅពហុកីឡដ្ឋានជាតិអូឡាំពិកនៅចុងឆ្នាំ១៩៧៦ ខៀវ សំផន បានឡើងអានចម្លើយសារភាពរបស់ ម៉ែន សាន ហៅ យ៉ា លេខាភូមិភាគឦសាន និងចម្លើយសារភាពរបស់បុគ្គលដែលទើបនឹងចាប់ខ្លួនថ្មីៗទៀត ។ នៅក្នុងចម្លើយសារភាព យ៉ា "ទទួលស្គាល់" ទោសក្បត់ជាតិ ។ អំពើក្បត់ជាតិជាបទឧក្រិដ្ឋមួយដែលត្រូវដឹងយ៉ាងច្បាស់នៅក្នុងបក្សកុម្មុយនិស្តកម្ពុជាថា លទ្ធផលចុងក្រោយគឺការប្រហារជីវិត ។ អាស្រ័យហេតុនេះ ការដឹងឮរបស់ ខៀវ សំផន ចំពោះចម្លើយសារភាពនេះ បង្ហាញយ៉ាងជាក់ស្តែងថា ខៀវ សំផន ដឹងអំពីវាសនាចុងក្រោយរបស់ យ៉ា និងអ្នកឯទៀតដែល "ព្រមសារភាព" ។

ខៀវ សំផន ប្រហែលជាបានទទួលរបាយការណ៍ពីប្រភពពត៌មានដើមដែលពិតជាបានប្រាប់គាត់ឲ្យដឹងអំពីការចាប់ខ្លួននិងធ្វើទុក្ខទោស"ខ្មាំងបង្កប់"នៅក្បែរព្រំដែនវៀតណាម "ការកម្ទេច" អ្នកតស៊ូរបស់កម្ពុជាប្រជាធិបតេយ្យដែលត្រូវបានចោទប្រកាន់ថាមានទំនាក់ទំនងជាមួយសេ.អ៊ី.អា នៅក្នុងប្រទេសថៃ និងការសួរចម្លើយ"សមាសធាតុមិនល្អ"នៅក្នុងកងយោធាគណៈមជ្ឈិម ។ របាយការណ៍អំពីពត៌មាននេះនិងពត៌មានផ្សេងដែលបានរៀបរាប់នៅក្នុងផ្នែកទី៤ ចំណុច១និង២ ទាក់ទងនឹង នួន ជា និង អៀង សារី ត្រូវបានចារថា សម្រាប់ផ្ញើទៅ"មន្ទីរ"និង"ឯកសារ" ។ ដោយសារតែតួនាទីជាផ្លូវការរបស់មន្ទីរ៨៧០រួមបញ្ចូលទាំងការតាមដានការអនុវត្តន៍គោលនយោបាយរបស់គណៈកម្មាធិការមជ្ឈិម ដូច្នេះពាក្យ"មន្ទីរ"នៅក្នុងរបាយការណ៍ទាំងនោះអាចជាមន្ទីរ៨៧០ ដែល ខៀវ សំផន មានមុខងារជាប្រធានតាំងពីដើមឆ្នាំ១៩៧៧ ។ ដូច្នេះ មន្ទីរ៨៧០ទទួលខុសត្រូវចំពោះការទុកដាក់ឯកសាររបស់គណៈមជ្ឈិម ។

ភ័ស្តុតាងនេះត្រូវបានគាំទ្រដោយសេចក្តីថ្លែងការណ៍ភ្ជាប់ពិរុទ្ធកម្មចេញពី ខៀវ សំផន តាំងពីការធ្លាក់ចុះនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨៧ ការិយាល័យអនុប្រធានកម្ពុជាប្រជាធិបតេយ្យទទួលបន្ទុកកិច្ចការបរទេសរបស់ ខៀវ សំផន បានចេញផ្សាយឯកសារមួយក្នុងគោលបំណងបញ្ចៀស ប៉ុល ពត, ខៀវ សំផន ខ្លួនឯង និងមេដឹកនាំផ្សេងទៀតដែលនៅមានជីវិតនៅឡើយពីការទទួលខុសត្រូវចំពោះ "ការសម្លាប់រង្គាល" ឬការសម្លាប់ដែលអាចចៀសវាងបាននៅពេលដែលបក្សកុម្មុយនិស្តកម្ពុជាកាន់អំណាច ។ ទោះបីជាមានបំណងដូច្នោះឯកសារនោះទទួលស្គាល់ថា បក្សកុម្មុយនិស្តកម្ពុជាបានប្រហារជីវិតសមាជិករបស់ខ្លួនប្រមាណ១១.០០០នាក់ ពីបទធ្វើជាភ្នាក់ងារយួន ។ ក្នុងចំនួនទាំងនេះ ឯកសារនោះបានបន្តថាមានតែប្រមាណ៨.០០០នាក់ប៉ុណ្ណោះដែលពិតជាបានរួមចំណែកនៅក្នុងការប៉ុនប៉ង"ធ្វើសកម្មភាពជាខ្សែសង្វាក់ដើម្បីផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ" ។ ទាំងនេះជាអ្នកដែលត្រូវចាប់ខ្លួនប្រឡំនៅក្នុងដំណាក់កាលនៃ"ការចាត់វិធានការចាប់និងដាក់ទណ្ឌកម្ម...ភ្នាក់ងារយួន" ។ ជាពិសេស ឯកសារដដែលបានរៀបរាប់ទៀតថាជនរងគ្រោះទាំងនោះត្រូវបានប្រហារជីវិត ទោះបីអ្នកនោះជា "ជនល្មើសតូចតាចឬជនស៊ីវិលគ្មានកំហុស"ក៏ដោយ ។ សេចក្តីថ្លែងការណ៍នេះផ្ទុយស្រឡះទៅនឹងការថ្លែងពីមុនមួយដែល ខៀវ សំផន បានជឿជាក់ថាមានតែមនុស្សម្នាក់ប៉ុណ្ណោះត្រូវចោទប្រកាន់ខុសពីបទក្បត់ជាតិ ។

ការចេញផ្សាយឯកសារនេះបានធ្វើឡើងក្រោយពីមានសេចក្តីថ្លែងការណ៍ផ្សេងទៀតដោយ (ឬមានប្រភពចេញពី) ខៀវ សំផន ដែលក្នុងនោះយ៉ាងហោចណាស់ ខៀវ សំផន ទទួលស្គាល់ថាបានដឹងឮអំពីការចាប់ខ្លួននិងការប្រហារជីវិតមួយចំនួន ទោះបីជា ខៀវ សំផន តែងតែបដិសេធថាគាត់និងសមាជិកផ្សេងទៀតនៃគណៈមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជាដែលនៅរស់មិនបានប្រព្រឹត្តអំពើសម្លាប់រង្គាលក៏ដោយ ។ ឧទាហរណ៍ នៅក្នុងបទសម្ភាសន៍មួយធ្វើឡើងនៅខែសីហា ឆ្នាំ១៩៨០ គឺមួយឆ្នាំក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ខៀវ សំផន បានអះអាងថារាល់ការប្រហារជីវិតដែលបានកើតឡើង ត្រូវបានប្រព្រឹត្តដោយពួកក្បត់នៅក្នុងបក្សដែលត្រូវបានសម្លាប់អស់ហើយ ។

បន្ទាប់ពីបានសួរខ្លួនឯងជាហូរហែថាតើមាន "អ្វីដែលមានផលអាក្រក់ដល់អាយុជីវិតរបស់ប្រជាជន" ខៀវ សំផន ឆ្លើយខ្លួនឯងថា "ប្រាកដជាមាន" ប៉ុន្តែ"មិនមែនក្នុងទ្រង់ទ្រាយធំដូចការសម្លាប់រង្គាល"នោះទេ ។ ភ្លាមៗនោះ ខៀវ សំផន បានបន្ថែមទៀតថា វត្តមាននៃការសម្លាប់រង្គាលបែបនោះ "គួរត្រូវស្រាយបញ្ជាក់ថាវាកើតឡើងដោយសារគិញយួន គិញខ្មែរដែលយួនលួចបញ្ចូលទៅក្នុងថ្នាក់ដឹកនាំរដ្ឋដែលវាកាន់តែមានអំណាចសំខាន់ថែមទៀត" ដូចជាលេខាភូមិភាគជាដើម ។ បន្ទាប់មកដោយនិយាយទាក់ទងនឹងការបោសសម្អាតកម្មាភិបាលទាំងនេះនិងជន"ក្បត់"ផ្សេងទៀត ខៀវ សំផន បានថ្លែងថា "មកដល់ឆ្នាំ១៩៧៧-១៩៧៨ យើងបានចម្រាញ់ពួកនេះចេញ ហើយដោះស្រាយស្ថានភាពនៅក្នុងប្រទេសរួចហើយ" ។

ភ័ស្តុតាងផ្សេងទៀតបង្ហាញថា ខៀវ សំផន បានរួមចំណែកជាបុគ្គលនៅក្នុងអំពើឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនិស្តកម្ពុជា ។ ទោះបីជាបច្ចុប្បន្នគ្មានភ័ស្តុតាងណាបញ្ជាក់ថា ខៀវ សំផន មានសិទ្ធិនិងអំណាចចាប់ចងនិងសម្លាប់ ឬថាគាត់បានចូលរួមដោយផ្ទាល់នៅក្នុងការប្រហារជីវិតអតីតមន្ត្រីរបបសាធារណរដ្ឋក៏ដោយ ក៏ ខៀវ សំផន បានគាំទ្រជាសាធារណៈនូវចំណាត់វិធានការប្រឆាំងនឹងខ្មាំងបដិវត្តន៍ក្នុងរបៀបមួយដែលបញ្ជាក់អំពីការដឹងឮនិងការគាំទ្រចំពោះគោលនយោបាយនៃការប្រហារជីវិតជនដែលត្រូវចាត់ទុកថាជាខ្មាំងបង្កប់ដែរ ។ ឧទាហរណ៍នៅក្នុងសេចក្តីអត្ថាធិប្បាយមួយអំពីច្បាប់រដ្ឋធម្មនុញ្ញដែលបានផ្សព្វផ្សាយនៅក្នុងឱកាសប្រកាសជាផ្លូវការនៅខែធ្នូ ឆ្នាំ១៩៧៥ ខៀវ សំផន បានព្រមានថា "ពួកចក្រពត្តិបរទេស" កំពុងតែខំប្រឹង"ជ្រៀតចូល" និង "ធ្វើសកម្មភាពប្រឆាំង"កម្ពុជាប្រជាធិបតេយ្យ ។ ខៀវ សំផន បានប្រកាសឲ្យមានភាពប្តូរផ្តាច់ក្នុងការ "វាយកម្ទេចពួកនេះ ទោះជាវាខំប្រឹងបន្លំខ្លួនយ៉ាងណាក៏ដោយ" និង"ប្រឆាំងនឹងខ្មាំងចក្រពត្តិទាំងអស់ឲ្យខាងតែបាន" ។ នៅក្នុងពេលដែលសេចក្តីថ្លែងការណ៍នេះកំពុងត្រូវបានធ្វើឡើងមន្ទីរស-២១មានដំណើរការរួចជាស្រេចទៅហើយ ។ យ៉ាងហោចណាស់មនុស្ស១៨នាក់ដែលត្រូវបានចាប់ខ្លួននិងក្រោយមកត្រូវយកទៅប្រហារជីវិតបានសរសេរ"ចម្លើយសារភាព"ថាខ្លួនជាខ្មាំងបង្កប់ ។ បើពិចារណាអំពីតួនាទីរបស់ ខៀវ សំផន នៅក្នុងរចនាសម្ព័ន្ធអំណាចរបស់កម្ពុជាប្រជាធិបតេយ្យ សេចក្តីថ្លែងការណ៍ប្រភេទនេះអាចជំរុញឲ្យកម្មាភិបាលថ្នាក់ក្រោមចាប់ខ្លួននិងប្រហារជីវិតជនក្បត់ជាប់សង្ស័យ រួមទាំងអតីតមន្ត្រីរបបសាធារណរដ្ឋផង ។

ចម្លើយសារភាពខ្លះចង្អុលបង្ហាញថា នៅចុងឆ្នាំ១៩៧៦ ខៀវ សំផន បានជាប់ពាក់ព័ន្ធដោយផ្ទាល់ជួសមុខឲ្យបក្សនៅក្នុងភារកិច្ចស៊ើបអង្កេតអំពីសកម្មភាពប្រឆាំងបក្សនៅក្នុងក្រសួងឃោសនាការ ហើយយ៉ាងហោចណាស់ ដោយសារមានមុខងារនេះ ខៀវ សំផន បានដឹងឮអំពីការធ្វើអត្តឃាតរបស់កម្មាភិបាលមួយរូបនៅក្នុងក្រសួងឃោសនាការដែលបានជាប់សង្ស័យពីបទក្បត់ជាតិគឺ ព្រុំ សំអា ។ នៅពេលដែលសម្ពាធរិះគន់បក្សរបស់ សំអា ត្រូវ"អង្គការ"ដឹងឮ ទំនងជាបានរាយការណ៍ទៅ នួន ជា ផង អង្គការបានបញ្ជូន ខៀវ សំផន ទៅក្រសួងឃោសនាការដើម្បីផ្តល់ការណែនាំ"ឲ្យស៊ើបអង្កេតបន្ថែមដើម្បីឲ្យដឹងថា វាជាខ្មាំងមែនឬអត់" ។ នៅដើមឆ្នាំ១៩៧៧ ដោយដឹងថា គាត់ពិតជាត្រូវចាប់ខ្លួន សំអា បានធ្វើអត្តឃាត ។ ខៀវ សំផន បានរាយការណ៍ភ្លាមៗទៅ"អង្គការ" អំពីអត្តឃាតកម្មរបស់ សំអា ដែលប្រហែលជាចម្លងជូនទៅ នួន ជា ផង ។ ក្រោយមក ខៀវ សំផន បានណែនាំឲ្យយកសាកសពរបស់ សំអា ទៅ"កប់ដោយសម្ងាត់" ។

ចម្លើយសារភាពផ្សេងផ្តល់តម្រុយថា ក្រោយពីបានទទួលតំណែងជាប្រធានមន្ទីរ៨៧០ ខៀវ សំផន បានចាប់ផ្តើមធ្វើការដោយផ្ទាល់ជាមួយមេដឹកនាំថ្នាក់ខ្ពស់របស់បក្ស គឺជាមួយ នួន ជា ឬប្រហែលជាមួយគណៈកម្មាធិការអចិន្ត្រៃយ៍ទាំងមូល ដើម្បីធានាអំពីការអនុវត្តឲ្យបានត្រឹមត្រូវនូវសេចក្តីសម្រេចចិត្តរបស់មេដឹកនាំបក្សឲ្យបន្តបោសសម្អាតខ្មាំងបង្កប់នៅក្នុងជួរបក្ស ។ ឧទាហរណ៍នៅក្នុងខែសីហា ឆ្នាំ១៩៧៧ តាមរយៈចម្លើយសារភាពរបស់លេខាភូមិភាគបស្ចិមឈ្មោះ ជូ ជេត ហៅ ថង ស៊ី, ខៀវ សំផន បានធ្វើដំណើរទៅភូមិភាគបស្ចិមដើម្បីស៊ើបអង្កេតទៅលើស្ថានភាពមិនច្បាស់លាស់នៃការបោសសម្អាតខ្មាំងមុនៗនិងបញ្ហាឯទៀតត្រូវបានបំផុសបំផុល ។ ការស៊ើបអង្កេតនេះ ធ្វើទៅលើទំនាស់រវាង ស៊ី និងអនុរបស់គាត់ឈ្មោះ ហេង ផល ។ របាយការណ៍នៃការស៊ើបអង្កេតរបស់ ខៀវ សំផន ពិតជាបានរួមចំណែកក្នុងការ

សម្រេចរបស់អង្គការឲ្យចាប់ខ្លួន ស៊ី ។

ក្រោយពីព្រឹត្តិការណ៍ទាំងនេះចប់ ខៀវ សំផន បានធ្វើសុន្ទរកថាមួយក្នុងតួនាទីជាប្រធានគណៈប្រធានរដ្ឋ នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៨ ជាផ្នែកមួយនៃការអបអរអំពីទិវាជាតិ១៧មេសារបស់កម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងសុន្ទរកថានោះ ខៀវ សំផន អបអរចំពោះ«បរាជ័យដ៏ដួរចត់»របស់ខ្មាំងយួនបង្កប់ខ្លួននៅក្នុងបក្សកុម្មុយនិស្តកម្ពុជាដែលត្រូវបានចាប់ខ្លួនរួចហើយ ។ ខៀវ សំផន បានបន្តថា ខ្មាំងបង្កប់បាន «ធ្វើសកម្មភាពបង្អាក់ដំណើរការបក្ស លួចយកការណ៍និងពង្រាយខ្សែបណ្តាញ ហើយបានរៀបចំផែនការធ្វើរដ្ឋប្រហារផ្តួលរំលំបក្សកុម្មុយនិស្តកម្ពុជានិងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ» ។ ខៀវ សំផន បានបញ្ជាក់ថា គាត់មិនខ្វល់ថាការបោសសម្អាតខ្មាំងបង្កប់អាចធ្វើឲ្យរលស់ចំនួនកម្មាភិបាលបដិវត្តន៍នោះទេ ពីព្រោះមានកម្មាភិបាលថ្មីនិងល្អៗជាច្រើននៅរង់ចាំចូលបម្រើអង្គការជំនួសអ្នកចាស់ ។ ថ្លែងនៅក្នុងដំណាក់កាលទីមួយនៃសកម្មភាពបោសសម្អាតខ្មាំងជាទូទៅដែលមិនត្រឹមតែចាប់ខ្លួន ជូ ជេត ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកម្មាភិបាលធំៗរបស់ភូមិភាគបូព៌ាផង មួយខែក្រោយពីការចេញសុន្ទរកថានេះ មានការបោសសម្អាតដ៏ធំមួយនៅភូមិភាគបូព៌ា ។ តាមសម្តីរបស់ ឌុច បើការបោសសម្អាតជាការសម្រេចចិត្តជាសម្ងាត់មួយដែល, ខៀវ សំផន បានធ្វើកំណត់ហេតុ ។

ចម្លើយសារភាពជាច្រើនបានបង្ហាញថា ខៀវ សំផន បានរួមចំណែកក្នុងការបោសសម្អាតខ្មាំងនៅឆ្នាំ១៩៧៨នៅក្នុងភូមិភាគបូព៌ា តាមរយៈការធានាថា យ៉ាងហោចណាស់កម្មាភិបាលមួយរូបដែលបានកំណត់ថាត្រូវចាប់ខ្លួនមិនបានដឹងមុនអំពីផែនការចាប់ខ្លួន ។ កម្មាភិបាលរូបនោះគឺ វ៉ីង ឆឹម ហៅ ភួង សមាជិកមួយរូបរបស់គណៈមជ្ឈិមបក្សទទួលខុសត្រូវខាងចម្ការកៅស៊ូ ។ ភួង ពិតជាបានទៅមន្ទីរ៨៧០ដើម្បីពិភាក្សាជាមួយ ប៉ុល ពត និង នួន ជា អំពីការរៀបចំភូមិភាគបូព៌ាសាជាថ្មី ។ នៅក្នុងអង្គប្រជុំមួយ នួន ជា បានធានាចំពោះ ភួង ថា បើ ភួង ចង់បានអ្វីដើម្បីធ្វើការងារឲ្យកាន់តែងាយស្រួល ភួង គួរទៅជួបជាមួយ ខៀវ សំផន ។ បន្ទាប់មក ខៀវ សំផន បានបរិភោគអាហារពេលល្ងាចនៅឯមន្ទីរ៨៧០ជាមួយ ភួង និងសមាជិកផ្សេងទៀតនៃគណៈមជ្ឈិមដែលនឹងត្រូវសម្លាប់ចោល ។ នៅពេលនោះមានការពិភាក្សាអំពីការចាប់ខ្លួនដែលបានធ្វើឡើងតាំងពីយូរមកហើយ ។ ភួង ត្រូវចាប់ខ្លួននៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៧៨ នៅភ្នំពេញ ។ ការចាប់ខ្លួនរបស់ ភួង អាចត្រូវបានពិភាក្សាជាមុននៅក្នុងអង្គប្រជុំឆ្នាំ១៩៧៨ កត់ត្រាដោយ ខៀវ សំផន ។ ក្នុងអង្គប្រជុំនេះ ប៉ុល ពត, នួន ជា និង សុន សេន បានដាក់បញ្ជាឲ្យធ្វើវិសុទ្ធកម្មកម្មាភិបាលភូមិភាគបូព៌ា ។ ដូច្នេះភ័ស្តុតាងពាក់ព័ន្ធនឹង ភួង បង្ហាញថា ខៀវ សំផន អាចរួមចំណែកដល់ការអនុវត្តអំពើឃោរឃៅមួយចំនួនរបស់បក្សកុម្មុយនិស្តកម្ពុជា ដោយដឹងយ៉ាងច្បាស់អំពីផលវិបាកនៃមុខងាររបស់ខ្លួន ។

## ការវិភាគតាមផ្លូវច្បាប់និងសេចក្តីសន្និដ្ឋាន

ការវិភាគរបស់យើងទាក់ទងទៅនឹងប្រធានគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានចង្អុលបង្ហាញអំពីការទទួលខុសត្រូវជាលក្ខណៈបុគ្គលរបស់ ខៀវ សំផន ចំពោះការប្រហារជីវិតនៅក្នុងប្រទេសកម្ពុជា ។ បន្ថែមទៅលើការបង្ហាញថា ខៀវ សំផន បានដឹងឮអំពីគោលនយោបាយប្រហារជីវិតរបស់បក្សកុម្មុយនិស្តកម្ពុជា ហើយពុំបានចាត់វិធានការដើម្បីបញ្ឈប់ការអនុវត្តន៍គោលនយោបាយទាំងនោះ មានភ័ស្តុតាងបញ្ជាក់ទៀតថា ខៀវ សំផន បានរួមចំណែកនៅក្នុងការអនុវត្តគោលនយោបាយប្រហារជីវិតរបស់បក្សតាមរយៈសុន្ទរកថាគាំទ្រគោលនយោបាយទាំងនោះ និងតាមរយៈការស៊ើបអង្កេតជួសមុខឲ្យបក្សកុម្មុយនិស្តកម្ពុជាទៅលើការអនុវត្តន៍នយោបាយបក្សរបស់អាជ្ញាធរនៅតាមតំបន់ ។

ដូចបានបកស្រាយខាងលើ ខៀវ សំផន បានធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈជាច្រើនដងចាប់តាំងពីខែធ្នូឆ្នាំ១៩៧៥រហូតមក បញ្ជាក់ពីការគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់បក្សក្នុងការធ្វើវិសុទ្ធកម្មបក្សឲ្យអស់ជនក្បត់ជាតិ ។ សេចក្តីថ្លែងការណ៍ទាំងនេះរួមទាំងសុន្ទរកថាមួយធ្វើឡើងនៅខែមេសា ឆ្នាំ១៩៧៨ក្នុងឱកាសបុណ្យខួបលើកទីមួយចំពោះ«ការរំដោះ»ទីក្រុងភ្នំពេញ ។ ក្នុងនោះ ខៀវ សំផន អបអរចំពោះ«បរាជ័យដ៏ដួរចត់»របស់ខ្មាំងយួនបង្កប់ខ្លួននៅក្នុងជួរបក្សកុម្មុយនិស្តកម្ពុជា ដែលត្រូវបានចាប់ខ្លួនរួចហើយពីបទ«ធ្វើសកម្មភាពបង្អាក់ដំណើរការបក្ស លួចយក

ការណ៍ ពង្រាយខ្សែរយៈ និងរៀបចំផែនការរដ្ឋប្រហារផ្តួលរំលំបក្សកុម្មុយនិស្តកម្ពុជានិងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ” ។ នៅក្នុងសុន្ទរកថានោះដែរ ខៀវ សំផន បានបញ្ជាក់ថា ខ្លួនមិនខ្វល់ថាការបោសសម្អាតខ្មាំងបង្កប់អាចធ្វើឲ្យរលស់ចំនួនកម្មាភិបាលបដិវត្តន៍ទេ ពីព្រោះមានកម្មាភិបាលថ្មីនិងល្អៗជាច្រើនរង់ចាំចូលបម្រើអង្គការជំនួស ។ ដូចការវិភាគមុនៗដែរ សេចក្តីថ្លែងការណ៍ទាំងនេះត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលដែលការប្រហារជីវិតប្រជាពលរដ្ឋដែលមិនដើរតាមលទ្ធិកុម្មុយនិស្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងវិសុទ្ធកម្មនៅក្នុងបក្សកុម្មុយនិស្តកម្ពុជាខ្លួនឯងកំពុងតែកើនឡើង ។ ដោយសារមានមុខងារជាមេដឹកនាំកំពូលមួយរូប សេចក្តីថ្លែងការណ៍របស់ ខៀវ សំផន អាចមានឥទ្ធិពលលើកកម្ពស់សកម្មភាពចាប់ខ្លួននិងប្រហារជីវិត ។ ម្យ៉ាងវិញទៀត ចម្លើយសារភាពខ្លះបញ្ជាក់ថា ខៀវ សំផន បានរួមចំណែកយ៉ាងសកម្មនៅក្នុងការជួយរែកមុខ និងចាប់ខ្លួនសត្រូវអង្គការដូចជាតាមរយៈការស៊ើបអង្កេតទៅលើសកម្មភាពជំទាស់បក្សនៅក្នុងក្រសួងឃោសនាការ ការស៊ើបអង្កេតទៅលើសកម្មភាពបោសសម្អាតកម្មាភិបាលនៅភូមិភាគបស្ចិមដែលនាំទៅរកការចាប់ខ្លួន ចង ស៊ី ដែលក្រោយមកត្រូវប្រហារជីវិត និងការជួយជ្រោមជ្រែងដល់ការចាប់ខ្លួនកម្មាភិបាលមួយរូបទៀតនៅភូមិភាគបូព៌ានៅពាក់កណ្តាលឆ្នាំ១៩៧៨ ដែលត្រូវបានប្រហារជីវិតដូច ចង ស៊ី ដែរ ។

មានភ័ស្តុតាងជាច្រើនគាំទ្រការអះអាងថា នៅក្នុងអំឡុងពេលនោះ ខៀវ សំផន បានដឹងព្រឺអំពីការចាប់ខ្លួន ការសួរចម្លើយនិងការប្រហារជីវិតកម្មាភិបាលបក្សទៅតាមគោលនយោបាយប្រហារជីវិតរបស់បក្ស ។ ដូចរៀបរាប់នៅខាងដើម ចាប់ពីខែមករា ឆ្នាំ១៩៧៦ ខៀវ សំផន ជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម និងមានមុខងារជាប្រធានមន្ទីរ៨៧០ ចាប់ពីដើមឆ្នាំ១៩៧៧ ដោយមានការទទួលខុសត្រូវផ្សេងៗ រួមទាំងតាមដានការសម្រេចចិត្តទៅលើគោលនយោបាយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ថែមទៀត ។ នៅក្នុងមុខងារទាំងពីរ ខៀវ សំផន ពិតជាបានអានឯកសារនិងពត៌មានផ្សេងៗទាក់ទងនឹងគោលនយោបាយប្រហារជីវិតរបស់បក្ស រួមទាំងការសម្រេចចិត្តនៅខែមីនា ឆ្នាំ១៩៧៦ របស់គណៈមជ្ឈិម(រៀបរាប់នៅក្នុងផ្នែកទី៣) ដើម្បីផ្តល់អំណាចឲ្យគណៈភូមិភាគនិងគណៈកម្មាធិការផ្សេងទៀតរបស់បក្សកុម្មុយនិស្តកម្ពុជា ក្នុងការសម្លាប់ជនទាំងឡាយណាដែលត្រូវបានសង្ស័យថាមានទោសធ្ងន់ធ្ងរពីបទប្រឆាំងបដិវត្តន៍ ។

ខៀវ សំផន មានវត្តមាននៅក្នុងអង្គប្រជុំឆ្នាំ១៩៧៨ ដែលក្នុងនោះ ប៉ុល ពត, សុន សេន និង នួន ជា បានសម្រេចចិត្តធ្វើវិសុទ្ធកម្មភូមិភាគបូព៌ា ។ ភ័ស្តុតាងខ្លះបញ្ជាក់ថា ខៀវ សំផន បានអានជាសាធារណៈនូវការរៀបរាប់នៅក្នុងចម្លើយសារភាពនៅចុងឆ្នាំ១៩៧៦ ។ ការអាននេះបូកបញ្ចូលទាំងភាពប្រាកដប្រជាថា ខៀវ សំផន បានដឹងព្រឺអំពីគោលនយោបាយប្រហារជីវិតរបស់បក្សបញ្ជាក់ថា ខៀវ សំផន បានដឹងថាមានចម្លើយសារភាពនិងតួនាទីរបស់ចម្លើយសារភាពនៅក្នុងការអនុវត្តន៍គោលនយោបាយប្រហារជីវិត ។

សេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ចាប់តាំងពីការធ្លាក់ចុះរបស់កម្ពុជាប្រជាធិបតេយ្យ គាំទ្របន្ថែមដល់ការសន្និដ្ឋានថា ខៀវ សំផន បានដឹងច្បាស់អំពីអំពើឃោរឃៅរបស់កម្ពុជាប្រជាធិបតេយ្យ ។ សេចក្តីថ្លែងការណ៍ខែកក្កដា ឆ្នាំ១៩៨៧ ចេញផ្សាយដោយការិយាល័យអនុប្រធានកម្ពុជាប្រជាធិប-តេយ្យទទួលបន្ទុកកិច្ចការបរទេសរបស់ ខៀវ សំផន បានរៀបរាប់ថាយ៉ាងហោចណាស់ ជនល្មើសកម្រិតស្រាលចំនួនបីពាន់នាក់ឬជនស៊ីវិលគ្មានកំហុស ត្រូវបានប្រហារជីវិតយ៉ាងខុសឆ្គងដោយបក្សកុម្មុយនិស្តកម្ពុជា ។

**ស៊្ទីវ ហេឌ័រ និង ប្រាយ៉ាន់ ធីធីម័រ**

# ពាក្យស្លោកខ្មែរក្រហម

◆ កម្ចាត់ជាច់ខាតភ្នាក់ងារយួនឈ្លានពានខាតធីធឹកដី ឱ្យអស់ពីអង្គការភាពនិងទឹកដីកម្ពុជាជារៀងរហូត។

◆ កម្ចាត់ជាច់ខាត ចំហររណបគេ ខ្ញុំគេ សារភាពនិយម ចុះចាញ់និយម។

◆ ប្រយុទ្ធជាច់ខាត ការពារឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពដែនដីកម្ពុជាប្រជាធិបតេយ្យ។

(ពាក្យស្លោក១៧មេសា ១៩៧៨)

# នយោបាយអន្តរការណ៍និងយុត្តិធម៌នៅកម្ពុជា

ប្រជាជនខ្មែរនៅទីក្រុងភ្នំពេញនៅក្នុងខែមិថុនា ឆ្នាំ២០០៣ មន្ត្រីផ្លូវការនៃរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានព្រមព្រៀងគ្នាបង្កើតតុលាការខ្មែរក្រហមមួយដែលទន្ទឹងរង់ចាំអស់រយៈពេលជាយូរមកហើយ ។ ជំហានចុងក្រោយតែមួយគត់ដើម្បីធ្វើឲ្យតុលាការនេះក្លាយជាការពិត គឺការផ្តល់សច្ចាប័នដោយរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាដែលត្រូវបានគោរពយ៉ាងទូលំទូលាយ ។ អស់រយៈពេលជិតប្រាំបួនខែ ផែនការទាំងឡាយសម្រាប់តុលាការខ្មែរក្រហមត្រូវគាំងដំណើរការជាថ្មីម្តងទៀតដោយសារមានការតវ៉ាអំពីលទ្ធផលបោះឆ្នោតកាលពីខែកក្កដាឆ្នាំ២០០៣ ។ នៅក្នុងខែកក្កដា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រកាសថា គណបក្សប្រជាជនឈ្នះ៧៣កៅអីក្នុងចំណោមកៅអីទាំងអស់១២៣នៅក្នុងរដ្ឋសភាជាតិ នៅខ្វះតែបន្តិចនឹងទទួលបានសំឡេងពីរភាគបីដើម្បីបង្កើតរដ្ឋាភិបាលមួយដោយខ្លួនឯង ។ គណបក្សសមរង្ស៊ីជាគណបក្សប្រឆាំងនិងគណបក្សហ៊្វុនស៊ិនប៉ិចជាគណបក្សរាជានិយម ដែលនីមួយៗទទួលបានប្រហែល២០ភាគរយនៃកៅអីទាំងអស់ បានបង្កើតសម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យមួយ ហើយបដិសេធមិនចូលរួមបង្កើតរដ្ឋាភិបាលថ្មីសម្រាប់ប្រទេសកម្ពុជាទេ ។ គណបក្សទាំងពីរបានចោទបកាន់ថាមានអំពើបន្លំសន្លឹកឆ្នោតហើយទាមទារឲ្យគណបក្សប្រជាជនទទួលយកដំណោះស្រាយត្រីភាគីដោយគ្មានសម្តេចហ៊ុន សែន ជាមេដឹកនាំ ។ គណបក្សប្រជាជនជំទាស់ ។ ទើបតែថ្មីៗនេះដែលយើងសង្កេតឃើញថាទំនាក់ទំនងរវាងគណបក្សហ៊្វុនស៊ិនប៉ិចនិងគណបក្សប្រជាជនបោះជំហានទៅមុខដែលហាក់បីដូចជាអាចត្រួសត្រាយផ្លូវសម្រាប់ការបង្កើតរដ្ឋសភាមួយសាជាថ្មី ។

ដូចបញ្ហាជាច្រើនផ្សេងទៀត តុលាការខ្មែរក្រហមត្រូវគាំងដំណើរដោយសារវិបត្តិនយោបាយនៅភ្នំពេញ ។ អ្នកគាំទ្រតុលាការខ្មែរក្រហមអាចត្រឹមតែសង្ឃឹមថាភាពអន្ទះសាររបស់ប្រជាជននិងការព្រួយបារម្ភដែលថា "មនុស្សពូកែ" មួយរូបនឹងលេចមុខឡើងនៅក្នុងឆាកនយោបាយកម្ពុជា និងជំរុញឲ្យគណបក្សនយោបាយធំៗជ្រើសយកដំណោះស្រាយឆាប់រហ័សមួយ ។ នយោបាយប្រទេសកម្ពុជានៅតែបន្តទទួលផលវិបាកនៃការមិនចុះសម្រុងគ្នារវាងគណបក្សកាន់អំណាចនិងគណបក្សប្រឆាំងធំៗ ។ អន្តរការណ៍នយោបាយរបស់ប្រទេសកម្ពុជាឆ្នាំ២០០៣-០៤ មានអំពើហិង្សានិងភាពចលាចលតិចតួចជាងកាលពីឆ្នាំ១៩៩៧-៩៨ ។ ទោះជាយ៉ាងណា អន្តរការណ៍នេះបញ្ជាក់ថា យុត្តិធម៌នៅក្នុងប្រទេសកម្ពុជាគឺមិនមែនគ្រាន់តែជាការកាន់ទុក្ខចំពោះអតីតកាលប៉ុណ្ណោះទេ ។ សូម្បីតែតុលាការខ្មែរក្រហមដែលនឹងកាត់សេចក្តីចំពោះឧក្រិដ្ឋកម្មផ្សេងៗរវាងឆ្នាំ១៩៧៥និង១៩៧៩ ក៏ត្រូវបានផ្សារភ្ជាប់យ៉ាងស្អិតល្មួតទៅនឹងការទាមទារឲ្យមានយុត្តិធម៌ សិទ្ធិមនុស្ស និងនយោបាយក្នុងពេលបច្ចុប្បន្ន ។ ដូចតុលាការផ្សេងដែលមានទម្រង់ប្រហាក់ប្រហែលគ្នា អង្គជំនុំជម្រះពិសេសដែលបានស្នើឡើងមានសភាពស្រដៀងគ្នាទៅនឹងតុលាការព្រហ្មទណ្ឌ "ទូទៅ" ប៉ុន្តែអាចរងឥទ្ធិពលនយោបាយដោយចៀសពុំរួច ។ ទោះជាអ្នកស្មាតស្មុំផ្នែកច្បាប់និងសីលធម៌ មិនពេញចិត្តនឹងចំណុចនេះក៏ដោយ តុលាការសំខាន់ប្រភេទនេះនៅក្នុងប្រទេសផ្សេងតែងតែមានគោលបំណងជួយសម្រួលដល់អន្តរការណ៍នយោបាយក៏ដូចជាផ្តល់យុត្តិធម៌ចំពោះបទល្មើសផ្សេងៗដែលបានកើតឡើងជានិច្ច ។

## សេចក្តីផ្តើម

ខ្ញុំនឹងព្យាយាមបកស្រាយអំពីសញ្ញាណនៃយុត្តិធម៌សម័យអន្តរកាលនៅក្នុងប្រទេសកម្ពុជាតាមរយៈការវិភាគទៅលើ "អន្តរការណ៍"សង្គមសេដ្ឋកិច្ចនិងនយោបាយដែលសហគមន៍ជាតិនិងអន្តរជាតិទាំងឡាយដោះស្រាយតាមរយៈនីតិវិធីច្បាប់ ដាក់ឲ្យមានការទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋកម្មទាំងឡាយដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ដូចនៅក្នុងប្រទេសកំពុង

អភិវឌ្ឍន៍ជាច្រើននៅលើពិភពលោក ប្រយោជន៍នយោបាយសំខាន់ៗ ហាក់ទេរទៅរកការពុំសូវព្យាយាមទាមទាររកយុត្តិធម៌ "ចំពោះការខូចខាត" នៃសង្គមស៊ីវិលនិងយុត្តិធម៌ "ចំពោះការបែងចែក(ទ្រព្យ)" (យុត្តិធម៌ដែលសហគមន៍មួយមិនបានផ្តល់ដល់សមាជិក រួមទាំងការបែងចែកដោយយុត្តិធម៌នូវផលប្រយោជន៍រួមនិងទទួលបន្ទុករួម) ។ ច្បាស់លាស់ណាស់ សម័យកម្ពុជាប្រជាធិបតេយ្យមានការជាប់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋធ្ងន់ធ្ងរ ក៏ដូចជាការប្រព្រឹត្តទោសពៃរ៍ផ្នែកស៊ីវិលដែលរួមចំណែកជាមួយហេតុផលផ្សេងទៀតឲ្យមានការបែងចែកធនធាន "មិនយុត្តិធម៌" ។ ការផ្តល់ជូននូវយុត្តិធម៌ "ពេញលេញ" ទៅជនរងគ្រោះនៃរបបខ្មែរក្រហមតម្រូវឲ្យមានល្បាយនៃយន្តការទាមទារសងការឈឺចាប់និងការខូចខាត ។

ទោះបីជាមានបទល្មើសព្រហ្មទណ្ឌនិងរដ្ឋប្បវេណីជាច្រើនកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដំណើរការ "យុត្តិធម៌សម័យអន្តរកាល" ដែលបានកំណត់ទ្រង់ទ្រាយដោយភាគីជាតិនិងអន្តរជាតិ មានអំណាចមានអារម្មណ៍ទៅលើការរៀបចំឲ្យមានសុវត្ថិភាពក្នុងរបបដឹកនាំនិងបំពេញតាមគំនិតជាមូលដ្ឋាននៃសាធារណជន ជាជាងធ្វើឲ្យមានឥទ្ធិពលទៅលើការកែប្រែសង្គមដែលមានប្រយោជន៍ទូលំទូលាយ ។ តុលាការខ្មែរក្រហមត្រូវបានរៀបចំឡើងដើម្បីកាត់ទោសតែអតីតមេដឹកនាំកំពូលរបស់របបកម្ពុជាប្រជាធិបតេយ្យនៅក្នុងអ្វីដែលប្រវត្តិវិទូ ស៊ីហ៊ិន ហេឌ័របានហៅថាជា "ណាហ្ស៊ីខុបនីយកម្ម" នៃរបបខ្មែរក្រហម ។ ជនល្មើសធ្ងន់ធ្ងរជាច្រើននូប ក្នុងនោះមានបុគ្គលខ្លះមានទំនាក់ទំនងជាមួយរដ្ឋាភិបាលបច្ចុប្បន្នត្រូវបានកាត់ចេញពីបញ្ជី ដោយមូលហេតុរក្សាស្ថិរភាពនយោបាយនិងការពារកុំឲ្យរបបបច្ចុប្បន្នបាត់បង់ ។ គ្មានការព្យាយាមសងការខូចខាតដល់ជនរងគ្រោះក្នុងទ្រង់ទ្រាយណាមួយទាល់តែសោះ សូម្បីតែក្នុងទម្រង់ដ៏តូចបំផុតក៏គ្មានដែរ ។ រឿងក្តីនៃប្រទេសកម្ពុជាមិនមែនខុសប្លែកពីប្រទេសដទៃទាំងស្រុងនោះទេ ។ ទោះបីជារដ្ឋជាក់លាក់មួយចំនួនដូចជាអាល្លឺម៉ង់និងឈីលី បានព្យាយាមផ្តល់បដិទានឬសងការឈឺចាប់ដល់ជនរងគ្រោះនៃអំពើហិង្សាពីអតីតកាល យន្តការនៃយុត្តិធម៌សម័យអន្តរកាលភាគច្រើនបានអើពើចំពោះអយុត្តិធម៌សេដ្ឋកិច្ច ហើយបានបង្កើតអតីតកាលនៅក្នុងទម្រង់មួយដែលបង្ហាញអំពីអំពើហិង្សានិងជំងឺនយោបាយមកជំនួសវិញ ។ ខាងក្រោមនេះគឺជាការបកស្រាយអំពីហេតុផលដោយលើកយកប្រទេសកម្ពុជាមកធ្វើជាឧទាហរណ៍ ។

## ពន្យល់អត្ថន័យនៃពាក្យ "អន្តរការណ៍" និង "យុត្តិធម៌"

នៅក្នុងប្រទេសកម្ពុជានិងនៅកន្លែងផ្សេង "យុត្តិធម៌សម័យអន្តរកាល" គឺជាទស្សនៈដ៏ស្មុគស្មាញនិងពោរពេញទៅដោយភាពចម្រូងចម្រាស់ ។ យើងតែងភ្ជាប់ពាក្យនេះទៅនឹងដំណើរការច្បាប់ឬពាក់កណ្តាលច្បាប់នៅក្នុងសង្គមទាំងឡាយ ដែលបានឆ្លងកាត់បម្លាស់ប្តូរនយោបាយលឿនពេក ហើយព្យាយាមស្វែងរកដំណោះស្រាយចំពោះវិបត្តិនៃរបបមុន ។ ការធ្លាក់ចុះនៃសហភាពសូវៀតនិងការរលំរលាយដោយផ្នែកនៃទម្រង់មិនប្រកាន់បក្សសម្ព័ន្ធនៃសង្គ្រាមត្រជាក់រួមជាមួយនិងកិច្ចខិតខំប្រឹងប្រែងថ្មីៗដឹកនាំដោយសហរដ្ឋអាមេរិកដើម្បីជះឥទ្ធិពលដល់បម្លាស់ប្តូររបបនយោបាយនៅក្នុង "រដ្ឋទុច្ចរិត" ខ្លះ បានធ្វើឲ្យយុត្តិធម៌សម័យអន្តរកាលក្លាយទៅជារឿងសាមញ្ញនាពេលបច្ចុប្បន្ន ។ ប៉ុន្តែដំណើរការដែលពាក្យ "យុត្តិធម៌សម័យអន្តរកាល" មានបំណងនឹងគ្រសោបនោះគឺមានអាយុចាស់ដូចប្រវត្តិរបស់មនុស្សជាតិខ្លួនឯងដែរ ។ ពីយុគសម័យបេប៊ីឡូនមកទល់សម័យសង្គ្រាមនៅបាកដាត បម្លាស់ប្តូរនយោបាយត្រូវបានអនុវត្តឡើងជាមធ្យោបាយដើម្បីសម្រេចនូវសញ្ញាណខុសៗគ្នានៃយុត្តិធម៌ ។ ដំណើរការជាផ្លូវការឬមិនផ្លូវការតែងតែអមដំណើរបម្លាស់ប្តូរទាំងឡាយ ដើម្បីកែតម្រូវកំហុសពីអតីតកាលនិងបញ្ជាក់អំពីសុពលភាពផ្នែកច្បាប់នៃរបបដឹកនាំថ្មី ។

នៅក្នុងករណីជាច្រើន ដំណើរការនៃយុត្តិធម៌សម័យអន្តរកាលបានកើតឡើងបន្ទាប់ពីការដួលរលំនៃរបបចាស់ ។ នៅក្នុងប្រទេសកម្ពុជា បញ្ហានយោបាយនិងយុត្តិសាស្ត្របានរាំងស្ទះដល់ការការពារកលូតលាស់នៃយុត្តិធម៌សម័យអន្តរកាលអស់រយៈពេលជិត២០ឆ្នាំ ។ ភ្លាមៗក្រោយពីការឈ្លានពានរបស់ប្រទេសវៀតណាមមកលើប្រទេសកម្ពុជា ការកាត់ទោសកំបាំងមុខចំពោះ ប៉ុល ពត និង អៀង សារី បានបញ្ជាក់អំពីកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលវៀតណាមនិងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងការប្រកាសអំពីអន្តរការណ៍នយោបាយស្របច្បាប់

តាមរយៈការផ្តល់យុត្តិធម៌ ។ ទោះជាយ៉ាងណាក៏ដោយប្រជាជនភាគច្រើននិងសហគមន៍អន្តរជាតិមិនបានទទួលស្គាល់តុលាការប្រជាជនបដិវត្តន៍នៃឆ្នាំ១៩៧៩បង្កើតឡើងដើម្បីកាត់ទោស "បន ប៉ុល ពត អៀង សារី"នោះទេ។ មូលហេតុគឺថា តុលាការនេះហាក់បីដូចជាបានផ្តល់"យុត្តិធម៌"មិនពេញលេញ ។ តុលាការប្រជាជនមិនបានស្តាប់ការទាញហេតុផលរបស់ចុងចោទ ហើយបានកាត់ទោសប្រហារជីវិតអតីតមេដឹកនាំរបបចាស់ដោយកំបាំងមុខ ។ លើសពីនេះ តុលាការនេះមិនបានចេញសាលក្រមគួរឲ្យជឿទុកចិត្តបានសម្រាប់មន្ត្រីខ្មែរក្រហមដែលបានគាំទ្រថ្នាក់ដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងកម្រិតជាតិ តុលាការបដិវត្តន៍មិនបានផ្តល់យុត្តិធម៌ដល់ជនរងគ្រោះបន្តិចណាសោះ ។

បញ្ហាមួយទៀតរបស់តុលាការបដិវត្តន៍ឆ្នាំ១៩៧៩គឺវាមិនបានផ្សារភ្ជាប់ទៅនឹងអន្តរការណ៍នយោបាយមួយដែលបានគាំទ្រដោយប្រជាជនកម្ពុជាជាច្រើននាក់និងសហគមន៍អន្តរជាតិភាគច្រើន ។ ទោះបីជាមានឧក្រិដ្ឋកម្មសែនរន្ធត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ប្រជាជនកម្ពុជាភាគច្រើនមិនបានស្វាគមន៍ចំពោះវត្តមានកងទ័ពវៀតណាមនៅក្នុងទឹកដីរបស់ខ្លួននិងរដ្ឋាភិបាលថ្មីដែលគាំទ្រដោយវៀតណាមឡើយ ។ ខ្មែរក្រហមដែលបានដកថយទៅកាន់ភាគពាយ័ព្យប្រទេសហើយបានធ្វើសង្គ្រាមឈ្លបអូសបន្លាយពេលដ៏យូរ បានបដិសេធយ៉ាងច្បាស់ក្រឡែតនូវអន្តរការណ៍នយោបាយនៅក្នុងប្រទេសក៏ដូចជាសម្តេចព្រះ នរោត្តម សីហនុ ដ៏មានប្រជាប្រិយភាពនិងកងកម្លាំងសាធារណរដ្ឋស្តាំនិយមរបស់កម្ពុជានៅសល់ពីរបប លន់ ណុល ។ នៅលើឆាកអន្តរជាតិ មានតែវៀតណាម សហភាពសូវៀត និងសម្ព័ន្ធមិត្តជិតស្និទ្ធបំផុតរបស់ប្រទេសទាំងពីរប៉ុណ្ណោះ ដែលទទួលស្គាល់ការឈ្លានពានស្របច្បាប់ ។ ប្រទេសថៃ ចិន សាំងហ្គាពួរ ម៉ាឡេស៊ី បារាំង ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក បានដឹកនាំមតិអន្តរជាតិភាគច្រើនលើសលុបប្រឆាំងនឹងការឈ្លានពាន ហើយរិះគន់តុលាការឆ្នាំ១៩៧៩ថាជា"តុលាការសម្រាប់បង្ហួត"បម្រើផលប្រយោជន៍នយោបាយ ។

ចំណុចដែលត្រូវលើកឡើងនោះគឺថា ការលំបាកក្នុងការកំណត់អត្ថន័យនៃ"យុត្តិធម៌សម័យអន្តរកាល"មានប្រភពមកពីសញ្ញាណប្រទូសរ៉ាយគ្នានៃ"យុត្តិធម៌" ។ ការខ្វែងគំនិតគ្នាក៏លេចចេញពីភាពមិននឹងនរនៃអន្តរការណ៍នយោបាយ នៅក្នុងសង្គមដែលទាមទាររកយុត្តិធម៌ភាគច្រើនដែរ ។ តើបម្លាស់ប្តូរនយោបាយនិងសង្គមបែបណាដែលដំណើរការស្វែងរកយុត្តិធម៌ ជំរុញ និងជួយសម្រុះសម្រួល? សំណួរនេះគឺត្រូវបានផ្សារភ្ជាប់យ៉ាងស្អិតល្អួតទៅនឹងនិយមន័យនៃពាក្យ "យុត្តិធម៌" ដែលសហគមន៍ជាតិនិងអន្តរជាតិជ្រើសរើស ។ ខ្ញុំសូមទាញហេតុផលថា នៅក្នុងករណីជាច្រើន អង្គភាពជាតិនិងអន្តរជាតិដែលមានអំណាចតែងតែព្យាយាមកំណត់នូវអ្វីដែលបង្កជា"យុត្តិធម៌សម័យអន្តរកាល" តាមវិធីមួយដែលជួយជំរុញដោយផ្ទាល់និងដោយប្រយោលដល់ការគ្រប់គ្រងនៅពេលអនាគតឬបច្ចុប្បន្នទៅលើរដ្ឋាភិបាលថ្មីនិងធនធានរបស់រដ្ឋនោះ ។

នៅក្នុងករណីខ្លះ តួអង្គដែលមានអំណាចផ្តោតការយកចិត្តទុកដាក់តែទៅលើផ្នែកយុត្តិធម៌"ចំពោះការឈឺចាប់" ហើយចាប់អារម្មណ៍តិចតួចស្ទួចស្តើងទៅលើសមាជិកនៃការដឹកនាំមុនដែលត្រូវបានផ្តួលរំលំ ។ នៅក្នុងករណីផ្សេងទៀត វិធានការដែលបានជ្រើសរើសយកមិនមែនដើម្បីសងការខូចខាតទេ ប៉ុន្តែវាបន្តជាប់ពាក់ព័ន្ធជាពិសេសជាមួយទោសពៃរ៍នយោបាយនិងឧក្រិដ្ឋកម្មពីអតីតកាល ។ ការវាយប្រហារទៅលើរបបដឹកនាំមុន ជួយកសាងគុណសម្បត្តិឲ្យរដ្ឋាភិបាលថ្មីក្នុងនាមជាភាគីប្រឆាំងនឹងរបបចាស់និងក្នុងនាមជាអ្នកដឹកនាំស្របច្បាប់នៃរបបថ្មី។ ផ្ទុយទៅវិញ របបដឹកនាំថ្មីៗនិងអ្នកគាំទ្រអន្តរជាតិតែងមើលស្រាលចំពោះយុត្តិធម៌ស៊ីវិលនិងយុត្តិធម៌ចំពោះការបែងចែកទ្រព្យដែលតែងតែគំរាមកំហែងដល់តំណែងរបស់អ្នកដឹកនាំថ្មីជាម្ចាស់ធនធានរដ្ឋតែមួយគត់ ។

ដូច្នេះ "យុត្តិធម៌សម័យអន្តរកាល" ជួនកាលអាចច្រឡំនឹង "ការលុបលាងកំហុសសម័យអន្តរកាល" ។ ការណ៍នេះពុំមែនមានន័យថានយោបាយអន្តរកាលនឹងជះឥទ្ធិពលអាក្រក់ទៅលើសង្គមទូទៅនោះទេ ប៉ុន្តែវាប្រាកដជាជួយពន្យល់ថាហេតុអ្វីបានជា "យុត្តិធម៌សម័យអន្តរកាល" តែងតែចាប់អារម្មណ៍ទៅលើជនដែលមានឋានន្តរស័ក្តិខ្ពស់ ហើយសុខចិត្តលះបង់ចោលនូវយុត្តិធម៌ស៊ីវិលនិងការបែងចែកទ្រព្យ ។ ការធ្វើដូចនេះអាចនាំមកនូវដំណើរ

ការដែលពុំអាចជម្រះបញ្ហាធំនៃភាពអយុត្តិធម៌សម្រាប់ជនរងគ្រោះភាគច្រើន ។

## បទពិសោធន៍នៃភាពអយុត្តិធម៌មុនសម័យអន្តរកាល

នៅពេលដែលមនុស្សម្នាក់រិះគិតអំពីលក្ខណៈដែលនាំទៅរកការទាមទារ"យុត្តិធម៌សម័យអន្តរកាល" អ្នកនោះតែងតែនឹកគិតពីអំពើហិង្សានិងឧក្រិដ្ឋកម្ម ។ នៅក្រោយសង្គ្រាមលោកលើកទីពីរ កេរ្តិ៍ឈ្មោះរបស់លោកខាងលិចបានជិតដាមទៅដោយអំពើប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វ ។ រូបភាពនៃការធ្វើទារុណកម្ម ការឃុំឃាំង និងការប្រហារជីវិតដោយពុំបានកាត់សេចក្តី តែងតែបន្តឲ្យមានការរំជួលអារម្មណ៍ខ្លាំងនិងបន្តឲ្យមានការប្រកាសទាមទាររក"យុត្តិធម៌"ពីក្រៅប្រទេស ។ នៅក្នុងសម័យអន្តរកាល វាមានសារសំខាន់ណាស់ថា ជនទាំងឡាយដែលមានការទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គួរត្រូវនាំឡើងតុលាការ ។ ទោះជាយ៉ាងណាក៏ដោយ វាជាការចាំបាច់ដើម្បីរំឭកថា សម្រាប់ជនរងគ្រោះភាគច្រើន បទពិសោធន៍ផ្ទាល់ខ្លួននៃភាពអយុត្តិធម៌មានកម្រិតហួសឆ្ងាយពីការរំលោភបំពានព្រហ្មទណ្ឌរបស់របបដែលបានផ្តួលរំលំ និងមេដឹកនាំនៃរបបនោះទៅទៀត ។ ការខូចខាតផ្នែកសេដ្ឋកិច្ចនិងអំពើហិង្សាក្នុងស្រុកជាផលវិបាកដែលតែងតែកើតមាននៅក្នុងសង្គមដែលមានវិបត្តិ ។

ប្រទេសកម្ពុជាជាឧទាហរណ៍ដ៏ល្អមួយ ។ តាំងតែពីឆ្នាំ១៩៧៩ នៅពេលដែលខ្មែរក្រហមត្រូវបានរុញចេញពីអំណាច ទីតាំងរូបវ័ន្តពីរបានក្លាយទៅជានិមិត្តរូបនៃអំពើហិង្សារបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ទីតាំងទីមួយគឺ"វាលពិឃាត"នៅជើងឯក ចម្ងាយប្រហែល១៥គីឡូម៉ែត្រខាងត្បូងទីក្រុងភ្នំពេញ ជាកន្លែងដែលជនរងគ្រោះជិត២ម៉ឺននាក់ត្រូវបានបណ្តើរជាជួររួចវាយទម្លាក់ម្តងមួយៗ ទៅក្នុងរណ្តៅរាប់សិបដែលបានជីករួចជាស្រេច ។ ទីតាំងទីពីរគឺអតីតគុកទួលស្លែង ។ មុនរបបខ្មែរក្រហម ទីតាំងនេះជាអនុវិទ្យាល័យ ។ មកដល់របបខ្មែរក្រហមទីតាំងនេះជាការិយាល័យសន្តិសុខកណ្តាលនៃបក្សកុម្មុយនិស្តកម្ពុជា ។ វាត្រូវបានស្គាល់ជាទូទៅថាជា "មន្ទីរស-២១" ។ វាបានក្លាយទៅជាទីតាំងសម្រាប់ឃុំឃាំង សួរចម្លើយ និងធ្វើទារុណកម្ម ជនដែលត្រូវបានចោទថាជាសត្រូវនៃអង្គការ មុនពេលដែលអ្នកទាំងនោះត្រូវយកទៅប្រហារជីវិតនៅវាលពិឃាតជើងឯក ។ លលាដ៍សពនៅជើងឯកនិងរូបថតអ្នកទោសនៅគុកទួលស្លែង ដែលក្នុងនោះមានទាំងស្ត្រី កុមារ និងមនុស្សចាស់ គឺជាតឹកតាងដ៏ល្បីល្បាញនិងគួរឲ្យខ្លាចបំផុត ដែលបញ្ជាក់អំពីការរំលោភបំពាននៃរបបកម្ពុជាប្រជាធិបតេយ្យ ។

រូបភាពជាច្រើននៃអំពើ"ប្រល័យពូជសាសន៍"ដែលថតនៅជើងឯក ទួលស្លែង និងទីតាំងផ្សេងទៀតនៅក្នុងប្រទេសកម្ពុជាបានជួយលើកកម្ពស់ការចាប់អារម្មណ៍ពីសាកលអន្តរជាតិឲ្យមានតុលាការព្រហ្មទណ្ឌមួយនៅក្នុងប្រទេសកម្ពុជា ។ ទោះជាយ៉ាងណាក៏ដោយ អំពើហិង្សាជាលក្ខណៈប្រព័ន្ធទាំងនេះតំណាងឲ្យផ្នែកដ៏តូចមួយប៉ុណ្ណោះនៃភាពអយុត្តិធម៌ទាំងអស់ដែលប្រជាជនកម្ពុជាទទួលរងរវាងឆ្នាំ១៩៧៥និង១៩៧៩ ។ ញត្តិជាង១លានច្បាប់របស់ជនរងគ្រោះដែលនៅរស់រានមានជីវិត ដែលប្រមូលនៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ និងការសម្ភាសន៍រាប់ពាន់ករណីនៅតាមតំបន់ធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាតាំងពីឆ្នាំ១៩៩៥ បង្ហាញថា ជនរងគ្រោះភាគច្រើននៃរបបខ្មែរក្រហមយល់ដឹងតិចតួចអំពីមេដឹកនាំនៃរបបនេះ ។ ប្រព័ន្ធទូរគមនាគមន៍អន់ថយ កម្រិតអនក្ខរកម្មខ្ពស់ និងការហាមឃាត់មិនឲ្យធ្វើដំណើរទៅណាមកណាដោយសេរី បានបង្កជាបទពិសោធន៍មួយដែលមានលក្ខណៈខុសៗគ្នាសម្រាប់អ្នកនៅរស់ ។ ប្រជាជនកម្ពុជាភាគច្រើនបានទទួលរងការរំលោភបំពាននៅក្នុងសហករណ៍ភូមិ ត្រូវបានហាមប្រាមមិនឲ្យរៀនសូត្រ ស្នាក់នៅសមរម្យ បរិភោគគ្រប់គ្រាន់ មិនមានជំនឿសាសនា និងមិនមានសិទ្ធិជួបជុំគ្រួសារនិងរៀបអាពាហ៍ពិពាហ៍ដោយខ្លួនឯង ។

ផ្នែកមួយនៃការឈឺចាប់នោះគឺ ប្រជាជនកម្ពុជាទូទៅបានទទួលរងភាពអយុត្តិធម៌ធ្ងន់ធ្ងរផ្នែកសេដ្ឋកិច្ច ។ បន្ទាប់ពីការ"រំដោះ"ទីក្រុងភ្នំពេញ ខ្មែរក្រហមបានអនុវត្តនូវការជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុង ។ ប្រជាជនរាប់លាននាក់ត្រូវបានបណ្តេញចេញពីផ្ទះសម្បែង បង្ខំឲ្យបោះបង់ចោលទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងត្រូវបំបែកចេញពីក្រុមគ្រួសារ ។ ក្រដាសប្រាក់ត្រូវបានបោះបង់ចោលលែងប្រើការ ហើយទ្រព្យសម្បត្តិរូបវ័ន្តត្រូវបាន

រឹបអូសដោយអង្គការនិងដាក់ជាសម្បត្តិរួម ។ ចលនទ្រព្យសេដ្ឋកិច្ចដែលបានសន្សំរាប់ជំនាន់មកហើយ ត្រូវសាបសូន្យក្នុងមួយប៉ព្រិចភ្នែក ។ ការខាតបង់ខាងសេដ្ឋកិច្ចសម្រាប់គ្រួសារនីមួយៗនិងសហគមន៍ទូទៅមានកម្រិតខ្ពស់ ។ អ្នកនៅរស់រានមានជីវិតភាគច្រើនមិនអាចស្តារឡើងវិញនូវអ្វីដែលបានបាត់បង់ទៅទេ ហើយប្រជាជនជាច្រើនបានបាត់បង់មធ្យោបាយទ្រទ្រង់សេដ្ឋកិច្ចគ្រួសារដោយសារតែការបាត់បង់សមាជិកគ្រួសារ ។ លើសពីនេះទ្រព្យសម្បត្តិដែលបានរឹបអូសយកទៅ ភាគច្រើននៅតែស្ថិតក្នុងដៃមន្ត្រីរដ្ឋាភិបាលក្រោយឆ្នាំ១៩៧៩ ។ ការផ្តល់«យុត្តិធម៌»ទៅឲ្យជនរងគ្រោះត្រូវរួមបញ្ចូលទាំងសំណងការបាត់បង់និងការឈឺចាប់របស់ប្រជាជន ។ ការធ្វើដូចនេះអាចយកទៅអនុវត្តនៅក្នុងសង្គមអន្តរកាលផ្សេងទៀតដែរ ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ពោលគឺប្រទេសអាហ្វ្រិកខាងត្បូង ហ្កាតេម៉ាឡា រ៉ាន់ដា ប៉េរូ ទីម័រខាងកើត តំបន់បាល់កង់ សេរ៉ាឡេអូន ហើយថ្មីៗនេះទៀតគឺអាហ្វហ្កានីស្ថាននិងអ៊ីរ៉ាក់ ។

## ទ្រឹស្តីរដ្ឋប្បវេណីនិងព្រហ្មទណ្ឌចំពោះយុត្តិធម៌សម័យអន្តរកាល

ទោះនៅក្នុងសម័យវិកវរឬនឹងនក៏ដោយ ស្ទើររាល់ប្រព័ន្ធច្បាប់ទំនើបស្វែងរកយុត្តិធម៌ចំពោះការខូចខាតនិងការឈឺចាប់តាមរយៈប្រព័ន្ធច្បាប់និងការជំនុំជម្រះផ្សេងៗគ្នា ។ និយាយរួម យុត្តិធម៌ចំពោះការឈឺចាប់ត្រូវបានផ្តល់តាមរយៈប្រព័ន្ធព្រហ្មទណ្ឌដោយយករដ្ឋមកតទល់ជាមួយនឹងបុគ្គលឬក្រុមមួយដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសប្រឆាំងនឹងសាធារណជនទូទៅ ។ ផ្ទុយទៅវិញ យុត្តិធម៌ចំពោះការខូចខាតតែងតែត្រូវបានទាមទារតាមរយៈអ្វីដែលប្រព័ន្ធច្បាប់អង់គ្លូសាក់សុងឲ្យឈ្មោះថាជាប្រក«ស៊ីវិល» ។ រឿងក្តីរដ្ឋប្បវេណីជារឿងទាក់ទងនឹងភាគីមិនមែនរដ្ឋពីរ អាចជាបុគ្គលឬអង្គភាព ហើយជាធម្មតាត្រូវបានរៀបចំឡើងដើម្បីសងការខូចខាតដល់ភាគីដែលទទួលរងការរំលោភបំពាន ។ មានតែនៅក្នុងករណីពិសេសទេ ដូចជាច្បាប់លហុរបស់អាមេរិក ទើបការសងជំងឺចិត្តត្រូវបានភ្ជាប់ជាមួយនឹងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ដែលហាក់ដូចជាបង្ហាញអំពីសំណងការឈឺចាប់ខ្លះៗ ។

និតិវិធីរដ្ឋប្បវេណីឬព្រហ្មទណ្ឌតែមួយមិនអាចផ្តល់ទម្រង់«ពេញលេញ»នៃយុត្តិធម៌ទៅឲ្យជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការធ្វើទារុណកម្ម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានទេ ។ យុត្តិធម៌រដ្ឋប្បវេណីអាចផ្តល់ឲ្យនូវសំណងការខូចខាតជាប្រាក់កាសសម្រាប់បទល្មើសខ្លះ ប៉ុន្តែខ្វះខាតការរិះគន់ពីសង្គមចំពោះបទល្មើស ការហាមប្រាមមិនឲ្យកើតឡើងជាថ្មី និងការដាក់ទណ្ឌកម្មចំពោះបទឧក្រិដ្ឋ ។ យ៉ាងណាមិញ សេចក្តីវិនិច្ឆ័យព្រហ្មទណ្ឌមួយក៏មិនអាចដោះស្រាយចំពោះការបាត់បង់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះជាច្រើនដែលបានបាត់បង់សុភមង្គលគ្រួសារដោយសារការដឹកនាំចាស់បានដែរ ។ នៅក្នុងប្រទេសកម្ពុជា អតីតមេដឹកនាំខ្មែរក្រហមមួយចំនួនរស់នៅក្នុងគេហដ្ឋានធំទូលាយ នៅពេលដែលជនរងគ្រោះរាប់លាននាក់បន្តចិញ្ចឹមជីវិតយ៉ាងលំបាកលំបិនតាមរយៈការធ្វើស្រែចម្ការនិងការប្រកបមុខរបរបានប្រាក់កម្រៃតិចតួច ។ អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី មានរថយន្តជាច្រើនគ្រឿងនិងគេហដ្ឋានដ៏ស្កឹមស្កៃមួយនៅក្នុងទីក្រុងភ្នំពេញ ចំណែកឯអតីតមេដឹកនាំផ្សេងទៀតដូចជា នួន ជា និង ខៀវ សំផន រស់នៅយ៉ាងសុខស្រួលនៅប៉ៃលិន ។ ទ្រព្យសម្បត្តិទាំងនេះជាលទ្ធផលនៃការធ្វើអាជីវកម្មមិនស្របច្បាប់ និងជំនួយថវិកាពីប្រទេសចិនដែលបានផ្តល់ឲ្យខ្មែរក្រហមពីពេលមុន ។

គួរឲ្យចម្លែកណាស់ មានតែជនជាប់សង្ស័យពីររូបប៉ុណ្ណោះគឺ ឌុច និង តាម៉ុក ដែលកំពុងជាប់ឃុំឃាំងតាំងពីឆ្នាំ១៩៩៩ រង់ចាំការកាត់សេចក្តីពីតុលាការ ។ មេដឹកនាំផ្សេងទៀតបានប្រើប្រាស់ប្រាក់កាស ឬបានចុះហត្ថលេខាទៅលើកិច្ចព្រមព្រៀងផ្នែកនយោបាយ ដើម្បីការពារខ្លួនពីការប្តឹងផ្តល់ផ្សេងៗនិងការជាប់ឃុំ ។ សូម្បីតែការកាត់ទោសដាក់ពន្ធនាគារយូរអង្វែងសម្រាប់អតីតមេដឹកនាំខ្មែរក្រហម ដូចជា អៀង សារី និង ខៀវ សំផន ក៏នឹងមិនផ្លាស់ប្តូរការពិតនៃភាពក្រីក្ររបស់អ្នកនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យបានដែរ ។ ករណីនេះពិតទាំងស្រុងនៅក្នុងប្រទេសមួយចំនួននៅអាមេរិកឡាទីននិងទ្វីបអាហ្វ្រិកដែលកំពុងងើបពីរបបដឹកនាំគាបសង្កត់ ។

ទោះបីជាមានអយុត្តិធម៌សេដ្ឋកិច្ចជាក់ស្តែងនៅក្នុងប្រទេស

កម្ពុជានិងសង្គមជាច្រើនផ្សេងទៀតក៏ដោយ នីតិវិធីច្បាប់អន្តរកាលមានទំនោរខ្លាំងទៅលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនៃអតីតមេដឹកនាំមុនៗ ។ នៅក្នុងករណីមួយចំនួន ដំណើរការនេះត្រូវបានផ្សារភ្ជាប់ទៅនឹងការកាត់ទោសព្រហ្មទណ្ឌជាផ្លូវការ ឯក្នុងពេលខ្លះគណៈកម្មការស្វែងរកការពិតបានព្យាយាមដាក់ឲ្យមានការទទួលខុសត្រូវដោយពុំចាំបាច់មានសំណង់ការឈឺចាប់ ។ មានតែរដ្ឋឬអង្គភាពអន្តរជាតិចំនួនតូចប៉ុណ្ណោះ ដែលបានពិចារណាអំពី «យុត្តិធម៌ចំពោះការខូចខាត» ដោយការបង្កើតស្ថាប័នផ្លូវការសម្រាប់ទទួលបណ្តឹងតវ៉ាផ្នែករដ្ឋប្បវេណី ការបែងចែកដីធ្លីម្តងទៀត និងការបែងចែកទ្រព្យធនសាជាថ្មីក្នុងទម្រង់ផ្សេងៗ ។ តាមពិត ការដោះស្រាយចំពោះអំពើខុសឆ្គងផ្នែករដ្ឋប្បវេណីនៅក្នុងបរិបទអន្តរកាលគឺពិបាកខ្លាំងណាស់ ។ ចំនួនដ៏ច្រើនលើសលប់នៃការរំលោភបំពាននឹងបង្កជាជម្រើសពិបាកៗ ក៏ដូចជាបញ្ហានៃប្រើប្រាស់ថវិការដ្ឋដែលក្រីក្រដែរទៅលើសំណងខូចខាតដែលមិនច្បាស់លាស់និងមានលក្ខណៈទូលំទូលាយពេក ។ ការពិតដែលត្រូវបានទទួលស្គាល់ស្វាត់ៗនោះគឺថា នៅក្នុងសង្គមអន្តរកាលជាច្រើន មិនមានមធ្យោបាយណាមួយអាចអនុវត្តបានដើម្បីដាក់ទណ្ឌកម្មចំពោះរាល់បុគ្គលដែលរំលោភសិទ្ធិមនុស្ស និងដើម្បី «ស្តារឡើងវិញ» នូវទ្រព្យសម្បត្តិដែលបានបាត់បង់នោះទេ ។

ការលំបាកខាងលើតែងតែត្រូវទទួលស្គាល់យ៉ាងងាយស្រួលនិងឆាប់រហ័ស ថាជាហេតុផលនៃការមិនស្វែងរកយុត្តិធម៌ចំពោះការខូចខាត ។ សូម្បីតែនៅក្នុងសង្គមទាំងឡាយដែលមានឆន្ទៈជំរុញឲ្យមានការផ្សះផ្សានិងរក្សាច្បាប់ទម្លាប់កំណែទម្រង់ដីធ្លីត្រឹមត្រូវ ការបែកចែកថវិការដ្ឋសាជាថ្មី និងសូម្បីតែតុលាការរដ្ឋបាលសាមញ្ញមួយដើម្បីទទួលបណ្តឹងរដ្ឋប្បវេណីចំពោះទ្រព្យនិងប្រាក់ចំណូលដែលបានបាត់បង់ ក៏ពិបាកធ្វើដែរ ។ នៅក្នុងសង្គមអន្តរកាលជាច្រើន ជនរងគ្រោះមួយភាគធំនឹងទទួលស្វាគមន៍និងគាំទ្រចំពោះការបង្កើតយន្តការសងការខូចខាតបែបនោះ ។ ក៏ប៉ុន្តែ រដ្ឋឬអង្គភាពអន្តរជាតិបានបង្កើតដំណើរការរបៀបនេះយ៉ាងកម្រនិងស្ទាក់ស្ទើរ ។ សរុបមក ដំណើរការសងការខូចខាតមិនបម្រើផលប្រយោជន៍សំខាន់ៗរយៈពេលខ្លី ក្នុងរូបរាងច្បាស់លាស់ ដូចតុលាការព្រហ្មទណ្ឌសម្រាប់កាត់ទោសមេដឹកនាំធំៗ ឬគណៈកម្មការស្វែងរកការពិតទេ ។

**ការធ្វើឲ្យស្របច្បាប់តាមរយៈការញែកឲ្យដាច់ៈ គុណសម្បត្តិនយោបាយនៃតុលាការនិងគណៈកម្មការស្វែងរកការពិត**

នីតិវិធីដាក់ឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឬការស៊ើបអង្កេតមិនព្រហ្មទណ្ឌទៅលើការប្រព្រឹត្តខុសផ្នែកនយោបាយនៃរបបដឹកនាំចាស់ ជួយរដ្ឋាភិបាលថ្មីនិងអ្នកគាំទ្ររដ្ឋាភិបាលនេះពង្រឹងកេរ្តិ៍ឈ្មោះនិងភាពស្របច្បាប់របស់ខ្លួនតាមរយៈការញែករបបថ្មីឲ្យដាច់ពីរបបដឹកនាំគាបសង្កត់ចាស់ ។ តុលាការព្រហ្មទណ្ឌផ្លូវការតែងតែកើតឡើងនៅក្នុងទីតាំងទាំងឡាយដែលតួអង្គអន្តរជាតិមានជាប់ពាក់ព័ន្ធខ្លាំង ហើយទាមទារឲ្យមានការកាត់ទោសព្រហ្មទណ្ឌនិងការចេញសាលក្រមតាមបែបលោកខាងលិច ។ រដ្ឋទាំងឡាយនៅលោកលិចបានជំរុញឲ្យមានតុលាការនៅក្នុងប្រទេសមួយចំនួនដូចជា រ៉្វាន់ដា អតីតយូហ្គោស្លាវី សេរ៉ាឡេអូន ទីម័រខាងកើត និងកម្ពុជា មួយផ្នែកដោយហេតុផលនៃការជឿជាក់ថាតុលាការបែបនោះនឹងមានប្រយោជន៍ដល់ការលើកកម្ពស់ការគោរពសិទ្ធិមនុស្ស មួយផ្នែកទៀតគឺដើម្បីបំពេញតាមការទាមទាររបស់ពលរដ្ឋខ្លួនទាំងនៅក្នុងនិងក្រៅប្រទេស ។ តុលាការទាំងនេះគាំទ្រចំពោះតម្លៃសេរីនិយម ប៉ុន្តែមានបំណងបង្ហាញការមិនពេញចិត្តជាអន្តរជាតិចំពោះរបបមុន សូម្បីតែនៅក្នុងករណីដែលតួអង្គអន្តរជាតិជាក់លាក់ខ្លះបានគាំទ្ររបបចាស់នៅក្នុងពេលដែលរបបនេះជិះជាន់ក៏ដោយ ។ តុលាការព្រហ្មទណ្ឌកាត់ទោសអតីតមេដឹកនាំ បង្កើតរបបថ្មីមួយដែលទទួលការគាំទ្រជាអន្តរជាតិថាជាអាជ្ញាធរស្របច្បាប់ និងជួយរដ្ឋាភិបាលឲ្យទទួលបានការគាំទ្រពីសាធារណជន តាមរយៈការបង្ហាញថាវាផ្តុយទាំងស្រុងទៅនឹងរបបដឹកនាំចាស់ ។

នៅក្នុងរដ្ឋមួយចំនួនដូចជាប្រទេសអាហ្វ្រិកខាងត្បូង និងប្រទេសកំពុងឆ្លងកាត់សម័យអន្តរកាលផ្សេងទៀតនៅអាមេរិកឡាទីន លក្ខខណ្ឌនយោបាយបានធ្វើឲ្យតុលាការព្រហ្មទណ្ឌផ្លូវការមិនគួរឲ្យចាប់អារម្មណ៍ ។ ការទាមទារឬការគាំទ្រមិនគ្រប់គ្រាន់ពីអន្តរជាតិ ឬតុល្យភាពមិនរឹងមាំនៃអំណាចនយោបាយនៅក្នុងប្រទេស បានជួយឲ្យគណៈកម្មការស្វែងរកការពិតក្លាយជាជម្រើសគួរទទួលយកចំពោះរដ្ឋាភិបាលថ្មីនៅក្នុងប្រទេសទាំង

នេះ ។ គណៈកម្មការស្វែងរកការពិតបង្ហាញថា តុលាការកាត់ទោសពិតជាជួយបម្រើដល់រដ្ឋាភិបាលថ្មី ។ យ៉ាងហោចណាស់ នៅក្នុងទ្រឹស្តី វាបង្កើតនូវការប្រថុយប្រថានតិចតួចថាភាគីដែលត្រូវគេចោទប្រកាន់នឹងវាយបកវិញចំពោះដំណើរការស្វែងរកយុត្តិធម៌ ។ គុណវិបត្តិដែលអាចមានរបស់គណៈកម្មការស្វែងរកការពិតក្នុងទស្សនៈនៃរបបថ្មីគឺថា វាអាចពិបាកក្នុងការ«គ្រប់គ្រង» ដោយសារមានអ្នកចូលរួមច្រើនដែលអាចជាសាក្សីនិងជាគោលដៅនៃការចោទប្រកាន់ ។

## នយោបាយនៃការតស៊ូដើម្បីយុត្តិធម៌របស់កម្ពុជា

នៅក្នុងប្រទេសកម្ពុជា គុណសម្បត្តិនយោបាយនៃការអនុវត្តដំណើរការដាក់ឲ្យមានការទទួលខុសត្រូវប្រឆាំងនឹងខ្មែរក្រហមត្រូវបានអបអរជាយូរយារមកហើយ ។ តុលាការនៅក្នុងឆ្នាំ១៩៧៩ បានបង្ហាញថា របបសាធារណរដ្ឋប្រជាមានិតកម្ពុជាដឹកនាំដោយ ហេង សំរិន និង ជា ស៊ីម បានព្យាយាមដាក់ខ្លួនឲ្យនៅឆ្ងាយពីខ្មែរក្រហម ហើយព្យាយាមធ្វើឲ្យរដ្ឋាភិបាលថ្មីស្របច្បាប់ ។ គួរកត់សម្គាល់ថា ភាពលំបាកវេទនាផ្នែកសេដ្ឋកិច្ចរបស់ប្រជាជនកម្ពុជាត្រូវបានអើពើ ។ រាល់អំពើហិង្សាទាំងអស់ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានបន្ទោសទៅលើមេដឹកនាំតែប៉ុន្មានរូបនៃបក្សកុម្មុយនិស្តកម្ពុជាប៉ុណ្ណោះ ។ តុលាការឆ្នាំ១៩៧៩ដែលត្រូវបានរិះគន់ទាំងក្នុងស្រុកនិងនៅបរទេស បានផ្តល់យុត្តិធម៌តិចតួចប៉ុណ្ណោះ ដោយសារមានទស្សនៈទូទៅថាតុលាការនេះជាឧបករណ៍នយោបាយសម្រាប់បម្រើផលប្រយោជន៍វៀតណាមនិងរបបថ្មី ។ ការពិតនេះបង្ហាញថា ដំណើរការយុត្តិធម៌សម័យអន្តរកាលអាចមានសារប្រយោជន៍តែចំពោះរបបថ្មីមួយប្រសិនបើយុត្តិធម៌នេះបានទទួលការទុកចិត្តពីប្រជាជន ។

ប៉ុន្មានឆ្នាំចុងក្រោយនេះ ក្តីសង្ឃឹមថានឹងមានតុលាការខ្មែរក្រហមបានលេចចេញសាជាថ្មីនៅក្នុងប្រទេសកម្ពុជា ដោយមានការគាំទ្រថ្មីពីអន្តរជាតិនិងប្រជាជននៅក្នុងប្រទេស ។ បរាជ័យផ្នែកយោធារបស់ខ្មែរក្រហមនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ និងការថយចុះភាពតានតឹងរវាងប្រទេសមហាអំណាចក្រោយឆ្នាំ១៩៩១ មានឥទ្ធិពលធំធេងមកលើកម្ពុជា ។ កត្តាទាំងនោះបានបណ្តាលឲ្យមានជាលើកទីមួយនូវដំណើរការស្វែងរកយុត្តិធម៌ចំពោះអំពើឧក្រិដ្ឋរបស់ខ្មែរក្រហម ។ ទោះបីជាយ៉ាងណាក៏ដោយ តាំងតែពីពេលដែលការចរចាបានចាប់ផ្តើមសាជាថ្មីនៅឆ្នាំ១៩៩៦ តម្រូវការរបស់ជនរងគ្រោះខ្មែររាប់លាននាក់ត្រូវបានដាក់ឲ្យស្ថិតនៅពីក្រោយនយោបាយដណ្តើមអំណាច ។ ការចរចាដើម្បីបង្កើតតុលាការចម្រុះមួយដោយមានការចូលរួមពីចៅក្រម ព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេត ជាតិនិងអន្តរជាតិ បានក្លាយទៅជាសមរភូមិដណ្តើមការគ្រប់គ្រងដំណើរការកាត់ទោស ។ ទាំងភាគីកម្ពុជា ទាំងភាគីអន្តរជាតិ បានថ្លែងថាដំណោះស្រាយរបស់ផងខ្លួនជាមធ្យោបាយប្រសើរបំផុតក្នុងការផ្តល់យុត្តិធម៌ជូនប្រជាជនកម្ពុជា ។

រដ្ឋាភិបាលកម្ពុជាបានទាមទារយ៉ាងដាច់អហង្ការថា មានតែមេដឹកនាំខ្មែរក្រហមតែប៉ុន្មានរូបប៉ុណ្ណោះដែលនឹងត្រូវនាំយកទៅកាត់ទោស ដោយលើកហេតុផលថាការកាត់ទោសអ្នកផ្សេងនឹងជះឥទ្ធិពលអាក្រក់ទៅលើស្ថិរភាពនយោបាយនិងសន្តិសុខជាតិ ។ អ្នករិះគន់លើនាយករដ្ឋមន្ត្រី ហ៊ុន សែន និងគណបក្សប្រជាជនបានអះអាងថា គោលបំណងពិតប្រាកដរបស់សម្តេច ហ៊ុន សែន ក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហមតែប៉ុន្មាននាក់គឺផ្សេង ។ សម្តេច ហ៊ុន សែន ជានាយយុទ្ធជនមួយរូបនៅក្នុងរបបខ្មែរក្រហមមុនពេលដែលគាត់ភៀសខ្លួនទៅប្រទេសវៀតណាមនៅពាក់កណ្តាលរបបខ្មែរក្រហម ហើយក្រោយមកត្រឡប់ចូលប្រទេសវិញក្នុងនាមជាមេដឹកនាំកងកម្លាំងឈ្លានពានគាំទ្រដោយវៀតណាម ។ សម្តេច ហេង សំរិន និងសម្តេច ជា ស៊ីម ក៏មានប្រវត្តិប្រហាក់ប្រហែលនឹងសម្តេច ហ៊ុន សែន ដែរ ។ មន្ត្រីកម្ពុជាបច្ចុប្បន្នជាច្រើនរូបជាអតីតកម្មាភិបាលខ្មែរក្រហម ហើយមានការសង្ស័យថា មន្ត្រីរដ្ឋាភិបាលបានឈានជើងចូលទៅក្នុងកិច្ចព្រមព្រៀងគួរឲ្យសង្ស័យជាមួយខ្មែរក្រហមដើម្បីទាក់ទាញការចុះចូលឬទទួលផលប្រយោជន៍សេដ្ឋកិច្ចតិចតួច ។ អ្នករិះគន់បានលើកហេតុផលថា អ្វីដែលគណបក្សប្រជាជនចង់បានពីតុលាការខ្មែរក្រហមគឺការការពារប្រជាប្រិយភាពនយោបាយនិងការទទួលស្គាល់ជាសាធារណៈថាជាគណបក្សដែលបានបញ្ចប់បញ្ហាខ្មែរក្រហមទាំងស្រុង ។

ហេតុនេះ គណបក្សប្រជាជនតែងតែត្រូវបានចាត់ទុកពីអន្តរជាតិថាជាឧបសគ្គចម្បងដល់ដំណើរការដាក់ឲ្យមានការ

ទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋរបស់ខ្មែរក្រហម ដោយមូលហេតុថាគណបក្សនេះមានសមាជិកជាអតីតខ្មែរក្រហម ហើយជាងនេះទៅទៀត គណបក្សប្រជាជនតែងតែសង្ស័យចំពោះគោលបំណងពិតប្រាកដរបស់លោកខាងលិច ។ នៅក្នុងឆ្នាំកន្លងទៅថ្មីៗ គណបក្សប្រជាជនហាក់ដូចជាមានឆន្ទៈកាន់តែខ្ពស់ដើម្បីបង្កើតតុលាការមួយដែលមានការចូលរួមជាលក្ខណៈជាតិនិងអន្តរជាតិ ។ រដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនបានប្រកាសជាធរមាននូវច្បាប់ដើម្បីបង្កើតតុលាការ នៅក្នុងឆ្នាំ២០០១ និងបានចុះហត្ថលេខាព្រមព្រៀងជាមួយអង្គការសហប្រជាជាតិនៅខែមិថុនា ឆ្នាំ២០០៣ ។ គណបក្សប្រឆាំងធំៗទាំងពីរគឺ ហ៊ុនស៊ិនប៉ិច និងសមរង្ស៊ី ឥឡូវនេះកំពុងស្ថិតនៅក្នុងមូលដ្ឋានមួយស្រដៀងគ្នាទៅនឹងប្រទេសខាងលិច ។ ជាសាធារណៈ គណបក្សទាំងពីរគាំទ្រការទាមទាររកយុត្តិធម៌ ប៉ុន្តែក្នុងចិត្តគិតថាតុលាការខ្មែរក្រហមអាចជួយពង្រឹងអំណាចរបស់សម្តេច ហ៊ុន សែន ។ ពុំមានហេតុផលបញ្ជាក់ថាតុលាការខ្មែរក្រហមជាហេតុផលមួយនៃការប្រឆាំងមិនព្រមបង្កើតរដ្ឋាភិបាលថ្មីរបស់គណបក្សទាំងពីរទេ ។

នៅលើឆាកអន្តរជាតិ មានការយល់ឃើញខុសៗគ្នាអំពីអ្វីដែលជាធាតុនៃ«យុត្តិធម៌សម័យអន្តរកាល»សម្រាប់កម្ពុជា ។ ប្រទេសចិននៅតែប្រឆាំងចំពោះតុលាការខ្មែរក្រហម ដោយសារប្រទេសនេះបានគាំទ្របក្សកុម្មុយនិស្តកម្ពុជា និងដោយភ័យខ្លាចការវាយប្រហារពីខាងលិចទៅលើកិច្ចការក្នុងតំបន់របស់ចិន ។ រដ្ឋាភិបាលក្រុងប៉េកាំងបានអះអាងថា ការជ្រៀតជ្រែកពីបរទេសទៅក្នុង«កិច្ចការផ្ទៃក្នុង»របស់កម្ពុជានឹងធ្វើឲ្យមានភាពអយុត្តិធម៌ ហើយរដ្ឋាភិបាលទីក្រុងភ្នំពេញគួរតែបង្កើតដំណើរការកាត់ទោសមួយនៅក្នុងស្រុក ។ សហរដ្ឋអាមេរិកបានដឹកនាំកិច្ចប្រឹងប្រែងសាធារណៈដើម្បីបង្កើតតុលាការ ប៉ុន្តែស្ទាក់ស្ទើរមិនហ៊ានយល់ព្រមបង្កើតតុលាការមួយដែលមានសមាសភាពខ្មែរច្រើនពេក ។ ពីខាងក្រៅ អាមេរិកបារម្ភថាចៅក្រមកម្ពុជាមិនស្មោះត្រង់និងងាយទទួលឥទ្ធិពលពីរដ្ឋាភិបាល ។ ដោយស្ងាត់ៗ មន្ត្រីអាមេរិកមិនមានបំណងឲ្យគណបក្សប្រជាជនទទួលបានគុណសម្បត្តិបង្កើតតុលាការនេះទេ ។ ព្រឹទ្ធបុរសអាមេរិក ចឹស ហែម និងតំណាងរាស្ត្រដាណា រ៉ូរ៉ាបាកឺរ ថែមទាំងបានទាមទារឲ្យបង្កើតសេចក្តីសម្រេចមួយដើម្បីស្នើឲ្យមានការកាត់ទោសសម្តេច ហ៊ុន សែន ជំនួស«មេដឹកនាំខ្មែរក្រហមចាស់ជរា»មួយចំនួន ។ រដ្ឋភាគច្រើននៅអឺរ៉ុបមានទស្សនៈស្រដៀងគ្នា ដែលនាំឲ្យមានការអូសបន្លាយមិនបានបង្កើតតុលាការកាន់តែយូរ ។

សម្រាប់សហគមន៍អន្តរជាតិ បញ្ហាចម្បងគឺថា តើសម្តេច ហ៊ុន សែន និងគណបក្សប្រជាជន អាចទុកចិត្តបានឬទេ ហើយថាតើសារប្រយោជន៍របស់តុលាការអាចជួយឲ្យគណបក្សប្រជាជនពង្រឹងអំណាចរបស់ខ្លួនបានឬទេ ។ ដូច្នេះការចរចាគ្នារវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាបញ្ជាក់យ៉ាងច្បាស់ថា តួអង្គមានអំណាចសំខាន់ៗជាច្រើនយល់ថាតុលាការខ្មែរក្រហមជារង្វាន់នយោបាយដែលត្រូវចាប់យក ។ ទស្សនៈនេះគួររួមចំណែកជាមួយនឹងការបដិសេធមិនទទួលខុសត្រូវចំពោះរាល់យុត្តិធម៌ព្រហ្មទណ្ឌគួរទុកចិត្តបានសម្រាប់ប្រជាជនកម្ពុជារាប់លាននាក់ដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ។ នៅក្នុងប្រទេសកម្ពុជាមិនទាន់មានតួអង្គនយោបាយណាមួយដែលឈ្នះ«រង្វាន់»បង្កើតតុលាការខ្មែរក្រហមនៅឡើយទេ ។ ឧទាហរណ៍សភាជាតិអាហ្វ្រិកនៃប្រទេសអាហ្វ្រិកខាងត្បូងបានផ្អែកមួយចំណែកយ៉ាងធំនៃការធ្វើឲ្យស្របច្បាប់នៃរដ្ឋាភិបាលរបស់ខ្លួនទៅលើការផ្តួលរំលំរបបអាប៉ាថេត និងការរៀបចំគ្រប់គ្រងគណៈកម្មការការពិតនិងការផ្សះផ្សាដ៏ទូលំទូលាយ ។ ឥឡូវនេះ ដំណើរការធ្វើឲ្យស្របច្បាប់ស្រដៀងគ្នាត្រូវបានលើកឡើងសម្រាប់របបនយោបាយថ្មីនៅអ៊ីរ៉ាក់និងអាហ្វហ្កានីស្ថាន ដែលកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតតុលាការព្រហ្មទណ្ឌកំពុងតែត្រូវបានធ្វើឡើងដោយមានការគាំទ្រពីសហគមន៍អន្តរជាតិ ។

## ឧបសគ្គនៃយុត្តិធម៌ចំពោះការខូចខាត

ប្រសិនបើដំណើរការព្រហ្មទណ្ឌឬដំណើរការទាមទារយុត្តិធម៌ចំពោះ«ការឈឺចាប់»អាចជួយពង្រឹងមូលដ្ឋាននៃរដ្ឋាភិបាលថ្មីមួយនិងអ្នកគាំទ្រខាងក្រៅរបស់រដ្ឋាភិបាលនេះ ដំណើរការ«សងការខូចខាត»តែងតែត្រូវបានមើលឃើញថាអាចធ្វើផ្ទុយទៅវិញ ។ ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនធ្វើដំណើរទៅមុខក្នុងកម្រិតមួយតាមទម្រង់នយោបាយសេដ្ឋកិច្ចមួយដែលអាចត្រូវបានពណ៌នាថាមានការ«បែងចែក» ។ «រដ្ឋបែងចែក»គឺជារដ្ឋមួយដែលរដ្ឋាភិបាល

ទទួលចំណូលពីប្រភពបរទេស ទោះបីតាមរយៈជំនួយអន្តរជាតិ ឬពន្ធលើអាជីវកម្មអន្តរជាតិក្តី ។ សេដ្ឋកិច្ចនៅក្នុងប្រទេសទាំងនេះងាយស្រួលនឹងកើតមានអំពើពុករលួយនិងការគ្រប់គ្រងមិនត្រឹមត្រូវ ពីព្រោះថាថ្នាក់ដឹកនាំនយោបាយមិនបានពឹងផ្អែកទៅលើពន្ធដែលប្រមូលបានពីប្រជាពលរដ្ឋខ្លួន ដើម្បីរក្សាអំណាចនិងរស់នៅយ៉ាងស្តុកស្តម្ភ ។ ភាគីនយោបាយប្រឆាំងតែងតែប្រកួតប្រជែងដើម្បី «កាន់កាប់ទង់ជាតិ» ដែលធ្វើឲ្យខ្លួនអាចគ្រប់គ្រងធនធានរដ្ឋសម្រាប់បម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ។ ទោះបីជានៅពេលដែលរបបដឹកនាំគួរឲ្យស្អប់ខ្ពើមត្រូវបានផ្តួលរំលំ ក៏បញ្ហាតែងតែកើតមាននៅពេលដែលរបបដឹកនាំថ្មីចាក់ឫសគល់កាន់តែរឹងមាំទៅនឹងតួនាទីដែលមានអភ័យឯកសិទ្ធិខ្ពស់ ។ រដ្ឋនិងភ្នាក់ងារអន្តរជាតិតែងតែរួមចំណែកដល់បញ្ហាតាមរយៈការគាំទ្ររដ្ឋាភិបាលទាំងនោះ ដើម្បីផលប្រយោជន៍នយោបាយ សេដ្ឋកិច្ច និងយុត្តិ-សាស្ត្រ ។ នេះគឺជាដំណើរការដែលធ្លាប់ឃើញនៅមុនក្នុងនិងក្រោយសង្គ្រាមត្រជាក់ នៅពេលដែលហេតុផលគាំទ្រពីបរទេសមានរូបរាងច្បាស់លាស់ ។

យន្តការ«សងការខូចខាត»គាំរាមកំហែងចំពោះរដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍន៍ ដោយលើកឡើងអំពីឱកាសដែលថារដ្ឋាភិបាលទាំងនេះនឹងត្រូវបង្ខំឲ្យបែងចែកដីធ្លីនិងធនធានផ្សេងទៀតសាជាថ្មីទៅឲ្យប្រជាពលរដ្ឋក្រីក្រ ។ នៅក្នុងប្រទេសកម្ពុជាអ្នកភូមិទាំងឡាយដែលបានរស់រានជីវិតពីរបបខ្មែរក្រហមតែងតែបញ្ជាក់អំពីទុក្ខសោកថា ទាំងអតីតកម្មាភិបាលខ្មែរក្រហម ទាំងមេដឹកនាំនយោបាយនិងយោធាបច្ចុប្បន្ន ជាម្ចាស់កម្មសិទ្ធដីធ្លីដ៏ធំទូលាយ ។ ម្ចាស់កម្មសិទ្ធទាំងនោះការពារដីធ្លីរបស់ខ្លួនដោយដាក់ពង្រាយទ័ពឬអង្គរក្សផ្ទាល់ខ្លួន ហើយតែងតែលក់ទៅឲ្យក្រុមហ៊ុនបរទេសនូវលិខិតអនុញ្ញាតឲ្យប្រមូលធនធានធម្មជាតិចេញពីតំបន់ ។ នៅក្នុងទីក្រុង មន្ត្រីរដ្ឋាភិបាលដែលមានប្រាក់បៀវត្សរ៍ប្រហែល ២៥ដុល្លារមួយខែ ប្រើប្រាស់រថយន្តមែរសីដែស និងមានវីឡាធំស្កឹមស្កៃ ដែលទាំងនេះសុទ្ធតែជាទ្រព្យសម្បត្តិសាធារណៈ ។ មន្ត្រីខ្លះគឺជាអតីតកម្មាភិបាលខ្មែរក្រហម ។ ចំពោះជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ភាពអយុត្តិធម៌ដែលចេះតែបន្តនេះជាបញ្ហាមួយធំដូចអំពើឃោរឃៅបង្ហូរឈាមរបស់ខ្មែរក្រហមពីអតីតកាលដែរ ។ អំពើពុករលួយរបស់រដ្ឋាភិបាលនិងការគ្របដណ្តប់ទៅលើធនធានសំខាន់ៗ អមដោយអំពើហិង្សារបស់របបកម្ពុជាប្រជាធិបតេយ្យ ជាប្រភពនៃអយុត្តិធម៌ ។

ប្រទេសមហាអំណាចធំៗមានការស្ទាក់ស្ទើរមិនព្រមតវ៉ារកយុត្តិធម៌ចំពោះការបែងចែកនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ ទោះបីជាប្រទេសជាមិត្តគាំទ្រចំពោះតុលាការដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មរបស់ជនរំលោភសិទ្ធិមនុស្សដ៏អាក្រក់បំផុតនៅក្នុងពិភពលោកក៏ដោយ ក៏អ្នកបោះឆ្នោតទាំងនោះមិនហ៊ាន (ឬមិនព្រម) គាំទ្រការផ្ទេរទ្រព្យធនក្នុងទ្រង់ទ្រាយធំដែរ ។ នៅក្នុងករណីខ្លះអ្នកមានអំណាចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍អាចព្រួយបារម្ភថាការជំរុញឲ្យមានការបែងចែកទ្រព្យសម្បត្តិសាជាថ្មី នឹងធ្វើឲ្យរង្គោះរង្គើដល់រដ្ឋាភិបាលបច្ចុប្បន្ននៅក្នុងសម័យអន្តរកាល ហើយនាំឲ្យមានភាពមិនប្រាកដប្រជាផ្នែកសេដ្ឋកិច្ច នយោបាយ និងយុត្តិសាស្ត្រ ។ មានការប្រថុយប្រថាននយោបាយមួយពាក់ព័ន្ធនឹងរាល់ដំណើរការនយោបាយបែងចែកសាជាថ្មី និងសុឆន្ទៈរបស់អំណាចខាងក្រៅក្នុងការទទួលយកថា ការប្រថុយប្រថាននឹងថយចុះនៅពេលដែលបញ្ហាសំខាន់ត្រូវដោះស្រាយផ្សេងលេចឡើង ។ នៅក្នុងករណីប្រទេសកម្ពុជា សម្ពាធអន្តរជាតិដែលបង្ខំឲ្យរដ្ឋាភិបាលបន្តធ្វើកំណែទម្រង់ បានប្រែប្រួលបន្តិចបន្តួចនៅពេលដែលបញ្ហាផ្សេងទៀតនៅក្នុងតំបន់ ដូចជាវិបត្តិនៅក្នុងប្រទេសទីម័រខាងកើត និងសកម្មភាពថ្មីៗប្រឆាំងនឹងអំពើភេរវកម្ម បានក្លាយជាអ្វីដែលត្រូវដោះស្រាយមុន ។ នៅពេលដែលបញ្ហាផ្សេងទាមទារឲ្យមានការគិតគូរអំណាចខាងក្រៅនិងភាគីអន្តរជាតិងាកទៅពង្រឹង «ស្ថិរភាព» ដោយរក្សាអ្វីដែលមានស្រាប់ ។

## ការបង្កើនជាអតិបរមានូវកម្រិតយុត្តិធម៌ចំពោះការខូចខាត

ការពិតដែលថារដ្ឋាភិបាលក្នុងសម័យអន្តរកាលនិងអ្នកគាំទ្ររដ្ឋាភិបាលនេះ ជាទូទៅពេញចិត្តតុលាការព្រហ្មទណ្ឌឬគណៈកម្មការស្វែងរកការពិត ជាជាងការស្វែងរកយុត្តិធម៌ចំពោះការខូចខាត មិនមែនជារឿងសម្ងាត់ទេ ។ មេដឹកនាំនៃប្រទេសកំពុងឆ្លងកាត់សម័យអន្តរកាល តែងតែផ្តល់ហេតុផលជាសាធារណៈចំពោះការសម្រេចចិត្តរបស់ខ្លួនដែលមិនឲ្យមានការបែងចែកទ្រព្យសម្បត្តិសាជាថ្មី ។ ហេតុផលទាំងនោះគឺ ដើម្បីរក្សាការ

ផ្សះផ្សាជាតិនិងសន្តិភាពឲ្យឋិតថេរយូរអង្វែង ។ ទស្សនីករណ៍នេះ មិនមែនថាខុសទាំងស្រុងនោះទេ ។ ដូចករណីប្រទេសជប៉ុន អាល្លឺម៉ង់ និងបារាំង នៅចុងទសវត្សរ៍ឆ្នាំ១៩៤០ បានបង្ហាញថា សង្គមមួយអាចជួយស្តារខ្លួនឯងបានតាមរយៈការប្រគល់ការទទួលខុសត្រូវទៅឲ្យមេដឹកនាំ មានលទ្ធភាពកាត់ទោសមេដឹកនាំទាំងនោះចំពោះអំពើហិង្សា និងនៅពេលខ្លះបញ្ចូលសមាជិករដ្ឋាភិបាលចាស់មកបម្រើការងារក្នុងសង្គម ។

មូលហេតុផ្ទាល់ខ្លួនមួយរបស់មេដឹកនាំសម្រាប់ការទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋកម្ម គឺការបម្រើប្រយោជន៍ផ្ទាល់ខ្លួនក្នុងកម្រិតតិចតួចណាមួយ ។ នៅក្នុងប្រទេសកម្ពុជានិងប្រទេសផ្សេង នីតិវិធីដាក់ឲ្យមានការទទួលខុសត្រូវអាចត្រូវបានប្រើប្រាស់ដើម្បីបង្ហាញថាការដឹកនាំថ្មីល្អដោយការផ្តល់យុត្តិធម៌ខ្លះចំពោះអំពើហិង្សាដែលរបបមុនបានប្រព្រឹត្ត ។ តុលាការដែលបានដាក់ស្នើឡើងនៅក្នុងប្រទេសអាហ្វហ្គានីស្ថាននិងអ៊ីរ៉ាក់ នឹងស្ថិតនៅក្រោមការវាយប្រហារដោយសារហេតុផលខាងលើ ។ អ្នករិះគន់ចំពោះការឈ្លានពានដែលដឹកនាំដោយសហរដ្ឋអាមេរិកពិតជាបកស្រាយថា រាល់នីតិវិធីដាក់ឲ្យមានការទទួលខុសត្រូវនៅប្រទេសអ៊ីរ៉ាក់ឬអាហ្វហ្គានីស្ថានជាមធ្យោបាយជួយផ្តល់ហេតុផលនៃសង្គ្រាមនិងដើម្បីបង្កើតរដ្ឋាភិបាលបែបលោកខាងលិច ។ ទោះបីជាក្នុងកម្រិតណាមួយក៏ដោយ អ្នករិះគន់ទាំងនេះពិតជានិយាយត្រូវ ។

សំណួរដែលគួរឲ្យចាប់អារម្មណ៍បំផុតគឺប្រហែលជាថា តើការសម្រេចចិត្តបែបនយោបាយ និងអំណាចដើម្បីបកស្រាយអំពី«យុត្តិធម៌សម័យអន្តរកាល»ក្នុងរបៀបជាក់លាក់មួយ ផ្តល់ប្រយោជន៍ដល់ជនរងគ្រោះភាគច្រើនឬទេ ។ នៅក្នុងប្រទេសកម្ពុជា ការបែងចែកទ្រព្យធនក្នុងទ្រង់ទ្រាយធំចេញពីអាជ្ញាធរដឹកនាំដោយគណបក្សប្រជាជន ឬនីតិវិធីព្រហ្មទណ្ឌដែលប៉ះពាល់ច្រើន ងាយនាំទៅរកសង្គ្រាមស៊ីវិល ។ នៅប្រទេសអ៊ីរ៉ាក់ឬអាហ្វហ្គានីស្ថាន «សំណងការខូចខាត»ពេញលេញចំពោះអំពើហិង្សារបស់ពួកតាលីបង់បាអាទីស និងការបែងចែកធនធានសាជាថ្មី អាចបង្កឲ្យមានវិបត្តិនយោបាយឬសង្គមធ្ងន់ធ្ងរ ។ ដូចនៅក្នុងករណីបញ្ហានយោបាយស្មុគស្មាញ សំណួរគឺ «កម្រិតណា» ។ តើវិធានការដាក់ឲ្យសងការខូចខាតស្ថិតនៅក្នុងកម្រិតណា? ហើយការដាក់ឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌមានដល់កម្រិតណាដើម្បីធានាថាយុត្តិធម៌នឹងទទួលបានជាអតិបរមាដោយមិនប៉ះពាល់ដល់សន្តិសុខសង្គម?

នៅក្នុងសង្គមកំពុងឆ្លងកាលសម័យអន្តរកាល អ្នកកាន់អំណាចតែងតែខំការពារអំណាចជ្រុលពេក ហើយជនរងគ្រោះអាចទាមទាររហូតដល់ប៉ះពាល់ដល់សន្តិសុខសង្គមច្រើនពេក ។ សង្គមអន្តរជាតិនិងតួអង្គមានអំណាចខាងក្រៅមានទំនោរគាំទ្រអ្នកមានអំណាចក្នុងប្រទេស ដោយគាំទ្រចំពោះការកាត់ទោសមេដឹកនាំនៃរបបមុន ដើម្បីបង្ហាញបរទេសថាខ្លួនកំពុង«ធ្វើអ្វីម្យ៉ាង»អំពីការរួចទោសដោយពុំចាំបាច់លះបង់ប្រយោជន៍សេដ្ឋកិច្ចនិងនយោបាយច្រើនពេក ។ ការងាកទៅរកដំណោះស្រាយ«សងការខូចខាត»ពេកឬមិនយកចិត្តទុកដាក់ពេក នឹងប៉ះពាល់ដល់ប្រយោជន៍យូរអង្វែងរបស់ជនរងគ្រោះនៃភាពអយុត្តិធម៌ ។ ការបែងចែកសាជាថ្មីតិចតួចពេកធ្វើឲ្យរបបដែលពុករលួយនិងដឹកនាំមិនមានប្រសិទ្ធភាពបន្តកាន់អំណាច ដែលមិនទាក់ទាញការវិនិយោគពីបរទេស និងមិនបង្កលក្ខណៈឲ្យមានការរីកចម្រើនយូរអង្វែង ។ ផ្ទុយទៅវិញ «យុត្តិធម៌នៃការខូចខាត»ច្រើនពេកអាចបង្កឲ្យមានអស្ថិរភាពនយោបាយនិងការដឹកនាំដែលនៅក្នុងកម្រិតមួយមានការចាំបាច់ចំពោះការរីកចម្រើននិងការវិនិយោគមានផ្លែផ្កា ។

## សេចក្តីបញ្ចប់

មិនមានរូបមន្តដើម្បីធ្វើឲ្យមានតុល្យភាពរវាងដំណើរការ«សងការឈឺចាប់»និង«ការខូចខាត»នៅក្នុងសង្គមអន្តរកាលនោះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ តាមរយៈការក្រឡេកមើលករណីប្រទេសកម្ពុជានិងប្រទេសផ្សេង យើងបានឃើញចំណុចមួយលេចឡើងយ៉ាងច្បាស់ ។ ដើម្បីធ្វើឲ្យ«យុត្តិធម៌សម័យអន្តរកាល»សម្រេចបានដូចក្នុងទ្រឹស្តី ចំណុចសំខាន់ត្រូវពិចារណានោះគឺថា តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីសម្រេចបានលទ្ធផលល្អបំផុតសម្រាប់ជនរងគ្រោះនៃអំពើហិង្សា មិនមែនដើម្បីពង្រឹងរចនាសម្ព័ន្ធនយោបាយថ្មីមួយដែលងាយនឹងទទួលរងការផ្តួលរំលំដូចគ្នានោះទេ ។

**ចន ឆរឆីអារី**

# កសាងសំណុំរឿងចោទប្រកាន់អតីតមេដឹកនាំខ្មែរក្រហម

អស់រយៈកាលជាងពីរទសវត្ស ប្រជាជនកម្ពុជាបានទទួលរង់ចាំយុត្តិធម៌ចំពោះទង្វើរបស់ខ្មែរក្រហម ។ នៅឆ្នាំ២០០៣ ប្រជាជនខ្មែរបានចាប់ផ្តើមមានក្តីសង្ឃឹមឡើងវិញ នៅពេលដែលរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានព្រមព្រៀងគ្នាបង្កើតតុលាការសម្រាប់កាត់សេចក្តីចំពោះបទឧក្រិដ្ឋទាំងឡាយដែលបានប្រព្រឹត្តិឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ។

នៅពេលតុលាការជិតបង្កើតឡើង មនុស្សទូទៅតែងងឿងឆ្ងល់ថា តើមេដឹកនាំខ្មែរក្រហមវ័យចំណាស់ណាខ្លះនឹងត្រូវនាំឡើងតុលាការ ។ ប៉ុល ពត ប្រធានបក្សកុម្មុយនិស្តកម្ពុជា បានស្លាប់នៅក្នុងឆ្នាំ១៩៩៨ ។ កែ ពក សមាជិកគណៈមជ្ឈិមស្លាប់នៅឆ្នាំ២០០២ ។ សៀវភៅ «បេក្ខជន៧រូបសម្រាប់ការកាត់ទោស» ត្រូវបានសរសេរឡើងដំបូងនៅចុងឆ្នាំ២០០១ គឺមុនពេលដែល កែ ពក ស្លាប់ ។ ចំណែក ខៀវ សំផន ដែលជាសមាជិកគណៈមជ្ឈិមមួយរូបដែរ បានបោះពុម្ពសៀវភៅមួយក្បាលក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ការបង្អត់អាហារ និងជំងឺ ដែលបានសម្លាប់ជីវិតប្រជាជនខ្មែរជិតពីរលាននាក់ ។ អៀង សារី ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការងារបរទេស និងជាសមាជិកគណៈកម្មាធិការមជ្ឈិមនិងគណៈកម្មាធិការអចិន្ត្រៃយ៍ បានចូលរួមជាមួយ ខៀវ សំផន ក្នុងការអះអាងពីភាពគ្មានកំហុស ។

សៀវភៅ «បេក្ខជន៧រូបសម្រាប់ការកាត់ទោស» គឺជាសៀវភៅទីមួយហើយដែលនិពន្ធឡើងក្នុងគោលបំណងវិភាគអំពីការទទួលខុសត្រូវរបស់មេដឹកនាំខ្មែរក្រហមនីមួយៗចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សៀវភៅនេះបកស្រាយអំពីឯកសារប្រវត្តិសាស្ត្រទាក់ទងនឹងសកម្មភាពការងារនៃរបបខ្មែរក្រហម និងផ្តល់ជូននូវការវិភាគផ្នែកច្បាប់ដើម្បីចោទប្រកាន់ជនសង្ស័យ ។ សៀវភៅនេះលើកយកភស្តុតាងបន្ថែមដើម្បីចោទប្រកាន់មេដឹកនាំខ្មែរក្រហមដូចជា នួន ជា, អៀង សារី, ខៀវ សំផន, តា ម៉ុក, កែ ពក, ស៊ូ ម៉េត និង មាស មុត រួមទាំងការរៀបរាប់អំពីដំណើរការចរចារគ្នារវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដែលនាំទៅរកកិច្ចព្រមព្រៀងនៅក្នុងឆ្នាំ២០០៣ អំពីការបង្កើតតុលាការនៅកម្ពុជាចូលរួមជាអន្តរជាតិដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមនិងជនទាំងឡាយណាដែលមានការទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឃោរឃៅរបស់ខ្មែរក្រហម ។

ជំនួយការអគ្គលេខាធិការសម្រាប់កិច្ចការច្បាប់នៃអង្គការសហប្រជាជាតិ រ៉ាល់ ហ្សាក់គ្លីន បានពោលថា «របាយការណ៍នេះនឹងក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ព្រះរាជអាជ្ញាទាំងអស់ ហើយវាជាចំណុចចាប់ផ្តើមនៃរាល់ការស៊ើបអង្កេត» ។

ដេវីដ ស្ហ៊ីវហ្វ័រ អតីតឯកអគ្គរដ្ឋទូតគចរសម្រាប់ឧក្រិដ្ឋកម្មសង្គ្រាម បានពោលថា «នេះជាសៀវភៅមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវផ្នែកក្រដាសស្នាមពីក្រោមរហូតដល់លើ ហើយវាសន្និដ្ឋានអំពីអំណាចដាក់បញ្ជារបស់មេដឹកនាំខ្មែរក្រហម» ។

ការបោះពុម្ពផ្សាយសៀវភៅ «បេក្ខជន៧រូបសម្រាប់ការកាត់ទោស» នៅឆ្នាំ២០០៤ដោយមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានជួយជ្រែជ្រែងដោយភ្នាក់ងារសហប្រតិបត្តិការណ៍អភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសស៊ុយអែដ (ស៊ីដា) និងមូលនិធិអភិវឌ្ឍន៍នៃវិទ្យាស្ថានសង្គមសេរី (ជាមូលនិធិមនុស្សធម៌មួយរបស់ប្រទេសស្វីស) ។

អ្នកនិពន្ធ ស្ទីវ ហេឌ័រ បង្រៀននៅវិទ្យាស្ថានច្បាប់និងវិទ្យាសាស្ត្រនយោបាយនៃមហាវិទ្យាល័យអាហ្វ្រិកនិងអាស៊ីនៃសាកលវិទ្យាល័យទីក្រុងឡុង ។ ជាបញ្ញាជននាំមុខផ្នែកប្រវត្តិ-សាស្ត្រកម្ពុជា ស្ទីវ ហេឌ័រ បានសរសេរអត្ថបទនិងសៀវភៅជាច្រើនអំពីប្រទេសកម្ពុជា ។ ថ្មីៗនេះលោកបានសរសេរសៀវភៅមួយមានចំណងជើងថា «កុម្មុយនិស្តនិយមរបស់កម្ពុជានិងវៀតណាមៈ ការចម្លងតាមនិងឯករាជភាពពីឆ្នាំ១៩៣០ដល់ឆ្នាំ១៩៧៥» ។ សៀវភៅនេះសហការនិពន្ធដោយ ប្រាយ៉ាន់ ធីទីម័រ ជាអ្នកឯកទេសផ្នែកទ្រឹស្តីនៃគណៈកម្មាការអន្តរអាមេរិកាំងស្តីអំពីសិទ្ធិមនុស្សនៃអង្គការរដ្ឋនៅអាមេរិក ។ ពីមុន ប្រាយ៉ាន់ ធីទីម័រ ជាសហការីស្រាវជ្រាវជាន់ខ្ពស់ និងជាអគ្គនាយកស្តីទីនៃការិយាល័យស្រាវជ្រាវអំពីបទឧក្រិដ្ឋសង្គ្រាមនៃមហាវិទ្យាល័យច្បាប់វ៉ាស៊ីនតោន សាកលវិទ្យាល័យអាមេរិកនៅទីក្រុងវ៉ាស៊ីនតោន ។

**ឆាំង យុ**



សមមិត្ត ខៀវ សំផន

រូបថតដោយៈ ចូសេហ្វ កុហ្វម៉ាន់



សមមិត្ត អៀង សារី

# តុលាការព្រហ្មទណ្ឌអន្តរជាតិៈ ទីបញ្ចប់របស់វប្បធម៌នៃភាពរួចទោស? តុលាការនិងវប្បធម៌នៃភាពរួចទោសនៅអាមេរិកឡាទីន

អាកប្បកិរិយារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនៅក្នុងទ្វីបអាមេរិកឡាទីនត្រូវបានកំណត់ដោយចៀសពុំរួចដោយអតីតកាលទើបនឹងកន្លងផុតទៅនៅក្នុងតំបន់ ជាអតីតកាលដែលត្រូវបានគាក់តែងដោយការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនិងទូទៅ ។ មានការខិតខំប្រឹងប្រែងតិចតួចប៉ុណ្ណោះដើម្បីទាមទាររកយុត្តិធម៌ពីជនដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋ ។ ដើម្បីស្វែងយល់អំពីវិធីដែលប្រទេសទាំងឡាយនៅក្នុងទ្វីបអាមេរិកឡាទីនឆ្លើយតបទៅនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ ការពិភាក្សាអំពីការប្រយុទ្ធទល់នឹងវប្បធម៌នៃការរួចទោសនៅក្នុងទ្វីបអាមេរិកឡាទីនជាការសំខាន់ ។

នៅក្នុងអំឡុងពេល២០ឆ្នាំមុន ក្រោយដំណាក់កាលជម្លោះប្រដាប់អាវុធឬការដឹកនាំផ្តាច់ការ ប្រទេសទាំងឡាយនៅក្នុងទ្វីបអាមេរិកឡាទីនបានតស៊ូជាមួយនឹងបញ្ហាយុត្តិធម៌ចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ។ នៅមុនឬក្នុងដំណាក់កាលនៃការផ្លាស់ប្តូរទៅកាន់លទ្ធិប្រជាធិបតេយ្យ ប្រទេសជាច្រើនបានអនុម័តច្បាប់លើកលែងទោសដែលបានបង្កើតឡើងដើម្បី "ជំរុញដល់ការផ្សះផ្សាជាតិ" ដែលប្រទេសទាំងនេះពន្យល់ថា ជាការចាំបាច់សម្រាប់ចៀសវាងមិនឲ្យមានភាពរំជើបរំជួលខាងយោធា និងដើម្បីធានាឲ្យមានសន្តិភាពយូរអង្វែង ។ ការលើកលែងទោសខ្លះគឺជា"ការលើកលែងទោសខ្លួនឯង"យ៉ាងច្បាស់ក្រឡែត (ដូចជានៅប្រទេសឈីលី និងប៉េរូ) ។ នៅក្នុងដំណាក់កាលដូចគ្នាប្រទេសអាហ្សង់ទីន ឈីលី អែលសាល់វ៉ាឌ័រ ហ្គាតេម៉ាឡា ហៃទី និងប៉េរូ បានបង្កើតគណៈកម្មការស្វែងរកការពិត ជាយន្តការដើម្បីដោះស្រាយការរំលោភសិទ្ធិមនុស្សដ៏ធំធេងកាលពីអតីតកាលកន្លងផុតទៅថ្មីៗ ។ ទោះបីជាគណៈកម្មការទាំងនេះមិនត្រូវបានបង្កើតឡើងដើម្បីជា"ថ្នូរសម្រាប់យុត្តិធម៌"ក៏ដោយ ជួនកាលគណៈកម្មការស្វែងរកការពិតត្រូវបានមើលឃើញថាមានតួនាទីបែបនោះ ។

នៅពេលមិនទាន់ចេញឆ្ងាយពីអតីតកាលនៃអំពើហិង្សានយោបាយបច្ចុប្បន្ន ប្រទេសជាច្រើននៅក្នុងទ្វីបអាមេរិកឡាទីនគិតថាខ្លួនមានការប្តូរផ្តាច់ចំពោះការការពារសិទ្ធិមនុស្ស ។ ប៉ុន្តែវាមិនមែនមានន័យថាប្រទេសទាំងនេះមានឆន្ទៈនឹងទាមទារយុត្តិធម៌ក្នុងនាមជាជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សពីអតីតកាល ឬថាវប្បធម៌នៃការរួចទោសមិនមានតទៅទៀតនោះទេ ។

***ការកំណត់វិសាលភាពនៃការលើកលែងទោស***

នៅក្នុងប្រទេសអែលសាល់វ៉ាឌ័រ ច្បាប់លើកលែងទោសនិងអាជ្ញាយុកាលតឹងរ៉ឹង ត្រូវបានបង្កើតឡើងដើម្បីការពារកុំឲ្យមានការកាត់ទោសក្នុងតុលាការព្រហ្មទណ្ឌចំពោះការរំលោភសិទ្ធិមនុស្សពីអតីតកាល ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅក្នុងប្រទេសផ្សេងទៀត តុលាការបានចាប់ផ្តើមកំណត់អំពីវិសាលភាពច្បាប់នៃការលើកលែងទោស ហើយនៅក្នុងករណីខ្លះបានរកឃើញថាអាជ្ញាយុកាលច្បាប់មិនអាចយកទៅប្រើប្រាស់ជាមួយបទឧក្រិដ្ឋមួយចំនួនទេ ។

កិច្ចប្រឹងប្រែងនេះត្រូវបានគាំទ្រដោយប្រព័ន្ធសិទ្ធិមនុស្សអន្តរអាមេរិកាំង ។ តុលាការនិងគណៈកម្មការអន្តរអាមេរិកាំងបានបដិសេធដោយផ្អែកទៅលើការប្រើប្រាស់ច្បាប់លើកលែងទោស ផ្ទុយទៅនឹងអនុសញ្ញាសហរដ្ឋអាមេរិកចំពោះសិទ្ធិមនុស្សចំពោះករណីផ្សេងៗទាក់ទងទៅនឹងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ។ លោក ដុកក្លាស់ ខាស់សែល បានពោលថា "វោហារសាស្ត្រដ៏មានអត្ថន័យនិងសមហេតុផល"របស់តុលាការនិងគណៈកម្មការអន្តរអាមេរិកាំងបានបញ្ជាក់យ៉ាងច្បាស់ថាៈ "ការលើកលែងទោសចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនៅក្នុងទម្រង់ទាំងឡាយដែលទទួលរងដោយប្រជាជននៅលើទ្វីបអាមេរិក រំលោភទៅលើករណីយកិច្ចរបស់រដ្ឋនិងសិទ្ធិរបស់ជនរងគ្រោះដែលបានរៀបរាប់នៅក្នុងកតិកាសញ្ញាសិទ្ធិមនុស្សក្នុងតំបន់" ។ លើសពីនេះ ប្រព័ន្ធការពារសិទ្ធិមនុស្សក្នុងតំបន់បានដាក់ចេញនូវសេចក្តីសម្រេចចិត្តសំខាន់ជាច្រើន ដែលបង្កឲ្យមានការស៊ើបអង្កេតសាជាថ្មីនិងផ្តល់

សំណងការខូចខាតចំពោះជនរងគ្រោះនៅក្នុងប្រទេសខ្លះ ។

គណៈកម្មការអន្តរអាមេរិកាំងអំពីសិទ្ធិមនុស្សបានប្រកាសថា ការទទួលស្គាល់ចំពោះការទទួលខុសត្រូវរបស់រដ្ឋាភិបាល ការស៊ើបអង្កេតធ្វើឡើងដោយគណៈកម្មការស្វែងរកការពិតនិងសូម្បីតែសំណងនៃការខូចខាត មិនមែនជាការបន្ទូរកាតព្វកិច្ចប្រើប្រព័ន្ធយុត្តិធម៌របស់រដ្ឋដើម្បីស៊ើបអង្កេតកាត់ទោស និងពិន័យ ឬដាក់ទណ្ឌកម្មយ៉ាងមានប្រសិទ្ធភាពចំពោះជនដែលទទួលខុសត្រូវចំពោះការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរឡើយ ។ គណៈកម្មការសិទ្ធិមនុស្សអន្តរអាមេរិកាំង និងតុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំងបានប្រកាសឲ្យរដ្ឋទាំងឡាយកែប្រែនីតិបញ្ញត្តិក្នុងស្រុកឲ្យសមស្របទៅតាមអនុសញ្ញាអាមេរិកចំពោះសិទ្ធិមនុស្សដែលធ្វើឲ្យច្បាប់លើកលែងទោសទូទៅក្លាយជា“មិនសមស្របនិងមិនមានអានុភាពតាមផ្លូវច្បាប់” ។

តុលាការជាតិនៅក្នុងប្រទេសជាច្រើនបានប្រកាសនូវសេចក្តីសម្រេចចិត្តជាផ្លូវការដែលដាក់កំណត់ឥទ្ធិពលនៃច្បាប់លើកលែងទោស ហើយថែមទាំងធ្វើឲ្យច្បាប់លើកលែងទោសទាំងនោះមិនស្របតាមច្បាប់រដ្ឋធម្មនុញ្ញ ។ តុលាការកំពូលរបស់ប្រទេសហុងឌូរ៉ាស បានប្រកាសនូវការសម្រេចចិត្តជាផ្លូវការសំខាន់ៗពីរ ។ ទីមួយ ចំពោះការរកឃើញថាការលើកលែងទោសមិនអាចផ្តល់ឲ្យបានទេមុនពេលដែលអង្គតុលាការបានស៊ើបអង្កេតគ្រប់ជ្រុងជ្រោយទៅលើរឿងក្តី ។ ទីពីរ ការសម្រេចថាច្បាប់រដ្ឋធម្មនុញ្ញមិនអនុញ្ញាតឲ្យមានអនុក្រឹត្យលើកលែងទោសណាដែលរាប់បញ្ចូលឧក្រិដ្ឋកម្មធម្មតាដែលប្រព្រឹត្តឡើងដោយសមាជិកនៃកងទ័ព ពីព្រោះឧក្រិដ្ឋកម្មធម្មតាមិនអាចចាត់ទុកថាទាក់ទងទៅនឹងឧក្រិដ្ឋកម្មនយោបាយទេ ។

ច្បាប់ផ្សះផ្សាជាតិរបស់ប្រទេសហ្គាតេម៉ាឡាឆ្នាំ១៩៩៦ កំហិតជាពិសេសនូវប្រយោជន៍ដ៏ធំធេងនៃការលើកលែងទោសដោយចាត់ចេញឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការបាត់ខ្លួន ការធ្វើទារុណកម្មនិងបទឧក្រិដ្ឋទាំងឡាយដែលមិនស្ថិតក្រោមអាជ្ញាយុកាលនៃច្បាប់ តាមរយៈច្បាប់អន្តរជាតិនិងច្បាប់នៃប្រទេសហ្គាតេម៉ាឡាដែលពាក់ព័ន្ធ ។ គណៈកម្មការបំភ្លឺប្រវត្តិសាស្ត្ររបស់ប្រទេសហ្គាតេម៉ាឡាបានប្រកាសយ៉ាងពិស្តារឲ្យមានការកាត់ទោសអំពើដែលមិនស្ថិតនៅក្រោមបរិបទច្បាប់លើកលែងទោស ។ អង្គការសិទ្ធិមនុស្សដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយជនរងគ្រោះនៅក្នុងមជ្ឈដ្ឋានដ៏លំបាកបំផុត បានព្យាយាមជំរុញឲ្យមានការស៊ើបអង្កេតថ្នាក់រដ្ឋទៅលើជនទាំងឡាយដែលមានការទទួលខុសត្រូវខ្ពស់ចំពោះបទឧក្រិដ្ឋទាំងនេះ ។ ការកាត់ទោសជនទាំងឡាយដែលមានការទទួលខុសត្រូវចំពោះការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរនៅក្នុងប្រទេសហ្គាតេម៉ាឡា បានជួបប្រទះនឹងឧបសគ្គជាច្រើនរួមទាំងការគំរាមកំហែងនិងការវាយប្រហារទៅលើមេធាវីសាក្សីនិងចៅក្រម ហើយនិងបណ្តឹងឧទ្ធរណ៍មិនផ្អែកលើច្បាប់ដែលធ្វើឲ្យទណ្ឌិតរួចខ្លួនទៅវិញ ។

### នៅផ្នែកខាងមុខនៃការតស៊ូ

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ តុលាការនៅក្នុងប្រទេសអាហ្សង់ទីនបានប្រើប្រាស់ទស្សនាទានច្បាប់“នៃប្រព័ន្ធអន្តរអាមេរិកាំងដើម្បីបង្ហាញថាច្បាប់លើកលែងទោសមិនមានអានុភាពតាមផ្លូវច្បាប់”ទេ ។ ប្រទេសអាហ្សង់ទីនបាននិងកំពុងឈានមុខក្នុងការតស៊ូប្រឆាំងវប្បធម៌នៃការរួចទោស ដោយបានកាត់ទោសមេទ័ពជាច្រើនរូបពីឆ្នាំ១៩៨៥ ដែលនៅទីបញ្ចប់ត្រូវបានបញ្ឈប់ដោយ“ច្បាប់រួចទោស”គឺ *ley de punto final nig ley de obediencia debida* អនុម័តនៅក្នុងឆ្នាំ១៩៨៦និង១៩៨៧ បន្ទាប់ពីមានការអនុគ្រោះទោសឲ្យទណ្ឌិតដោយប្រធានាធិបតីមេណែម នៅក្នុងឆ្នាំ១៩៩០ ។ រហូតមកដល់ឆ្នាំនេះទើបអង្គនីតិបញ្ញត្តិប្រទេសអាហ្សង់ទីនបានបញ្ចប់ច្បាប់ទាំងនេះ ដោយមូលហេតុចង់ទាមទារយុត្តិធម៌នៅក្នុងប្រទេសអាហ្សង់ទីនសាជាថ្មី ។ ចៅក្រមសហព័ន្ធបានប្រើប្រាស់ច្បាប់សិទ្ធិមនុស្សអន្តរជាតិដើម្បីកំណត់ថា “ច្បាប់រួចទោស” ទាំងពីរខាងលើ“មិនមានអានុភាពតាមផ្លូវច្បាប់ទេ” ។ សេចក្តីសម្រេចពីតុលាការកំពូលនៅមិនទាន់បានធ្វើនៅឡើយ ។

បន្ថែមទៅលើការធ្វើឲ្យគ្មានសុពលភាពនៃ “ច្បាប់រួចទោស” នីតិក្រមអាហ្សង់ទីនបានបោះឆ្នោតដើម្បីលើកកម្រិតអនុសញ្ញាស្តីអំពីការមិនប្រើប្រាស់អាជ្ញាយុកាលច្បាប់ចំពោះបទឧក្រិដ្ឋសង្គ្រាម និងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិឲ្យមានសុពលភាពស្មើនឹងច្បាប់រដ្ឋធម្មនុញ្ញ ។ មិនគួរឲ្យភ្ញាក់ផ្អើលទេ ប្រទេសអាហ្សង់ទីនបានចូល

រួមយ៉ាងសកម្មនៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ តាមការពិត ព្រះរាជអាជ្ញាទីមួយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិឈ្មោះថា លូអ៊ិស ម៉ូរ៉ិនណូ អូខេមប៉ូ ជាជនជាតិអាហ្សង់ទីន ធ្លាប់បានធ្វើជាព្រះរាជអាជ្ញារងនៅក្នុងដំណើរការដ៏មានជោគជ័យក្នុងការកាត់ទោសក្រុមមេទ័ពនៅប្រទេសអាហ្សង់ទីន ។

កិច្ចខិតខំប្រឹងប្រែងដើម្បីទាមទាររកយុត្តិធម៌សម្រាប់ឧក្រិដ្ឋកម្មនៃអតីតកាលក៏កំពុងតែធ្វើឡើងដែរនៅក្នុងប្រទេសឈីលីមួយផ្នែកជាការឆ្លើយតបទៅនឹងរឿងក្តីរបស់លោក ពីណូចេ និងនៅក្នុងប្រទេសប៉េរូ ។ នៅក្នុងខែមីនា ឆ្នាំ២០០១ តុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំងបានចេញសាលក្រមថា ច្បាប់លើកលែងទោសជាទូទៅនៅឆ្នាំ១៩៩៥របស់ប្រទេសប៉េរូដែលធ្វើឡើងក្នុងបំណងការពារក្រុមមេទ័ពពីការកាត់ទោស មិនអាចជារបាំងនៃការស៊ើបអង្កេតនិងការកាត់ទោសសមាជិកថ្នាក់ដឹកនាំយោធារបស់ប៉េរូដែលជាប់ពាក់ព័ន្ធនៅក្នុងអំពើឃាតកម្មសម្លាប់មនុស្ស១៥នាក់ឡើយ(រឿងក្តី បារីយុស អាល់តុស)ពីព្រោះថាច្បាប់លើកលែងទោសជាទូទៅបានរំលោភទៅលើអនុសញ្ញាស្តីអំពីសិទ្ធិមនុស្សរបស់សហរដ្ឋអាមេរិក ។ បន្ទាប់ពីតុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំងបានដាក់ចេញនូវសេចក្តីសម្រេចចិត្តនៅក្នុងរឿងក្តី បារីយុស អាល់តុស តុលាការកំពូលប៉េរូបានបញ្ជាឲ្យបើកការស៊ើបអង្កេតសាជាថ្មីចំពោះរឿងក្តីដែលត្រូវបានលុបចោលកាលពីឆ្នាំ១៩៩៥ ដោយផ្អែកទៅលើច្បាប់លើកលែងទោសរបស់ប្រទេសប៉េរូ ។

គណៈកម្មការការពិតនិងផ្សះផ្សារបស់ប្រទេសប៉េរូបានចេញផ្សាយរបាយការណ៍របស់ខ្លួននៅថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០០៣ ។ របាយការណ៍នេះបានបដិសេធចោលនូវឱកាសនៃការលើកលែងទោសនិងប្រកាសទាមទារឲ្យរដ្ឋាភិបាលប៉េរូបន្តកាត់ទោស ។ គណៈកម្មការនេះបាន "ទាមទារកុំឲ្យរដ្ឋាភិបាលប្រើប្រាស់ការលើកលែងទោស ការអនុគ្រោះទោស ឬអំណាចប្រធានាធិបតីដោយឯកឯង ប៉ុន្តែឲ្យប្រើប្រាស់នៅក្នុងក្របខ័ណ្ឌដ៏តឹងរ៉ឹងដែលកំណត់ដោយតុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង ។ គណៈកម្មការការពិតនិងផ្សះផ្សាបាននិងកំពុងប្រឆាំងរាល់ការអនុគ្រោះទោសផ្អែកច្បាប់ណាមួយដែលត្រូវបានមើលឃើញថាការស្វែងរកការពិតនិងយុត្តិធម៌ចំណុះឲ្យផលប្រយោជន៍រដ្ឋ ។ ខុសពីគណៈកម្មការស្វែងរកការពិតនៅអាមេរិកកណ្តាល គណៈកម្មការការពិតនិងការផ្សះផ្សារបស់ប៉េរូបានប្រគល់រឿងក្តីខ្លះទៅឲ្យការិយាល័យព្រះរាជអាជ្ញាសម្រាប់កាត់សេចក្តីនៅក្នុងប្រព័ន្ធយុត្តិធម៌ជាតិ ។

នៅទូទាំងអាមេរិកកណ្តាល កិច្ចខិតខំប្រឹងប្រែងដើម្បីកាត់ទោសជនដែលមានការទទួលខុសត្រូវចំពោះការបាត់ខ្លួនរាប់ពាន់ករណី ការសម្លាប់រង្គាល ការប្រហារជីវិតក្រៅអំណាចតុលាការនិងការធ្វើទារុណកម្ម បាននាំទៅរកការផ្តន្ទាទោសតិចតួចប៉ុណ្ណោះ ។ នេះដោយសារមូលហេតុថា រដ្ឋាភិបាលនិងប្រព័ន្ធយុត្តិធម៌ភាគច្រើនមានឆន្ទៈនយោបាយតិចតួច(ឬគ្មានសោះ) ក្នុងការកាត់ទោសឬស្វែងរកមធ្យោបាយដើម្បីជម្នះឧបសគ្គផ្នែកច្បាប់ ។ ទោះជាយ៉ាងណាក៏ដោយ ក៏កាលពី១០ឆ្នាំមុន ការគាំទ្រចំពោះការកាត់ទោសបានថយចុះដោយសារមានទស្សនៈថា ការលើកលែងទោសជាទូទៅដែលរារាំងមិនឲ្យមានយុត្តិធម៌សម្រាប់ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ជាលក្ខខណ្ឌចាំបាច់សម្រាប់សន្តិភាពនិងស្ថិរភាពក្នុងសង្គម ។ តាមការពិតមានរបកគំហើញនិយាយថាច្បាប់លើកលែងទោសទូទៅបំពានទៅលើអនុសញ្ញាស្តីអំពីសិទ្ធិមនុស្សរបស់សហរដ្ឋអាមេរិកនិងរដ្ឋធម្មនុញ្ញជាតិ ។ ចំពោះករណីអាមេរិកឡាទីន មានហេតុផលបញ្ជាក់យ៉ាងច្បាស់ថា គណៈកម្មការការពិតមិនមែនជាផ្លូវនៃយុត្តិធម៌នោះទេ ហើយក៏មិនគួរចាត់ទុកថាជាផ្លូវនៃយុត្តិធម៌ដែរ ។

ប្រទេសទាំងឡាយនៅក្នុងទ្វីបអាមេរិកឡាទីនដែលកន្លងមកមិនមានឆន្ទៈនឹងក្រសោបយកយុត្តិធម៌សម្រាប់ការរំលោភសិទ្ធិមនុស្ស បច្ចុប្បន្ននេះបានបង្ហាញអំពីការប្តូរផ្តាច់ថ្មីដើម្បីធានាឲ្យមានយុត្តិធម៌អន្តរជាតិនៅក្នុងពេលអនាគត ។ ឧទាហរណ៍ នៅក្នុងបរិបទនៃការដឹកនាំប្រទេសទៅរកលទ្ធិប្រជាធិបតេយ្យ នៅទីបំផុតប្រទេសមួយចំនួនបានទទួលស្គាល់ដែនសមត្ថកិច្ចចាំបាច់ដែលតម្រូវឲ្យមានតុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំងដើម្បីដោះស្រាយចំពោះការរំលោភសិទ្ធិមនុស្សនៅថ្ងៃអនាគត ។

## តុលាការព្រហ្មទណ្ឌអន្តរជាតិៈ ការរីកចម្រើន និង ឧបសគ្គ

ការពិភាក្សាវែកញែកទៅលើការផ្តល់សច្ចានុម័តដល់លក្ខន្តិកៈច្បាប់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ បានកើតឡើង ហើយប្រឆាំងនឹងមូលដ្ឋាននៃការរួចទោសដែលផ្តល់ដោយរដ្ឋ ។ រដ្ឋាភិបាលប្រជាធិបតេយ្យថ្មីបានប្រឹងប្រែងដើម្បីបង្ហាញថាខ្លួនកំពុងតែសម្របខ្លួនទៅនឹងបទដ្ឋានសិទ្ធិមនុស្ស ។ ទស្សនាទានច្បាប់អន្តរអាមេរិកាំងកំពុងកើតឡើងទាក់ទងទៅនឹងការរួចទោស ។ លើសពីនេះទៀត អង្គការក្រៅរដ្ឋាភិបាលក៏មិនពេញចិត្តនឹងការឆ្លើយតបជាផ្លូវការទៅនឹងអំពើឃោរឃៅដែលកើតឡើងពីអតីតកាល ។ ប្រទេសទាំងឡាយដែលមិនមានឆន្ទៈនឹងដោះស្រាយបញ្ហារំលោភសិទ្ធិមនុស្សពីអតីតកាល បានផ្តល់សច្ចានុម័តដល់លក្ខន្តិកៈច្បាប់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិដែលបញ្ជាក់ថារឿងក្តីស្រដៀងគ្នាដែលកើតឡើងនៅពេលអនាគតអាចឋិតនៅក្រោមដែនសមត្ថកិច្ចច្បាប់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ទោះបីជារឿងក្តីពីមុនៗមិននៅក្រោមសមត្ថកិច្ចក៏ដោយ) ។ មកទល់បច្ចុប្បន្ន ប្រទេសចំនួន១២នៅទ្វីបអាមេរិកឡាទីន បានចុះហត្ថលេខាទៅលើសន្ធិសញ្ញាទីក្រុងរ៉ូមនិងផ្តល់សច្ចានុម័តដល់សន្ធិសញ្ញានោះ ។ ប្រទេសទាំងនោះមានប្រទេស អាហ្សង់ទីន បូលីវៀ ប្រេស៊ីល កូស្តារីកា កូឡុំប៊ី អេក្វាឌ័រ ហុងឌូរ៉ាស ប៉ាណាម៉ា ប៉ារ៉ាហ្គាយ ប៉េរូ វេណេហ្ស៊ូអេឡា និងយូរ៉ូហ្គាយ ។ នៅអាមេរិកឡាទីន មានតែប្រទេសឈីលីមួយទេ ដែលមិនទាន់បានផ្តល់សច្ចានុម័តដល់លក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ប្រទេសជាច្រើននៅអាមេរិកកណ្តាលមិនទាន់បានផ្តល់សច្ចានុម័តនៅឡើយទេ ដូចជាប្រទេស អែលសាលវ៉ាឌ័រ ហ្គាតេម៉ាឡា នីការ៉ាហ្គា និងប្រទេសម៉ិចស៊ិក ។

រដ្ឋាភិបាលប្រទេសឈីលី អែលសាល់វ៉ាឌ័រ និងម៉ិចស៊ិក បានស្នើឲ្យមានកំណែទម្រង់ច្បាប់រដ្ឋធម្មនុញ្ញ មុនពេលឈានទៅដល់ការផ្ញើសច្ចាប័នលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូម ។ ប្រទេសម៉ិចស៊ិកបានចុះហត្ថលេខាទៅលើលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូម ហើយព្រឹទ្ធសភាបានអនុម័តចំពោះកំណែទម្រង់ច្បាប់រដ្ឋធម្មនុញ្ញដែលដាក់ស្នើឡើងដោយរដ្ឋាភិបាលប្រធានាធិបតី ហ្វុក់ នៅខែធ្នូ ឆ្នាំ២០០២ ។ កំណែទម្រង់នេះនៅតែត្រូវការឲ្យមានការគាំទ្រពី“គណៈកម្មការនៃតំណាង» និងរដ្ឋម៉ិកស៊ិកភាគច្រើន ។

នៅក្នុងប្រទេសមួយចំនួន កំណែទម្រង់ច្បាប់រដ្ឋធម្មនុញ្ញត្រូវបានស្នើឡើង ឬអនុម័ត ដើម្បីចៀសវាងភាពមិនស្របគ្នាជាមួយច្បាប់រដ្ឋធម្មនុញ្ញចាស់ ។ ចំណែកនៅប្រទេសផ្សេងទៀត បញ្ហាទាក់ទងនឹងច្បាប់រដ្ឋធម្មនុញ្ញបានក្លាយទៅជាលេសសម្រាប់បដិសេធការផ្ញើសច្ចាប័ន ។ នៅក្នុងប្រទេសនីការ៉ាហ្គា ការផ្ញើសច្ចាប័នមិនមែនជារបៀបវារៈនៃការពិភាក្សានយោបាយទេ ។

ប្រទេសទាំងឡាយនៅអាមេរិកឡាទីនបានពិភាក្សាវែកញែកទៅលើប្រធានបទជាច្រើនក្នុងការពិចារណាទៅលើការគោរពតាមលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូម ។ ប្រធានបទទាំងនេះគឺជាបញ្ហានៃអធិបតេយ្យភាពជាតិ ថាតើការផ្ទេរជនជាប់ចោទទៅឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិខុសគ្នាពីការផ្ញើបត្យាប័នពលរដ្ឋរបស់ប្រទេសមួយដែលតែងតែហាមប្រាមដោយច្បាប់រដ្ឋធម្មនុញ្ញឬទេ ប្រធានបទមួយទៀតគឺ ថាតើការការពារដោយអភ័យឯកសិទ្ធិពិសេសដែលផ្តល់ដោយរដ្ឋាភិបាលនិងគាំទ្រដោយច្បាប់រដ្ឋធម្មនុញ្ញបង្កើតជាឧបសគ្គដល់ការផ្តល់សច្ចាប័នដល់លក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិឬទេ ឧបសគ្គទី៣គឺ ថាតើការកាត់ទោសប្រហារជីវិតនៅក្រោមលក្ខន្តិកៈច្បាប់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិជាការប៉ះពាល់ដល់ច្បាប់រដ្ឋធម្មនុញ្ញនៃប្រទេសជាច្រើននៅអាមេរិកឡាទីនដែលហាមប្រាមមិនឲ្យមានការកាត់ទោសប្រហារជីវិតឬទេ?

នៅក្នុងប្រទេសខ្លះ តុលាការឬអង្គជំនុំជម្រះរដ្ឋធម្មនុញ្ញបានចេញសាលក្រមទាក់ទងនឹងភាពស្របគ្នារវាងលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូមនិងបទបញ្ញត្តិនៃច្បាប់រដ្ឋធម្មនុញ្ញជាតិ ។ អង្គជំនុំជម្រះរដ្ឋធម្មនុញ្ញរបស់តុលាការកំពូលនៃប្រទេសកូស្តារីកា ជាអង្គច្បាប់នាំមុខក្នុងការប្រើប្រាស់បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ បានបកស្រាយផ្នែកមួយនៃទស្សនាទានច្បាប់របស់ខ្លួនថា “យោលទៅតាមសិទ្ធិមនុស្ស លិខិតូបករណ៍អន្តរជាតិត្រូវបានផ្តល់មិនត្រឹមតែតម្លៃមួយស្រដៀងនឹងច្បាប់រដ្ឋធម្មនុញ្ញប៉ុណ្ណោះទេ ប៉ុន្តែដោយសារលិខិតូករណ៍ផ្តល់សិទ្ធិឬការធានាខ្ពស់ដល់ប្រជាជន វាមានតម្លៃខ្ពស់ជាងច្បាប់រដ្ឋធម្មនុញ្ញ» ។ ទាក់ទងនឹងការកាត់ទោសដាក់ពន្ធនាគារអស់មួយជីវិត (cadena perpetua) អង្គជំនុំជម្រះរដ្ឋធម្មនុញ្ញថ្លែងថាៈ “ដើម្បីផ្ទេរបុគ្គលដែលតុលាការព្រហ្មទណ្ឌអន្តរជាតិកោះហៅមិនត្រឹមតែត្រូវពិចារណាអំពីសញ្ជាតិរបស់បុគ្គលនោះប៉ុណ្ណោះទេ ប៉ុន្តែត្រូវសម្រេចថាការដាក់ទោសមិនអាចជាការជាប់ពន្ធនាគារ

អស់មួយជីវិត ឬការកាត់ទោសផ្សេងទៀតដូចជាទោសប្រហារជីវិតដែលមិនបានអនុម័តជាធរមាននៅក្នុងច្បាប់ប្រទេសកូស្តារីកា» ។

ដោយមានការបកស្រាយបែបនេះ អន្តជំនុំជម្រះរដ្ឋធម្មនុញ្ញលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូម ត្រូវបានអនុម័តចូលទៅក្នុងច្បាប់ប្រទេសកូស្តារីកា នៅថ្ងៃទី១ ខែមករា ឆ្នាំ២០០១ ។

តុលាការរដ្ឋធម្មនុញ្ញរបស់ប្រទេសកូឡុំប៊ីដែលជាអន្តច្បាប់ឈានមុខមួយផ្សេងទៀតខាងការប្រើប្រាស់បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិបានពិនិត្យលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូមដែលនាំទៅរកការធ្វើវិសោធនកម្មច្បាប់រដ្ឋធម្មនុញ្ញដែលអនុញ្ញាតឲ្យមានការផ្តល់សច្ចាប័នរបស់ប្រទេសកូឡុំប៊ី ។ តុលាការរដ្ឋធម្មនុញ្ញបានថ្លែងថា «ការអនុញ្ញាតឲ្យមានប្រព្រឹត្តិកម្មនៃការធានាមួយផ្សេងដែលរៀបរាប់នៅក្នុងច្បាប់រដ្ឋធម្មនុញ្ញជាទម្រង់ច្បាប់សារធាតុនៅក្រោមលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូមនឹងមានអានុភាពតែក្នុងចំណុចណាដែលកំណត់ដោយលក្ខន្តិកៈច្បាប់នោះប៉ុណ្ណោះ»(មាត្រាទី៩៣) ។

តុលាការកំពូលនៃប្រទេសហុងឌូរ៉ាសបានគាំទ្រការឲ្យសច្ចានុម័តចំពោះលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូម ដោយបញ្ជាក់អំពីការធ្វើបត្យាប័ននិងការផ្ទេរជនជាប់ចោទ អភ័យឯកសិទ្ធិ និងទ្រឹស្តី *ne bis in idem* (ទ្រឹស្តីច្បាប់ដែលចែងថាគ្មានជនណាម្នាក់អាចកាត់ទោសពីរដងចំពោះបទឧក្រិដ្ឋតែមួយ) ។ ដោយមានសំណើពីអគ្គនីតិប្រតិបត្តិ តុលាការរដ្ឋធម្មនុញ្ញរបស់ប្រទេសហ្កាតេម៉ាឡាបានដាក់ចេញនូវការសន្និដ្ឋានមួយថាគ្មានខបសគ្គរដ្ឋធម្មនុញ្ញចំពោះការផ្តល់សច្ចាប័នឲ្យលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូមទេ ។ ទោះជាយ៉ាងណានេះក្តី ក៏នៅតែមានការប្រឆាំងពីគណបក្សនយោបាយសំខាន់ៗ ដូច្នេះហ្កាតេម៉ាឡាមិនទាន់បានចុះហត្ថលេខាឬផ្តល់សច្ចានុម័តឲ្យលក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិនៅឡើយទេ ។ តុលាការរដ្ឋធម្មនុញ្ញរបស់ប្រទេសឈីលីបានចេញសាលក្រមថា ប្រសិនបើគ្មានកំណែទម្រង់ច្បាប់រដ្ឋធម្មនុញ្ញ បទបញ្ញត្តិខ្លះនៃលក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិនឹងបំពានទៅលើច្បាប់រដ្ឋធម្មនុញ្ញរបស់ប្រទេសឈីលី ។

ទោះជាយ៉ាងណា បើប្រៀបធៀបទៅនឹងប្រទេសទាំងឡាយនៅអឺរ៉ុប បណ្តាប្រទេសនៅអាមេរិកឡាទីនដែលបានផ្តល់សច្ចាប័ននៅមានការយឺតយ៉ាវនៅឡើយក្នុងការចាប់ផ្តើមអនុម័តច្បាប់ ។ នៅពេលដែលក្រុមប្រទេសនៅអាមេរិកឡាទីនពិនិត្យទៅលើច្បាប់របស់ខ្លួនសំណើសំខាន់ៗជាច្រើនត្រូវបានពិភាក្សាដែលអាចបញ្ចូលការការពារដោយច្បាប់អន្តរជាតិទៅក្នុងបទដ្ឋានច្បាប់ជាតិ ។ សំណើទាំងនេះរួមមានការធ្វើដំណើរទៅមុខនៃការលុបបំបាត់ចោលនូវអាជ្ញាយុកាលច្បាប់នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ការធ្វើទារុណកម្ម ការបាត់ខ្លួន ការប្រហារជីវិតក្រៅតុលាការ ការកាត់ទោសមិនត្រឹមត្រូវនិងឧក្រិដ្ឋកម្មផ្សេងទៀតដែលមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិ ។ ស្រដៀងគ្នានេះដែរ បទបញ្ញត្តិខ្លះត្រូវបានស្នើឡើងថាឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនអាចស្ថិតក្រោមការលើកលែងឬអភ័យទោសបានទេ ។ នៅពេលកំពុងធ្វើដំណើរទៅមុខនោះទៅកាន់ការអនុម័តកំណែទម្រង់ដើម្បីអនុញ្ញាតឲ្យមានការអនុវត្តន៍លក្ខន្តិកៈច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ប្រទេសនៅអាមេរិកឡាទីនមានឱកាសមួយដែលមិនធ្លាប់មានដើម្បីសម្របច្បាប់ជាតិខ្លួនឲ្យស្របទៅនឹងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។

## កូឡុំប៊ីៈ ខបសគ្គចំពោះមុខដែនសមត្ថកិច្ចតុលាការព្រហ្មទណ្ឌអន្តរជាតិ

កូឡុំប៊ី ជាប្រទេសតែមួយគត់នៅក្នុងតំបន់ ដែលជម្លោះប្រដាប់អាវុធកំពុងផ្ទុះឡើងនាំមកនូវរឿងក្តីស្មុគស្មាញជាងគេ ហើយក៏ជាប្រទេសដែលតុលាការព្រហ្មទណ្ឌអន្តរជាតិនឹងដំណើរការមុនគេដែរ ។ ក្រោយពីបានផ្តល់សច្ចានុម័តទៅឲ្យលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូម រដ្ឋាភិបាលរបស់អតីតប្រធានាធិបតី អាន់ដ្រេ ប៉ាស្ត្រាណា បានប្រកាសថា «គ្មានបទបញ្ញត្តិណាមួយនៅក្នុងលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូមអំពីការអនុវត្តដែនសមត្ថកិច្ចនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ រារាំងចំពោះការផ្តល់សម្បទានដល់ការលើកលែងទោសឬការអនុគ្រោះទោសសម្រាប់បទល្មើសនយោបាយដោយរដ្ឋកូឡុំប៊ី ដោយហេតុថា ការផ្តល់សម្បទាននេះត្រូវបានធ្វើដោយផ្អែកទៅលើច្បាប់រដ្ឋធម្មនុញ្ញ ទ្រឹស្តីនិងបទដ្ឋានច្បាប់អន្តរជាតិដែលទទួលស្គាល់ដោយប្រទេសកូឡុំប៊ី» ។ ប្រធានាធិបតីស្នងតំណែងពីប្រធានាធិបតី ប៉ាស្ត្រាណា គឺលោក អាល់វ៉ារ៉ូ យូរីប៊ី កំពុងតែ

ដាក់សំណើឲ្យមានការលើកលែងទោសមេដឹកនាំក្រុមទាហានប៉ារ៉ា ។ សំណើរបស់លោកបានរិះគន់ការតស៊ូអាវុធហើយ «គាំទ្រដំណើរការកសាងសន្តិភាព» ។

ភ្លាមៗបន្ទាប់ពីបានឲ្យសច្ចាប័នអនុម័តទៅលក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ រដ្ឋាភិបាលរបស់លោក ប៉ាស្ត្រាណា បានអនុវត្តតាមមាត្រាទី១២៤ ក្នុងមូលហេតុការពារមិនឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចទៅលើ«ឧក្រិដ្ឋកម្មសង្គ្រាម»ដែលសង្ស័យថាបានប្រព្រឹត្តដោយពលរដ្ឋកូឡុំប៊ី ឬនៅក្នុងទឹកដីរបស់ប្រទេសនេះអស់រយៈពេល៧ឆ្នាំ ។ អ្នកច្បាប់អ្នកការពារសិទ្ធិមនុស្ស និងអគ្គព្រះរាជអាជ្ញារបស់ប្រទេសកូឡុំប៊ីបានប្រកាសឲ្យរដ្ឋាភិបាលបច្ចុប្បន្នបោះបង់ចោលការសម្រេចចិត្តរបស់រដ្ឋាភិបាលមុនដែលអនុវត្តតាមមាត្រាទី១២៤ ។ ប៉ុន្តែដោយមូលហេតុថាឧក្រិដ្ឋកម្មសង្គ្រាមដែលបានធ្វើឡើងនៅក្នុងប្រទេសកូឡុំប៊ីមានភាពទូលំទូលាយ ឬមានបែបផែនត្រឹមត្រូវ ហើយធ្វើសំដៅទៅលើជនស៊ីវិល បទឧក្រិដ្ឋទាំងនេះអាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ រដ្ឋាភិបាលរបស់ប្រទេសកូឡុំប៊ីមិនអាចទប់ស្កាត់មិនឲ្យមានតុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានប្រព្រឹត្តឡើងក្រោយពេលដែលប្រទេសកូឡុំប៊ីបានចុះហត្ថលេខាយល់ព្រមទទួលស្គាល់លក្ខន្តិកៈច្បាប់ទីក្រុងរ៉ូមឡើយ ។

អ្នកចរចាសន្តិភាពកូឡុំប៊ីបានប្រកាន់គោលជំហរមួយជាយូរមកហើយថា ការលើកលែងទោសជាទូទៅនឹងត្រូវការជាចាំបាច់ដើម្បីបញ្ចប់ជម្លោះប្រដាប់អាវុធជាច្រើនទសវត្សរ៍របស់ប្រទេសនេះ ។ អ្នកដែលបានទទួលខុសត្រូវចំពោះការប្រហារជីវិតក្រៅអំណាចតុលាការ ការធ្វើទារុណកម្ម ការបាត់ខ្លួន និងការចាប់ពង្រត់ មានដូចជាយោធាប្រតិព័ទ្ធស្តាំនិយមដែលជាអ្នកអនុវត្តការងារក្រខ្វក់របស់អង្គភាពយោធានៅក្នុងឆ្នាំកន្លងទៅថ្មីៗ ពួកឧទ្ទាមឆ្វេងនិយម និងសមាជិកកងកម្លាំងប្រដាប់អាវុធ ។ ច្បាប់លើកលែងទោសដែលដាក់ស្នើដោយប្រធានាធិបតី យូរីប៊ី បានបង្កើតគ្រោងការថ្មីមួយ ដែលក្នុងនោះ សមាជិករបស់ក្រុមប្រដាប់អាវុធនឹងទទួលការព្យួរទោសក្រោយពីត្រូវបានរំសាយ និង«រួមវិភាគទានយ៉ាងមានប្រសិទ្ធភាពដល់សន្តិភាពជាតិ» ។ ច្បាប់ដែលបានដាក់ស្នើឡើងនឹងតម្រូវឲ្យមានចៅក្រមសម្រាប់កំណត់ការព្យួរទោស នៅពេលដែលៈ ១)ជនជាប់ចោទជាសមាជិកនៃ«ក្រុមប្រដាប់អាវុធនៅក្រៅច្បាប់» ដែលបានប្រកាសពីបទឈប់បាញ់គ្នា ហើយកំពុងតែរួមចំណែកយ៉ាងសកម្មនៅក្នុងដំណើរការសន្តិភាព ឬជាបុគ្គលមួយរូបដែលបានស្ម័គ្រចិត្តលះបង់ការតស៊ូអាវុធ ។ ២)ទណ្ឌិតបានសន្យាថាឈប់ប្រព្រឹត្តបទឧក្រិដ្ឋម្តងទៀត និងអនុវត្តច្បាប់ទាំងឡាយដែលមានប្រយោជន៍ចំពោះសំណងការខូចខាតដល់ជនរងគ្រោះដើម្បីបញ្ចប់ជម្លោះនិងសន្តិភាព ។

បុគ្គលដែលបានទទួលការព្យួរទោសនឹងតម្រូវឲ្យធ្វើកិច្ចការមួយចំនួនដើម្បីសងការខូចខាតចំពោះជនរងគ្រោះដើម្បីបញ្ចប់ដើម្បីឬសម្រេចសន្តិភាពក្នុងតំបន់ ។ ការឃ្លាំមើលពីតុលាការនឹងមានរយៈពេលត្រឹម៥ឆ្នាំ ។ ការដាក់ទោសអាចធ្វើតាមវិធីផ្សេងគ្នា មានដូចជាការហាមប្រាមមិនឲ្យស្វែងរកមុខតំណែងដែលទទួលបានដោយការបោះឆ្នោត ការងារជាបុគ្គលិក ការងារសាធារណៈ ការកាន់កាប់អាវុធ ការរស់នៅឬធ្វើដំណើរទៅកន្លែងណាមួយ ការដាក់កំហិតភូមិសាស្ត្រ និងការដាក់កំហិតមិនឲ្យទៅក្បែរឬទាក់ទងជាមួយជនរងគ្រោះ ។ បុគ្គលទាំងនេះនឹងត្រូវបង្គាប់ឲ្យបង្ហាញពីការសោកស្តាយតាមរយៈការសងជំងឺចិត្តដល់ជនរងគ្រោះដោយប្រគល់ដីធ្លីទៅឲ្យជនរងគ្រោះវិញឬបង់ប្រាក់ពិន័យ ។

ដោយសំណើនេះត្រូវបានលើកឡើងក្នុងពេលដែលគ្មានដំណើរការកសាងសន្តិភាពនៅក្នុងប្រទេសកូឡុំប៊ី រដ្ឋាភិបាលលោកយូរីប៊ី បានសន្យាជាមួយកម្លាំងទាហានប៉ារ៉ាថា ក្រោយពីបានរំសាយអ្នកទាំងនោះនឹងមិនត្រូវឃុំឃាំងទេ ។ អង្គការសង្កេតការណ៍សិទ្ធិមនុស្សបានថ្លែងថាៈ «គ្មានបទបញ្ញត្តិណាមួយនៅក្នុងច្បាប់ដែលធានាឲ្យបាននូវការស៊ើបអង្កេតមិនលម្អៀងឬការកាត់ទោសឲ្យបានត្រឹមត្រូវទេ ។ គ្មានគ្រឿងលើកទឹកចិត្តដែលនឹងជំរុញឲ្យជនជាប់ចោទប្រាប់ការពិតអំពីឧក្រិដ្ឋកម្មឡើយ ជាពិសេសនៅពេលដែលអ្នកជាប់ពាក់ព័ន្ធជាមន្ត្រីរដ្ឋាភិបាលឬនាយទាហាន ។ គ្មានយន្តការណាមួយដែលបានដាក់ស្នើឡើងដើម្បីអនុញ្ញាតជនរងគ្រោះនៃអំពើឃោរឃៅតវ៉ាចំពោះការសម្រេចចិត្តរបស់លោកប្រធានាធិបតី ដើម្បីកំណត់ថានរណាអាចរួចផុតពីការដាក់

ទោសឡើយ» ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកូឡុំប៊ី បានចេញសេចក្តីប្រកាសព័ត៌មានមួយបញ្ជាក់ថា សំណើច្បាប់បើកចំហឲ្យមានការរួចទោស ហើយ«អនុញ្ញាតឲ្យរដ្ឋប្រើប្រាស់ការដាក់ទោសតាមជម្រើសផ្សេងចំពោះជនដែលមានការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋអន្តរជាតិ ដោយមូលហេតុថា ការដាក់ទោសតាមជម្រើសផ្សេងជាកម្រិតទាបពេក វារំលោភទៅលើទ្រឹស្តីប្រជាធិបតេយ្យនៃការដាក់ទោសឲ្យបានសមស្របទៅតាមកម្រិតនៃទោសពៃរ៍» ។ ឧត្តមស្នងការអង្គការសហប្រជាជាតិក៏បានកត់សម្គាល់ដែរអំពីកង្វះខាតនៃគម្រោងសងការខូចខាតដែលពុំបានការពារសិទ្ធិជនរងគ្រោះឲ្យបានគ្រប់គ្រាន់ ។ សេចក្តីថ្លែងការណ៍នេះបានបង្ហាញថា តុលាការព្រហ្មទណ្ឌអន្តរជាតិមានដែនសមត្ថកិច្ចទៅលើអំពើទាំងឡាយណាដែលបង្កជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងទឹកដីកូឡុំប៊ី ។

សហរដ្ឋអាមេរិកខ្វាយខ្វល់ចំពោះច្បាប់ដាក់ទោសតាមជម្រើសផ្សេងដែលបានស្នើឡើង ។ ការបារម្ភចម្បងរបស់អាមេរិកគឺថា ឧក្រិដ្ឋជនរត់ពន្ធគ្រឿងញៀនអាចកេងយកប្រយោជន៍ពីច្បាប់នេះ ហើយព្យាយាមគេចពីការត្រូវធ្វើបត្យាប័នទៅឲ្យសហរដ្ឋអាមេរិក ។ ក្រុមទាហានប៉ារ៉ាមីលីទែរ ព្រៃត្រូវបានបង្ហាញថាមានការពាក់ព័ន្ធជាមួយការជួញដូរគ្រឿងញៀននៅក្នុងប្រទេសកូឡុំប៊ី ។ ដើម្បីចៀសវាងស្ថានភាពបែបនេះ សហរដ្ឋអាមេរិកបានទាមទារឲ្យរដ្ឋាភិបាលកូឡុំប៊ីធានាឲ្យបានថា ការចោទប្រកាន់ទៅលើអ្នកដែលយកចំណេញពីច្បាប់ គួរផ្អែកទៅលើហេតុការណ៍ជាក់លាក់ជាដាច់ចំណុចទូទៅ ។ ដោយយល់ស្របជាមួយនឹងអ្នករិះគន់ សហរដ្ឋអាមេរិកបានផ្តល់យោបល់ថា គួរផ្តល់តួនាទីមួយដល់ជនរងគ្រោះឲ្យចូលរួមក្នុងដំណើរការនេះ ហើយការដាក់ទោសដែលបានកំណត់គួរតែសមស្របទៅនឹងការខូចខាត ។

## តើអ្វីទៅជាការស៊ើបអង្កេតពិតប្រាកដ?

បញ្ហានៃការបំពេញឲ្យគ្នានឹងមានសារសំខាន់បំផុតនៅក្នុងប្រទេសកូឡុំប៊ីដែលមានប្រព័ន្ធយុត្តិធម៌មួយដែលហាក់ដូចជាមានដំណើរការទោះបីជាការរួចទោសនៅតែកើតឡើងក៏ដោយ ។ ប្រសិនបើសំណើនៃការរួចទោសនេះ ឬអ្វីប្រហាក់ប្រហែលគ្នាត្រូវបានអនុម័តជាច្បាប់ ព្រះរាជអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិចាំបាច់ត្រូវតែពិចារណាថាតើគួរចាត់ទុកកិច្ចព្រមព្រៀងលើកលែងទោសបែបនោះជាការហាមប្រាមដល់ការកាត់ទោសចំពោះបទឧក្រិដ្ឋផ្សេងៗដែលអាចឋិតនៅក្រោមដែនសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែរឬទេ ។ ជាក់ស្តែង សំណួរបែបនេះនឹងគ្រាន់តែលេចឡើងនៅក្នុងករណីមានបទឧក្រិដ្ឋដែលបានប្រព្រឹត្តបន្ទាប់ពីការចូលជាសមាជិករបស់ប្រទេសកូឡុំប៊ី (ពីព្រោះដែនសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិមិនគ្របដណ្តប់ទៅលើហេតុការណ៍ពីអតីតកាលទេ) ។

លក្ខន្តិកៈច្បាប់ទីក្រុងរ៉ូមមិនបានបញ្ជាក់អំពីលក្ខខណ្ឌដែលធ្វើឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិគួរគោរពកិច្ចព្រមព្រៀងលើកលែងទោសនោះទេ ។ ប្រទេសកូឡុំប៊ីក៏មិនអាចធានាថាការលើកលែងទោសដែលខ្លួនបានដាក់ស្នើឡើងនឹងចៀសផុតពីការរិះគន់ពីអន្តរជាតិនោះដែរ ។ តាមរយៈមាត្រាទី១៧នៃលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូម រឿងក្តីមួយដែលកំពុងស៊ើបអង្កេត (ឬបានស៊ើបអង្កេត) ដោយភាគីរដ្ឋមួយ អាចកាត់សេចក្តីបានដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ប្រសិនបើ«រដ្ឋនោះមិនមានឆន្ទៈ (ឬខ្វះលទ្ធភាព) ក្នុងការស៊ើបអង្កេតឬកាត់ទោស» ។ លក្ខន្តិកៈច្បាប់នេះពន្យល់ទៀតថា ក្នុងការកំណត់អំពី«កង្វះឆន្ទៈ»នៅក្នុងរឿងក្តីណាមួយ តុលាការព្រហ្មទណ្ឌអន្តរជាតិគួរពិចារណាទៅលើបីចំណុច ។ ទី១) តើដំណើការកាត់ទោស ឬការសម្រេចចិត្តថ្នាក់ជាតិត្រូវបានធ្វើឡើង«ក្នុងគោលបំណងការពារជនដែលជាប់ពាក់ព័ន្ធពីការទទួលខុសត្រូវពីបទឧក្រិដ្ឋដែលឋិតក្រោមដែនសមត្ថកិច្ចរបស់តុលាការឬទេ» ទី២) តើដំណើរការកាត់ក្តីត្រូវបានធ្វើឡើងដោយឯករាជ្យនិងមិនលម្អៀងឬទេ ។ ទី៣) តើ«ដំណើរការកាត់ក្តីត្រូវបានធ្វើឡើងតាមរបៀបមួយដែលនៅក្នុងកាលៈទេសៈនោះមិនស្របតាមគោលបំណងដើមនៃការនាំជនជាប់ពាក់ព័ន្ធឡើងតុលាការឬទេ»? ការបំពេញឲ្យគ្នាសំដៅទៅរកការស៊ើបអង្កេតព្រហ្មទណ្ឌតែប៉ុណ្ណោះ ។

នៅក្នុងការពិភាក្សាអំពីកិច្ចព្រមព្រៀងទៅលើការលើកលែងទោស បញ្ញាជនផ្នែកច្បាប់បានព្យាយាមញែកការលើកលែងទោសនៅប្រទេសអាហ្វ្រិកខាងត្បូងចេញពីនីតិវិធីផ្សេង

ទៀត ដោយសារថា ការលើកលែងទោសនៅប្រទេសអាហ្វ្រិកខាងត្បូងមានលក្ខណៈខុសប្លែកពីគេ គឺតម្រូវឲ្យមានសវនាការនិងការឆ្លើយសារភាព ។ មិនមានប្រទេសណាមួយនៅអាមេរិកឡាទីនចម្លងតាមគំរូប្រទេសអាហ្វ្រិកខាងត្បូងដែលផ្តល់ការលើកលែងទោសឲ្យជនទាំងឡាយណាដែលបានទទួលស្គាល់កំហុសនៅក្នុងសវនាការរបស់គណៈកម្មាធិការស្វែងរកការពិតនោះទេ ។ នៅពេលដែលសំណើបច្ចុប្បន្នរបស់ប្រទេសកូឡុំប៊ីទទួលយក “ការកំណត់ដោយបុគ្គល” នៃការលើកលែងទោសរបស់ប្រទេសអាហ្វ្រិកខាងត្បូង តម្រូវការរបស់សំណើគឺមិនតឹងរ៉ឹងទេ បើប្រៀបធៀបទៅនឹងការទាមទារឲ្យមានការបកស្រាយពេញលេញអំពីការចូលរួមរបស់បុគ្គលនៅក្នុងអំពើឧក្រិដ្ឋនិងមូលហេតុនយោបាយច្បាស់លាស់ ។ គំរូរបស់ប្រទេសកូឡុំប៊ីអាចត្រូវបានអនុវត្តនៅក្រោមដំណើរការស្វែងរកសន្តិភាព ឬការពិតនិងយុត្តិធម៌ ។ នៅពេលដែលទាមទាររកតុលាការដែលមានលក្ខណៈបុគ្គល សំណើនេះផ្តោតសំខាន់ទៅលើភាពប្តូរផ្តាច់របស់បុគ្គលនៅថ្ងៃមុខក្នុងការទាមទាររកសន្តិភាព ជាជាងស្វែងរកការការពារសិទ្ធិរបស់ជនរងគ្រោះនិងការពិតថាតើបទឧក្រិដ្ឋដែលបានធ្វើមានមូលហេតុនយោបាយឬទេ ។ ការស៊ើបអង្កេតព្រហ្មទណ្ឌកាន់តែមិនអាចធ្វើបានថែមទៀត ។ សំណើនេះមិនបានអើពើចំពោះសម្តីរបស់អតីតប្រធានាធិបតីប៉ាស្ត្រាណា ដែលបានរៀបរាប់អំពីដែនកំណត់នៃការលើកលែងទោស ។ មិនតែប៉ុណ្ណោះ សំណើរនេះថែមទាំងមិនបានអើពើចំពោះទស្សនាទានច្បាប់របស់ប្រព័ន្ធសិទ្ធិមនុស្សអន្តរអាមេរិកាំង និងទ្រឹស្តីដែលហាមប្រាមការលើកលែងទោសចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ទៀតផង ។

## តួនាទីរបស់សហរដ្ឋអាមេរិក

ដោយសារអំណាចរបស់សហរដ្ឋអាមេរិកអសមានចិត្តរបស់សហរដ្ឋអាមេរិកចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិមានឥទ្ធិពលខ្លាំងនៅក្នុងប្រទេសជាច្រើននៅអាមេរិកឡាទីន ។ អាមេរិកកណ្តាលពឹងពាក់ច្រើនលើសហរដ្ឋអាមេរិក ។ ប្រទេសកូឡុំប៊ីជាអ្នកនាំមុខគេក្នុងតំបន់ខាងទទួលជំនួយសេដ្ឋកិច្ចនិងយោធា ។ នៅក្នុងខែកន្លងទៅថ្មីៗនេះ សហរដ្ឋអាមេរិកបានទទូចឲ្យមាន “កិច្ចព្រមព្រៀងលើកលែងទោស” ទ្វេភាគី ដើម្បីធានាថាបុគ្គលិករបស់អាមេរិកនឹងមិនត្រូវប្រគល់ ឬផ្ទេរទៅឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិពីប្រទេសទាំងអស់ដែលបានផ្តល់សច្ចានុម័តឲ្យសន្ធិសញ្ញាទីក្រុងរ៉ូម និងពីប្រទេសដែលមិនបានផ្តល់ដោយគ្មានការអនុញ្ញាតពីសហរដ្ឋអាមេរិក ។ ប្រទេសដែលមិនបំពេញតាមការទាមទាររបស់សហរដ្ឋអាមេរិកអាចនឹងគ្មានជំនួយយោធា ។ ថ្មីៗនេះជំនួយយោធាមានទឹកប្រាក់ចំនួន៥លានដុល្លារអាមេរិក (ក្នុងជំនួយ ១៣០ លានដុល្លារសម្រាប់ឆ្នាំនេះ) ត្រូវបានដកហូតជាបណ្តោះអាសន្នរហូតដល់ប្រទេសកូឡុំប៊ីយល់ព្រមចំពោះបទបញ្ញត្តិបែបនោះ ។

នៅក្នុងតំបន់មួយដែលសម្ងំទៅខាងជើង ការបដិសេធរបស់សហរដ្ឋអាមេរិកចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិមានឥទ្ធិពលយ៉ាងធំធេង ។ ការទាមទាររបស់សហរដ្ឋអាមេរិកអំពីកិច្ចព្រមព្រៀងលើកលែងទោសទ្វេភាគី ពង្រឹងដោយការផ្អាកជំនួយយោធាបានធ្វើឲ្យកិច្ចប្រឹងប្រែងបង្កើតតុលាការដ៏រឹងមាំមួយចុះខ្សោយ ។ រដ្ឋាភិបាលនៅក្នុងតំបន់បានយល់ព្រមក្រោមសម្ពាធរបស់សហរដ្ឋអាមេរិក ទោះបីជាមានការបដិសេធពីអ្នកគាំទ្រសិទ្ធិមនុស្សនិងពីគណបក្សប្រឆាំងក៏ដោយ ។ ប្រទេសជាច្រើនដូចជា អែលសាល់វ៉ាដ័រ និងនីការ៉ាហ្កា ដែលមិនបានចុះហត្ថលេខា ឬផ្តល់សច្ចានុម័តឲ្យលក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានចុះហត្ថលេខាទៅលើកិច្ចព្រមព្រៀងលើកលែងទោសទ្វេភាគីជាមួយសហរដ្ឋអាមេរិក ក៏ដូចជាភាគីរដ្ឋផ្សេងទៀត (ដូចជា បូលីវៀ កូឡុំប៊ី និងហុងឌូរ៉ាស) ។

ការពុះពារមិនផ្តល់សច្ចាប័ននៅក្នុងប្រទេសផ្សេងទៀតនៅក្នុងទ្វីបអាមេរិកឡាទីន ប្រហែលជាជំហានចុងក្រោយក្នុងការប្រើប្រាស់តុលាការព្រហ្មទណ្ឌអន្តរជាតិឲ្យបានពេញលេញនៅក្នុងទ្វីបអាមេរិកឡាទីន ។ ការធានាឲ្យបាននូវការអនុវត្តច្បាប់មួយរយភាគរយនៅទ្វីបអាមេរិកឡាទីន ហើយនិងដែនសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិលើរឿងក្តីនៅក្នុងប្រទេសកូឡុំប៊ី ក៏ដូចជាការលើកលែងទោសចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបានបង្កជាឧបសគ្គធំធេងដល់ដំណើរការពេញលេញរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។

**ម៉ាហ្គារ៉េត ផប់គីន**

# ខៀវ សំផន ធ្វើស្វ័យទិតៀនឆ្នាំ២០០៤



ខៀវ សំផន

សុភាសិតមួយបាននិយាយក្នុងលំនាំនេះថា «គោដំបៅខ្នងភ្លែកហើររំលងវាបក់កន្ទុយ» ។ ចំពោះខ្ញុំផ្ទាល់ ខ្ញុំជឿថា គោដែលបក់កន្ទុយពេលក្អែកហើររំលងមិនប្រាកដ១០០ភាគរយថាពិតជាគោដំបៅខ្នងនោះទេ ។ ពោលគឺអាចមានករណីដែលគោមួយបក់កន្ទុយចៃដន្យចំពេលដែលក្អែកហើររំលង ប៉ុន្តែគោនោះមិនមានដំបៅក៏ថាបាន ។ ដូចគ្នានេះដែរ ខ្ញុំជឿថា ខៀវ សំផន នៅតែជាជនបរិសុទ្ធរហូតលុះត្រាតែមានតុលាការកាត់សេចក្តីថាគាត់មានទោស ។ អ្នកច្បាប់ក៏ជឿយ៉ាងដូច្នេះដែរ ។ ពេលឃើញតុលាការកំពុងខិតជិតមកមិនទាន់ទាំងបានកាត់សេចក្តីផង ស្រាប់តែ ខៀវ សំផន បក់កន្ទុយមុនទៅហើយ ។ ទោះបីជាតុលាការមិនទាន់កាត់សេចក្តីក៏ដោយ ក៏ខ្ញុំមិនទាន់ជឿថាគាត់មានទោសដែរ ប៉ុន្តែការបក់កន្ទុយនេះធ្វើឲ្យខ្ញុំកាន់តែចង់ដឹងការពិតខ្លាំងឡើងទៀត ។

ខណៈដែលប្រជាជនជាច្រើនកំពុងចាប់អារម្មណ៍អានសៀវភៅគាត់យ៉ាងកុះករចង់ដឹងការពិតនេះ ខ្ញុំតែងរំឭកខ្លួនឯង មិត្តភក្តិ និងមិត្តរួមការងារថា ការពិតមិនប្រាកដថាបានមកពីសម្តីបុគ្គលម្នាក់ទេ ។ ដូច្នេះចំណងជើងសៀវភៅរបស់ ខៀវ សំផន គួរតែដាក់ថា «ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះតាមទស្សនៈរបស់ខ្ញុំ» វិញ ។ មូលហេតុគឺថា ក្នុងឋានៈជាអ្នកមានសញ្ញាប័ត្រថ្នាក់បណ្ឌិតតាំងពី៥០ឆ្នាំមុននោះ ការសរសេរប្រវត្តិសាស្ត្រតាមរបៀបសៀវភៅ ខៀវ សំផន នេះ ដោយមិនបានបញ្ជាក់ថា តាមរយៈទស្សនៈខ្លួនឯងតែម្នាក់ពិតជាមានការខុសចន្លោះច្រើនពេកហើយ ។ ក្រៅពីព្រឹត្តិការណ៍ដែលគាត់បានជួបនិងឃើញផ្ទាល់ ហើយយកមកសរសេរ គាត់មិនបានយោងប្រភពគ្រប់គ្រាន់ទេ ។ នេះមិនគិតដល់ការក្តោបយកប្រវត្តិសាស្ត្រជិត៤០ឆ្នាំមកដាក់ក្នុងសៀវភៅមិនដល់២០០ទំព័រផងនោះ ។ ម្យ៉ាងវិញទៀត អ្នកអានអាចសួរបានថាតើហេតុដូចម្តេចបានជា ខៀវ សំផន មិនសរសេរតាំងពីយូរមក ឬមួយចាំបក់កន្ទុយពេលក្អែកហើរមកកៀក? ខ្ញុំជឿថា ខៀវ សំផន ពិតជាមានហេតុផលរបស់គាត់ ប៉ុន្តែនេះប្រហែលជាមិនមែនជាហេតុផលរបស់គាត់ចង់ប្រាប់អ្នកអានទេមើលទៅ?

ទោះជាយ៉ាងណាក៏ដោយ ខ្ញុំទទួលស្គាល់សៀវភៅរបស់ ខៀវ សំផន ថាជាការធ្វើស្វ័យទិតៀន ឬជាចម្លើយសារភាពមួយដែលជាទម្លាប់របស់បណ្តាសមមិត្ត ឬរបបកុម្មុយនិស្ត ដែល ខៀវ សំផន បានស្គាល់ច្រើនមកហើយ ។ ខ្ញុំអាចមើលឃើញថា លើកនេះអ្វីដែលប្លែកគឺគាត់និយាយការពារច្រើនជាងទិតៀនខ្លួនឯង ហើយគាត់ក៏មិននិយាយពីអ្នកនៅក្បែរខ្លួន ឬនិយាយឲ្យបានអស់នូវអ្វីដែលខ្លួនបានឃើញបានដឹងដែរ ។

ចម្លែកដែរ លើកនេះបន្ទាប់ពីគាត់ស្វ័យទិតៀនហើយគ្មាននរណាធ្វើដូចជំនាន់ខ្មែរក្រហមរបស់គាត់ដែលយកប្រជាជននិងសមមិត្តខ្លួនឯងទៅដាក់គុកឬសម្លាប់ចោលដោយគ្មានតុលាការកាត់ទោសនោះទេ ។ កាន់តែចម្លែកទៅទៀតនោះគឺចម្លើយសារភាពនេះគ្មាននរណាបង្ខំគាត់ឡើយ ។ ប៉ុន្តែ ខៀវ សំផន ពិតជាមិនចង់ឲ្យនរណាកាត់សេចក្តីគាត់ដូចជំនាន់របស់គាត់ដែលកាត់សេចក្តីអតីតសមមិត្តរបស់គាត់ទេ ។ អតីតយុទ្ធជនម្នាក់រស់នៅខេត្តកំពង់ឆ្នាំងបាននិយាយទាំងអន្ទះសាថា បើសមមិត្តរបស់គាត់នៅរស់វិញប្រាកដជាចង់បានយុត្តិធម៌និងការកាត់សេចក្តីត្រឹមត្រូវជាងគាត់ទៅទៀត ហើយខ្ញុំសូមបន្ថែមថា អ្នកទាំងនោះចង់បានយុត្តិធម៌ជាងមេដឹកនាំ ខៀវ សំផន របស់ខ្លួន

ទៅទៀត ។

បណ្ដាសមមិត្តរបស់ ខៀវ សំផន ដែលស្លាប់យ៉ាងអយុត្តិធម៌ និងតវ៉ាដោយគ្មាននរណាដឹងឮមានចំនួនរាប់ពាន់នាក់ នេះគិតត្រឹមតែនៅគុកទួលស្លែង(ស-២១)ប៉ុណ្ណោះ ។ នៅក្នុងដួងព្រលឹងរបស់បណ្ដាសមមិត្តទាំងនោះ (ទាំងអ្នករស់ ទាំងអ្នកស្លាប់) ប្រាកដជាអស់សង្ឃឹម ហើយស្គាល់មេៗកាន់តែច្បាស់ ប្រសិនបើដឹងថាមេៗរបស់ខ្លួន ដែលពីមុនធ្លាប់ខ្លួនតវ៉ាយ៉ាងម៉េចក៏មិនឮ ឥឡូវបែរជាមកទាររកយុត្តិធម៌តែម្នាក់ឯងទៅវិញ ។ ក្នុងចំណោមអ្នកទាំងនេះ ខ្ញុំសូមលើកយកករណីសមមិត្ត ហ៊ូ នឹម (រដ្ឋមន្ត្រីក្រសួងឃោសនាការ) ដែលខៀវ សំផន ស្គាល់ជិតស្និទ្ធបំផុត ហើយដែលបានអះអាងថា នៅសម័យនោះមិនបានដឹងពីការចាប់ការតវ៉ា ឬការសម្លាប់អ្វីទាំងអស់ ។

ហ៊ូ នឹម ជាអ្នកទោសដែលបន្តប់នូវការតវ៉ាយ៉ាងអាថ៌កំបាំង ដែលការតវ៉ារបស់គាត់គ្មាននរណារកខុសរកត្រូវ ឬដឹងឮជាសារធារណៈដូច ខៀវ សំផន ហើយថែមទាំងរងទារុណកម្មទៀតផង ។

ហ៊ូ នឹម កើតនៅឆ្នាំ១៩៣០(ឆ្នាំមមី)ក្នុងត្រកូលកសិករ នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ ហ៊ូ នឹម បានទទួលសញ្ញាប័ត្រទុតិយភូមិនៅវិទ្យាល័យព្រះស៊ីសុវត្ថិ និងបានទទួលអាហារូបករណ៍ទៅសិក្សាថ្នាក់ឧត្តមសិក្សានៅប្រទេសបារាំង ។ នៅក្នុងសម័យសង្គមរាស្ត្រនិយម ហ៊ូ នឹម ធ្លាប់កាន់តំណែងខ្ពស់ៗ ដូចជា ធ្វើជាតំណាងរាស្ត្រ និងជាសមាជិកគណៈកម្មាធិការកែទម្រង់សេដ្ឋកិច្ច ។ មកដល់ឆ្នាំ១៩៦៧ ហ៊ូ នឹម បានរត់ចូលព្រៃតស៊ូធ្វើបដិវត្តន៍ខ្មែរក្រហម ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហ៊ូ នឹម មាននាទីជារដ្ឋមន្ត្រីក្រសួងឃោសនាការ ។ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៧ ពេលដែលគាត់កំពុងតែមមាញឹករៀបចំកម្មវិធីដង្ហាយបុណ្យខួប ១៧ មេសា គាត់ក៏ត្រូវចាប់ខ្លួន ដោយចោទថាជាខ្សែសេ.អ៊ី.អា និងចង់បង្កើតបក្សថ្មី ។ ហ៊ូ នឹម បានត្រូវសម្លាប់នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៧ បន្ទាប់ពីឆ្លើយតវ៉ាថាគ្មានកំហុស ។ នៅទីបំផុត ហ៊ូ នឹម សម្រេចសរសេរថា "បានក្បត់មែន" ប៉ុន្តែបើពិនិត្យតាមខ្លឹមសារនៃការសរសេរនោះឲ្យបានច្បាស់លាស់ ហ៊ូ នឹម មិនខុសពីកម្មាភិបាលដែលត្រូវចាប់មុនៗឡើយ គឺកម្មាភិបាលទាំងនេះតែងបានបន្តប់នូវការតវ៉ាមួយយ៉ាងសម្ងាត់និងស៊ិតស្អាញបំផុត ។ ដូចគ្នានឹងលំនាំទូទៅនៃចម្លើយរបស់អ្នកទោសនៅគុកទួលស្លែងដែរ ហ៊ូ នឹម បានសរសេរថា គាត់មានពាក់ព័ន្ធជាមួយកម្មាភិបាលដែលត្រូវចាប់មុនគាត់បន្តបន្ទាប់ ដូចជា ចាន់ ចក្រី (លេខាកងពល ១៧០ និងសេនាធិការ) សួស នៅ ហៅ ឈូក (លេខាតំបន់២៤) ម៉ែន សាន ហៅ យ៉ា (លេខាភូមិភាគព្យសាននិងភ័ស្តុភារសេនាធិការ) កុយ ធួន ហៅ ឃួន លេខាភូមិភាគឧត្តរនិងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម) និង ស្បូវ អឿន (លេខាកងពល៣១០) ជាដើម ។ អ្នកទាំងអស់នេះ សុទ្ធតែត្រូវបានចោទថា បង្កើតបក្សថ្មីដែលមានលក្ខណៈសេរីនិយម បម្រើឲ្យសេ.អ៊ី.អា ឬវៀតណាម និងការព្យាយាមប៉ះបោរដណ្ដើមអំណាចពី ប៉ុល ពត ។ រយៈពេល៨៦ថ្ងៃ នៅក្នុងគុកទួលស្លែង ហ៊ូ នឹម ត្រូវឈ្មោះទង់ សិងហឿន ហៅ ប៉ុន ជាអ្នកសួរចម្លើយនិងធ្វើទារុណកម្មក្រោមការបញ្ជាផ្ទាល់ពីមេគុកឈ្មោះ កាំង ហ្គិចអៀវ ហៅឌុច ។ ចម្លើយសារភាពរបស់គាត់សរុបមានចំនួន៩០ទំព័រ ។ នៅថ្ងៃចាប់ខ្លួនភ្លាម ហ៊ូ នឹម បានសរសេររៀបរាប់ចំនួន១៧ទំព័រ(សម្ដែងភាពស្មោះសរបស់ខ្លួនចំពោះបក្សបក្សកុម្មុយនិស្តកម្ពុជា) ។ គាត់បានសរសេរដោយមានការភ្ញាក់ផ្អើលជាខ្លាំងៈ "ខ្ញុំគ្មានចិត្តគំនិតអីក្បត់បក្សទេ ហើយគ្មានខ្សាំងសេ.អ៊ី.អាណា ពួកចក្រពត្តិសេរីនិយមណា ឬពួកយួន ឬពួកអាសឹង ង៉ុកថាន់ ណាមកចាត់តាំងខ្ញុំឲ្យបន្តប់ក្នុងបក្ស យើងបំផ្លាញបក្សយើងទេ ។ បើបក្សសម្លាប់ខ្ញុំ ក៏ខ្ញុំនៅឆ្លើយយ៉ាងនេះរហូតដល់ដង្ហើមចុងបំផុត ។" ហ៊ូ នឹម បានបន្តសុំឲ្យបក្សអនុញ្ញាតឲ្យខ្លួនចូលរួមបុណ្យ១៧មេសានេះទៀតផង ។

នៅថ្ងៃបន្ទាប់គឺត្រូវនឹងថ្ងៃទី១១-១២ ខែមេសា ហ៊ូ នឹម សរសេរបាន១១ទំព័រទៀត គាត់នៅតែបន្តបកស្រាយភាពបរិសុទ្ធស្មោះត្រង់របស់គាត់ចំពោះបក្សដដែល ។ ចម្លើយលើកនេះដូចមុនដែរ គាត់សរសេរទៅកាន់ "បងប៉ុល បងនួន បងវ៉ាន់ បងវន សមខៀវ សមហែម" មិនបានសរសេរផ្ទាល់ទៅ ប៉ុន អ្នកសួរចម្លើយនោះទេ ។ គាត់សរសេរថា "ខ្ញុំពុំស្មានថាខ្លួនខ្ញុំដែលអង្គការស្គាល់បងៗស្គាល់និងអប់រំ ហើយបំពេញភារកិច្ចទាំងយប់ទាំងថ្ងៃតាំងពីចូលបក្សមកដោយស្មោះត្រង់បំផុត មកជាប់ចោទដ៏ធ្ងន់ធ្ងរយ៉ាង

នេះទេ ។» លើសពីនេះនៅថ្ងៃទី១៣ ខែមេសា ហ៊ូ នឹម បានសរសេរកំណាព្យរៀបរាប់អំពីជីវិតកំព្រាឪពុក ការក្រលំបាក ម្តាយឈឺអត់ថ្នាំ ហើយដែលគាត់បានកត់ចំណាំថា នឹងស្មោះត្រង់ជាមួយជាតិ ជាមួយកម្មករកសិករជានិច្ច ។ គាត់ហាក់បីដូចជាកំពុងរំឭកគុណម្តាយនៅគ្រាចុងក្រោយ ម្យ៉ាងហាក់ដូចជាសុំអង្វរបក្សថាកុំសម្លាប់ខ្លួន ព្រោះខ្លួនជាកូនកសិករក្រជាអ្នកតស៊ូដែរ ។ គ្រានេះ ហ៊ូ នឹម មិនបានដឹងសោះថា អ្នកដែលត្រូវបានចាប់មកទួលស្លែង គឺមានន័យថាមានទោសរួចជាស្រេចទៅហើយ ។ សំណេររបស់គាត់មិនបានទទួលលទ្ធផលអ្វីទេ ហើយបែរជាធ្វើឲ្យអ្នកសួរចម្លើយកាន់ខឹងថែមទៀត ។ ដាក់ស្លែង បន្ទាប់ពីអានចម្លើយរួច ប៉ុនបានវាយ ហ៊ូ នឹម នឹងរំពាត់ ហើយយកទៅបញ្ច្រាកទឹក រួចរាយការណ៍ទៅ ឌុច នៅថ្ងៃទី១៤មេសាថា ការវាយដំនេះគឺដើម្បីបំបាក់ដំហរ ។ មិនឃើញមានឯកសារណាបញ្ជាក់ថា ឌុច បានបញ្ជាទៅ ប៉ុន យ៉ាងណាទេ ប៉ុន្តែនៅលើចម្លើយមានចំណារ ទំនងអក្សររបស់ ឌុច សរសេរថា «មិនទាន់សារភាពសោះ» ។ ការធ្វើទារុណកម្មបំបាក់ដំហរពិតជាបានជោគជ័យមែន ព្រោះថាចាប់ថ្ងៃទី១៤ មេសា រហូតដល់ថ្ងៃបញ្ចប់ ហ៊ូ នឹម ពិតជាឆ្លើយដូចដែលអ្នកសួរចង់បាន ថាខ្លួនជាភ្នាក់ងារសេ.អ៊ី.អា ដែលដុយស្រឡះនឹងចម្លើយមុនពេលទទួលរងទារុណកម្ម ។ ប៉ុន្តែនៅពេលចាប់ផ្តើមសរសេរ ហ៊ូ នឹម ហាក់ដូចកំពុងតវ៉ាលួចខ្សឹបប្រាប់នរណាម្នាក់ថាចម្លើយខ្លួនដែលសរសេរនេះ ចេញមកពីការបង្ខិតសុទ្ធសាធ ដោយបក្សជឿថាគាត់មានទោសរួចទៅហើយ ដូចនេះគាត់ត្រូវតែសរសេរដើម្បីចៀសវាងការទទួលទារុណកម្ម ។ គាត់សរសេរក្នុងន័យនេះថា «ឥឡូវបក្សវិនិច្ឆ័យខ្ញុំថាខ្មាំងហើយ ។ ខ្ញុំសូមប្រគល់ខ្លួនជូនបក្សហើយ» ។ ដូចគ្នានេះដែរ ដើម្បីចង់បង្ហាញភាពបរិសុទ្ធរបស់គាត់ ទោះបីគាត់កំពុងសរសេរថាក្បត់ ក៏គាត់នៅតែទទូចសុំឲ្យបក្សប្រៀបធៀបចម្លើយគាត់ លើកមុននិងក្រោយហើយធ្វើការវិនិច្ឆ័យផង ។ ក្រោយមកគាត់ហាក់ដូចជាដឹងថា ស្លាប់កាន់តែរហ័សល្អជាងនៅរស់ទទួលទារុណកម្ម ។ ដូចនេះគាត់ក៏សរសេរថា«ខ្ញុំគ្មានលាក់បាំងអីទៀតទេ ។...ហើយខ្ញុំលាក់ក៏គ្មានអីចំណេញចំពោះខ្ញុំ ព្រោះខ្ញុំត្រូវតែស្លាប់ទៅហើយ» ។

តាមពិតការតវ៉ាក្នុងចម្លើយសារភាពរបស់ ហ៊ូ នឹម មានដាក់ថាផ្ញើទៅកាន់សមមិត្តហែម (ឬ ខៀវ សំផន) ដែរ ។ ខៀវ សំផន បានឆ្លើយថាគាត់មិនបានដឹងឮពីការចាប់ខ្លួននិងចម្លើយរបស់កម្មាភិបាលក្រសួងឃោសនាការឡើយ ។ បើតាមសៀវភៅដែលគាត់ចេញផ្សាយថ្មីៗនេះ ខៀវ សំផន បានសរសេរថា ហ៊ូ នឹម បានលះបង់ តស៊ូស្នេហាជាតិ និងជឿជាក់មកលើបក្សគឺដូចអ្វីដែល ហ៊ូ នឹម បានសារភាពពីដំបូងដែរ ។ ហ៊ូ នឹម ពិតជាធ្លាប់ស្គាល់និងកម្សត់កម្រជាមួយ ខៀវ សំផន ទាំងនៅភ្នំពេញនិងនៅក្នុងព្រៃនៅចុងទសវត្សរ៍ ឆ្នាំ១៩៦០ ខៀវ សំផន បន្តថា «ខ្ញុំពុំអាចជឿថាគាត់ (ហ៊ូ នឹម) អាចក្បត់បានទេ» ។ ហ៊ូ នឹម ក៏ដូចជាប្រជាជនរាប់លាននាក់ ពិតជាស្លាប់ទៅមិនអស់ចិត្ត គាត់បានតវ៉ាតែគ្មាន អ្នកដឹងឮ ហើយគ្មានតុលាការ សូម្បីតែសមមិត្ត ហែមរបស់គាត់ ក៏មិនដឹងផង(?)» ។ ហ៊ូ នឹម ពិតជាឆ្លើយទាំងវិលវល់ «ចុកចាប់ នៅក្នុងដួងព្រលឹងនិងក្នុងខ្លួនប្រាណ» ដូច ខៀវ សំផន គិតនោះ មិនខុសទេ ។ ទោះជាយ៉ាងណាក៏ដោយ ហ៊ូ នឹម ស្លាប់ទៅមិនមានសំណាងដូចសមមិត្ត ខៀវ សំផន របស់គាត់ទេ ដែលសង្គមបច្ចុប្បន្នអាចតវ៉ាបកស្រាយជាសាធារណៈតាមរយៈតុលាការមួយដែល នឹងកាត់សេចក្តីក្នុងពេលឆាប់ៗនេះ ។

សរុបមកវិញ ខ្ញុំយល់ថាមតិស្ម័យទិតៀនរបស់ ខៀវ សំផន យ៉ាងហោចណាស់មានប្រយោជន៍ក៏ចំពោះអ្នកប្រវត្តិសាស្ត្រ ។ អ្នកប្រវត្តិសាស្ត្រអាចស្រង់បានពត៌មានថ្មីឬបានប្រភពថ្មីៗបន្ថែមពីលើពត៌មានចាស់ ជាពិសេសត្រង់ព្រឹត្តការណ៍ដែលគាត់បានជួបផ្ទាល់ ឬឃើញផ្ទាល់ភ្នែក ។ ខ្ញុំយល់ថា ខៀវ សំផន គួរតែសរសេរសៀវភៅឲ្យបានច្រើនជាលក្ខណៈវិទ្យាសាស្ត្រ ឬជាលក្ខណៈជំនាញ ឲ្យសមទៅតាមសញ្ញាប័ត្រនិងបទពិសោធន៍ ដើម្បីឲ្យមានប្រយោជន៍ដល់កូនខ្មែរនិងមនុស្សជាតិជំនាន់ក្រោយ ។ ប៉ុន្តែអ្វីដែលអាចនាំឲ្យឲ្យមានគ្រោះថ្នាក់នោះ គឺអាចកើតចេញមកពីអ្នកដែលបានអានហើយយល់ថាស្អប់ ខៀវ សំផន ពេក ឬជឿស៊ប់លើ ខៀវ សំផន ពេក ហើយងាកទៅរកផ្លូវកាត់ក្តីមុនពេលមានតុលាការ ។ ដូចយើងធ្លាប់ដឹងហើយ ការអានឬស្តាប់មតិមួយអាចនាំឲ្យមានការស្អប់ ស្រលាញ់ រហូតដល់ការចូលធ្វើបដិវត្តន៍ហើយសម្លាប់មនុស្សដោយគ្មានតុលាការ និងការវាយបំផ្លាញស្ថានទូតថៃនាពេលថ្មីៗកន្លងមកនេះជាដើម ។ **សឹម សុរិយ៉ា**

# សូមសួរទៅអតីតសមមិត្តអង្គការ


ប៉ុល ពត

អស់រយៈពេល២៥ឆ្នាំកន្លងផុតទៅហើយដែលប្រជាពលរដ្ឋនិងមាតុភូមិកម្ពុជាដ៏អភ័ព្វបាន ឆ្លងផុតពីរបបដ៏ឃោរឃៅមហាព្រៃផ្សៃប្រល័យពូជសាសន៍ ។

ពិតមែនតែរយៈពេលកន្លងទៅនេះមានរយៈពេលយូរមកហើយក្តី  ក៏ប៉ុន្តែស្លាកស្នាមនៃ អតីតកាលដ៏ជូរចត់រកទីបំផុតគ្មាននេះវាបានបន្សល់ទុកគ្មានថ្ងៃភ្លេចសម្រាប់ជាប្រវត្តិសាស្ត្រ របស់ជាតិខ្មែរនិងពលរដ្ឋខ្មែរគ្រប់រូបចងក្រងចារឹកទុក  ដើម្បីឲ្យកូនខ្មែរគ្រប់ជំនាន់បានរៀនសូត្រ យល់ដឹងនូវព្រឹត្តិការណ៍ដ៏គួរឲ្យរន្ធត់នេះ  ដែលក្នុងពិភពលោកគ្មានប្រជាពលរដ្ឋណាបានទទួលរងគ្រោះ ដូចជាប្រជាពលរដ្ឋកម្ពុជាទេ ហើយក៏ជាប្រយោជន៍ដើម្បីអ្នកជំនាន់ក្រោយខិតខំចៀសវាងដើម្បីកុំឲ្យ ដាននៃប្រវត្តិសាស្ត្រអតីតកាលដ៏ជូរចត់នេះលងបន្លាចប្រជាជាតិខ្មែរយើងតទៅទៀត ។


នួន ជា

បច្ចុប្បន្ននេះ  ថ្វីដ្បិតបរទេសជាតិនិងអន្តរជាតិកំពុងរៀបចំបង្កើតស្ថាប័នតុលាការដ៏សមស្រប មួយដើម្បីនាំអតីតមេដឹកនាំខ្មែរក្រហមយកទៅកាត់ទោសដោយមានឯកសារនិងភ័ស្តុតាង  និងសាក្សី គ្រប់គ្រាន់យ៉ាងណាក៏ដោយ  ក៏នៅពុំទាន់លេចចេញនូវក្តីសង្ឃឹមថា“តុលាការមួយនឹងដំណើរការ” កាត់ទោសក្នុងពេលឆាប់ៗខាងមុខនេះណាស់  ក្នុងពេលដែលមេដឹកនាំខ្មែរក្រហមទាំងឡាយកាន់តែ មានវ័យចំណាស់និងមានជំងឺរុករានជិតស្លាប់ទៅហើយ ។

ប្រសិនបើគ្មាន “ការកាត់ទោស” ពួកអតីតអង្គការទាំងនោះទេ ប្រវត្តិអតីតកាលដ៏ឃោរឃៅ នេះវាគ្រាន់តែជាប្រវត្តិសាស្ត្រដែលស្រពេចស្រពិលគ្មានន័យតែប៉ុណ្ណោះ ដែលមិនអាចយកជាបាន ការឡើយ  ព្រោះអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយពិតជា“ពុំហ៊ានជឿ” នូវរឿងរ៉ាវដ៏ខ្លោចផ្សា ក្នុងរបបវាលពិឃាតនេះទេ ។  រឿងរ៉ាវដែលបានកើតឡើងនេះនៅវិនាទីបញ្ចប់គេបែរជាពុំអាចរក ឃើញអ្នកណាជាអ្នកបង្កើត ហើយអ្នកណាជាអ្នកទទួលខុសត្រូវក្នុងរឿងដ៏ធំនេះទៅវិញ ។


អៀង សារី

ក្នុងនាមជាប្រជាពលរដ្ឋខ្មែរម្នាក់ដែលធ្លាប់បានរងគ្រោះដោយអយុត្តិធម៌ក្នុងរបបប្រល័យ ពូជសាសន៍ដែលដឹកនាំដោយអង្គការកំពូលមហាឃាតករចុងសតវត្សរ៍ទី២០  ដែលតែងលើកតម្កើង


ខៀវ សំផន


សុន សេន


តាម៉ុក


ឌុច

ខ្លួនឯងថាជាសម័យ"មហាលោតផ្លោះ មហាអស្ចារ្យ" ក្រោមការដឹកនាំដ៏ឈ្លាសវៃនៃអគ្គមគ្គុទេសក៍ដូចតទៅ÷

១) សាឡុត ស ឬ ប៉ុល ពត, បងប៉ុល, បង៨៧

២) ឡៅ បេងកន ឬ នួន ជា, អ៊ីនួន

៣) គីម ត្រាង ឬ អៀង សារី, បងវ៉ាន់

៤) ខៀវ សំផន ឬ មិត្តហែម

៥) សុន សេន ឬ មិត្តខៀវ

៦) ឈិត ជឿន ឬ តាម៉ុក

៧) កាំង ហ្គិចអៀវ ឬ មិត្តឌុច។

តាមការសិក្សានិងស្រាវជ្រាវរាល់បណ្ដាសៀវភៅឬឯកសារនានាដែលទាក់ទងនឹង"ព្រឹត្តិការណ៍ស្ដីពីខ្មែរក្រហម" ខ្ញុំបាទកំណត់ឃើញថា សមាសភាពរបស់ដែលហៅថា "អង្គការ" ស្អីគេនោះ គឺបុគ្គលទាំង៧រូបខាងលើនេះហើយដែលជាក្បាលម៉ាស៊ីនដឹកនាំរួមគំនិតបញ្ញានិងអនុវត្តដោយផ្ទាល់ដៃក្នុងរបបប្រល័យពូជសាសន៍៣ឆ្នាំ ៨ខែ ២០ថ្ងៃ។ មកដល់បច្ចុប្បន្ននៅសល់តែ៥នាក់ប៉ុណ្ណោះដែលកំពុងមានជីវិតរស់នៅ គឺ២នាក់ត្រូវជាប់ឃុំឃាំងរបស់រដ្ឋាភិបាល ៣នាក់ទៀតកំពុងរស់នៅយ៉ាងមាន"ផាសុកភាព"ជាងប្រជាពលរដ្ឋខ្មែរដែលធ្លាប់រងគ្រោះពីអំពើរបស់មេដឹកនាំទាំងនោះទៅទៀត។

តាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានលោកឆាំង យុ ជាប្រធាន ហើយដែលជាមជ្ឈមណ្ឌលឯករាជ្យសិក្សាស្រាវជ្រាវរកសំណុំរឿងឯកសារនិងភ័ស្តុតាងនានាស្ដីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ខ្ញុំបាទសូមប្រើសិទ្ធិក្នុងនាមជាមនុស្សជាប្រជាពលរដ្ឋ និងជាជនរងគ្រោះម្នាក់ ដើម្បីដាក់សំណួរទៅ"អតីតអង្គការ" ដែលសព្វថ្ងៃនេះនៅមានជីវិតនៅឡើយ សូមមេត្តាឆ្លើយតបដើម្បីឲ្យប្រជាពលរដ្ឋរាប់លាននាក់ដែលធ្លាប់រងគ្រោះដ៏អយុត្តិធម៌បានដឹងនិងយល់ថាតើពួកអស់លោកធ្វើដូច្នេះដើម្បីអ្វី?

សំណួរទាំងនោះមានដូចខាងក្រោម÷

១) តើហេតុអ្វីបានជា"អង្គការ"ចាំបាច់ត្រូវតែជម្លៀសប្រជាពលរដ្ឋរាប់លាននាក់ទាំងបង្ខំឲ្យចេញពីទីក្រុង ទីរួមខេត្តដែលទើបរំដោះនាថ្ងៃ១៧មេសា១៩៧៥?

◆ហេតុអ្វីត្រូវបង្ខិតបង្ខំ គំរាមកំហែង បោកបញ្ឆោត ធ្វើបាប លួចសម្លាប់ សម្លាប់ជាចំហ ចំពោះប្រជាពលរដ្ឋក្នុងពេលជម្លៀស ដោយគ្មានគិតពីច្បាប់ ច្បាប់សង្គ្រាម មនោសញ្ចេតនាអ្វីទាំងអស់ សូម្បីតែព្រះសង្ឃ អ្នកជំងឺ ជនពិការ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ កុមារសុទ្ធតែត្រូវ"អ្នកឈ្នះ"កម្ចាត់ចេញគ្មានយោគយល់ដូច្នេះ?

◆ប្រៀបធៀបបដិវត្តន៍វៀតណាមនិងឡាវដែលសុទ្ធតែធ្វើសង្គ្រាមប្រឆាំងនឹង"ចក្រពត្តិ" ហើយមានលំនាំប្រហាក់ប្រហែល



 

គ្មានទីផបដិវត្តន៍ខ្មែរដែរ ហេតុអ្វីបដិវត្តន៍ប្រទេសទាំងពីរមិនសាហាវឃោរឃៅព្រៃផ្សៃដូចបដិវត្តន៍ខ្មែរដែលប្រជាពលរដ្ឋខ្មែររង់ចាំថ្ងៃរំដោះថ្ងៃមានសន្តិភាពបែរជាអង្គការរំដោះដើម្បីកម្ទេចទៅវិញ ។ តើអង្គការចាត់ទុកប្រជាពលរដ្ឋខ្មែរជាអ្វី? (សូមកុំឆ្លើយយកលេសតាមលក្ខណៈទ្រឹស្តីដូចជាសក្តិភូមិ មូលធន ប្រតិកិរិយា ...។ល ។)

២) ភ្លាម ៗ ក្រោយពីបានជ័យជម្នះ ក្រោយជម្លៀសប្រជាពលរដ្ឋបានជោគជ័យរួចមក អង្គការបានបែងចែកប្រជាពលរដ្ឋជាបីវណ្ណៈភ្លាម ៗ នៅពេលដែលខ្លួនស្រែកកោក ៗ ពីជ័យជំនះជាប្រវត្តិសាស្ត្រ២០០០ឆ្នាំរបស់ខ្លួនក្នុងការលុបបំបាត់វណ្ណៈជិះជាន់ ។ វណ្ណៈបីដែលអង្គការបង្កើតថ្មីមានអត្ថន័យសាហាវឃោរឃៅជាងវណ្ណៈចាស់ទៅទៀតគឺ÷

◆ វណ្ណៈពេញសិទ្ធិ = ពេញសិទ្ធិនឹងរស់?

◆ វណ្ណៈត្រៀម = ត្រៀមរស់ឬស្លាប់?

◆ វណ្ណៈបញ្ញើ = ផ្ញើទុកសិន ឲ្យរស់ឬស្លាប់?

◆ តើនេះហៅថាបែងចែកវណ្ណៈដែរឬទេ?

◆ តើរំដោះប្រជាជនឲ្យរួចផុតពីការជិះជាន់ ដើម្បីកាប់សម្លាប់គ្នារវាងខ្មែរនិងខ្មែរឬយ៉ាងណា?

៣) អង្គការបដិវត្តន៍មហាលោតផ្លោះមហាអស្ចារ្យមានទស្សនៈនយោបាយមិនចង់រណបបរទេស មិនចង់ធ្វើខ្ញុំកញ្ជះគេមិនរណបយួន (បដិសេធសហព័ន្ធឥណ្ឌូចិន) ហើយរហូតចង់វាយដណ្តើមយកទឹកដីកម្ពុជាក្រោមទៀតផង ។ ប្រសិនបើមានគំនិតដូច្នេះ ហេតុអ្វីអង្គការបែរជាសម្លាប់ជាតិឯងដូចជាទាហានប៉ូលិសមន្ត្រីរដ្ឋការសង្គមចាស់ រហូតដល់បញ្ញវ័ន្ត និស្សិត សិស្ស ប្រជាពលរដ្ឋដែលមិនដឹងអីទៅវិញ ព្រោះអ្នកខាងលើមិនមែន“ឧក្រិដ្ឋជនក្នុងសង្គ្រាម៥ឆ្នាំរបស់អង្គការ” ទេ គឺគ្រាន់តែកាន់ឬឈរនៅម្ខាង ៗ ប៉ុណ្ណោះ ។ តើក្រៅពីកម្ទេចសម្លាប់ អង្គការគ្មានមធ្យោបាយណាផ្សេងទេឬ? (រៀនសូត្រ អប់រំ កែប្រែ...)

ខ្ញុំសូមសួរថា ជាឪពុកម្តាយ បើចិញ្ចឹមដឹកនាំកូនឃើញកូនបែកឆ្វេង មិនស្តាប់បង្គាប់ឬដំបូន្មាន ស្រាប់តែខុសគិតតែសម្លាប់ៗ តើជាឪពុកម្តាយបែបណា?

◆អ្នកដែលទើបរំដោះសុទ្ធតែ“ខ្មាំង”សុទ្ធតែត្រូវសម្លាប់ រួចចុះការធ្វើ“វិសុទ្ធកម្មបោសសម្អាត”ក្នុងឆ្នាំ១៩៧៦-៧៧-៧៨ ទៅលើកម្មាភិបាលជាន់ខ្ពស់រហូតដល់ថ្នាក់ទាបបំផុតដែលសុទ្ធតែជាអ្នករួមចំណែកធ្វើឲ្យបដិវត្តន៍មានជ័យជម្នះនោះ ហេតុអ្វីបានជា“អង្គការ”ត្រូវតែ“សម្លាប់”ដែរ? តើពួកនោះខុសអ្វី? ភ័ស្តុតាង? រួចបើមានកំហុស ហេតុអ្វីបានជាត្រូវតែ“សម្លាប់”? រួចបើសម្លាប់ ហេតុអ្វីត្រូវសម្លាប់តាំងពីប្រពន្ធកូនមិត្តភក្តិខ្សែរយៈពីលើដល់ក្រោម ដែលភាគច្រើនគឺសុទ្ធតែអ្នកមិនដឹងអ្វីទាំងអស់ទៅវិញ?

◆ទូទាំងប្រទេស“អង្គការ”បានជំរុញឲ្យបង្កើតសហករណ៍ស៊ីរួម



សុន សេន

 

ដេករួម ធ្វើការរួម ។ ក្នុងសហករណ៍ទាំងនោះ ប្រជាពលរដ្ឋដែលជាទាសករដាច់ថ្លៃរបស់ "អង្គការ" ត្រូវធ្វើការច្រើនបំផុតស៊ីតិចបំផុត សម្រាកតិចបំផុត សម្លាប់ងាយបំផុត ។ តើអង្គការយល់ថាសហករណ៍រីកចម្រើននិងរឹងមាំដោយរបៀបណាបើមនុស្សមួយកង (ហាសិបនាក់) ហូបបបរមួយខ្ទះមានអង្ករតែបីកំប៉ុងក្នុងមួយពេលនោះ? តើមនុស្សដែលគ្មានអ្វីហូបអាចធ្វើការមានប្រសិទ្ធភាពក្នុងរយៈពេលពីដប់ពីរទៅដប់ប្រាំម៉ោងដែរឬទេ? តើមនុស្សដែលមានជំងឺអាចជាដោយគ្មានថ្នាំនិងការព្យាបាលថែទាំឬយ៉ាងណា?

ក្នុងសំណួរទីបីដែលមានចំណុចទាំងបីដែលខ្ញុំលើកមកនិយាយនេះ តើវាស្របឬផ្ទុយគ្នាពីទស្សនៈរបស់អង្គការដែល "មិនចង់រណបគេ"និង"ចង់វ៉ៃយួន"នោះ ។ ខ្ញុំសូមសួរ"អតីតអង្គការ" ថាបើពួកលោកសម្លាប់កម្លាំងរស់របស់ប្រជាពលរដ្ឋ (ទាហាន យោធា បញ្ញវន្ត និស្សិត យុវជន ប្រជាពលរដ្ឋ) ដែលជាកម្លាំងស្នូលរបស់ជាតិអស់ដូច្នេះ តើលោកមានគំនិតចង់ឲ្យកុមារដែលមានអាយុបីខួបដែលខ្លួនយល់ថាវានឹងស្មោះត្រង់នឹងអង្គការនោះ ទៅវាយវៀតណាមដើម្បីដណ្ដើម"ទឹកដីកម្ពុជាក្រោម" មកវិញឬយ៉ាងណា?

តើលោកសង្ឃឹមថា ប្រជាជនដែលស្គមមានតែស្បែកដណ្ដប់ឆ្អឹង ហើយដែល"បាក់ស្មារតី" ក្នុងរបបលោកអាចធ្វើសង្គ្រាមនឹងប្រទេសវៀតណាមដោយរបៀបណា?

ខ្ញុំមិនជឿថាពួកអង្គការល្ងង់រហូតដល់ធ្វើអ៊ីចឹងទេ ព្រោះពួកអស់លោកសុទ្ធតែជាបញ្ញវន្តដែលប្រទេសជាតិបានបញ្ជូនទៅសិក្សានៅប្រទេសបារាំង ។ ត្រង់ចំណុចនេះ ខ្ញុំចង់ដឹង ខ្ញុំចង់សួរនូវសំណួរខ្លីបំផុតថា÷

តើពួក"អង្គការ"មាន"ខួរក្បាល"ជាពូជសាសន៍អ្វី? ពិតណាស់ គឺមិនមែនជា"ខ្មែរ"ទេ ។

៤) រាល់ពេលសម្ភាសជាមួយអ្នកកាសែតបរទេសឬក៏ជាការសរសេរផ្សាយជាទស្សនៈរបស់ខ្លួន អៀង សារី, អៀង ធិរិទ្ធ, នួន ជា, ខៀវ សំផន តែងតែបដិសេធថា ក្នុងរបបខ្លួនគ្មានការសម្លាប់មនុស្សទេ មានស្លាប់ប្រជាជនតែប៉ុន្មានពាន់នាក់ប៉ុណ្ណោះដែលរងគ្រោះដោយសារជំងឺចាស់ជរា រួចបដិសេធទៀតថាការធ្វើ"ជ្រុលហួសខ្លះៗ"គឺជាអំពើរបស់កម្មាភិបាលមូលដ្ឋានឬភ្នាក់ងារខ្មាំងបង្កប់ធ្វើឲ្យបក្សខ្សោយ ។ល ។និង ។ល ។

បើអ៊ីចឹងមែនសុំសួរថា÷

◆តើ"មន្ទីរស-២១"ជាអ្វី? អ្នកណាជាអ្នកបង្កើតដឹកនាំ? បញ្ជា? ដើម្បីអ្វី? (នេះមិនទាន់សួរអំពីគុកនៅតាមមូលដ្ឋាន)ឬក៏សមមិត្ត ឌុច បង្កើតដោយខ្លួនឯង? ស្វ័យត? ចុះមកចាប់មនុស្សមកដាក់គុកដោយចិត្តឯង? សម្លាប់ដោយចិត្តឯង?

◆បើអ៊ីចឹងមែនស្រុកខ្មែរក្នុងចន្លោះពីឆ្នាំ១៩៧៥ ទៅ៧៩ គឺជាប្រទេសដែលកម្មាភិបាលបដិវត្តន៍គ្រប់រូបមានសិទ្ធិស្វ័យសម្រេចកម្ទេចសម្លាប់អ្នកណាក៏បាន? កម្មាភិបាលម្នាក់ជា "អង្គការ"ម្នាក់?

◆តើរណ្ដៅសាកសពរាប់ម៉ឺនដែលមាននៅក្នុងមាតុភូមិដ៏អភ័ព្វនៃយើងជារណ្ដៅអ្វី? ហេតុអ្វីបានជាមួយរណ្ដៅៗមានសាកសពរាប់រយពាន់នាក់? ពីព្រោះជនជាតិខ្មែរដូចសាសន៍ដទៃទៀតដែរ មនុស្សម្នាក់ស្លាប់គឺមិនខ្វះដីកប់ទេ ហើយសាសន៍ខ្មែរក៏មិនសូវមានទំនៀមទម្លាប់កប់សពដែរ ពិសេសការកប់សពរួមគ្នារាប់រយពាន់ដូច្នេះ ។ បើមិនមែនជាការសម្លាប់ទាំងពូជទេ តើហេតុអ្វីត្រូវកប់ក្នុងរណ្ដៅរួម?

ពាក្យស្លោកមួយចំនួនដូចជា÷

◆ទុកមិនចំណេញ ដកចេញមិនខាត

◆ដីកស្មៅត្រូវដីកទាំងឫស

◆ចាប់ច្រឡំ១០នាក់ប្រសើរជាលែងច្រឡំម្នាក់ ។ល ។និង ។ល ។

តើពាក្យស្លោកខាងលើនេះចេញមកពីប្រភពណា? ពាក្យស្លោកខាងលើមិនមែនជាបទបញ្ជាឲ្យសម្លាប់របស់អង្គការទេឬ? ចុងក្រោយបំផុត ខ្ញុំបាទសូមសួរ"អតីតអង្គការ" ដូចជាខ្ញុំហ្នឹងឬឆោតទៅចុះថា÷

ចាប់តាំងពីពេលដែលពួកអស់លោកធ្វើបដិវត្តន៍ ពួកលោកតែងបំផុសជាប់ជាប្រចាំថា កម្ទេចវណ្ណៈសក្តិភូមិ មូលធន នាយទុន ប្រតិកិរិយាឲ្យផុតពូជ ។ ជាក់ស្ដែងក្រោយជ័យជម្នះក្នុងអំណាចរបស់អស់លោកគឺធ្វើមែនរហូតដល់សម្គាល់ថាឲ្យតែស្បែកសពាក់វ៉ែនតាគឺពួកអាសក្តិភូមិ មូលធន នាយទុនហើយ រហូតប្រជា

ជនមូលដ្ឋានស្អប់ប្រជាជនថ្មី(១៧មេសា) តាំងពីដានដើង ។ បន្ទាប់មកក៏មានការសម្លាប់ប្រជាជនថ្មីរហូតដល់ប្រជាជនចាស់តាមទំនើងចិត្ត ។ សម្លាប់ៗៗៗ! សាច់ស ពាក់វ៉ែនតា តភ្លាំ រិះគន់ សើច យំ បាក់នង្គ័ល បាក់ផ្លែចប លួចបេះដូងមួយផ្លែ ស្រូវមួយក្តួរ... ។ល ។និង ។ល ។ សុទ្ធតែ "ខ្មាំង" គឺមានលក្ខណៈគ្រប់គ្រាន់នឹង"ស្លាប់" ។

ចុះខ្ញុំសួរថា សាឡុត ស ឬ ប៉ុល ពត ខ្សែស្រឡាយគាត់ក្រែងជាពួក"សក្តិភូមិ"ដែរឬ? បងស្រីជាស្នំឯកព្រះមហាក្សត្រ បងប្រុសគាត់ឈ្មោះ ឡុត សួង ជាមន្ត្រីធ្វើការក្នុងព្រះរាជវាំង បងថ្លៃស្រីឈ្មោះ ជា សាមី ជាគ្រូរបាំព្រះរាជទ្រព្យ... ។

ឡៅ បេងគន ហៅ នួន ជា គឺត្រូវជាក្មួយរបស់ ស៊ីវ ហេង មេខ្មែរវៀតមិញដែលបានក្បត់បក្សរត់ចូលពួក លន់ ណុល ក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ។

គឹម ត្រាង ហៅ អៀង សារី ជាជនដែលមានដើមកំណើតនៅវៀតណាម មានម្តាយជាជនជាតិយួនសុទ្ធឈ្មោះ ង៉ៀង ធីឡឹយ ។

បងប្អូនស្រីទាំងពីរនាក់ដែលត្រូវជាប្រពន្ធរបស់ សាឡុត ស ឈ្មោះ ខៀវ ប៉ុណ្ណារី និង ខៀវ ធីរិទ្ធ កើតចេញពីត្រកូលអភិជនឪពុកជាចៅក្រម ។

យ៉ាងហោចណាស់ក៏ពួក"អង្គការ"ទាំងនោះមានសាច់សទ្រលុកៗ ពាក់វ៉ែនតា និងជាបញ្ញាជនមកពីប្រទេសបារាំងដែរ ដែលទាំងនេះសុទ្ធតែជា"កម្មែល"មានសារជាតិវណ្ណៈសក្តិភូមិ មូលធន នាយទុន និងបរទេស ដូចដែលខ្លួនបានដាក់បទបញ្ញាឲ្យបដិវត្តន៍ដ៏មហាអស្ចារ្យរបស់ខ្លួន បោសសម្អាតនិងកម្ទេចឲ្យផុតពូជចំពោះប្រជាជនខ្មែរទាំងមូលដែលមិនដឹងអ្វីសោះ ។

◆តើ"អតីតអង្គការ"សម្លាប់ពួកគេព្រោះអ្វី?

◆បើព្រោះតែវណ្ណៈសក្តិភូមិ មូលធន នាយទុន ចុះខ្លួនឯងដែលមានសារជាតិអ៊ីចឹងដែរ គិតយ៉ាងម៉េច?

◆ចុះបច្ចុប្បន្ននេះបើប្រជាពលរដ្ឋសូមកាត់ទោសពួកអស់លោកដែលជា"មហាឃាតករ" ដោយ "យកទាំងពូជ" ដូចលោកធ្លាប់បានធ្វើមក"ធ្វើដូចគ្នា" តើពួកអស់លោក"សុខចិត្ត"ដែរឬទេ? ព្រោះថា សូម្បីពួកអស់លោកធ្វើបដិវត្តន៍បែបឡប់សតិបំផ្លាញជាតិឯង បើកឱកាសឲ្យបរទេសឈ្លានពានប្រទេសជាតិបែបនេះ ហើយពួកអស់លោកនៅតែគ្មានសេចក្តីក្លាហានឲ្យស័ក្តិសមជាអ្នកនយោបាយ"ហ៊ានស៊ីហ៊ានសង" ហ៊ានទទួលខុសត្រូវនូវអំពើដែលខ្លួនបានប្រព្រឹត្តនោះផងទេ គឺនៅតែតភ្លាំ ប្រកែក និងនៅតែទះទ្រូងយ៉ាងគឃ្លើនគ្មានការអៀនខ្មាសថាខ្លួនគ្មានទោសកំហុស ថាខ្លួនមិនបានដឹងមិនបានធ្វើទៅវិញ ។

ចុះបើអស់លោកមិនធ្វើឬមិនដឹង តើមនុស្សស្លាប់រាប់លាននាក់ ឆ្អឹងគរដូចដំបូកដូចភ្នំ តើជាស្នាដៃអ្នកណា?

ខ្ញុំបាទជាប្រជាពលរដ្ឋខ្មែរម្នាក់ដែលបានរងគ្រោះយ៉ាងឈឺចាប់បំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់អស់លោក សូមអង្វរដោយទទូចបំផុតថា បំណាច់តាំងខ្លួនជាអ្នកនយោបាយរហូតដល់ល្បីសុសសាយទូទាំងពិភពលោកថាជា"មហាឃាតករ" ដែលពូកែសម្លាប់ជាតិឯងដូច្នេះ ពួកអស់លោកដែល"ជ្រៀងជ្រ"ទៅហើយ ត្រូវតែហ៊ាន"ទទួលការពិត"ក្នុងស្មារតីជាអ្នកនយោបាយប្រកបដោយឧត្តមគតិ"ហ៊ានធ្វើហ៊ានទទួលខុសត្រូវ" ដើម្បីឡើងនិយាយពីការពិតនៅក្នុង"សវនាការតុលាការពិសេស" ដើម្បីបើកទំព័រប្រវត្តិសាស្ត្រចារសាច់រឿងពិតប្រាកដដែលខ្លួនបានអនុវត្តឲ្យប្រជាពលរដ្ឋខ្មែរទាំងអស់បានចាកផុតពីការឈឺចាប់ពីការមន្ទិលសង្ស័យ និងដើម្បីឲ្យកូនខ្មែរជំនាន់ក្រោយបានយល់ដឹងយ៉ាងច្បាស់ ដើម្បីឲ្យមនុស្សជំនាន់ក្រោយខិតខំបញ្ចៀសនូវ"មេរៀនដ៏អាក្រក់" នេះកុំឲ្យមក"សាកល្បង" ឬពិសោធន៍ជាថ្មីទៀត នៅលើមាតុភូមិដ៏ អភ័ព្វរបស់យើង ។



ខៀវ ប៉ុណ្ណារី



ខៀវ ធីរិទ្ធ ឬ អៀង ធីរិទ្ធ

ខ្ញុំបាទរង់ចាំចម្លើយពី"អតីតអង្គការ"ដោយអនុះសារ ។

**ព្រាប ច័ន្ទផាណ្ណា**

# ភាពកំសាករបស់ ខៀវ សំផន ដូចស្វាទាំងបី

ខៀវ សំផន គឺប្រៀបបានទៅនឹងស្វាទាំងបី (ក្នុងសុភាសិតលោកខាងលិច)៖ ខៀវ សំផន មិនបានឃើញអ្វី មិនបានឮអ្វី និងមិនបាននិយាយអ្វីទាំងអស់ ។ នោះគឺជាអ្វីដែល ខៀវ សំផន បានអះអាងការពារខ្លួននៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា "ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់" ។ សៀវភៅនេះនឹងមិនមានសុពលភាពនៅក្នុងតុលាការទេ ប៉ុន្តែវាបញ្ជាក់នូវអ្វីដែលសម្តេចព្រះ នរោត្តម សីហនុ បានសរសេរគឺ ខៀវ សំផន គឺជាជនកំសាកបំផុតដែលព្រះអង្គធ្លាប់បានជួប ។



"ស្តាប់មិនឮ មើលមិនឃើញ និយាយមិនប៉ះពាល់អំពើអាក្រក់" ជាសុភាសិតដែលត្រូវគេនិយមប្រើប្រាស់នៅលោកខាងលិចសំដៅចំពោះអ្នកដែលបដិសេធមិនបានជាប់ពាក់ព័ន្ធ ។ សុភាសិតនេះត្រូវគេនិយមតាងដោយសត្វស្វាល្អិតបីក្បាលអង្គុយយកដៃបិទមាត់ បិទភ្នែក និងបិទត្រចៀក បដិសេធមិនបានធ្វើអ្វីខុសចំពោះម្ចាស់វា ។

ខៀវ សំផន ធ្វើពុតជាមិនដឹងអ្វីទាំងអស់ទាក់ទងនឹងការចាប់ចង ការប្រហារជីវិត និងអំពីគុកទួលស្លែង ទើបតែពេលថ្មីៗនេះទេដែល ខៀវ សំផន បានដឹងដោយសារបានមើលភាពយន្តឯកសាររបស់ រិទ្ធី ប៉ាន់ មានចំណងជើងថា "មន្ទីរ ស-២១ជាក្បាលម៉ាស៊ីនសម្លាប់មនុស្សរបស់ខ្មែរក្រហម" ។ ការបកស្រាយបែបនេះមិនមានន័យអ្វីទាល់តែសោះ ។ ខៀវ សំផន ពិតជាបានអានទស្សនាវដ្តី "ទង់បដិវត្តន៍" របស់បក្សកុម្មុយនិស្តកម្ពុជាដែលចេញផ្សាយប្រចាំខែ ។ នៅក្នុងឆ្នាំ១៩៧៦ ទស្សនាវដ្តីនេះបានសរសេរថា បញ្ញាជនអនុធនទាំងឡាយដូចជាមន្ត្រីស៊ីវិល សាស្ត្រាចារ្យ សិស្សវិទ្យាល័យ និងនិស្សិត មិនមានសេសសល់តទៅទៀតទេ ពីព្រោះត្រូវបានចាប់ខ្លួនអស់ហើយ ។ ខៀវ សំផន បាននិយាយដោយខ្លួនឯងផ្ទាល់នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨ នៅក្នុងអង្គប្រជុំមួយនៅទីក្រុងភ្នំពេញដែលមានមនុស្សប្រមាណ២ម៉ឺននាក់ចូលរួមថា ប្តេជ្ញាកម្ទេចរាល់ "សមាសភាពមិនល្អ" ដែលខំប្រឹងលាក់ខ្លួននៅក្នុងជួរបក្សបន្ទំជាធ្វើកម្មាភិបាល ។ ខៀវ សំផន មិនបាននិយាយអំពីការកម្ចាត់មិត្តចាស់របស់ខ្លួន ហ៊ូ យន់ និង ហ៊ូ នឹម ចេញពីបក្សទេ ។ តើ ខៀវ សំផន មិនបានសង្កេតឃើញថាជនទាំងពីររូបបាត់ខ្លួនពីមជ្ឈដ្ឋានសាធារណៈទេឬ?

ខៀវ សំផន បានធ្វើពើជានិយាយថា គាត់ភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលបានដឹងថាប្រជាជនត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយបច្ចុប្បន្នគាត់ក៏មិនដឹងថាការសម្រេចចិត្តនេះត្រូវបានធ្វើឡើងនៅពេលណាដែរ ។ ប៉ុន្តែ ខៀវ សំផន បានចូលរួមដោយខ្លួនឯងនៅក្នុងសន្និសីទបក្សនាខែកក្កដា ឆ្នាំ១៩៧១ ដែលបានសម្រេចថាត្រូវជម្លៀសប្រជាជនចេញពីទីក្រុង ។

ខៀវ សំផន បាននិយាយការពារខ្លួនថា រហូតដល់ពេលគាត់ទៅប៉ៃលិននៅក្នុងឆ្នាំ១៩៩៨ ទើបគាត់បានដឹងតាមរយៈសៀវភៅសរសេរជាភាសាបរទេសថា ទាហានកម្ពុជាប្រជាធិប-តេយ្យបានសម្លាប់ជនស៊ីវិលវៀតណាមនៅតាមព្រំដែន ។ តើ ខៀវ សំផន មិនបានស្តាប់វិទ្យុទីក្រុងភ្នំពេញទេឬ? នៅថ្ងៃទី១០

ខែឧសភា ឆ្នាំ១៩៧៨ វិទ្យុនេះបានពន្យល់អំពីពាក្យស្លោករបស់បក្សដែលរៀបរាប់អំពីការប្រយុទ្ធមួយទល់នឹង៣០ គឺទាហានខ្មែរក្រហមម្នាក់អាចទប់ទល់ជាមួយទាហានវៀតណាម៣០នាក់... ដូច្នេះកម្ពុជាប្រជាធិបតេយ្យត្រូវការត្រឹមតែទាហាន២លាននាក់ប៉ុណ្ណោះដើម្បីយកឈ្នះលើខ្មាំងយួន៥០លាននាក់ ហើយកម្ពុជានៅសល់ប្រជាជន៦លាននាក់ថែមទៀត។ នេះគឺជាសម្ដីដែលបង្កឲ្យមានអំពើប្រល័យពូជសាសន៍។

នៅក្នុងមន្ទីរ៨៧០ ខៀវ សំផន បានចាត់ចែងការបែងចែកទំនិញរវាងសហករណ៍និងរដ្ឋ។ ខៀវ សំផន គួរដឹងថាមានអង្ករចំនួនប៉ុន្មានត្រូវបានកាត់ចេញពីសហករណ៍ហើយនាំចេញក្រៅប្រទេសនៅពេលដែលប្រជាជនកំពុងអត់អាហារ។ ដោយសារខៀវ សំផន បានសិក្សាអំពីសេដ្ឋកិច្ចនៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ដូច្នេះ ខៀវ សំផន ពិតជាបានយល់យ៉ាងស៊ីជម្រៅថា ទ្រឹស្ដី "មហាលោតផ្លោះមហាអស្ចារ្យ" របស់បក្ស ដើម្បីបង្កើនទិន្នផលស្រូវឲ្យបាន៣តោនក្នុងមួយហិកតាក្នុងរយៈពេលខ្លីរួចនាំចេញអង្ករឲ្យដល់មួយលានតោននៅឆ្នាំ១៩៧៧ ជាគម្រោងមួយដែលមិនអាចសម្រេចបានឡើយ។ នៅពេលនោះ ទស្សនាវដ្ដីទង់បដិវត្តន៍បានគំរាមចំពោះអ្នកដែលមិនបានធ្វើតាមផែនការ "៣តោនក្នុងមួយហិកតា" របស់បក្ស ហើយចោទអ្នកទាំងនោះជាសត្រូវវណ្ណៈ។ ការចោទប្រកាន់នេះបាននាំឲ្យមានការសម្លាប់រង្គាលតាមរយៈការបង្អត់អាហារប្រជាជន។

ឥឡូវនេះ ខៀវ សំផន សុំការអត់ឱនពីបងប្អូនរួមជាតិខ្លួន មិនមែនឲ្យអត់ឱនចំពោះបទឧក្រិដ្ឋរបស់ខ្មែរក្រហមទេ ប៉ុន្តែអត់ឱនចំពោះភាពឆោតល្ងង់និងការមិនដឹងឮរបស់ខ្លួន។ ខៀវ សំផន និយាយការពារខ្លួនដោយប្រើប្រាស់ហេតុផលដ៏ថ្លៃថ្នូរថា គាត់ធ្វើអ្វីៗទាំងអស់ដើម្បីអាយុជីវិតនិងសុខុមាលភាពជាតិ។ ខៀវ សំផន ថែមទាំងហ៊ាននិយាយថា បក្សមានបំណងកសាងយុត្តិធម៌សង្គម។

សៀវភៅរបស់ ខៀវ សំផន ផ្ដល់នូវគម្រុយអំពីទម្រង់នៃការការពារខ្លួនរបស់ ខៀវ សំផន នៅក្នុងតុលាការ។ វាសមហេតុផលណាស់ដែល ខៀវ សំផន បានជ្រើសយកមេធាវីកំណាចហ្សាក់ វែរហ្សែស មកការពារក្ដី។ វែរហ្សែស ធ្លាប់បានស្ម័គ្រចិត្តការពារក្ដីឲ្យ ស្លូបូដាន់ មីឡូសីវិក (អតីតប្រធានាធិបតីប្រទេសយូហ្គូស្លាវី) ដែលជា "ជនគ្មានកំហុស" មួយរូបដែរ។

**ម៉ូដ សាន់ឃ្វីស**

***ទីក្រុងស្តុកខូម ប្រទេសស៊ុយអែដ***



# មិននិយាយមិនបាន

ជាឱកាសល្អណាស់ដែលខ្ញុំបានចូលរួមចំណែកក្នុងការសរសេររឿងរ៉ាវសោកនាដកម្មនិងឧក្រិដ្ឋកម្មមហាព្រៃផ្សៃដែលប្រវត្តិសាស្ត្រមនុស្សលោកមិនធ្លាប់បានជួបប្រទះ ហើយដោយខ្ញុំធ្លាប់បានឆ្លងកាត់ជាក់ស្តែងក្នុងរបបឃោរឃៅដ៏ឆ្កួតលេលារបស់កម្ពុជាប្រជាធិបតេយ្យនោះ ។ ខ្ញុំបានសម្រេចចិត្តសរសេរអត្ថបទនេះជាឯកសារសម្រាប់កូនចៅជំនាន់ក្រោយតទៅទៀត ។

សូមកុំគិតថាពេលវេលាដែលកន្លងទៅទទេឲ្យសោះ ។ ប្រជាជនខ្មែរជាអ្នករងគ្រោះនិងមានជំងឺផ្លូវចិត្តបែកបាក់ខ្ទេចខ្ទាំរាំរ៉ៃជាងគេក្នុងពិភពលោកនេះ ។ ក្នុងនាមខ្ញុំជាខ្មែររងគ្រោះម្នាក់ ខ្ញុំគិតថា បើខ្ញុំមិនព្រមចូលរួមក្នុងការសរសេរការពិតដែលខ្ញុំបានដឹងឮនិងជួបប្រទះព្រមទាំងទទួលរងនូវការឈឺចាប់ដ៏ខ្លាំងក្លាបរិយាយពុំបាន គឺមានន័យថាខ្ញុំជាមនុស្សសោះអង្គើយនឹងការរំលោភលើសិទ្ធិមនុស្សជាតិ ហើយផ្តេកផ្តួលលើកម្មវាសនាប្រៃជន្ម ។

ខ្ញុំធ្លាប់ដឹងតាមសភាពជារាស្ត្រសាមញ្ញថាទុក្ខលំបាកវេទនារបស់ប្រជាជនខ្មែរគឺមិនមែនមកពីសីលធម៌អគតិរបស់អ្នកដឹកនាំប្រទេសនោះទេ ។ ប្រសិនបើអ្នកដឹកនាំស្រុកទេសមានគតិបណ្ឌិត ទសពិធរាជធម៌ ព្រហ្មវិហារធម៌ និងអនុវត្តឲ្យបានល្អត្រឹមត្រូវតាមគោលការណ៍នេះ ប្រទេសកម្ពុជាដែលធ្លាប់ជាប្រទេសមានកិត្យានុភាពរុងរឿងពីសម័យមហានគរមិនមែនធ្លាក់ខ្លួនយ៉ាងគំហុកដូចឥឡូវនេះទេ ។ ប្រជារាស្ត្រកម្ពុជានិងសកលលោកដឹងច្បាស់ណាស់ថា គឺគ្មានអ្នកណាធ្វើឲ្យយើងអន់ក្រៅពីខ្លួនយើងនោះទេ ។

អតីតកាលកន្លងទៅ ប៉ុន្តែវាអាចហុចផលជាមេរៀនល្អនិងអាក្រក់ឲ្យយើងចងចាំនិងទប់ស្កាត់បង្ការទំនាស់មិនឲ្យកើតមានជាថ្មីទៀត ។ សូមអ្នកដឹកនាំដែលមានចំណេះដឹងជ្រៅជ្រះនិងអ្នកដឹកនាំឆោតល្ងង់ដែលមិនសូវដឹងខុសដឹងត្រូវល្មមភ្ញាក់រឭកឡើង បើចង់ឲ្យដែនទីនិងឈ្មោះខ្មែរមានលើសកលលោកនឹងគេ ។ សូមត្រួតពិនិត្យឡើងវិញ ហើយកែខ្លួនដោយឆ្ពុះបញ្ចាំងទង្វើអាក្រក់ ដែលប្រឆាំងនឹងសីលធម៌ពុទ្ធសាសនានិយមរបស់ខ្លួនប្រឆាំងនឹងច្បាប់និងសិទ្ធិរបស់មនុស្សជាតិនៃពិភពលោកទាំងមូលផង ដែលគេដឹងកាន់តែច្រើនឡើងៗនិងមានបំណងចង់រកយុត្តិធម៌ឲ្យប្រជាពលរដ្ឋខ្មែរដែលរងគ្រោះនៅក្រោមរបបដ៏ព្រៃផ្សៃរបស់មេដឹកនាំទាំងនោះ ។

មិនបាច់ទម្លាក់កំហុសលើអ្នកណាយករួចខ្លួនទេ ។ ប៉ុន្តែដាច់ខាតត្រូវតែមានតុលាការអន្តរជាតិដើម្បីកាត់ទោសឧក្រិដ្ឋជនភេរវជនប្រឆាំងនឹងសិទ្ធិមនុស្ស ។ ខ្ញុំមិនមានជំនឿថាតុលាការនៅក្នុងស្រុកតែឯកឯងនឹងមិនអាចរកយុត្តិធម៌ឲ្យជនរងគ្រោះខ្មែរដែលសល់ពីស្លាប់ក្រោមរបបប្រល័យពូជសាសន៍បានឡើយពីព្រោះថា តុលាការនេះជាតុលាការដែលមានសមាសភាពដៃដល់កាន់ជើងជនដៃដល់ទាំងអស់នោះដែរ ។ ប្រជារាស្ត្រខ្មែរទាំងអស់មិនទទួលយកភាពបន្ទំក្លែងក្លាយរបស់ជនអសោចកាត់ទោសជនអសោចគ្នាឯងក្រោមរូបភាពផ្សះផ្សាជាតិនិងលើកលែងទោសពីសំណាក់ជនណាជាដាច់ខាត ។ សូមគាំទ្រទាំងស្រុងការបង្កើតឲ្យមានតុលាការអន្តរជាតិត្រឹមត្រូវមួយដ៏យុត្តិធម៌ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមនិងជនដៃដល់កំបាំងមុខមួយចំនួនដែលបាននិងកំពុងតែទាញស្រុកទេសព្រមទាំងប្រជារាស្ត្រឲ្យធ្លាក់រណ្តៅជ្រៅនរកទាំងរស់ ។

ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជានិងដល់លោកនាយកទស្សនាវដ្តីស្វែងរកការពិតព្រមទាំងសហការីទាំងអស់ដែលបាននិងបន្តការខិតខំស្រាវជ្រាវ ចងក្រងនិងប្រមូលផ្តុំនូវភ័ស្តុតាងទាំងឡាយសម្រាប់តម្កល់ជូនដល់តុលាការអន្តរជាតិរបស់អង្គការសហប្រជាជាតិ ដើម្បីជំនុំជម្រះជនដែលអនុវត្តផែនការបរទេសដោយចេតនាសម្លាប់រង្គាលប្រជាជាតិឯងដើម្បីពង្រីកមនោគមវិជ្ជាកុម្មុយនិស្តលើប្រទេសកម្ពុជាក៏ដូចអាស៊ី-អាគ្នេយ៍ ។ ខ្ញុំសូមបួងសួងដល់ព្រះជាម្ចាស់ សូមព្រះអង្គផ្តល់ប្រាជ្ញាដល់សេចក្តីសម្រេចរបស់អ្នកស្នេហាយុត្តិធម៌និងសិទ្ធិមនុស្សពិតប្រាកដរបស់អង្គការសហប្រជាជាតិ ។ **ឡាច ឆខាង**

## ខេត្តក្រចេះ:

# អតីតកាលដែលនៅតែចងចាំជានិច្ច

លោកតារបស់ខ្ញុំឈ្មោះ ក្រង តាំងឈន កើតនៅឆ្នាំ១៩២៥ នៅភូមិក្រគរ ឃុំក្រគរ ស្រុកក្រចេះ ខេត្តក្រចេះ ។ កាលពីជំនាន់ប៉ុលពតដោយមានការភ័យខ្លាចការកាប់សម្លាប់របស់ខ្មែរក្រហម គាត់ក៏បានប្តូរឈ្មោះទៅជា ទុង សៅ ។ ចំណែកប្រពន្ធរបស់គាត់ឈ្មោះ ម៉ុត វឿន ។ គាត់មានកូន៦នាក់ ប្រុស៣នាក់និងស្រី៣នាក់ ។ អ្នកទាំងអស់គ្នាសុទ្ធតែធ្លាប់បានឆ្លងកាត់របបខ្មែរក្រហមដ៏ជូរចត់ ។ ថ្វីត្បិតតែលោកតានិងលោកយាយរបស់ខ្ញុំស្លាប់បាត់បង់ជីវិតដោយរោគាពាធនៅក្រោយសម័យខ្មែរក្រហមក៏ដោយ ក៏រឿងរ៉ាវកម្សត់ដែលគាត់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហមនៅតែដក់ជាប់ក្នុងគំនិតក្រុមគ្រួសារខ្ញុំជានិច្ច ។ ជាងនេះទៅទៀតខ្ញុំដែលជាចៅប្រុសរបស់គាត់ បានដឹងរឿងរ៉ាវក្រុមគ្រួសាររបស់តាខ្ញុំក្នុងរបបកម្ពុជាប្រជាធិប-តេយ្យតាមរយៈការនិទានប្រាប់របស់អ៊ំស្រីខ្ញុំឈ្មោះ ក្រង ស៊ីណែត និងប្តីរបស់គាត់ បានសរសេររឿងនេះឡើងវិញដើម្បីទុកជាឯកសារទៅថ្ងៃក្រោយ ។

នៅក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ដែលធ្វើឡើងដោយ លន់ ណុល ផ្នែកខ្លះនៃខេត្តក្រចេះបានក្លាយទៅជាតំបន់រំដោះ ។ នៅក្នុងឆ្នាំ១៩៧០ គណៈគ្រប់គ្រងតំបន់ត្រូវការបោះឆ្នោតជ្រើសរើសមេឃុំសម្រាប់ឃុំក្រគរដែលស្ថិតនៅចម្ងាយប្រមាណបីគីឡូម៉ែត្រពីទីរួមខេត្តក្រចេះ ។ កាលនោះបេក្ខជនឈរឈ្មោះមាន ហុង នីន អុល ណារិន និងលោកតារបស់ខ្ញុំ ។ លោកតាខ្ញុំបានជាប់ឆ្នោតជាមេឃុំ ។ គាត់ធ្វើជាមេឃុំបានពីរឆ្នាំ នៅឆ្នាំ១៩៧៣ លោកតាឈប់ធ្វើមេឃុំ ហើយទៅធ្វើជាជាងសំណង់នៅមន្ទីរពេទ្យខ្សារ ព្រោះគាត់មានជំនាញខាងសំណង់ ។ ចាប់ពីឆ្នាំ១៩៧៣ដល់ឆ្នាំ១៩៧៥ លោកតាបានសាងសង់មន្ទីរពេទ្យនិងស្ពានជាច្រើននៅក្នុងខេត្ត ។ ចំណែកលោកយាយរបស់ខ្ញុំនៅភូមិឯណោះវិញអង្គការឲ្យធ្វើការនៅក្នុងសហករណ៍ដកស្ទូងបង្កបង្កើនផល ។



ក្រុមគ្រួសាររបស់ ឌី រ៉ាំបូលី ក្នុងឆ្នាំ១៩៩៤

ឆ្នាំ១៩៧៥ជាឆ្នាំដែលខ្មែរក្រហមដណ្តើមកាន់កាប់បានទីក្រុងភ្នំពេញ លោកតាបានវិលត្រឡប់មកភូមិកំណើតជួបជុំគ្រួសារវិញ ។ ដោយសារតែប្រជាប្រិយភាពនិងស្នាដៃរបស់គាត់ដែលបន្សល់ទុកពីមុនមក គាត់ត្រូវបានអង្គការតែងតាំងឲ្យធ្វើជាមេឃុំជាថ្មីម្តងទៀត ប៉ុន្តែដោយសារតែលោកតាមិនស្តាប់បញ្ជាពីអង្គការថ្នាក់លើ ខ្មែរក្រហមក៏ដកគាត់ឲ្យទៅធ្វើជាងសំណង់ នៅ

មន្ទីរពេទ្យខ្សាវដដែល ។ មន្ទីរពេទ្យខ្សាវជាមន្ទីរពេទ្យមួយយ៉ាងសំខាន់នៅក្នុងខេត្តក្រចេះ ។ រាល់អ្នករបួសដោយសង្គ្រាមនៅក្នុងខេត្តត្រូវយកមកព្យាបាលនៅក្នុងមន្ទីរពេទ្យនេះ ។

ពេលនោះខ្មែរក្រហមបានចាប់ផ្តើមសម្លាប់រង្គាលប្រជាជននៅក្នុងខេត្ត ។ មុនដំបូងការសម្លាប់បានចាប់ផ្តើមពីអ្នកដែលមានតំណែងធំៗពីសម័យមុន រហូតដល់ចុងក្រោយខ្មែរក្រហមចម្រាញ់យកប្រជាជនធម្មតាដែលមានជាប់សាច់សាលោហិតជាមួយវៀតណាម ។ សាច់ញាតិរបស់ខ្ញុំជាច្រើននាក់ដែលមានប្តីឬប្រពន្ធជាជនជាតិវៀតណាម ត្រូវខ្មែរក្រហមសម្លាប់ទាំងគ្រួសារ សូម្បីតែកូនដែលទើបនឹងកើតក៏មិនទុកដែរ ។ នៅចន្លោះឆ្នាំ១៩៧៦ ដល់១៩៧៨ ខ្មែរក្រហមបានសម្លាប់ប្រជាជននៅក្នុងខេត្តក្រចេះអស់ជាច្រើននាក់ ។

នៅចុងឆ្នាំ១៩៧៨ យុទ្ធជនខ្មែរក្រហមម្នាក់បានខ្សឹបប្រាប់លោកតាខ្ញុំថា គាត់បានឃើញឈ្មោះរបស់លោកតាខ្ញុំត្រូវគូសខ្វែងក្រហម ។ នេះមានន័យថាលោកតារបស់ខ្ញុំនឹងត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលក្នុងពេលឆាប់ៗនេះហើយ ។ លោកតាកើតទុក្ខក្រៀមក្រំយ៉ាងខ្លាំងក្រោយពេលឮដំណឹងនេះ ។ មិនយូរប៉ុន្មាន ស្នូរកាំភ្លើងបានលាន់ឡើងនៅឯភ្នំប្រាំពាន់ក្នុងស្រុកឆ្លូង ។ លោកតាមានសង្ឃឹមតិចៗថានឹងបានរួចជីវិតពីសេចក្តីស្លាប់ ។ លោកតាគិតក្នុងចិត្តថា គាត់នឹងរត់ទៅពីក្រោយភ្នំប្រាំពាន់ ហើយវាយចូលមកក្នុងវិញជាមួយនឹងកងទ័ពរំដោះ ។

ក្រោយថ្ងៃ៧មករា ឆ្នាំ១៩៧៩ គ្រួសារទាំងមូលបានជួបជុំគ្នាវិញ ប៉ុន្តែនៅបាត់អ៊ំប្រុសរបស់ខ្ញុំពីរនាក់ដែលបានភៀសខ្លួនក្នុងអំឡុងពេលចលាចល ។ លោកតាខ្ញុំត្រូវបានប្រជាជនបោះឆ្នោតឲ្យធ្វើជាមេឃុំក្រគរជាថ្មីម្តងទៀត ។ មិនយូរប៉ុន្មាន អ៊ំប្រុសរបស់ខ្ញុំម្នាក់ក៏បានមកដល់ផ្ទះវិញ ចំណែកម្នាក់ទៀតកំពុងស្ថិតនៅក្នុងជំរំរបស់ខ្មែរក្រហមនៅឡើយ ។ ដោយសារពិបាកក្នុងការរស់នៅជាមួយនឹងខ្មែរក្រហមពេក អ៊ំរបស់ខ្ញុំម្នាក់នោះបានសម្រេចចិត្តរត់គេចពីខ្មែរក្រហមមករួមរស់ជាមួយនឹងក្រុមគ្រួសារវិញ ។

មកទល់នឹងពេលនេះ ថ្វីដ្បិតតែប្រទេសកម្ពុជាយើងបានទទួលសន្តិភាពគ្មានសង្គ្រាមកាប់សម្លាប់ខ្មែរនិងខ្មែរគ្នាឯងក៏ដោយ ក៏ប្រជាជនកម្ពុជានៅតែចង់ដឹងនិងចង់ឃើញការកាត់ទោសមេដឹកនាំខ្មែរក្រហមប្រកបដោយយុត្តិធម៌ ដើម្បីស្វែងរកឲ្យឃើញពីមូលហេតុនិងមេខ្លោងនៃអំពើប្រល័យពូជសាសន៍ដ៏ឃោរឃៅនេះ និងដើម្បីរកយុត្តិធម៌ជូនអ្នកដែលបានស្លាប់ទៅ ក៏ដូចជាបង្ហាញឲ្យអន្តរជាតិមើលឃើញថា ខ្មែរពុំមែនជាជាតិសាសន៍ដែលចូលចិត្តការកាប់សម្លាប់គ្នានោះទេ តែជាជាតិសាសន៍ដែលត្រូវការយុត្តិធម៌ សច្ចធម៌ និង សុខសន្តិភាព ។

អ្វីៗនៅក្នុងរបបខ្មែរក្រហមបានកន្លងផុតទៅជាងពីរទសវត្សរ៍ហើយ ប៉ុន្តែការខូចខាត ឈឺចាប់ និងការបាត់បង់ជីវិតប្រជាជនជាងពីរលាននាក់ គ្មានអ្វីដែលអាចយកមកកាត់ថ្លៃដើម្បីជាសំណងដល់ជនរងគ្រោះបានទេ ។ ដូច្នេះ ការបង្កើតតុលាការដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមគឺគ្រាន់តែជាការឆ្លើយតបមួយយ៉ាងស្តួចស្តើងបំផុតសម្រាប់ជនរងគ្រោះ ។ ហេតុដូចនេះ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមគួរតែត្រូវបង្កើតឡើងឲ្យបានឆាប់ និងប្រកបដោយតម្លាភាពដើម្បីឆ្លើយតបទៅនឹងការទាមទារដ៏ទទូចរបស់ប្រជាជនកម្ពុជា ។

**ឌី ខាំបូលី**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

# សេចក្តីប្រកាសរកក្រុមគ្រួសារ

នាងខ្ញុំឈ្មោះ ប៉ូច គីមឡាង អាយុ៥៤ឆ្នាំ បច្ចុប្បន្នរស់នៅភូមិដូនម៉ៅលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ចម្ងាយពីប៉ុស្តិ៍ទន្លេបិទ១២០០ម៉ែត្រ ផ្ទះលេខ០៧៤ (ព្រែកលុប) បានទទួលដំណឹងថាឈ្មោះ លឹម ឆ្ងួន ហៅ ថៃ នៅរស់ ហើយបច្ចុប្បន្នគាត់រស់នៅតំបន់៤១ ទីក្រុងអ៊ែលក្រូល ឬសាក់កាម៉ាន់តូ រដ្ឋកាលីហ្វ័រញ៉ា ផ្ទះលេខ៦៦៧ ។ គាត់មានហាងលក់បាយ គុយទាវ កាហ្វេ មានលេខ១៦២ ។ ស្រុកកំណើតគាត់នៅដីក្រែងក្នុងខេត្តសៀមរាប ។ គាត់មានបងប្អូនចំនួន៨នាក់ ប្រុស៤នាក់ ស្រី៤នាក់ ។ កាលគាត់បែកគ្នានៅឆ្នាំ១៩៧៦ក្នុងជំនាន់ប៉ុលពត នៅខ្វាចក្រសាំងទិសខាងកើត ។ គាត់មានកូនស្រីម្នាក់ឈ្មោះ លឹម វិសាល បច្ចុប្បន្នមានអាយុ២៩ឆ្នាំហើយ ។

បើឈ្មោះ លឹម ឆ្ងួន ហៅ ថៃ បានទទួលលិខិតនេះហើយ សូមទូរស័ព្ទមកលេខៈ

(៨៥៥) ០១២ ៩០៩ ៩៤៨

ឬ (៨៥៥) ០១២ ៨២៣ ០៣៧

ឬ (៨៥៥) ០១២ ៧៤២ ០១៥

# សេចក្តីប្រកាសរកបងប្អូន




នាងខ្ញុំឈ្មោះ ស៊ុម សារឿន ជនជាតិខ្មែរ អាយុ៥២ឆ្នាំ ។ ឪពុកឈ្មោះ ហេង ស៊ុម ជាទាហាននៅខេត្តក្រចេះ (ទទួលមរណភាពនៅឆ្នាំ១៩៩៦) ម្តាយឈ្មោះ ភិន សាង ស្លាប់ដោយជំងឺក្នុងរបបប៉ុលពតក្នុងអាយុ៧៣ឆ្នាំ ។ បច្ចុប្បន្ននាងខ្ញុំជាមន្ត្រីរាជការនៅសាលាខេត្តក្រចេះ ។ នាងខ្ញុំបានអានដោយយកចិត្តទុកដាក់ទស្សនាវដ្តីស្វែងរកការពិត ហើយបានចាប់អារម្មណ៍ខ្ពស់ទៅលើទំព័រស្រាវជ្រាវរកក្រុមគ្រួសារដែលបានបាត់ខ្លួនឬព្រាត់ប្រាសគ្នា ពេលដែលកងទ័ពខ្មែរក្រហមបណ្តេញប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

នាងខ្ញុំសូមសួររកបងប្អូនបង្កើត៨នាក់ ក្មួយស្រី និងប្អូនថ្លៃ ដែលបានបែកបាក់គ្នាតាំងឆ្នាំ១៩៧៥ មកដល់សព្វថ្ងៃមិនបានទទួលដំណឹងនៅឡើយ ។ អ្នកទាំងអស់នេះមានឈ្មោះដូចតទៅ ÷ ទី១) បងប្រុសឈ្មោះ ហេ គិមសាន បច្ចុប្បន្នអាយុ ៥៦ឆ្នាំ ទី២) ប្អូនស្រីឈ្មោះ ហេ គិមឈន ទី៣) ប្អូនស្រីឈ្មោះ ហេ សាវ៉ន (គ្រូបង្រៀន) ទី៤) ប្អូនស្រីឈ្មោះ ហេ ឌឿក ទី៥) ប្អូនប្រុសឈ្មោះ ហេ វុទ្ធី ទី៦) ប្អូនស្រីឈ្មោះ ហេ ស្រី ទី៧) ប្អូនប្រុសឈ្មោះ ហេ រតនា ទី៨) ប្អូនប្រុសឈ្មោះ ហេ ពៅ ទី៩) ក្មួយស្រីឈ្មោះ សាវី បុទុម ទី១០) ប្អូនថ្លៃឈ្មោះ សាវី ស ។ មុនឆ្នាំ១៩៧៥ ក្រុមគ្រួសារនាងខ្ញុំមានទីលំនៅនៅគីឡូម៉ែត្រលេខ៤ ក្រោយរោងចក្រសូគីឡេ SOKILAI ក្បែរពេទ្យឫស្សីកែវក្រុងភ្នំពេញ ។ បើបងប្អូនណាបានស្គាល់ ឬសាមីខ្លួនបានឃើញឬឮដំណឹងនេះ សូមមេត្តាផ្តល់ព័ត៌មានទៅសាលាខេត្តក្រចេះតាមទូរស័ព្ទលេខ (០៧២) ៩៧១ ៦៦៤, (០៧២) ៩៧១ ៦៧៤ ឬទូរស័ព្ទដៃលេខ (០១១) ៦៨១ ៦៥១ និង (០១១) ៧៧៨ ១២៩ ដោយអនុគ្រោះ ។ សូមអរគុណ ។







ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក្នុងមួយច្បាប់តម្លៃ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 51, March 2004.**
**Funded by Germany, Norway, Sweden, the Netherlands, and USA.**